# បុគ្គល ១០ពួក



-បុគ្គលពួក១ មាន៥០
-បុគ្គលពួក២ មាន២៦
-បុគ្គលពួក៣ មាន១៧
-បុគ្គលពួក៤ មាន២៩
-បុគ្គលពួក៥ មាន១៤
-បុគ្គលពួក៦ មាន១
-បុគ្គលពួក៧ មាន២
-បុគ្គលពួក៨ មាន១
-បុគ្គលពួក៩ មាន១
-បុគ្គលពួក១០ មាន១

ប្រមូលរៀបរៀងដោយៈ
ភិក្ខុ ញាតិសង្គហោ ជា វ៉ាវី

ពុទ្ធសករាជ ២៥៦៧

| | |
|---|---|
| ឈ្មោះសៀវភៅ | **បុគ្គល១០** |
| អ្នកប្រមូលរៀបរៀងដោយ | ភិក្ខុ ញាតិសង្គហោ ជា វ៉ារី |
| ត្រួតពិនិត្យដោយ | លោកម្ចាស់គ្រូ វី សាលឿត |
| | លោកម្ចាស់ នាង ណៃ |
| | លោកគ្រូ នាគ ទី |
| ឧបត្ថម្ភការបោះពុម្ពដោយ | សប្បុរសជនទូទៅ |
| បោះពុម្ពលើកទី២ | ចំនួន១៥០ក្បាល |
| ចេញផ្សាយឆ្នាំ | ព.ស ២៥៦៧ / គ.ស ២០២៣ |
| គោលបំណង | សម្រាប់ជាធម្មទាន |
| ផ្សាយចេញពី | វត្តមហាវ័ន "គិរីរម្យចាស់" ស្ថិតនៅភូមិថ្មី |

ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ

# អារម្ភកថា

សៀវភៅ “**បុគ្គល១០ពួក**” នេះ ខ្ញុំរៀបរៀងឡើង ព្រោះបានសិក្សាព្រះអភិធម្ម **គម្ពីរបុគ្គលប្បញ្ញត្តិ** ជាមួយលោកគ្រូ នាគ ទី ឃើញថា ព្រះធម៌ដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់សម្តែងនៅក្នុងគម្ពីរនេះមានអត្ថន័យយ៉ាងពីរោះ ដែលព្រះអង្គសម្តែងពីប្រភេទបុគ្គលពួក១ ដល់ពួក១០ តែងមានប្រាជកនៅក្នុងលោក ទើបខ្ញុំព្យាយាមប្រមូលឯកសារផ្សេងៗដើម្បីជាជំនួយក្នុងការរៀបរៀង។

សូមបញ្ជាក់ផងដែរថា សៀវភៅដែលពុទ្ធបរិស័ទកំពុងអាននេះ គឺជាស្នាដៃដំបូងរបស់ខ្ញុំ។ ព្រះធម៌ក្នុងសៀវភៅនេះ ខ្ញុំបានកាន់យកព្រះត្រៃបិដកលេខ៨៣ និងអដ្ឋកថា បុគ្គលប្បញ្ញត្តិជាគោលក្នុងការរៀបរៀង ហើយក៏បានទាញយកព្រះធម៌ពីកន្លែងផ្សេងៗដែលជាប់ទាក់ទងគ្នា ដូចជា ៖ គម្ពីរធម្មសង្គណី គម្ពីរមជ្ឈិមនិកាយ គម្ពីរអង្គុត្តរនិកាយ គម្ពីរសាមន្តប្បាសាទិកា គម្ពីរវិសុទ្ធមគ្គ និងអភិធម្មត្ថសង្គហៈ៩ បរិច្ឆេទ មកដាក់បញ្ចូលផងដែរ ។

ថ្វីត្បិតថា សៀវភៅនេះជាស្នាដៃលើកដំបូងរបស់ខ្ញុំ ប្រាកដជាចៀសមិនផុតពីការខុសភ្លាំងភ្លាត់ដោយអក្ខរាវិរុទ្ធ និងន័យសេចក្តីប្រែដោយអចេតនាពុំខានឡើយ។ អាស្រ័យហេតុដូច្នេះ ខ្ញុំសូមខន្តីអភ័យអត់ទោស រាល់កំហុសខុសឆ្គងទាំងឡាយដែលកើតមានឡើងនៅក្នុងសៀវភៅនេះ អំពីសំណាក់លោកអ្នកចេះដឹងទាំងឡាយ សូមលោកអ្នកទាំងឡាយនោះអភ័យអត់ទោស និងជួយកែតម្រូវឱ្យទាន៕

# បញ្ជាក់

ដោយការបោះពុម្ពលើកទីមួយមានការភ្លាំងភ្លាត់ចំនួនមាតិកាខ្លះ ដូចជា បុគ្គលពួក១មានចំនួន៥០ តែភ្លាត់ទៅជា៥៤(.(៤៧) សោតាបន្នោ ~~(៤៨)~~សោតាបត្តិផលសច្ឆិកិរិយាយ បដិបន្នោ,(៤៩) សកទាគាមី~~(៥០)~~សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នោ, (៥១) អនាគាមី ~~(៥២)~~អនាគាមិផលសច្ឆិកិរិយាយ បដិបន្នោ, (៥៣) អរហា ~~(៥៤)~~អរហត្តផលសច្ឆិកិរិយាយ បដិបន្នោ។)

បុគ្គលពួក៤មាន២៩ តែភ្លាត់ទៅជា៣០((២២) រូបប្បមាណោ រូបប្បសន្នោ ឃោសប្បមាណោ ឃោសប្បសន្នោ ~~(២៣)~~ លូខប្បមាណោ លូខប្បសន្នោ ធម្មប្បមាណោ ធម្មប្បសន្នោ ។)

ព្រោះហេតុដូច្នេះហើយ ប្រសិនបើពុទ្ធបរិស័ទឃើញមាតិកាសៀវភៅទាំងពីរភាគនេះហើយ សូមកុំងឿងឆ្ងល់ឡើយ។

# សេចក្ដីថ្លែងអំណរគុណ

១.សូមថ្លែងអំណរអរព្រះគុណដល់ លោកម្ចាស់គ្រូ **ទីឃរត្តោ វី សារឿត** ព្រះគ្រូចៅអធិការ **វត្តគិរីរម្យចាស់** ដែលបានជួយត្រួតពិនិត្យន័យសេចក្ដី និងអក្ខរាវិរុទ្ធក្នុង សៀវភៅនេះ ប្រសិនបើគ្មានលោកម្ចាស់គ្រូជួយពិនិត្យទេ មិនអាចចេញជាលទ្ធផលនេះបានឡើយ។

២. សូមថ្លែងអំណរអរគុណដល់ លោកគ្រូ **នាគ ធី** ដែលបានជួយបង្រៀនព្រះធម៌នេះ។

៣. សូមថ្លែងអំណរអរគុណដល់ញោម **ឧបាសិកា ហាវ សាវុធ ឧបាសិកា ហាវ សុគុន** និង **ឧបាសិកា ហេង វួចលាង** ដែលបានជួយខ្នះខ្នែងក្នុងការងារធម្មទាននេះ។

៤.សូមថ្លែងអំណរអរគុណដល់ពុទ្ធបរិស័ទទូទៅដែលបានចូលថវិកាក្នុងការបោះពុម្ពសៀវភៅនេះ។

ជាទីបញ្ចប់ ខ្ញុំសូមប្រគេនពរនិង ជូនពរដល់ ព្រះថេរានុថេរៈគ្រប់ព្រះអង្គ និងពុទ្ធបរិស័ទទាំងអស់ឱ្យជួបប្រទះតែពុទ្ធពរទាំង៤ប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ៕

ថ្ងៃអាទិត្យ ១កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

វត្តគិរីរម្យចាស់ ថ្ងៃទី១៥ ខែតុលា គ.ស២០២៣

ភិក្ខុ ញាតិសង្គហោ **ជា រ៉ាវី**

# សន្ទិក្រាប់មាតិកា

មាតិកា ទំព័រ


បុគ្គលប្បញ្ញត្តិ ........................................................ ១

ឯកកនិទ្ទេស ........................................................ ១៩

(១). សមយវិមុត្តបុគ្គល ........................................................ ១៩

(២). អសមយវិមុត្តបុគ្គល ........................................................ ២១

(៣). កុប្បធម្មបុគ្គល ........................................................ ២៤

(៤). អកុប្បធម្មបុគ្គល ........................................................ ២៧

(៥) បរិហានបុគ្គល ........................................................ ២៩

(៦) អបរិហានបុគ្គល ........................................................ ២៩

(៧). ចេតនាភព្វបុគ្គល ........................................................ ២៩

(៨). អនុរក្ខនាភព្វោ ........................................................ ៣០

(៩). បុថុជ្ជនបុគ្គល ........................................................ ៣៣

(១០). គោត្រភូបុគ្គល ........................................................ ៣៤

(១១ -១២ ). កយូបរតបុគ្គល និងអភយូបរតបុគ្គល ............ ៣៧

(១៣). អភព្វាគមនបុគ្គល ........................................................ ៤០

(១៤). កញ្ញាគមនបុគ្គល ........................................................ ៤០

(១៥-១៦). និយតបុគ្គល និងអនិយតបុគ្គល ...................... ៤៣

(១៧ -១៨). បដិបន្នក និងផលេដ្ឋិតបុគ្គល .......................... ៤៥

(១៩). សមសីសីបុគ្គល ..................................................... ៤៦

( ២០ ). បិតកប្បីបុគ្គល ........................................................ ៤៨

(២១ -២២ ). អរិយបុគ្គល និង មិនមែនអរិយបុគ្គល ............ ៥១

(២៣ -២៤-២៥ ).សេក្ខបុគ្គល, អសេក្ខបុគ្គល និង នេវ សេក្ខា

នាសេក្ខបុគ្គល........................................................................ ៥២

(២៦). តេវិជ្ជបុគ្គល ............................................................ ៥៣

(២៧). ឆឡភិញ្ញបុគ្គល ........................................................ ៥៣

(២៨). សម្មាសម្ពុទ្ធបុគ្គល ...................................................... ៥៤

(២៩). បច្ចេកពុទ្ធបុគ្គល........................................................ ៥៧

(៣០). ឧភតោភាគវិមុត្តបុគ្គល ............................................ ៥៨

(៣១). បញ្ញាវិមុត្តបុគ្គល ...................................................... ៦២

(៣២). កាយសក្ខីបុគ្គល ....................................................... ៦៣

(៣៣). ទិដ្ឋិប្បត្តបុគ្គល........................................................ ៦៣

(៣៤). សទ្ធាវិមុត្តបុគ្គល ........................................................ ៦៩

(៣៥). ធម្មានុសារីបុគ្គល ........................................................ ៧៣

(៣៦). សទ្ធានុសារីបុគ្គល ........................................................ ៧៤

(៣៧). សត្តក្ខត្តុំបរមបុគ្គល ........................................................ ៧៨

(៣៨). កោលំកោលបុគ្គល ........................................................ ៨០

(៣៩). ឯកពីជីបុគ្គល ........................................................ ៨២

(៤០). សកទាគាមិបុគ្គល ........................................................ ៨៧

(៤១). អនាគាមិបុគ្គល ........................................................ ៨៩

(៤២).អន្តរាបរិនិព្វាយិបុគ្គល ........................................................ ៩១

(៤៣).ឧបហច្ចបរិនិព្វាយី ........................................................ ៩៣

(៤៤).អសង្ខារបរិនិព្វាយី ........................................................ ៩៤

(៤៥).សសង្ខារបរិនិព្វាយី ........................................................ ៩៥

(៤៦)ឧទ្ធំសោតោអកនិដ្ឋគាមិបុគ្គល ........................................................ ៩៧

(៤៧). សោតាបន្នបុគ្គល ........................................................ ១០៤

(៤៨). សកទាគាមិបុគ្គល ........................................................ ១០៤

(៤៩). អនាគាមិបុគ្គល ........................................................ ១០៤

(៥០). អរហន្តបុគ្គល ............................................................១០៥

ទុកនិទ្ទេស .......................................................................................១០៧

(១). បុគ្គលចូលចិត្តក្រោធជាដើម ......................................១០៧

(២). បុគ្គលលុបគុណគេជាដើម ..........................................១០៩

(៣) .បុគ្គលមានសេចក្តីប្រណែនជាដើម ..............................១១២

(៤) បុគ្គលមានសេចក្តីអួតអាងជាដើម ..............................១១៩

(៥) អហិរិកបុគ្គលជាដើម ....................................................១២២

(៦) បុគ្គលប្រដៅក្រជាដើម ..................................................១២៣

(៧) បុគ្គលមានទ្វារមិនបានរក្សាក្នុងឥន្ទ្រិយជាដើម .............១៣០

(៨) បុគ្គលភ្លេចស្មារតីជាដើម ..............................................១៣៤

(៩) បុគ្គលវិបត្តិចាកសីលជាដើម .......................................១៣៥

(១០) បុគ្គលមានសញ្ញោជនខាងក្នុងជាដើម .......................១៤២

(១១) បុគ្គលមិនក្រោធជាដើម ..............................................១៤៤

(១២) បុគ្គលមិនលុបគុណគេជាដើម ..................................១៤៥

(១៣) បុគ្គលមិនមានសេចក្តីប្រណែនជាដើម ......................១៤៦

(១៤) បុគ្គលមិនអួតអាងជាដើម ..........................................១៤៨

(១៥) បុគ្គលមានសេចក្ដីខ្មាសបាបជាដើម..........................១៤៩
(១៦) បុគ្គលប្រដៅងាយជាដើម ........................................១៥២
(១៧) បុគ្គលមានទ្វាររក្សាហើយក្នុងឥន្ទ្រិយទាំងឡាយជាដើម
....................................................................................................១៥៥
(១៨) បុគ្គលមានសតិតាំងមាំជាដើម .................................១៦១
(១៩) បុគ្គលបរិបូណ៌ដោយសីលជាដើម ...........................១៦២
(២០) ទ្វេ បុគ្គលា ទុល្លភា លោកស្មឹ ....................................១៧០
(២១) ទ្វេ បុគ្គលា ទុត្តប្បយា.................................................១៧២
(២២) ទ្វេ បុគ្គលា សុត្តប្បយា ...............................................១៧៤
(២៣) ទ្វិន្នំ បុគ្គលានំ អាសវា វឌ្ឍន្តិ .......................................១៧៥
(២៤) ទ្វិន្នំ បុគ្គលានំ អាសវា ន វឌ្ឍន្តិ.....................................១៧៨
(២៦).តិត្តោ ច តប្បេតា ច ..................................................១៨៥
តិកមាតិកា ........................................................................................១៨៦
(១) .បុគ្គលមិនមានសេចក្ដីសង្ឃឹមជាដើម .........................១៨៧
(២).គយោ គិលានូបមា បុគ្គលា ........................................១៩០
(៣).បុគ្គលជាកាយសក្ខីជាដើម ..........................................១៩៦

(៤). បុគ្គលមានវាចាដូចលាមកជាដើម ...............................១៩៧

(៥). បុគ្គលមានចិត្តប្រៀបដោយដំបៅជាដើម ....................២០១

(៦). បុគ្គលដែលមានភ្នែកខ្វាក់ជាដើម ................................២០៣

(៧). បុគ្គលមានបញ្ញាដូចក្អមផ្កាប់ .......................................២០៤

(៨) .បុគ្គលមានរាគៈមិនទាន់ប្រាស់ទៅជាដើម ...................២១០

(៩). បុគ្គលប្រៀបដូចគំនូសថ្មជាដើម.................................២១១

(១០).តយោ បោត្ថកូបមា បុគ្គលា .......................................២១៣

(១១) តយោ កាសិកវត្ថុបមា បុគ្គលា.................................២១៦

(១២). បុគ្គលដែលគេប្រមាណបានដោយងាយ ................២២០

(១៣). បុគ្គលមិនគួរសេពគប់ជាដើម .................................២២២

(១៤). បុគ្គលដែលគួររង្កៀសជាដើម .................................២២៥

(១៥).បុគ្គលមានប្រក្រតីធ្វើឱ្យបរិបូណ៌ក្នុងសីលជាដើម ......២២៨

(១៦). តយោ សត្ថារោ ........................................................២៣២

(១៧). អបរេបិ តយោ សត្ថារោ.........................................២៣៤

ចតុក្កនិទ្ទេស ........................................................................២៣៥

(១). បុគ្គលជាអសប្បុរសជាដើម .......................................២៣៦

(២). បុគ្គលអាក្រក់ជាដើម ..................................................២៣៧

(៣)បុគ្គលមានធម៌អាក្រក់ជាដើម.........................................២៣៧

(៤). បុគ្គលប្រកបដោយទោសជាដើម ................................២៣៨

(៥). ឧគ្ឃដិតញ្ញូបុគ្គលជាដើម..............................................២៣៩

(៦). បុគ្គលអ្នកឆ្លើយ៤យ៉ាង...................................................២៤១

(៧). ចត្តារោ ធម្មកថិកា បុគ្គលា ..........................................២៤២

(៨). ចត្តារោ វលាហកូបមា បុគ្គលា ......................................២៤៣

(៩). ចត្តារោ មូសិកូបមា បុគ្គលា...........................................២៤៦

(១០). ចត្តារោ អម្ពូបមា បុគ្គលា ............................................២៤៨

(១១) ចត្តារោ កុម្ភូបមា បុគ្គលា ..............................................២៥០

(១២) ចត្តារោ ឧទករហទូបមា បុគ្គលា ..................................២៥០

(១៣) ចត្តារោ ពលិពទ្ទូបមា បុគ្គលា ....................................២៥២

(១៤) .ចត្តារោ អាសីវិសូបមា បុគ្គលា ..................................២៥៤

(១៥). បុគ្គលមិនគួរតិះដៀលជាដើម ...................................២៥៧

(១៦). បុគ្គលគួរតិះដៀលជាដើម ..........................................២៥៨

(១៧). បុគ្គលពោលតិះដៀលតាមកាលដែលគួរជាដើម ......២៥៩

(១៨). បុគ្គលចិញ្ចឹមជីវិត៤ពួក ............................................២៦០

(១៩). បុគ្គល៤ពួកមកងងឹត ទៅងងឹតជាដើម ....................២៦១

(២០). បុគ្គលឱនចុះហើយ ឱនចុះទៀតជាដើម ....................២៦៥

(២១) .ចត្តារោ រុក្ខូបមា បុគ្គលា ...........................................២៦៦

(២២). សេចក្តីជ្រះថ្លា ៤ ពួក ...................................................២៦៧

(២៣). បុគ្គលបដិបត្តិដើម្បីប្រយោជន៍ខ្លួនជាដើម៤ពួក ........២៧១

(២៤). បុគ្គលដុតកំដៅខ្លួនឯងជាដើម .................................២៧៤

(២៥). បុគ្គលមានរាគៈជាដើម៤ពួក ...................................២៧៩

(២៦). បុគ្គលបានចេតោសមថៈជាដើម៤ពួក ....................២៧៩

(២៧) .បុគ្គលទៅតាមក្រសែទឹកជាដើម៤ពួក.....................២៨១

(២៨). បុគ្គលជាអ្នកចេះដឹងតិចជាដើម ...............................២៨៣

(២៩). បុគ្គលជាសមណៈ មិនកម្រើកញាប់ញ័រជាដើម........២៨៤

បញ្ចកនិទ្ទេស...............................................................................២៨៦

(១) បុគ្គលប្រព្រឹត្តល្មើសផង ក្តៅក្រហាយផងជាដើម ........២៨៦

(២ ) បុគ្គលឱ្យហើយមើលងាយវិញជាដើម .......................២៩២

(៣ ) .បញ្ច យោធាជីវូបមា បុគ្គលា .....................................២៩៥

(៤). បញ្ចបិណ្ឌបាតិកា ..........................................................៣០០

ឆក្កនិទ្ទេស ..........................................................................៣០២

សត្តកនិទ្ទេស .......................................................................៣០៤

អដ្ឋកនិទ្ទេស ........................................................................៣១៦

នវកនិទ្ទេស ..........................................................................៣១៦

ទសកនិទ្ទេស ........................................................................៣១៧

# បុគ្គលប្បញ្ញត្តិ

## មាតិកា

### ១. ឯកកនុទ្ទេសោ

កិត្តាវតា បុគ្គលានំ បុគ្គលប្បញ្ញត្តិ ?

(១) សមយវិមុត្តោ

(២) អសមយវិមុត្តោ

(៣) កុប្បធម្មោ

(៤) អកុប្បធម្មោ

(៥) បរិហានធម្មោ

(៦) អបរិហានធម្មោ

(៧) ចេតនាភព្វោ

(៨) អនុរក្ខណាភព្វោ

(៩) បុថុជ្ជនោ

(១០) គោត្រភូ

(១១) ភយូបរតោ

(១២) អភយូបរតោ

(១៣) ភព្វាគមនោ

(១៤) អភព្វាគមនោ

(១៥) និយតោ

(១៦) អនិយតោ
(១៧) បដិបន្នកោ
(១៨) ផលេដ្ឋិតោ
(១៩) សមសីសី
(២០) ឋិតកប្បី
(២១) អរិយោ
(២២) អនរិយោ
(២៣) សេក្ខោ
(២៤) អសេក្ខោ
(២៥) នេវ សេក្ខោ នាសេក្ខោ
(២៦) តេវិជ្ជោ
(២៧) ឆឡភិញ្ញោ
(២៨) សម្មាសម្ពុទ្ធោ
(២៩) បច្ចេកសម្ពុទ្ធោ
(៣០) ឧភតោភាគវិមុត្តោ
(៣១) បញ្ញាវិមុត្តោ
(៣២) កាយសក្ខី
(៣៣) ទិដ្ឋិប្បត្តោ
(៣៤) សទ្ធាវិមុត្តោ

(៣៥) ធម្មានុសារី

(៣៦) សទ្ធានុសារី

(៣៧) សត្តក្ខត្តុំបរមោ

(៣៨) កោលង្កោលោ

(៣៩) ឯកពីជី

(៤០) សកទាគាមី

(៤១) អនាគាមី

(៤២) អន្តរាបរិនិព្វាយី

(៤៣) ឧបហច្ចបរិនិព្វាយី

(៤៤) អសង្ខារបរិនិព្វាយី

(២៥)សសង្ខារបរិនិព្វាយី

(៤៦)ឧទ្ធំសោតោ អកនិដ្ឋគាមី

(៤៧) សោតាបន្នោ សោតាបត្តិផលសច្ឆិកិរិយាយ បដិប-
ន្នោ

(៤៨) សកទាគាមី សកទាគាមិផលសច្ឆិកិរិយាយ បដិ-
បន្នោ។

(៤៩) អនាគាមី អនាគាមិផលសច្ឆិកិរិយាយ បដិបន្នោ

(៥០) អរហា អរហត្តផលសច្ឆិកិរិយាយ  បដិបន្នោ។

# <u>ឯកកមាតិកា និដ្ឋិតា</u>

## ២. ទុកឧទ្ទេសោ

## ទ្វេ បុគ្គលា

(១) កោធនោ ច ឧបនាហី ច

(២) មក្ខី ច បលាសី ច

(៣) ឥស្សុកី ច មច្ឆរី ច

(៤) សឋោ ច មាយាវី ច

(៥) អហិរិកោ ច អនោត្តប្បី ច

(៦) ទុព្វចោ ច បាបមិត្តោ ច

(៧) ឥន្ទ្រិយេសុ អគុត្តទ្វារោ ច ភោជនេ អមត្តញ្ញូ ច

(៨) មុដ្ឋស្សតិ ច អសម្បជានោ ច

(៩) សីលវិបន្នោ ច ទិដ្ឋិវិបន្នោ ច

(១០) អជ្ឈត្តសំយោជនោ ច ពហិទ្ធាសំយោជនោ ច

(១១) អក្កោធនោ ច អនុបនាហី ច

(១២) អមក្ខី ច អបឡាសី ច

(១៣) អនិស្សុកី ច អមច្ឆរី ច

(១៤) អសឋោ ច អមាយាវី ច

(១៥) ហិរិមា ច ឱត្តប្បី ច

(១៦) សុវចោ ច កល្យាណមិត្តោ ច

(១៧) ឥន្ទ្រិយេសុ គុត្តទ្វារោ ច, ភោជនេ មត្តញ្ញូ ច

(១៨) ឧបដ្ឋិតស្សតិ ច សម្បជានោ ច

(១៩) សីលសម្បន្នោ ច ទិដ្ឋិសម្បន្នោ ច

(២០) ទ្វេ បុគ្គលា ទុល្លភា លោកស្មឹ

(២១) ទ្វេ បុគ្គលា ទុត្តប្បយា

(២២) ទ្វេ បុគ្គលា សុតប្បយា

(២៣) ទ្វិន្នំ បុគ្គលានំ អាសវា វឌ្ឍន្តិ

(២៤) ទ្វិន្នំ បុគ្គលានំ អាសវា ន វឌ្ឍន្តិ

(២៥) ហីនាធិមុត្តោ ច បណីតាធិមុត្តោ ច

(២៦) តិត្តោ ច តប្បេតា ច

# ទុកមាតិកា និដ្ឋិតា

## ៣. តិកឧទ្ទេសោ

### តយោ បុគ្គលា

(១) និរាសោ អាសំសោ វិគតាសោ

(២) តយោ គិលានូបមា បុគ្គលា

(៣) កាយសក្ខី ទិដ្ឋិប្បត្តោ សទ្ធាវិមុត្តោ

(៤) គូថភាណី បុប្ផភាណី មធុភាណី

(៥) អរុកូបមចិត្តោ បុគ្គលោ វិជ្ជូបមចិត្តោ បុគ្គលោ វជិរូបមចិត្តោ បុគ្គលោ

(៦) អន្ធោ ឯកចក្ខុ ទ្វិចក្ខុ

(៧) អវកុជ្ជប្បញ្ញោ បុគ្គលោ ឧច្ឆង្គប្បញ្ញោ បុគ្គលោ បុថុប្បញ្ញោ បុគ្គលោ

(៨) អត្ថេកច្ចោ បុគ្គលោ កាមេសុ ច ភវេសុ ច អវីតរាគោ, អត្ថេកច្ចោ បុគ្គលោ កាមេសុ វីតរាគោ ភវេសុ អវីតរាគោ, អត្ថេកច្ចោ បុគ្គលោ កាមេសុ ច ភវេសុ ច វីតរាគោ

(៩) បាសាណលេខូបមោ បុគ្គលោ, បថវីលេខូបមោ បុគ្គលោ, ឧទកលេខូបមោ បុគ្គលោ

(១០) តយោ បោត្ថកូបមា បុគ្គលា

(១១) តយោ កាសិកវត្ថូបមា បុគ្គលា

(១២) សុប្បមេយ្យោ, ទុប្បមេយ្យោ, អប្បមេយ្យោ

(១៣) អត្ថេកច្ចោ បុគ្គលោ ន សេវិតព្វោ ន ភជិតព្វោ ន បយិរុបាសិតព្វោ, អត្ថេកច្ចោ បុគ្គលោ សេវិតព្វោ ភជិតព្វោ បយិរុបាសិតព្វោ, អត្ថេកច្ចោ បុគ្គលោ សក្កត្វា គរុកត្វា សេវិតព្វោ ភជិតព្វោ បយិរុបាសិតព្វោ

(១៤) អត្ថេកច្ចោ បុគ្គលោ ជិគុច្ឆិតព្វោ ន សេវិតព្វោ ន ភជិតព្វោ ន បយិរុបាសិតព្វោ, អត្ថេកច្ចោ បុគ្គលោ អជ្ឈុបេក្ខិតព្វោ ន សេវិតព្វោ ន ភជិតព្វោ ន បយិរុបាសិត-ព្វោ, អត្ថេកច្ចោ បុគ្គលោ សេវិតព្វោ ភជិតព្វោ បយិរុបាសិតព្វោ

(១៥) អត្ថេកច្ចោ បុគ្គលោ សីលេសុ បរិបូរីការី, សមាធិស្មឹ មត្តសោការី, បញ្ញាយ មត្តសោការី, អត្ថេកច្ចោ បុគ្គលោ សីលេសុ ច បរិបូរីការី, សមាធិស្មឹច បរិបូរីការី, បញ្ញាយ មត្តសោ ការី, អត្ថេកច្ចោ បុគ្គលោ សីលេសុ ច បរិបូរីការី, សមាធិស្មឹ ច បរិបូរីការី, បញ្ញាយ ច បរិបូរីការី

(១៦) តយោ សត្ថារោ

(១៧) អបរេបិ តយោ សត្ថារោ។

# តិកមាតិកា និដ្ឋិតា

## ៤. ចតុក្កឧទ្ទេសោ

## ចត្តារោ បុគ្គលា

(១) អសប្បុរិសោ, អសប្បុរិសេន អសប្បុរិសតរោ, សប្បុរិសោ, សប្បុរិសេន សប្បុរិសតរោ។

(២) បាបោ, បាបេន បាបតរោ, កល្យាណោ, កល្យាណេន កល្យាណតរោ ។

(៣) បាបធម្មោ, បាបធម្មេន បាបធម្មតរោ, កល្យាណធម្មោ, កល្យាណធម្មេន កល្យាណធម្មតរោ ។

(៤) សាវជ្ជោ, វជ្ជពហុលោ, អប្បសាវជ្ជោ, អនវជ្ជោ។

(៥) ឧគ្ឃដិតញ្ញូ, វិបចិតញ្ញូ, នេយ្យោ, បទបរមោ។

(៦) យុត្តប្បដិភាណោ, នោ មុត្តប្បដិភាណោ, មុត្តប្បដិភាណោ, នោ យុត្តប្បដិភាណោ, យុត្តប្បដិភាណោ ច មុត្តប្បដិភាណោ ច, នេវ យុត្តប្បដិភាណោ នោ មុត្តប្បដិភាណោ ។

(៧) ចត្តារោ ធម្មកថិកា បុគ្គលា ។

(៨) ចត្តារោ វលាហកូបមា បុគ្គលា ។

(៩) ចត្តារោ មូសិកូបមា បុគ្គលា ។

(១០) ចត្តារោ អម្ពូបមា បុគ្គលា។

(១១) ចត្តារោ កុម្ភូបមា បុគ្គលា។

(១២) ចត្តារោ ឧទករហទូបមា បុគ្គលា។

(១៣) ចត្តារោ ពលិពទ្ទូបមា បុគ្គលា។

(១៤) ចត្តារោ អាសីវិសូបមា បុគ្គលា ។

(១៥) អត្ថេកច្ចោ បុគ្គលោ អននុវិច្ច អបរិយោគាហេត្វា អវណ្ណារហស្ស វណ្ណំ ភាសិតា ហោតិ, អត្ថេកច្ចោ បុគ្គលោ អននុវិច្ច អបរិយោគាហេត្វា វណ្ណារហស្ស អវណ្ណំ ភាសិតា ហោតិ, អត្ថេកច្ចោ បុគ្គលោ អននុវិច្ច អបរិយោគាហេត្វា អប្បសាទនីយេ ឋានេ បសាទំ ឧបទំសិតា ហោតិ, អត្ថេកច្ចោ បុគ្គលោ អននុវិច្ច អបរិយោគាហេត្វា បសាទនីយេ ឋានេ អប្បសាទំ ឧបទំសិតា ហោតិ ។

(១៦) អត្ថេកច្ចោ បុគ្គលោ អនុវិច្ច បរិយោគាហេត្វា អវណ្ណារហស្ស អវណ្ណំ ភាសិតា ហោតិ, អត្ថេកច្ចោ បុគ្គលោ អនុវិច្ច បរិយោគាហេត្វា វណ្ណារហស្ស វណ្ណំ ភាសិតា ហោតិ, អត្ថេកច្ចោ បុគ្គលោ អនុវិច្ច បរិយោគាហេត្វា អប្បសាទនីយេ ឋានេ អប្បសាទំ ឧបទំសិតា ហោតិ, អត្ថេកច្ចោ បុគ្គលោ អនុវិច្ច បរិយោគាហេត្វា បសាទនីយេ ឋានេ បសាទំ ឧបទំសិតា ហោតិ។

(១៧) អត្ថេកច្ចោ បុគ្គលោ អវណ្ណារហស្ស អវណ្ណំ ភាសិតា ហោតិ ភូតំ តច្ឆំ កាលេន នោ ច ខោ វណ្ណារហស្ស វណ្ណំ

ភាសិតា ហោតិ ភូតំ តច្ឆំ កាលេន, អត្ថេកច្ចោ បុគ្គលោ វណ្ណារហស្ស វណ្ណំ ភាសិតា ហោតិ ភូតំ តច្ឆំ កាលេន នោ ច ខោ អវណ្ណារហស្ស អវណ្ណំ ភាសិតា ហោតិ ភូតំ តច្ឆំ កាលេន, អត្ថេកច្ចោ បុគ្គលោ អវណ្ណារហស្ស ច អវណ្ណំ ភាសិតា ហោតិ ភូតំ តច្ឆំ កាលេន វណ្ណារហស្ស ច វណ្ណំ ភាសិតា ហោតិ ភូតំ តច្ឆំ កាលេន, អត្ថេកច្ចោ បុគ្គលោ នេវ អវណ្ណារហស្ស អវណ្ណំ ភាសិតា ហោតិ ភូតំ តច្ឆំ កាលេន នោ ច វណ្ណារហស្ស វណ្ណំ ភាសិតា ហោតិ ភូតំ តច្ឆំ កាលេន ។

(១៨) ឧដ្ឋានផលូបជីវី នោ បុញ្ញផលូបជីវី, បុញ្ញផលូបជីវី នោ ឧដ្ឋានផលូបជីវី, ឧដ្ឋានផលូបជីវី ច បុញ្ញផលូបជីវី ច, នេវ ឧដ្ឋានផលូបជីវី នោ បុញ្ញផលូបជីវី ។

(១៩) តមោ តមបរាយនោ, តមោ ជោតិបរាយនោ, ជោតិ តមបរាយនោ, ជោតិ ជោតិបរាយនោ។

(២០) ឱណតោណតោ, ឱណតុណ្ណតោ, ឧណ្ណតោណតោ, ឧណ្ណតុណ្ណតោ ។

(២១) ចត្តារោ រុក្ខូបមា បុគ្គលា ។

(២២) រូបប្បមាណោ រូបប្បសន្នោ ឃោសប្បមាណោ ឃោសប្បសន្នោ លូខប្បមាណោ លូខប្បសន្នោ ធម្មប្បមាណោ ធម្មប្បសន្នោ ។

(២៣) អត្ថេកច្ចោ បុគ្គលោ អត្តហិតាយ បដិបន្នោ ហោតិ នោ បរហិតាយ, អត្ថេកច្ចោ បុគ្គលោ បរហិតាយ បដិបន្នោ ហោតិ នោ អត្តហិតាយ; អត្ថេកច្ចោ បុគ្គលោ អត្តហិតាយ ចេវ បដិបន្នោ ហោតិ បរហិតាយ ច, អត្ថេកច្ចោ បុគ្គលោ នេវ អត្តហិតាយ បដិបន្នោ ហោតិ នោ បរហិតាយ ។

(២៤) អត្ថេកច្ចោ បុគ្គលោ អត្តន្តបោ ហោតិ អត្តបរិតាបនានុយោគមនុយុត្តោ, អត្ថេកច្ចោ បុគ្គលោ បរន្តបោ ហោតិ បរបរិតាបនានុយោគមនុយុត្តោ, អត្ថេកច្ចោ បុគ្គលោ អត្តន្តបោ ច ហោតិ អត្តបរិតាបនានុយោគមនុយុត្តោ បរន្តបោ ច បរបរិតាបនានុយោគមនុយុត្តោ, អត្ថេកច្ចោ បុគ្គលោ នេវអត្តន្តបោ ហោតិ ន អត្តបរិតាបនានុយោគមនុយុត្តោ, ន បរន្តបោ ន បរបរិតាបនានុយោគមនុយុត្តោ សោ អនត្តន្តបោ អបរន្តបោ ទិដ្ឋេវ ធម្មេ និច្ឆាតោ និព្វុតោ សីតីភូតោ សុខប្បដិសំវេទី ព្រហ្មភូតេន អត្តនា វិហរតិ ។

(២៥) សរាគោ, សទោសោ, សមោហោ, សមានោ ។

(២៦) អត្ថេកច្ចោ បុគ្គលោ លាភី ហោតិ អជ្ឈត្តំ ចេតោសមថស្ស ន លាភី អធិប្បញ្ញាធម្មវិបស្សនាយ, អត្ថេកច្ចោ បុគ្គលោ លាភី ហោតិ អធិប្បញ្ញាធម្មវិបស្សនាយ ន លាភី អជ្ឈត្តំ ចេតោសមថស្ស, អត្ថេកច្ចោ បុគ្គលោ លាភី ចេវ ហោតិ អជ្ឈត្តំ ចេតោសមថស្ស, លាភី ច អធិប្បញ្ញាធម្មវិបស្សនាយ, អត្ថេកច្ចោ បុគ្គលោ នេវ លាភី ហោតិ អជ្ឈត្តំ ចេតោសមថស្ស ន លាភី អធិប្បញ្ញាធម្ម-វិបស្សនាយ។

(២៧) អនុសោតគាមី បុគ្គលោ, បដិសោតគាមី បុគ្គលោ, ឋិតត្តោ បុគ្គលោ, តិណ្ណោ បារគតោ ថលេ តិដ្ឋតិ ព្រាហ្មណោ។

(២៨) អប្បស្សុតោ សុតេន អនុបបន្នោ, អប្បស្សុតោ សុតេន ឧបបន្នោ, ពហុស្សុតោ សុតេន អនុបបន្នោ, ពហុស្សុតោ សុតេន ឧបបន្នោ។

(២៩) សមណមចលោ, សមណបទុមោ, សមណបុណ្ឌរីកោ, សមណេសុ សមណសុខុមាលោ។

## ចតុក្កមាតិកា និដ្ឋិតា

## ៥. បញ្ចកឧទ្ទេសោ

## បញ្ច បុគ្គលា

(១) អត្ថេកច្ចោ បុគ្គលោ អារព្ភតិ ច វិប្បដិសារី ច ហោតិ តញ្ច ចេតោវិមុត្តឹបញ្ញាវិមុត្តឹ យថាភូតំ នប្បជានាតិ យត្ថស្ស តេ ឧប្បន្នា បាបកា អកុសលា ធម្មា អបរិសេសា និរុជ្ឈន្តិ, អត្ថេកច្ចោ បុគ្គលោ អារព្ភតិ ន វិប្បដិសារី ហោតិ តញ្ច ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ យថាភូតំ នប្បជានាតិ យត្ថស្ស តេ ឧប្បន្នា បាបកា អកុសលា ធម្មា អបរិសេសា និរុជ្ឈន្តិ, អត្ថេកច្ចោ បុគ្គលោ នារព្ភតិ វិប្បដិសារី ហោតិ តញ្ច ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ យថាភូតំ នប្បជានាតិ, យត្ថស្ស តេ ឧប្បន្នា បាបកា អកុសលា ធម្មា អបរិសេសា និរុជ្ឈន្តិ, អត្ថេកច្ចោ បុគ្គលោ នារព្ភតិ ន វិប្បដិសារី ហោតិ តញ្ច ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ យថាភូតំ នប្បជានាតិ, យត្ថស្ស តេ ឧប្បន្នា បាបកា អកុសលា ធម្មា អបរិសេសា និរុជ្ឈន្តិ, អត្ថេកច្ចោ បុគ្គលោ នារភតិ ន វិប្បដិសារី ហោតិ តញ្ច ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ យថាភូតំ បជានាតិ យត្ថស្ស តេ ឧប្បន្នា បាបកា អកុសលា ធម្មា អបរិសេសា និរុជ្ឈន្តិ។

(២) ឧត្វា អវជាតាតិ, សំវាសេន អវជាតាតិ, អាជេយ្យមុខោ ហោតិ, សោរសោ ហោតិ, មង្គោ មោមូហោ ហោតិ ។

(៣) បញ្ចូ យោជាជីវូបមា បុគ្គលា ។

(៤) បញ្ចូ បិណ្ឌចាតិកា ។

(៥) បញ្ចូ ខលុបច្ឆាភត្តិកា ។

(៦) បញ្ចូ ឯកាសនិកា ។

(៧) បញ្ចូ បំសុកូលិកា ។

(៨) បញ្ចូ តេចីវរិកា ។

(៩) បញ្ចូ អារញ្ញិកា ។

(១០) បញ្ចូ រុក្ខមូលិកា ។

(១១) បញ្ចូ អព្ភោកាសិកា។

(១២) បញ្ចូ នេសជ្ជិកា។

(១៣) បញ្ចូ យថាសន្ថតិកា។

(១៤) បញ្ចូ សោសានិកា។

## <u>បញ្ចកមាតិកា និដ្ឋិតា</u>

## ៦. ឆក្កឧទ្ទេសោ

### ឆ បុគ្គលា

(១) អត្ថេកច្ចោ បុគ្គលោ បុព្វេ អននុស្សុតេសុ ធម្មេសុ សាមំ សច្ចានិ អភិសម្ពុជ្ឈតិ តត្ថ ច សព្វញ្ញុតំ បាបុណាតិ ពលេសុ ច វសីភាវំ ។ អត្ថេកច្ចោ បុគ្គលោ បុព្វេ អននុស្សុតេសុ ធម្មេសុ សាមំ សច្ចានិ អភិសម្ពុជ្ឈតិ ន ច តត្ថ សព្វញ្ញុតំ បាបុណាតិ ន ច ពលេសុ វសីភាវំ ។ អត្ថេកច្ចោ បុគ្គលោ បុព្វេ អននុស្សុតេសុ ធម្មេសុ សាមំ សច្ចានិ អនភិសម្ពុជ្ឈតិ ទិដ្ឋេ ចេវ ធម្មេ ទុក្ខស្សន្តករោ ហោតិ សាវកបារមិញ្ចបាបុណាតិ។ អត្ថេកច្ចោ បុគ្គលោ បុព្វេ អននុស្សុតេសុ ធម្មេសុ សាមំ សច្ចានិ អនភិសម្ពុជ្ឈតិ ទិដ្ឋេវ ធម្មេ ទុក្ខស្សន្តករោ ហោតិ ន ច សាវកបារមឹ បាបុណាតិ ។ អត្ថេកច្ចោ បុគ្គលោ បុព្វេ អននុស្សុតេសុ ធម្មេសុ សាមំ សច្ចានិ អនភិសម្ពុជ្ឈតិ ន ច ទិដ្ឋេវ ធម្មេ ទុក្ខស្សន្តករោ ហោតិ អនាគាមី ហោតិ អនាគន្តា ឥត្ថត្តំ។ អត្ថេកច្ចោ បុគ្គលោ បុព្វេ អននុស្សុតេសុ ធម្មេសុ សាមំ សច្ចានិ អនភិសម្ពុជ្ឈតិ ន ច ទិដ្ឋេវ ធម្មេ ទុក្ខស្សន្តករោ ហោតិ សោតាបន្នសកទាគាមី ហោតិ អាគន្តា ឥត្ថត្តំ។

## ឆក្កមាតិកា និដ្ឋិតា ។

### ៧. សត្តកឧទ្ទេសោ

### សត្ត បុគ្គលា

(១) សត្ត ឧទកូបមា បុគ្គលា។ សកិំ និមុគ្គោ និមុគ្គោវ ហោតិ, ឧម្មុជ្ជិត្វា និមុជ្ជ តិ, ឧម្មុជ្ជិត្វា ឋិតោ ហោតិ, ឧម្មុជ្ជិត្វា វិបស្សតិ វិលោកេតិ, ឧម្មុជ្ជិត្វា បតរតិ, ឧម្មុជ្ជិត្វា បដិគាធប្បត្តោ ហោតិ, ឧម្មុជ្ជិត្វា តិណ្ណោ ហោតិ បារគតោ ថលេ តិដ្ឋតិ ព្រាហ្មណោ។

(២) ឧភតោភាគវិមុត្តោ បញ្ញាវិមុត្តោ កាយសក្ខី ទិដ្ឋិប្បត្តោ សទ្ធាវិមុត្តោ ធម្មានុសារី សទ្ធានុសារី។

## <u>សត្តកមាតិកា និដ្ឋិតា</u>

### ៨. អដ្ឋកឧទ្ទេសោ

### អដ្ឋ បុគ្គលា

(១) ចត្តារោ មគ្គសមង្គីនោ, ចត្តារោ ផលសមង្គីនោ បុគ្គលា។

## អដ្ឋកមាតិកា និដ្ឋិតា

### ៩. នវកឧទ្ទេសោ

### នវ បុគ្គលា

(១) សម្មាសម្ពុទ្ធោ, បច្ចេកសម្ពុទ្ធោ, ឧភតោភាគវិមុត្តោ, បញ្ញាវិមុត្តោ, កាយសក្ខី, ទិដ្ឋិប្បត្តោ, សទ្ធាវិមុត្តោ, ធម្មានុ - សារី, សទ្ធានុសារី។

## នវកមាតិកា និដ្ឋិតា

### ១០. ទសកឧទ្ទេសោ

### ទស បុគ្គលា

(១) បញ្ចន្នំ ឥធ និដ្ឋា, បញ្ចន្នំ ឥធ វិហាយ និដ្ឋា។

# <u>ឧសភមាតិកា និទ្ទិសា</u>

# បុគ្គលប្បញ្ញត្តិមាតិកា និទ្ទិសា

# ឯកកនិទ្ទេស

## ( បុគ្គលពួក១ )

## (១). សមយវិមុត្តបុគ្គល

បុគ្គលខ្លះក្នុងលោកនេះ បាន**វិមោក្ខ៨**ដោយនាមកាយ តាមកាលគួរ មានតាមកាល តាមសម័យគួរ អាសវៈពួកខ្លះ របស់បុគ្គលនោះក៏បានអស់ទៅ **ព្រោះឃើញដោយបញ្ញា** នេះហៅថា **បុគ្គលជាសមយវិមុត្ត** ។

អធិប្បាយ

ពាក្យថា **វិមោក្ខ** បានដល់ វិមោក្ខទាំង៨ (អដ្ឋវិមោក្ខ : រូបាវចរ៤ អរូបាវចរៈ៤ ដោយសុត្តន្តន័យ) ។ពិតមែន ពាក្យថា វិមោក្ខ នេះជាឈ្មោះរបស់សមាបត្តិទាំង៨នោះ ព្រោះរួចចាកធម៌ដែលជាសត្រូវទាំងឡាយ (នីវរណធម៌៥ និងធម៌ដែលជាសត្រូវដល់ឈានតាមលំដាប់) ។ ពាក្យថា **កាយេន** : នាមកាយ ដែលកើតព្រមជាមួយនិងវិមោក្ខ ( បានដល់នាមក្ខន្ធ៣ដ៏សេស ) ។

# កាលមាន ២ យ៉ាង

**១.អកាល** =ជាកាលដែលលោកធ្វើវត្តបដិបត្តផ្សេងៗ ពេលនោះជាកាលដែលលោកមិនចូលសមាបត្តិទេ។

**២.កាល**=ពេលដែលលោកធ្វើវត្តបដិបត្តិទាំងនោះស្រេចហើយ ឬចន្លោះកាលនោះ លោកចូលទៅកាន់ទីកន្លែងដែលស្ងាត់ហើយ ចូលសមាបត្តិនេះហៅថាជាកាលដែលលោកចូលសមាបត្តិ ។

ពាក្យថា "សមាបត្តិ"នេះ បានដល់ បុគ្គលដែលបានរូបឈានដោយការកន្លងបង់នីវរណៈ និងអង្គឈានតាមលំដាប់, និងបុគ្គលដែលបានអរូបឈានដោយការកន្លងបង់រូបឈាន។

ពាក្យថា **បញ្ញាយ ចស្ស ទិស្វា** ប្រែថា ព្រោះឃើញដោយបញ្ញា សេចក្ដីថា ព្រោះឃើញសង្ខារដោយវិបស្សនាបញ្ញា ឃើញសច្ចធម៌ទាំង៤ ដោយមគ្គប្បញ្ញា។

ពាក្យថា **ឯកច្ចេ អាសវា បរិក្ខីណា ហោន្តិ** ប្រែថា អាសវៈពួកខ្លះ របស់បុគ្គលនោះក៏បានអស់ទៅ " អធិប្បាយថា អាសវៈទាំងឡាយ ដែលបឋមមគ្គ ជាដើម គប្បីប្រហារចំណែកមួយៗ (តាមលំដាប់មគ្គ) អស់ទៅ បុគ្គលនេះ លោកហៅថា **សមយ-**

***វិមុត្តោ*** : *អ្នករួចហើយ ដោយសម័យ" ។ ក៏ពាក្យថា អាសវៈរបស់បុគ្គលដែលអស់ទៅខ្លះ បុថុជ្ជន ដែលជាអ្នកបានសមាបត្តិ៨ក្តី មិនបានក្តី មិនដែលលះបង់កិលេសដោយចំណែកណា១ទេ ដូច្នេះទើបទ្រង់មិនកាន់យក* (*ក្នុងបទនេះ*)*។សូម្បីព្រះខីណាស្រពដែលបានសមាបត្តិ៨ក្តី មិនបានក្តី ក៏ទ្រង់មិនកាន់យកដែរព្រោះព្រះអរហន្តទាំងឡាយមិនមានកិលេសនៅសល់ទៀតឡើយ។ ដូច្នេះសមយវិមុត្តបុគ្គលនេះ បានដល់ ព្រះសោតាបន្ន ព្រះសកទាគាមី អនាគាមីដែលបានសមាបត្តិ៨ ។*

ចប់សមយវិមុត្តបុគ្គល

## (២). អសមយវិមុត្តបុគ្គល

*បុគ្គលខ្លះក្នុងលោកនេះ មិនបានសមាបត្តិ៨ ដោយនាមកាយ តាមកាលគួរ តាមសម័យគួរទេ អាសវៈរបស់បុគ្គលនោះបានអស់ទៅ ព្រោះឃើញដោយបញ្ញា នេះហៅថា* ***បុគ្គលជាអសមយវិមុត្ត*** *។ សូម្បីព្រះអរិយបុគ្គលទាំងអស់ ក៏ឈ្មោះថា* ***អសមយវិមុត្ត ក្នុងអរិយវិមោក្ខ*** (*លោកុត្តរវិមោក្ខដែរ*) ។

***អធិប្បាយ***

ពាក្យថា **អសមយវិមុត្តោ** ប្រែថា បុគ្គលរួចផុតដោយមិនអាស្រ័យសមាបត្តិ៨ បានដល់ ព្រះអរហន្តដែលជា សុក្ខវិបស្សកៈ។ ចំណែកឯព្រះសុក្ខវិបស្សកបុគ្គលក្រៅនេះ ដូចជា ព្រះសោតាបន្ន ព្រះសកទាគាមី ព្រះអនាគាមី និង ព្រះអរហន្តដែលបានសមាបត្តិ៨ និងបុថុជ្ជនមិនបានត្រាស់ទុកក្នុងទុកៈ(សមយវិមុត្តោ និងអសមយវិមុត្តោ)នេះទេ ។ដូច្នេះបុគ្គលទាំងនេះ ឈ្មោះថា ទុកមុត្តកបុគ្គល ។ ព្រោះហេតុដូច្នោះ ទើបព្រះសាស្តាទ្រង់រួបរួមបុគ្គលទាំងឡាយ ដែលព្រះអង្គទ្រង់កាន់យក និងមិនកាន់យក ក្នុងខាងក្រោយ គឺអ្នកបែរទៅខាងក្រោយ ព្រោះភាវៈនៃព្រះអង្គជាអ្នកមានបញ្ញាជាគ្រឿងត្រាស់ដឹងហើយដោយល្អទើបត្រាស់នូវពាក្យជាដើមថា **សព្វេបិ អរិយបុគ្គលា** : សូម្បីព្រះអរិយបុគ្គលទាំងអស់ ។

ពាក្យថា អរិយវិមោក្ខេ : ក្នុងអរិយវិមោក្ខ បានដល់ វិមោក្ខដែលជាលោកុត្តរ ដែលដល់នូវការរាប់ថា“**អរិយៈ**” ព្រោះឆ្ងាយចាកកិលេសទាំងឡាយ ។

**សេចក្តីនេះមានពាក្យអធិប្បាយថា** ៖សម័យក្តី អសម័យក្តី របស់លោកអ្នកចូលសមាបត្តិ៨ខាងក្រៅពុទ្ធសាសនាមាន។ សម័យ ឬអសម័យរបស់លោកអ្នកផុតដោយមគ្គវិមោក្ខ រមែងមិន

មាន(ខាងក្រៅព្រះពុទ្ធសាសសនា)ទេ ។ សទ្ធារបស់បុគ្គលណា មានកម្លាំង និងវិបស្សនាដែលបុគ្គលឯណា ប្រារព្ធហើយមានពិត, តែការចាក់ធ្លុះមគ្គ និងផលរបស់អ្នកនោះដែលកំពុងដើរ,ឈរ, អង្គុយ,ដេក,ទំពារនិងបរិភោគមិនមានក៏ទេ ព្រោះហេតុនោះ សម័យនិងអសម័យរបស់អ្នកផុតដោយមគ្គវិមោក្ខ ទើបមិនមាន ។ ព្រោះហេតុដូច្នោះ បទថា“ **មគ្គវិមោក្ខេន វិមុច្ចនស្ស សមយោ វា អសមយោ វា នត្ថិ**”នេះព្រះមានព្រះភាគ ព្រះអង្គជាធម្មរាជា ទ្រង់រួបរួមបុគ្គលទាំងឡាយ ដែលព្រះអង្គទ្រង់កាន់យក និងទ្រង់មិនកាន់យកមករួបរួមក្រោយ ហើយលើកឡើងកាន់បែបដែនដែលជាបិដ្ឋិវដ្តកៈនេះ។សូម្បីបុថុជ្ជន អ្នកបានសមាបត្តិ៨ ក៏ព្រះអង្គទ្រង់មិនមានបំណងយក ដោយបែបដែននេះឡើយ , តែថា ព្រះមានព្រះភាគកាលនឹងទ្រង់ចែកបុគ្គលអ្នកបានសមាបត្តិ៨នោះ ក៏គប្បីចែកនូវភាពជាសមយវិមុត្តបុគ្គល ដោយអំណាចនៃកិលេសដែលលោកសង្កត់សង្កិនទុកហើយដោយសមាបត្តិ ។

**ចប់អសមយវិមុត្តបុគ្គល**

## (៣). កុប្បធម្មបុគ្គល

*បុគ្គលខ្លះក្នុងលោកនេះ បាន**សមាបត្តិប្រកបដោយរូបក្តី ប្រកបដោយអរូបក្តី** បុគ្គលនោះឯង មិនបានតាមប្រាថ្នា មិនបានដោយមិនលំបាក មិនបានដោយងាយ ចូលមិនបានផង ចេញមិនបានផង តាមឱកាសដែលប្រាថ្នា តាមសមាបត្តិ ដែលប្រាថ្នា តាមកាលកំណត់ ដែលប្រាថ្នាទេ ដំណើរនុ៎ះរមែងមានត្រង់ដែលសមាបត្តិទាំងនោះ កម្រើកព្រោះអាស្រ័យសេចក្តីប្រមាថ របស់បុគ្គលនោះ នេះហៅថា **បុគ្គលជាកុប្បធម្មៈ** ។*

*អធិប្បាយ*

*សមាបត្តិធម៌ ដែលបុគ្គលណាសម្រេចហើយ រមែងកម្រើក រមែងវិនាស ព្រោះហេតុនោះ បុគ្គលនោះ ទើបឈ្មោះថា* **កុប្បធម្មោ** *អ្នកមានធម៌ដែលកម្រើក ។* ***អកាមលាភី*** *: រូបឈានក្តី អរូបឈានក្តី គឺ មិនមែនជាអ្នកបានតាមសេចក្តីប្រាថ្នា ព្រោះភាពជាអ្នកមិនស្ទាត់ជំនាញហើយ ដោយអាការៈទាំង៥ យ៉ាង (វសី៥) អធិប្បាយថា ជាអ្នកមិនជំនាញចូលសមាបត្តិ ។*

**មានសេចក្តីអធិប្បាយដូច្នេះថា៖** ព្រះយោគីរមែងប្រាថ្នានឹងចូលខ្លះ ចេញខ្លះ នូវសមាបត្តិណាៗ ក្នុងទីណាៗ រហូតដល់អស់កាលយូរមានប្រមាណប៉ុនណា រមែងមិនអាចដើម្បីនឹងចូលខ្លះចេញខ្លះ នូវសមាបត្តិនោះៗ ក្នុងទីនោះៗ រហូតដល់អស់កាល យូរមានប្រមាណប៉ុណ្ណោះ គឺងើយមើលព្រះចន្ទ ឬព្រះអាទិត្យ ហើយកំណត់ថា "កាលព្រះចន្ទ ឬព្រះអាទិត្យនេះទៅកាន់ទី ប្រមាណប៉ុណ្ណោះហើយ អាត្មាអញនឹងចេញចាកសមាបត្តិ " ហើយក៏ចូលឈាន រមែងមិនអាចដើម្បីនឹងចេញតាមការកំណត់ទុករមែងចេញក្នុងចន្លោះវិញព្រោះខ្លួនជាអ្នកមិនជំនាញក្នុងសមាបត្តិ **បមាទមាគ-ម្ម**: ព្រោះអាស្រ័យនូវសេចក្តីប្រមាទ ។

**បុគ្គល ៣ ពួក៖** បុថុជ្ជនអ្នកបានសមាបត្តិ៨, ព្រះសោតា-បន្ន , ព្រះសកទាគាមី បុគ្គលទាំងនេះ លោកហៅថា **កុប្បធម្មោ**: អ្នកមានធម៌កម្រើក ព្រោះធម៌ដែលជាសត្រូវចំពោះសមាធិ និងវិបស្សនា របស់លោកទាំងនោះ លោកសង្កត់ទុកមិនល្អជម្រះលាងមិនល្អ ព្រោះហេតុដូច្នោះ សមាបត្តិរបស់លោកទាំងនោះ ទើបវិនាសសូន្យទៅ ។ម្យ៉ាងទៀតវិនាសទៅ សូន្យទៅព្រោះសីលដាច់

ឬព្រោះការកន្លងអាបត្តិក៏មិនមែន គឺជាអ្នកបែកធ្លាយវត្តសូម្បីតិច តួចក៏មាន ។

## សេចក្តីនេះមានរឿងជាឧទាហរណ៍

បានឮថា ព្រះថេរមួយអង្គចម្រើនសមាបត្តិ គឺយកស្ថានទីមួយជាទី ធ្វើសមាបត្តិ កាលបើលោកទៅកាន់ស្រុកដើម្បីបិណ្ឌបាត ពួកក្មេងលេងនៅត្រង់បរិវេណវិហារ លុះពួកក្មេងទាំងនោះលេងរួចហើយ ក៏នាំគ្នាជៀសចេញទៅ ព្រះថេរមកហើយគិតថា "ពួកក្មេងៗគង់នឹងមកបោសបរិវេណ"ទើបលោកមិនបោស ទើបព្រះថេរៈចូលទៅកាន់វិហារដោយគិតថា"យើងនឹងចូលសមាបត្តិ" លោកមិនអាចដើម្បីនឹងចូលបាន ទើបរំពឹងដល់សីលថា " ព្រោះហេតុអ្វីហ្ន៎ " ដូច្នោះ លោកមិនឃើញការឈានកន្លងសិក្ខាបទសូម្បីមានប្រមាណតិចតួច ទើបពិចារណាមើលថា "វត្តភេទ គឺការបែកធ្លាយនៃវត្តរបស់យើងមានឬ" បានដឹងថាខ្លួនមិនបានបោសទីបរិវេណកុដិ លុះញុំាងកិច្ចនោះឱ្យសម្រេចហើយ ក៏ទៅអង្គុយចូលសមាបត្តិដោយមិនលំបាក។

**ចប់កុប្បធម្មបុគ្គល**

## (៤). អកុប្បធម្មបុគ្គល

បុគ្គលខ្លះ ក្នុងលោកនេះ បានសមាបត្តិទាំងឡាយប្រកបដោយរូបក្តី ប្រកបដោយអរូបក្តី បុគ្គលនោះឯង បានតាមប្រាថ្នា បានមិនលំបាក បានដោយងាយ ចូលផង ចេញផង តាមឱកាសដែលប្រាថ្នា តាមសមាបត្តិដែលប្រាថ្នា តាមកាលកំណត់ដែលប្រាថ្នា ដំណើរនុ៎ះមិនមែនហេតុ មិនមែនជាឱកាសទេ ត្រង់ដែលសមាបត្តិទាំងនោះ កម្រើកព្រោះអាស្រ័យសេចក្តីប្រមាទរបស់បុគ្គលនោះ នេះហៅថា **បុគ្គលអកុប្បធម្មៈ** ។សូម្បីពួកព្រះអរិយបុគ្គលទាំងអស់ ក៏ឈ្មោះថា **អកុប្បធម្មៈ ក្នុងអរិយវិមោក្ខដែរ។**

អធិប្បាយ

**អកុប្បធម្មបុគ្គល** បណ្ឌិតគប្បីជ្រាបដោយអំណាច នៃបដិបក្ខន័យរបស់កុប្បធម្មបុគ្គល ដែលពោលទុកហើយនោះឯង ។ ក៏ពាក្យថា អកុប្បធម្មៈ នេះជាឈ្មោះថារបស់ព្រះអរិយបុគ្គល ២ ជំពូក គឺ **ព្រះអនាគាមីដែលបានសមាបត្តិ៨ និងព្រះខីណាស្រព** ។ ពិតមែនហើយ ធម៌ទាំងឡាយ ដែលជាសត្រូវដល់សមាធិ និងវិបស្សនារបស់លោកទាំងនោះ លោកសង្កត់ទុកល្អហើយ ជម្រះ

លាងទុកល្អហើយ ព្រោះហេតុដូច្នោះ កាលបើលោកទាំងនោះ សូម្បីញ៉ាំងកាលឱ្យអស់ទៅដោយកិច្ច មានការសន្ទនា និងភាពជាអ្នកត្រេកអរដោយពួកគណៈជាដើម ឬដោយសេចក្តីប្រមាទដែលមិនសមគួរដល់ខ្លួនយ៉ាងណាមួយដទៃៗ សមាបត្តិក៏មិនកម្រើក មិនវិនាស, តែថា ព្រះសោតាបន្ន ព្រះសកទាគាមី ព្រះអនាគាមី និងព្រះខីណាស្រពជាសុក្ខវិបស្សកៈ រមែងមិនបានក្នុងទុកៈនេះទេ លោកទាំងនោះ ទើបឈ្មោះថា **ទុកមុត្តកបុគ្គល ។**

ព្រោះហេតុដូច្នោះ ទើបព្រះសាស្តាទ្រង់រួបរួមបុគ្គលទាំងឡាយ ដែលព្រះអង្គទ្រង់កាន់យក និងទ្រង់មិនកាន់យកក្នុងពេលក្រោយ ហើយ លើកឡើងកាន់បែបដែន ជាមួយនឹង បិដ្ឋិវដ្ដកបុគ្គលទាំងឡាយទុកសូម្បីក្នុងទុកៈនេះ ព្រោះព្រះអង្គមានបញ្ញាជាគ្រឿងត្រាស់ដឹងល្អ ទើបត្រាស់ ពាក្យជាដើមថា **សព្វេបិ អរិយបុគ្គលា** = សូម្បីពួកព្រះអរិយបុគ្គលទាំងអស់ ។

ម្យ៉ាងទៀត ប្រសិនបើការកម្រើកសេចក្តីវិនាសនៃសមាបត្តិ ៨របស់លោកនឹងគប្បីមានឡើង តែលោកុត្តរធម៌ ដែលលោកចាក់ធ្លុះហើយមួយគ្រា មិនអាចកម្រើក និងវិនាសទៅឡើយ ពាក្យនេះលោកពោលសំដៅយកអ្នកសម្រេចលោកុត្តរធម៌នោះ។

(៥). **បរិហានបុគ្គល** =បុគ្គលមានធម៌សាបសូន្យ ។

(៦). **អបរិហានបុគ្គល**= បុគ្គលមានធម៌មិនសាបសូន្យ ។

ទាំងពីរនេះមានសេចក្តីប្លែកផ្សេងគ្នាត្រឹមតែព្យញ្ជនៈប៉ុណ្ណោះ, ពាក្យអធិប្បាយដ៏សេសដូចគ្នាកុប្បធម្មបុគ្គល និងអកុប្បធម្មបុគ្គលហើយ ៕

ចប់អកុប្បធម្មបុគ្គល

(៧). ចេតនាភព្វបុគ្គល

បុគ្គលខ្លះក្នុងលោកនេះ បានសមាបត្តិប្រកបដោយរូបក្តី ប្រកបដោយអរូបក្តី បុគ្គលនោះឯង មិនបានតាមប្រាថ្នា មិនបានដោយមិនលំបាក មិនបានដោយងាយ ចូលមិនបានផង ចេញមិនបានផង តាមឱកាសដែលប្រាថ្នា តាមសមាបត្តិ ដែលប្រាថ្នា តាមកាលកំណត់ ដែលប្រាថ្នាដើម្បីចូល ក៏រមែងសាបសូន្យចាកសមាបត្តិទាំងនោះ បើមិនចូលទេ ក៏សាបសូន្យចាកសមាបត្តិទាំងនោះ នេះហៅថា បុគ្គលជា **ចេតនាភព្វ**: បុគ្គលគួរដោយចេតនា ។

អធិប្បាយ

ពាក្យថា **ចេតនាភព្វោ** បានដល់ គួរដើម្បីនឹងដល់ភាពមិនសាបសូន្យជុំវិញនៃចេតនា។ពាក្យថា **សចេ អនុសញ្ចេតេតិ** : បានដល់ បើចូលសមាបត្តិ អធិប្បាយថា: ក៏ព្រះយោគីកាលចូលសមាបត្តិ ឈ្មោះថា រមែងយកចិត្តទុកដាក់ទើបលោកមិនសាបសូន្យ ព្រះយោគីក្រៅអំពីនេះ រមែងសាបសូន្យ ។

ចប់ចេតនាភព្វបុគ្គល

## (៨). អនុរក្ខនាភព្វោ

បុគ្គលខ្លះក្នុងលោកនេះបានសមាបត្តិប្រកបដោយរូបក្តីប្រកបដោយអរូបក្តី បុគ្គលនោះឯង មិនបានតាមប្រាថ្នា មិនបានដោយមិនលំបាក មិនបានដោយងាយ ចូលមិនបានផង ចេញមិនបានផង តាមឱកាសដែលប្រាថ្នា តាមសមាបត្តិដែលប្រាថ្នា តាមកាលកំណត់ដែលប្រាថ្នា បើរក្សាគឺសេពឧបការៈធម៌ហើយចូលសមាបត្តិ រមែងមិនសាបសូន្យចាកសមាបត្តិទាំងនោះ បើមិនតាមរក្សាទេ រមែងសាបសូន្យចាកសមាបត្តិទាំងនោះនេះហៅថា **បុគ្គលជាអនុរក្ខនាភព្វៈ** បុគ្គលគួរដោយការតាមរក្សា។

អធិប្បាយ

ពាក្យថា **អនុរក្ខនាភព្វោ** បានដល់ គួរដើម្បីដល់ភាពមិនសាបសូន្យជុំវិញនៃការតាមរក្សា ។

ពាក្យថា **សចេ អនុរក្ខតិ** សេចក្តីថា បើព្រះយោគីលះបង់ធម៌ដែលមិនមានឧបការៈ សេពធម៌ ដែលមានឧបការៈក្នុងការចូលសមាបត្តិ ។ ក៏កាលលោកបដិបត្តិហើយយ៉ាងនេះ ឈ្មោះថា តាមរក្សា ទើបលោកមិនសាបសូន្យ, ព្រះយោគីក្រៅពីនេះ រមែងសាបសូន្យ ។

បណ្តាព្រះយោគីទាំងពីរពួកនេះអនុរក្ខនាភព្វបុគ្គលប៉ុណ្ណោះមានសេចក្តីអង់អាចច្រើនជាងព្រះយោគីដែលឈ្មោះថា **ចេតនាភព្វបុគ្គល** ។ព្រោះថា ចេតនាភព្វបុគ្គល មិនដឹងធម៌ដែលមានឧបការៈដល់សមាបត្តិទេ , កាលមិនដឹងទើបបន្ថយ គឺរមែងនាំធម៌ដែលជាឧបការៈចេញទៅ សេពធម៌ដែលមិនមានឧបការៈ ,កាលសេពធម៌ដែលមិនមានឧបការៈទាំងនោះ លោករមែងសាបសូន្យចាកសមាបត្តិ ។តែ**អនុរក្ខនាភព្វបុគ្គល** រមែងដឹងធម៌ដែលមានឧបការៈ និងធម៌ដែលមិនមានឧបការៈ កាលដឹងរមែងបន្ថយ គឺ

នាំធម៌ដែលមិនមានឧបការៈចេញទៅ សេពធម៌ដែលមានឧបការៈទាំងឡាយ ទើបមិនសាបសូន្យចាកសមាបត្តិ ។

ប្រៀបដូចអ្នកស្រែ ដែលរក្សាស្រែ ២នាក់ ជាឧទាហរណ៍

អ្នកស្រែម្នាក់កើតរោគស្គមលឿង អត់ធន់ត្រជាក់ជាដើមមិនបាន ,មនុស្សម្នាក់ទៀតមិនមានរោគ អត់ធន់ចំពោះវេរាបាន។ មនុស្សដែលមានរោគ មិនចុះអំពីខ្ទមទៅរក្សាស្រែទេ , គេលះបោលការរក្សាស្រែទាំងយប់ទាំងថ្ងៃ, ពួកសេក ព្រាប និងក្ងោកជាដើម នាំគ្នាមកកាន់ស្រែរបស់គេទាំងយប់ទាំងថ្ងៃ ចឹកស៊ីគួរស្រូវសាលី, ក្នុងវេលាយប់ ពួកម្រឹគនិងជ្រូកជាដើម ចូលទៅកាន់លានស្រែទាត់កកាយ ដូចជាកន្លែងដែលខ្លួនធ្វើទុកដោយខ្លួនឯង, គ្រាទាត់កកាយហើយ គេរមែង មិនបានសូម្បីត្រឹមតែស្លូង ស្រូវទៀត ព្រោះហេតុនៃសេចក្តីប្រមាទរបស់ខ្លួន ។

ចំណែកអ្នកស្រែដែលមិនមានរោគ មិនលះបោលការរក្សាស្រែរហូតទាំងយប់ទាំងថ្ងៃ គេរមែងបានស្រូវប្រមាណ ៤ រទេះខ្លះ, ៨រទេះខ្លះអំពីទីប្រមាណមួយករីសៈ ព្រោះសេចក្តីមិនប្រមាទរបស់ខ្លួនគេ។

ព្រះយោគី ២ រូបនេះ បណ្ឌិតគប្បីជ្រាបព្រះយោគីជា ***ចេតនាភព្វបុគ្គល*** ដូចមនុស្សមានរោគរក្សាស្រែ ,***អនុរក្ខនាភព្វបុគ្គល*** ដូចមនុស្សមិនមានរោគ ។

**ចប់អនុរក្ខនាភព្វោ**

## (៩). បុថុជ្ជនបុគ្គល

បុគ្គលណាមិនទាន់លះបង់សញ្ញោជនៈ ៣ មិនប្រតិបត្តិដើម្បីលះបង់ធម៌ទាំងនោះ នេះហៅថា បុគ្គលជាបុថុជ្ជន ។

**អធិប្បាយ**

***សញ្ញោជនៈ៣*** ÷ ទិដ្ឋិសញ្ញោជនៈ១ , សីលព្វតបរាមាសសញ្ញោជនៈ១,វិចិកិច្ឆាសញ្ញោជនៈ១។ក៏សញ្ញោជនៈទាំងនោះ ឈ្មោះថា លោកលះបានហើយក្នុងខណៈនៃផលចិត្ត។ ព្រះអង្គរមែងសម្តែងថា ក៏បុថុជ្ជននេះ រមែងមិនមានសូម្បីក្នុងខណៈនៃផលចិត្ត ។ បទថា **តេសញ្ច ធម្មានំ** : សញ្ញោជនៈធម៌ទាំងនោះ ។ ក៏បុថុជ្ជនឈ្មោះថា អ្នកបដិបត្តិហើយដើម្បីលះសញ្ញោជនៈ ទាំងនោះក្នុងខណៈនៃមគ្គចិត្ត ។តែបុថុជ្ជននេះ រមែងមិនមាន សូម្បីក្នុងខណៈ

នៃមគ្គចិត្ត ពាលបុថុជ្ជនអ្នកល្ងង់ខ្លៅប៉ុណ្ណោះ ដែលលះកម្មដ្ឋានហើយ ។

## ចប់បុថុជ្ជនបុគ្គល

## (១០). គោត្រភូបុគ្គល

ការយាងចុះគឺការកើតប្រាកដនៃអរិយធម៌ (លោកុត្តមគ្គ) ក្នុងលំដាប់ស្មើ នៃពួកធម៌ណា បុគ្គលដែលប្រកបព្រមដោយធម៌ទាំងនោះ នេះហៅថា **គោត្រភូបុគ្គល**។

អធិប្បាយ

**កុសលធម៌ជាង៥០**ដែលកើតព្រមនិងគោត្រភូញាណ មុនមគ្គញ្ញាណដែលកើតឡើង ធម៌នោះ ព្រះមានព្រះភាគត្រាស់ថា គោត្រភូបុគ្គល ព្រោះឈានកន្លងញាណរបស់បុថុជ្ជន គោត្ររបស់បុថុជ្ជន មណ្ឌលរបស់បុថុជ្ជន និងបញ្ញត្តិរបស់បុថុជ្ជនទាំងពួងហើយឈានចុះកាន់ញាណរបស់ព្រះអរិយ គោត្ររបស់ព្រះអរិយ មណ្ឌលរបស់ព្រះអរិយ និងបញ្ញត្តិរបស់ព្រះអរិយៈបានដោយញាណដែលមានព្រះនិព្វានជាអារម្មណ៍ ៕

**កុសលធម៌៥៦**[១] ÷ ១. ផស្ស, ២ .វេទនា, ៣. សញ្ញា, ៤.ចេតនា, ៥. ចិត្ត,៦ . វិតក្ក, ៧. វិចារ, ៨. បីតិ, ៩. សុខ, ១០.ឯកគ្គតា, ១១.សទ្ធិន្ទ្រិយ៍,១២. វីរិយិន្ទ្រិយ៍, ១៣. សតិន្ទ្រិយ៍, ១៤.សមាធិន្ទ្រិយ៍, ១៥. បញ្ញិន្ទ្រិយ៍,១៦. មនិន្ទ្រិយ៍, ១៧. សោមនស្សិន្ទ្រិយ៍, ១៨. ជីវិតិ-ន្ទ្រិយ៍, ១៩. សម្មាទិដ្ឋិមគ្គង្គ, ២០. សម្មាសង្កប្ប, ២១. សម្មាវាយាមៈ ,២២. សម្មាសតិ , ២៣. សម្មាសមាធិ, ២៤. សទ្ធាពលៈ , ២៥.វីរិយពលៈ, ២៦. សតិពលៈ, ២៧. សមាធិពលៈ, ២៨.បញ្ញាព-លៈ, ២៩. ហិរិពលៈ, ៣០. ឱត្តប្បពលៈ, ៣១. អលោភ, ៣២. អ-ទោសៈ , ៣៣ អមោហៈ, ៣៤. អនភិជ្ឈា, ៣៥. អព្យាបាទ , ៣៦. សម្មាទិដ្ឋិក្នុងលោកិយ, ៣៧. ហិរិ, ៣៨. ឱត្តប្ប, ៣៩. កាយ-បស្សទ្ធិ, ៤០. ចិត្តបស្សទ្ធិ,៤១. កាយលហុតា, ៤២. ចិត្តលហុតា, ៤៣. កាយមុទុតា, ៤៤. ចិត្តមុទុតា, ៤៥. កាយកម្មញ្ញតា, ៤៦. ចិត្ត-កម្មញ្ញតា, ៤៧. កាយបាគុញ្ញតា, ៤៨. ចិត្តបាគុញ្ញតា, ៤៩. កាយុ-ជុកតា,៥០. ចិត្តុជុកតា, ៥១. សតិ, ៥២. សម្បជញ្ញៈ,៥៣. សមថ-, ៥៤. វិបស្សនា, ៥៥. បគ្គហៈ,៥៦. អវិក្ខេប ។

---

[១] ធម្មសង្គណី

**និង យេ វាបនកធម៌៩ទៀត** គឺ ១.ឆន្ទ,២ .មនសិការ,៣ .អធិមោក្ខ , ៤. តត្រមជ្ឈត្តតា, ៥. ករុណា ,៦ .មុទិតា និង ៧. សម្មាវាចា. ៨. សម្មាកម្មន្ត . ៩ សម្មាអាជីវៈ សរុប៦៥ដួង(៥៦+៩=៦៥) ។

**សរុបមក** =បើពោលតាម ព្រះពុទ្ធដីកាដោយត្រង់ មហា-កុសលដួងទី១នេះ មានសម្បយុត្តធម៌៥៦ដួង តែទ្រង់នៅប្រទាន ជាន័យ ថានៅមានពួក ***យេ វាបនកធម៌*** ដែលត្រូវបូករួមបញ្ចូល ថែមទៀត តែមិនបានបញ្ជាក់ថា យេ វាបនកធម៌មានប៉ុន្មានដួង ឡើយ ទើបអដ្ឋកថាពោលបញ្ជាក់ថា មាន យេវាបនកធម៌មាន៩ ដួង ទៀត ដូច្នេះ កាលបើបូកសរុបមក មានសម្បយុត្តធម៌ដែល ប្រកប៦៥ដួង ។ ក្នុង៦៥ដួងនេះទៀតសោត បើពោលដោយ ***អគ្គហិតគហនន័យ*** តាមព្រះពុទ្ធដីកាដោយត្រង់មាន**៣០** + ***យេវាបនកធម៌ ៩ = ៣៩ ( ៣០+៩=៣៩ )*** ។ ក្នុង ៣៩ ដួង មានចិត្តមួយដួងចូលរួមផងដែរ កាលបើដកចិត្តមួយដួងចេញ ហើយ មានត្រឹម ៣៨ ដួងប៉ុណ្ណោះ ដូច្នេះទើប អភិធម្មត្ថស-ង្គហៈពោលថា ចិត្តនេះមានចេតសិក៣៨ដួង សមដូច ***ព្រះពុទ្ធដីកា*** និង ***ព្រះអដ្ឋកថា***បានពោលថា៖***យេ វា បន តស្មឹ សមយេ អញ្ញេបិ អត្ថិ បដិច្ចសមុប្បន្នា អរូបិនោ ធម្មា ឥមេ ធម្មា កុសលា។***

*(ពាក្យថា* **យេវាបនក** : *មានរូបវិគ្គហៈ ថា យេ* **វា បនកាតិ កាយន្តិ កថិយន្តិ យេវាបនកា** ។ *ពួកធម៌ណាដែលព្រះសម្មាសម្ពុទ្ធ ទ្រង់សម្តែងថា ពួកធម៌ណានីមួយកាលកើតឡើង រមែងមានធម៌ដ៏ទៃទៀតកើតរួមគ្នា ធម៌នោះ ឈ្មោះថា យេវាបនកធម៌)* ៕

ចប់គោត្រភូបុគ្គល

## (១១-១២). ភយូបរតបុគ្គល និងអភយូបរតបុគ្គល

*សេក្ខៈបុគ្គល៧ពួក និងបុគ្គលជាបុថុជ្ជន ដែលមានសីល ឈ្មោះថា* ***ភយូបរតបុគ្គល*** *។ព្រះអរហន្ត ឈ្មោះថា* ***អភយូបរតបុគ្គល*** *។*

*អធិប្បាយ*

**ភយូបរតបុគ្គល =** *បុគ្គលឯណាលះបង់ចោល សេចក្តីអាក្រក់ ព្រោះការភ័យខ្លាច ព្រោះហេតុនោះ បុគ្គលនោះ ទើបឈ្មោះថា ភយូបរតោៈ អ្នកលះចោល សេចក្តីអាក្រក់ ព្រោះការភ័យខ្លាច ។*

**អធិប្បាយថា** *ក៏ព្រះសេក្ខបុគ្គល ៧ ពួក និងបុថុជ្ជនទាំងឡាយ អ្នកមានសីល ខ្លាចហើយរមែងវៀរចាកបាប គឺមិនធ្វើបាបឡើយ ។*

**ព្រះអរិយបុគ្គល ៧ ពួក និងបុថុជ្ជនទាំងឡាយ រមែងភ័យខ្លាច ក្នុងភ័យ៤យ៉ាង**

***១.ទុគ្គតិភ័យ*** = *ភ័យព្រោះខ្លាចបន្ទាប់ពីស្លាប់ទៅកើតក្នុងអបាយភូមិ។*

***២.វដ្តភ័យ*** = *ភ័យព្រោះនៅមានជាតិនាំទៅកាន់ភព។*

***៣.កិលេសភ័យ*** = *ភ័យព្រោះនៅមានកិលេសមិនទាន់បានលះ ។*

***៤.ឧបវាទភ័យ*** = *ភ័យព្រោះកើតអំពីការតិះដៀលរបស់អ្នកដទៃ។*

*បណ្តាភ័យទាំង៤នេះ **បុថុជ្ជន**រមែងខ្លាចភ័យទាំងបួន ព្រោះហេតុដូច្នោះទើបមិនធ្វើបាប ។សម្រាប់**ព្រះសេក្ខៈបុគ្គល៣ពួក**គឺ ព្រះសោតាបន្ន ព្រះសកទាគាមី និងព្រះអនាគាមី លោកទាំងនេះ កន្លងផុតហើយចាកអំពីទុគ្គតិភ័យបានហើយ ភ័យ៣ផ្សេងទៀត លោកមិនទាន់លះបាន ព្រោះហេតុដូច្នោះ ទើបលោកមិនធ្វើបាប ។ ព្រះសេក្ខៈអ្នកទាំងនៅក្នុងមគ្គ ឈ្មោះថា អ្នកវៀរចាកភ័យ ដោយអំណាចនៃការសម្រេច ឬព្រោះភាពជាអ្នកកាត់ភ័យមិនទាន់ដាច់ស្រេចនៅឡើយ ទើបឈ្មោះថា **ភយូបរតបុគ្គល** ។*

**អភយូបរតបុគ្គល** = *ព្រះខីណាស្រព ឈ្មោះថា អភយូបរតបុគ្គល លោកមិនខ្លាចសូម្បីត្រឹមតែម្យ៉ាង ក្នុងបណ្តាភ័យទាំង៤ នោះ ។ពិតមែនហើយ ព្រះខីណាស្រពលោកកាត់ភ័យបានដាច់ស្រឡះហើយ ព្រោះហេតុដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា*

**អភយូបរតោ** អ្នកលះបង់ចោលសេចក្តីអាក្រក់ដោយមិនភ័យខ្លាច។ **សួរថា:** លោកមិនខ្លាចសូម្បីឧបវាទភ័យ ឬ? **ឆ្លើយថា:** លោកមិនខ្លាចទេ តែគួរពោលថាលោករក្សាឧបវាទភ័យ។បណ្ឌិតគប្បីជ្រាបដូចព្រះថេរៈ ជាខីណាស្រពក្នុងស្រុកទោណុប្បលវាបីជាតួយ៉ាង ។

## ចប់ភយូបរតបុគ្គល និងអភយូបរតបុគ្គល

## (១៣). អភព្វាគមនបុគ្គល

បុគ្គលណាប្រកបដោយគ្រឿងរាំងគឺ**កម្ម** ប្រកបដោយគ្រឿងរាំងគឺ**កិលេស** ប្រកបដោយគ្រឿងរាំងគឺ**វិបាក** ជាអ្នកមិនមាន**សទ្ធា** មិនមាន**ឆន្ទៈ** មាន**បញ្ញា**អាប់អន់ ល្ងង់ខ្លៅ មិនគួរឈានកាន់ចុះសម្មត្តនិយាម ក្នុងកុសលធម៌ទាំងឡាយ នេះឈ្មោះថា បុគ្គលជា **អភព្វាគមនៈ** ។

ចប់អភព្វាគមនបុគ្គល

## (១៤). ភព្វាគមនបុគ្គល

បុគ្គលណាមិនប្រកបដោយគ្រឿងរារាំងគឺ**កម្ម** មិនប្រកបដោយគ្រឿងរារាំងគឺ**កិលេស** មិនប្រកបដោយគ្រឿងរារាំងគឺ **វិបាក** ជាអ្នកមាន**សទ្ធា** មាន**ឆន្ទៈ** មាន**បញ្ញា** មិនល្ងង់ខ្លៅ គួរឈានចុះកាន់សម្មត្តនិយាមក្នុងធម៌ជាកុសលទាំងឡាយ នេះឈ្មោះថា បុគ្គលជា ភព្វាគមនៈ ។

អធិប្បាយ

## អភព្វាគមនបុគ្គល

បុគ្គលណា មិនគួរដើម្បីនឹងសម្រេចនូវសម្មត្តនិយាម ព្រោះហេតុនោះ អ្នកនោះឈ្មោះថា **អភព្វាគមនបុគ្គល** ។

ពាក្យថា **កម្មាវរណេន** = ដោយកម្មដែលជាគ្រឿងរារាំង បានដល់ អនន្តរិយកម្ម៥។

ពាក្យថា **កិលេសាវរណេន** = ដោយកិលេសជាគ្រឿងរារាំង បានដល់ និយតមិច្ឆាទិដ្ឋិ ។

ពាក្យថា **វិបាកាវរណេន** = ដោយវិបាកជាគ្រឿងរារាំង បានដល់បដិសន្ធិដោយអហេតុកៈ និងទ្វិហេតុកៈចិត្ត។

ពាក្យថា **អស្សទ្ធា** = អ្នកមិនមានសទ្ធា បានដល់ ជាអ្នកវៀរចាកការជឿក្នុងព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ។

ពាក្យថា **អច្ឆន្ទិកា** = អ្នកមិនមានឆន្ទៈ បានដល់ វៀរចាកសេចក្តីពេញចិត្តក្នុងកត្តុកម្យតាកុសល ។ វៀរចាកជម្ពូទ្វីបចេញទ្វីបពាដ៏សេស មិនមានឆន្ទៈក្នុងការបំពេញកុសលទេ ។

ពាក្យថា **ទុប្បញ្ញា** = មានបញ្ញាទន់ខ្សោយ បានដល់ វៀរចាក ភវង្គបញ្ញា (បដិសន្ធិប្រាសចាកបញ្ញា)។

ពាក្យថា **អភព្វា** = អ្នកមិនគួរ បានដល់ មិនមានឧបនិស្ស័យនៃមគ្គ ផល ។

ពាក្យថា **និយាមំ** = និយាម បានដល់ មគ្គនិយាម១ សម្មត្តនិយាម១ , ពាក្យថា ឱក្កមិតុំ =ដើម្បីឈានចុះ សេចក្តីថា មិនគួរដើម្បីនឹងឈានកន្លង គឺចុះកាន់និយាម ពោលគឺ សម្មត្តៈ ក្នុងធម៌ទាំងឡាយដែលជាកុសល ដើម្បីនឹងតាំងមាំក្នុងមគ្គផលនោះបាន។

## ភព្វាគមនបុគ្គល

បណ្ឌិតគប្បីជ្រាប ភព្វាគមនបុគ្គល ដោយបដិបក្ខន័យអំពីអភព្វាគមនបុគ្គលដែលពោលហើយ ។

***ព្រះមានព្រះភាគត្រាស់ទុកយ៉ាងនេះថា*** ៖*បុគ្គលណាធ្វើបញ្ចានន្តរិយកម្ម១, ជាអ្នកនិយតមិច្ឆាទិដ្ឋិ១, បដិសន្ធិដោយអហេតុកៈនិងទ្វិហេតុកៈចិត្ត, មិនជឿគុណព្រះរតនត្រ័យ១, មិនមានសេចក្តីពេញចិត្តក្នុងការបំពេញកុសល១, មានភវង្គបញ្ញាមិនបរិបូរណ៍១, មិនមានឧបនិស្ស័យនៃមគ្គនិងផល១ បុគ្គលទាំងអស់នេះមិនគួរដើម្បីឈានចុះកាន់សម្មត្តនិយាមធម៌គឺមិនអាចត្រាស់ដឹង មគ្គផលនិព្វានបានឡើយ។*

ចប់ភព្វាគមន និង អភព្វាគមនបុគ្គល

## (១៥-១៦). និយតបុគ្គល និងអនិយតបុគ្គល

បុគ្គលប្រកបដោយអនន្តរិយកម្ម ៥ ពួក បុគ្គលប្រកបដោយនិយតមិច្ឆាទិដ្ឋិ និងអរិយបុគ្គល ៨ ពួក ឈ្មោះថា **និយតបុគ្គល** ។ បុគ្គលក្រៅពីនេះ ឈ្មោះថា **អនិយតបុគ្គល** ។

អធិប្បាយ

### មិច្ឆត្តនិយតបុគ្គល

បុគ្គលដែលប្រព្រឹត្តអនន្តរិកម្ម និងនិយតមិច្ឆាទិដ្ឋិ[២] ឈ្មោះថា និយត(ទៀង)ព្រោះជាអ្នកទៀងដើម្បីប្រយោជន៍ដល់នរកបន្ទាប់ពីស្លាប់ ។

### សម្មត្តនិយតបុគ្គល

ព្រះអរិយបុគ្គល៨ជំពូក ឈ្មោះថា ទៀងព្រោះទៀងដើម្បីប្រយោជន៍ដល់មគ្គនិងផលខាងលើដោយភាពជាអ្នកចម្រើនដោយបញ្ញាដ៏ប្រពៃនិងដើម្បីប្រយោជន៍ដល់ អនុបាទាបរិនិព្វាន។

ចំណែកបុគ្គលដ៏សេស មានគតិមិនទៀង ប្រៀបដូចកំណាត់ឈើដែលបុគ្គលបោះទៅលើអាកាស មិនដឹងថា ចុង កណ្តាល

---

2 ដែលប្រព្រឹត្តទៅក្នុងជវនដួងទី៧

ឬគល់ ធ្លាក់ចុះមកមុន យ៉ាងណាបុគ្គលទាំងនោះក៏ដូចគ្នាដែរ ។ បណ្ឌិតគប្បីជ្រាបថា ឈ្មោះថា អ្នកមិនទៀង ព្រោះការកំណត់ពិតប្រាកដមិនបានថា អ្នកនេះនឹងកើតក្នុងគតិឈ្មោះឯណោះដូច្នេះទេ។ ក៏តាមន័យដែលអ្នក**ឧត្តរកុរុទ្វីប** មានគតិទៀង តាមដែលព្រះអង្គត្រាស់ទុកនោះ មិនមែនត្រាស់ដោយអំណាចនៃនិយតធម៌នេះទេ,តាមពិត មិច្ឆត្តនិយតធម៌ និងសម្មត្តនិយតធម៌ប៉ុណ្ណោះ ឈ្មោះថា**និយត**(ទៀង) ។ក៏បុគ្គលនេះ ព្រះមានព្រះភាគត្រាស់ហៅថា "**បុគ្គលនិយមោ** "ដោយអំណាចនៃមិច្ឆត្តធម៌ និងសម្មត្តធម៌ ទាំងនោះមានប្រការដូច្នេះ ។

ចប់និយតបុគ្គល និងអនិយតបុគ្គល

# (១៧-១៨). បដិបន្នកា និងផលដ្ឋិតបុគ្គល

បុគ្គល៤ពួកដែលព្រមព្រៀងដោយមគ្គ ឈ្មោះថា **បដិបន្នកបុគ្គល** ។ បុគ្គល៤ពួក ដែលព្រមព្រៀមដោយផល ឈ្មោះថា ផលេដ្ឋិត បុគ្គល ។

អធិប្បាយ

ពាក្យថា **មគ្គសមង្គិនោ** = អ្នកព្រមព្រៀងដោយមគ្គ បាន ដល់ បុគ្គលអ្នកតាំងនៅក្នុងខណៈមគ្គចិត្ត (មគ្គចិត្ត៤) ។ បុគ្គល ដែលតាំងនៅក្នុងមគ្គចិត្តនោះ ឈ្មោះថា បដិបន្នកបុគ្គល ។

ពាក្យថា **ផលសមង្គិនោ** = អ្នកព្រមព្រៀងដោយផល បាន ដល់ អ្នកបានផល( ផលចិត្ត៤ )។ រាប់តាំងអំពីការបានផលឡើងទៅ លោកទាំងនោះ សូម្បីនៅមិនចូលផលសមាបត្តិ ក៏ឈ្មោះថា តាំង នៅក្នុងផលនោះ មែនពិត ។

**ចប់បដិបន្នកបុគ្គល**

## (១៩). សមសីសីបុគ្គល

បុគ្គលណាមានការអស់ទៅនៃអាសវៈ និងការអស់ទៅនៃជីវិត មិនមុនមិនក្រោយ (គឺព្រមគ្នា) នេះឈ្មោះថា **បុគ្គលជាសមសីសី ។**

អធិប្បាយ

### សមសីសីបុគ្គល៣ពួក

១ .***ឥរិយាបថសមសីសី=*** បុគ្គលឯណាកំពុងចង្រ្កម ផ្ដើមតាំងវិបស្សនា ក៏សម្រេចព្រះអរហត្តទាំងនៅចង្រ្កមនោះឯង ហើយបរិនិព្វាន ដូចព្រះបទុមត្ថេរ ចម្រើនវិបស្សនានៅពេលកំពុងឈរ បានសម្រេចព្រះអរហន្តហើយបរិនិព្វាន ដូចព្រះតិស្សត្ថេរនៅវិហារកោដបពិតសម្រេចព្រះអរហត្តហើយបរិព្វាននៅពេលអង្គុយក្ដីកំពុងដេកក្ដី ក៏មានន័យដូចគ្នា ។ នេះឈ្មោះថា ឥរិយាបថសមសីសីបុគ្គល។

២. **រោគសមសីសីបុគ្គល=** បុគ្គលឯណាកើតរោគអ្វីមួយ ចម្រើនវិបស្សនាខាងក្នុងរោគនោះឯងសម្រេចព្រះអរហត្តហើយបរិនិព្វានដោយរោគនោះឯង បុគ្គលនេះ ឈ្មោះថា រោគសមសីសី ។

៣.***ជីវិតសមសីសី*** = *សីសៈនេះមាន ១៣ គឺ* ***តណ្ហា*** *ឈ្មោះថា បលិពោធសីសៈ,**មានៈ** ឈ្មោះថា ពន្ធនសីសៈ, **ទិដ្ឋិ** ឈ្មោះថាបរាមាសសីសៈ,**ឧទ្ធច្ច** ឈ្មោះថា វិក្ខេបសីសៈ,**អវិជ្ជា** ឈ្មោះថា កិលេសសីសៈ,**សទ្ធា** ឈ្មោះថា អធិមោក្ខសីសៈ, **វិរិយ** ឈ្មោះថា បគ្គហសីសៈ, **សតិ** ឈ្មោះថា ឧបដ្ឋានសីសៈ, **សមាធិ** ឈ្មោះថា អវិក្ខេបសីសៈ ,**បញ្ញា** ឈ្មោះថា ទស្សនសីសៈ,**ជីវិតិន្ទ្រិយ** ឈ្មោះថា បវត្តសីសៈ, **វិមោក្ខ** ឈ្មោះថា គោចរសីសៈ, **និរោធ** ឈ្មោះថា សង្ខារសីសៈ ។*

***កិលេសសីសៈ*** *ក្នុងខណៈពេលអរហត្តមគ្គកើតឡើង លះបង់អវិជ្ជា ឈ្មោះថា កិលេសសីសៈ ។**បវត្តសីសៈ** ចុតិចិត្តកើតឡើងរមែងគ្របសង្កត់ជីវិតិន្ទ្រិយ ឈ្មោះថា បវត្តសីសៈ តែក៏មិនអាចគ្របសង្កត់កិលេសបានដែរ ចិត្តដែលគ្របសង្កត់អវិជ្ជាដទៃង ចិត្តដែលគ្របសង្កត់ជីវិតិន្ទ្រិយដទៃង ។ប្រសិនសីសៈទាំង២នេះរបស់បុគ្គលនេះឯណាដាច់ព្រមគ្នា បុគ្គលនោះឈ្មោះថា* **ជីវិតសមសីសី** ។

***សួរថា:*** *សីសៈពីរនេះមានព្រមគ្នាយ៉ាងណា ?*

***ឆ្លើយថា៖*** *ព្រោះមានព្រមគ្នា ដោយវារៈ ។ អធិប្បាយថា ការចេញចាកមគ្គ រមែងមានដោយវារៈណា វារៈនោះ ឈ្មោះថា មានព្រមគ្នា គឺថា បុគ្គលណាតាំងនៅក្នុងបច្ចវេក្ខណៈញាណ១៩គឺ បច្ចវេក្ខណៈក្នុងសោតាបន្ន៥, ក្នុងសកទាគាមិមគ្គ៥, ក្នុងអនាគាមិមគ្គ៥,ក្នុងអរហត្តមគ្គ៤ ហើយធ្លាក់ចុះកាន់ភវង្គ ទើបបរិនិព្វាន សេចក្តីអស់ទៅ នៃសីសៈទាំងពីរ យ៉ាងនេះ ទើបឈ្មោះថា ព្រមគ្នាព្រោះសេចក្តីព្រមគ្នាដោយវារៈទាំងនោះ ព្រោះហេតុដូច្នោះ បុគ្គលនោះទើបព្រះមានព្រះភាគត្រាស់ថា* ***ជីវិតសមសីសី ។*** *ក៏បុគ្គលនេះប៉ុណ្ណោះព្រះមានព្រះភាគប្រាថ្នាយកក្នុង* ***សមសីសីនិទ្ទេសនេះ ។***

ចប់សមសីសីបុគ្គល

## (២០). ឋិតកប្បីបុគ្គល

*បុគ្គលនេះ ជាអ្នកប្រតិបត្តិ ដើម្បីធ្វើឱ្យជាក់ច្បាស់នូវ សោតាបត្តិផល ទុកជាវេលាភ្លើងឆេះកប្បនឹងមាន បើបុគ្គលនេះមិនទាន់ធ្វើឱ្យជាក់ច្បាស់ នូវសោតាបត្តិផល ដរាបណា ភ្លើងក៏មិនឆេះកប្បដរាបនោះ នេះហៅថា* ***បុគ្គលជាឋិតកប្បី*** *។ បុគ្គលដែលព្រមព្រៀងដោយមគ្គទាំងអស់ ក៏ឈ្មោះថា* ***ឋិតកប្បីដែរ*** *។*

# អធិប្បាយ

កប្បតាំងនៅព្រោះបុគ្គលនោះមាន ព្រោះហេតុនោះ បុគ្គលនោះទើប ឈ្មោះថា **ឋិតកប្បី** : អ្នកមានកប្បដែលតាំងនៅ។ អធិប្បាយថា ជាអ្នកអាចដើម្បីនឹងឱ្យកប្បតាំងនៅបាន ។

ពាក្យថា **នេវ តាវ** : បុគ្គលអ្នកដល់ព្រមដោយមគ្គ (មគ្គសមង្គី-បុគ្គល) មិនបានធ្វើឱ្យជាក់ច្បាស់នូវសោតាបត្តិផលត្រឹមណា កប្បក៏មិនត្រូវបានភ្លើងឆេះត្រឹមនោះ, សូម្បីកប្បកំពុងឆេះ លោកអ្នកដល់ព្រមដោយមគ្គនោះ មិនឆេះឡើយ គប្បីតាំងនៅបាន ។

កប្បកាលវិនាសត្រូវវិនាសរហូត ១សែនកោដិចក្រវាឡ តែកាលព្រះពុទ្ធសាសនាតាំងនៅ ឈ្មោះថា កប្បវិនាស រមែងមិនមាន ទាំងសាសនាក៏មិនមាន ក្នុងវេលាដែលកប្បវិនាស ។ សូម្បីកាលបើយ៉ាងនោះ ព្រះសាស្តាទ្រង់នាំហេតុនេះមក ដើម្បីនឹងសម្តែងសេចក្តីមិនមានអន្តរាយ សូម្បីយ៉ាងនេះកប្បគប្បីតាំងនៅបាន តែអន្តរាយនៃផលចិត្តរបស់មគ្គបុគ្គល ដែលអ្វីៗ ក៏មិនអាចនឹងធ្វើបានឡើយ។

***សួរថា:*** បុគ្គលនេះ សូម្បីឱ្យកប្បតាំងនៅបាន គប្បីតាំងនៅរហូតអស់កាលមានប្រមាណប៉ុនណា ?

***ឆ្លើយថា:*** ការចេញចាកមគ្គ រមែងមានក្នុងវេលាវារៈណា លោកក៏គប្បីតាំងនៅរហូតអស់កាលមានប្រមាណប៉ុណ្ណោះ ។

***វិធីនៃការតាំងនៅមានអធិប្បាយដូច្នេះ៖***កាល***ភវង្គចិត្ត***រលត់ហើយ ***មនោទ្វារាវជ្ជនចិត្ត***ក៏កើតឡើង តអំពីនោះ***អនុលោមញ្ញាណ*** (បរិកម្ម,ឧបចារៈ អនុលោម) ក៏កើតរលត់ ៣ខណៈ ***គោត្រភូចិត្ត***កើតឡើង ១ខណៈ ***មគ្គ១ខណៈ*** ***ផលចិត្ត***កើតឡើង ២ខណៈ ***ចិត្តក៏ធ្លាក់ចុះកាន់ភវង្គ*** , បន្ទាប់មក***បច្ចវេក្ខណញ្ញាណកើត៥ដង*** បុគ្គលនេះ គប្បីតាំងនៅរហូតអស់កាលមានប្រមាណប៉ុណ្ណោះ ។

*ម្យ៉ាងទៀត លោកអាចារ្យលើកឧបមាយ៉ាងនេះថា កាលគេចងសិលា១យោជន៍និងខ្សែ៣ចង្វាយព្យួរទុកលើក្បាលរបស់អ្នកដល់ព្រមដោយសោតាបត្តិមគ្គ សូម្បីខ្សែនោះ ដាច់អស់ ១ចង្វាយក្តី ២ចង្វាយក្តី ៣ចង្វាយក្តី ក៏មិនអាចធ្លាក់មកលើក្បាលអ្នកដល់ព្រមដោយមគ្គបានដែរគឺថា ដរាបណាសោតាបត្តិផលមិនទាន់កើត ដុំសិលានោះក៏តាំងនៅលើអាកាសដែលដូចជាការបោក*

*បញ្ចោតដុំពពកដូច្នោះដែរ ដុំសិលានោះមិនបានធ្វើអន្តរាយដល់បុគ្គលមគ្គានន្តរៈបានទេ។ ក៏បុគ្គលអ្នកតាំងនៅក្នុងសោតាបត្តិមគ្គប៉ុណ្ណោះ នឹងឈ្មោះថា តាំងនៅរហូតមួយកប្បក៏ទេ , សូម្បីអ្នកដល់ព្រមដោយមគ្គក្រៅអំពីនេះ ក៏តាំងនៅរហូតមួយកប្បដូចគ្នា ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទ្រង់ទាញយកបុគ្គលដែលព្រះអង្គទ្រង់កាន់យក និងទ្រង់មិនកាន់យកពេលក្រោយ ហើយលើកឡើងកាន់បែបផែននេះ ព្រមនិងបិដ្ឋិវដ្តកបុគ្គលទាំងឡាយ សូម្បីបុគ្គលអ្នកដល់ព្រមដោយមគ្គទាំងអស់ ក៏ឈ្មោះថា ឋិតកប្បី ដែរ ។*

ចប់ឋិតកប្បីបុគ្គល

## (២១-២២). អរិយបុគ្គល និង មិនមែនអរិយបុគ្គល

*អរិយបុគ្គលទាំង ៨ពួកឈ្មោះថាអរិយៈ ។ បុគ្គលក្រៅពីនេះឈ្មោះថា* ***អនរិយ*** *។*

*អធិប្បាយ*

ពាក្យថា **អរិយ** : ព្រោះជាអ្នកឆ្ងាយចាកកិលេសទាំងឡាយ, ជាអ្នកប្រសើរជាងលោក ព្រមទាំងទេវលោក និងជាអ្នកបរិសុទ្ធ ។ បុគ្គលក្រៅពីនេះមិនឈ្មោះថា អរិយទេ ព្រោះមិនបរិសុទ្ធ ។

ចប់អរិយ និងអនរិយបុគ្គល

## (២៣-២៤-២៥).សេក្ខបុគ្គល, អសេក្ខបុគ្គល និង នេវសេក្ខា ជាសេក្ខបុគ្គល

បុគ្គល៤ពួក ព្រមព្រៀងដោយមគ្គ បុគ្គល៣ពួកព្រមព្រៀងដោយផល ឈ្មោះថា **សេក្ខៈ** ។ព្រះអរហន្ត ឈ្មោះថា **អសេក្ខៈ** ។ បុគ្គលក្រៅពីនេះ ឈ្មោះថា មិនមែនសេក្ខៈ ទាំងមិនមែនអសេក្ខៈ ។

អធិប្បាយ

បុគ្គលឯណាដល់ព្រមដោយអរិយមគ្គក្នុងខណៈនៃមគ្គចិត្តផង ដល់ព្រមដោយអរិយផល ក្នុងខណៈនៃផលចិត្តផង ជនទាំងនេះ នៅសិក្សា នូវសិក្ខាទាំង៣ មានអធិសីលសិក្ខាជាដើម, ព្រោះហេតុនោះ ជនទាំងនោះ ទើបឈ្មោះថា **សេក្ខា** : **អ្នកនៅសិក្សាក្នុងសិក្ខាទាំង៣** បានដល់ព្រះអរិយបុគ្គល ៧ ពួកខាងក្រោម ព្រោះលោកកំពុងនៅដោយអាការយ៉ាងនេះ។ចំណែកព្រះអរហន្ត លោក

សិក្សានូវសិក្ខាទាំង ៣ក្នុងខណៈនៃអរហត្តផល កិច្ច គឺការសិក្សា រមែងមិនមានដល់លោកទៀតទេ, ព្រោះហេតុដូច្នោះ ព្រះអរហន្ត ទើបឈ្មោះថា **អសេក្ខា** : **អ្នកចប់ការសិក្សា** ។ ព្រះខីណាស្រព ទាំងឡាយ ឈ្មោះថា **សិក្ខិតាសេក្ខា** : អសេក្ខបុគ្គលដែលសិក្សា ស្រេចហើយ អំពីបុគ្គលដទៃ ព្រោះភាវៈនៃសីលជាដើមលោក បានសិក្សាហើយក្នុងសំណាក់នៃបុគ្គលដទៃ ។ ព្រះសម្មាសម្ពុទ្ធ និងព្រះបច្ចេកពុទ្ធជាម្ចាស់ទាំងឡាយ ឈ្មោះ**ថា អសេក្ខិតាសេក្ខា** : អសេក្ខបុគ្គលដែលមិនសិក្សាអំពីសំណាក់បុគ្គលដទៃ ព្រោះភាវៈ នៃព្រះអង្គជាសយម្ភូ គឺជាអ្នកត្រាស់ដឹងដោយខ្លួនឯង ។ បុគ្គល ទាំងឡាយដ៏សេស ឈ្មោះថា សេក្ខៈ ក៏មិនមែន អសេក្ខ ក៏មិន មែន ព្រោះហេតុនោះ ទើបឈ្មោះថា **នេវ សេក្ខា នាសេក្ខា** ៕

ចប់សេក្ខបុគ្គលនិងអសេក្ខបុគ្គល

## (២៦). តេវិជ្ជបុគ្គល

បុគ្គលប្រកបដោយវិជ្ជា ៣យ៉ាង ឈ្មោះថា **បុគ្គលបានវិជ្ជា ៣** ។

## (២៧). ឆឡភិញ្ញាបុគ្គល

បុគ្គលប្រកបដោយអភិញ្ញា ៦ ឈ្មោះថា បាន**អភិញ្ញា ៦** ។

## អធិប្បាយ

បុគ្គលអ្នកញុំាងបុព្វេនិវាស និងទិព្វចក្ខុញ្ញាណ ឱ្យកើតឡើង ហើយសម្រេចព្រះអរហន្តខាងក្រោយក្តី អ្នកសម្រេចព្រះអរហត្ត មុន ហើយញុំាងបុព្វេនិវាស និងទិព្វចក្ខុញ្ញាណឱ្យកើតឡើងក្តី ឈ្មោះថា អ្នកមានវិជ្ជា ៣ ទាំងអស់ ។ ការកំណត់ក្នុងការសម្រេច ជាធុរៈក្នុងទីនេះថា “ពាក្យដែលពោលទុកក្នុងព្រះសូត្រ ជាការសម្តែងដោយអម ពាក្យដែលពោលទុកក្នុងព្រះអភិធម្ម ជាការសម្តែងដោយត្រង់”ព្រោះហេតុនោះ បុគ្គលអ្នកញុំាងវិជ្ជា ២ ឱ្យកើតឡើងមុន ហើយសម្រេចព្រះអរហត្តខាងក្រោយនោះឯង ព្រះអង្គទ្រង់បំណងយកក្នុង តេវិជ្ជនិទ្ទេសនេះ ។ សូម្បីបុគ្គលអ្នកមានអភិញ្ញា ៦ ក៏មានន័យដូចគ្នានេះ ៕

ចប់តេវិជ្ជបុគ្គលនិង ឆឡភិញ្ញបុគ្គល

## (២៨). សម្មាសម្ពុទ្ធបុគ្គល

បុគ្គលណា ត្រាស់ដឹងដោយខ្លួនឯង នូវសច្ចក្នុងធម៌ទាំងឡាយ ដែលខ្លួនមិនធ្លាប់បានឮ ក្នុងកាលមុន ក៏ដល់នូវសព្វញ្ញុតញ្ញាណ ក្នុងធម៌ទាំងនោះផង ដល់នូវភាពស្ទាត់ក្នុងទសពលញ្ញាណផង នេះគប្បីជ្រាបថា បុគ្គលនោះជា **ព្រះសម្មាសម្ពុទ្ធ**។

## អធិប្បាយ

ពាក្យថា **បុព្វេ អននុស្សុតេសុ** បានដល់ ធម៌ដែលមិនធ្លាប់បានស្តាប់អំពីមុន ក្នុងសំណាក់នៃបុគ្គលដទៃ មុនពេលត្រាស់ដឹងសច្ចធម៌ក្នុងបច្ឆិមភព ។ ក៏ក្នុងភពមុនៗអំពីភពនេះ ព្រះពោធិសត្តទ្រង់ផ្នួសក្នុងព្រះពុទ្ធសាសនារៀន ព្រះត្រៃបិដកទាំង ៣ ហើយលើកឡើងកាន់គតបច្ចាគតវត្ត គឺវត្តដែលនាំកម្មដ្ឋានទៅនិងនាំត្រឡប់មកផ្តើមតាំងកម្មដ្ឋានរហូតដល់អនុលោម និងគោត្រភូញាណ ។ ព្រោះហេតុនោះ ពាក្យថា “**សម្មាសម្ពុទ្ធោ**” នេះលោកពោលសំដៅយកភាពជាអ្នកមិនមាននរណាមួយ ជាអាចារ្យក្នុងបច្ឆិមភព គឺជាតិចុងក្រោយបំផុតប៉ុណ្ណោះ ។

ពិតហើយព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ដឹងអរិយសច្ចទាំង៤ ដោយមិនមានការស្តាប់អំពីបុគ្គលដទៃឡើយ ព្រោះភាពនៃព្រះអង្គជាអ្នកមានបារមីពេញបរិបូណ៌ហើយ ។

ពាក្យថា **តត្ថ ច សព្វញ្ញុតំ បាបុណាតិ ពលេសុ ច វសីភាវំ** បានដល់ រមែងដល់ភាពជាអ្នកជំនាញក្នុងការប្រព្រឹត្តសព្វញ្ញុតញ្ញាណ និងទសពលញ្ញាណទាំងឡាយ ។ក៏កិច្ចដទៃ ឈ្មោះថា គួរធ្វើ រមែងមិនមានដល់ព្រះពុទ្ធ

ទាំងឡាយ ចាប់ពីការសម្រេចព្រះសព្វញ្ញុតញ្ញាណ និងទសពល-ញ្ញាណទាំងឡាយ ។ ដូចយ៉ាងឥស្សរិយយសទាំងអស់ នរណាមួយមិនគួរពោលថា ឈ្មោះថា ឥស្សរិយយសនេះ មិនមកដល់ខត្តិយកុមារជាឧភតោសុជាត ចាប់ផ្តើមអំពីការបានអភិសេក, ឥស្សរិយយសនេះ រមែងជាធម្មជាតិមកហើយទាំងអស់ យ៉ាងណា ឈ្មោះថា គុណនេះដែលនរណាមួយ ក៏មិនគួរពោលថា មិនមកដល់ហើយ ដល់ព្រះពុទ្ធទាំងឡាយ , ព្រះពុទ្ធទាំងឡាយមិនចាក់ធ្លុះហើយ, និងមិនប្រចក្សដល់ព្រះពុទ្ធទាំងឡាយ , ចាប់ផ្តើមអំពីការសម្រេចអរហត្តមគ្គ សូម្បីគុណ គឺព្រះសព្វញ្ញុតញ្ញាណជាដើម ឈ្មោះថា មកហើយ ព្រះពុទ្ធបានចាក់ធ្លុះហើយ ធ្វើឱ្យប្រចក្សហើយដូច្នោះដែរ។ (មានន័យសរុបថា ព្រះគុណទាំងឡាយរបស់ព្រះពុទ្ធជាម្ចាស់ សម្រេចឡើងនៅពេលអរហត្តមគ្គកើតឡើងព្រមគ្នាតែម្តង មិនមានការព្យាយាមចម្រើនពេលក្រោយទៀតទេ)

ពាក្យថា **អយំ វុច្ចតិ** = បុគ្គលនេះ ហៅថា បុគ្គលអ្នកមានសព្វញ្ញុតញ្ញាណគុណដែលចាក់ធ្លុះហើយ ដោយអរិយមគ្គ ដោយអានុភាពនៃសេចក្តីសម្រេចហើយ ដោយបារមីដែលបរិបូណ៌ មានប្រការដូច្នេះ ទើបឈ្មោះថា ***សម្មាសម្ពុទ្ធ*** ៕

ចប់សម្មាសម្ពុទ្ធបុគ្គល

## (២៩). បច្ចេកពុទ្ធបុគ្គល

*បុគ្គលណាត្រាស់ដឹងដោយខ្លួនឯងនូវសច្ចក្នុងធម៌ទាំងឡាយដែលខ្លួនមិនធ្លាប់បានឮក្នុងកាលមុន តែមិនដល់នូវសព្វញ្ញុតញ្ញាណ ក្នុងធម៌ទាំងនោះផង មិនដល់នូវ ភាពស្ទាត់ ក្នុងទសពលញ្ញាណផង បណ្ឌិតគប្បីជ្រាបថា បុគ្គលនោះជា**ព្រះបច្ចេកពុទ្ធ**។*

អធិប្បាយ

*ពាក្យថា **បុព្វេ អននុស្សុតេសុ** ដូចដែលបានអធិប្បាយខាងដើមហើយ ។ ក៏ព្រះបច្ចេកពុទ្ធទាំងឡាយចាក់ធ្លុះ អរិយសច្ចទាំង៤ដោយខ្លួនឯងមិនមានអាចារ្យ តែមិនបានសម្រេចព្រះសព្វញ្ញុតញ្ញាណ និងទសពលញ្ញាណឡើយ។*

ចប់បច្ចេកពុទ្ធបុគ្គល

## (៣០). ឧភតោភាគវិមុត្តបុគ្គល

បុគ្គលខ្លះក្នុងលោកនេះ បានវិមោក្ខ ៨ ដោយនាមកាយ ទាំងអាសវៈរបស់បុគ្គលនោះ ក៏អស់ទៅ ព្រោះឃើញដោយបញ្ញា នេះហៅថា **បុគ្គលជា ឧភតោភាគវិមុត្ត** ។

អធិប្បាយ

ពាក្យថា **បញ្ញាយ ចស្ស ទិស្វា** សេចក្តីថា អាសវៈទាំង៤អស់ទៅ ព្រោះឃើញការប្រព្រឹត្តទៅនៃសង្ខារដោយវិបស្សនាបញ្ញា , ឃើញសច្ចធម៌ទាំង៤ ដោយមគ្គប្បញ្ញា ។ នេះហៅថា ឧភតោភាគវិមុត្តបុគ្គល ។

**វាទព្រះថេរ៣ព្រះអង្គ ៖** ១.**ព្រះចុល្លនាគត្ថេរ** អ្នកទ្រទ្រង់ព្រះត្រៃបិដក = បុគ្គលណាបានរួចផុតដោយ វិក្ខម្ភនវិមោក្ខសមាបត្តិ និងរួចផុតហើយដោយ សមុច្ឆេទវិមោក្ខមគ្គ ព្រោះហេតុនោះ ទើបឈ្មោះថា ឧភតោភាគវិមុត្ត។

២.**ព្រះមហាធម្មរក្ខិតត្ថេរ** អ្នកទ្រទ្រង់ព្រះត្រៃបិដក = អ្នករួចផុតហើយដោយរូបកាយផង ទាំងនាមកាយផង ទើបឈ្មោះថា ឧភតោភាគវិមុត្ត ។

៣.**ព្រះចូឡភយត្ថេរ** អ្នកទ្រទ្រង់ព្រះត្រៃបិដក = បុគ្គលអ្នករួចផុតវិសេសហើយ ដោយវិក្ខម្ភនវិមោក្ខសមាបត្តិអស់១វារៈ រួចផុតវិសេសហើយ ដោយសមុច្ឆេទវិមោក្ខមគ្គអស់១វារៈ ទើបហៅថា ឧភតោភាគវិមុត្ត ។ ព្រះថេរៈ៣ព្រះអង្គលោកជាបណ្ឌិត លោកពោលត្រឹមត្រូវល្អហើយ។ តែបើពោលដោយសង្ខេបទៅ ថា បុគ្គលឯណាផុតវិសេសហើយ អំពីរូបកាយដោយអរូបសមាបត្តិ ផុតវិសេសហើយអំពីនាមកាយ ដោយមគ្គ ព្រោះហេតុនោះ បុគ្គលនោះទើបឈ្មោះថា **ឧភតោភាគវិមុត្ត** ព្រោះរួចផុតហើយអំពីចំណែកទាំងពីរ ។

## ឧភតោភាគវិមុត្ត មាន៥ពួក

១.បុគ្គលចូលអរូបសមាបត្តិទី១ កាលចេញហើយពិចារណាសង្ខារ បានសម្រេចព្រះអរហន្ត ។

២.បុគ្គលបានអរូបសមាបត្តិទី២កាលចេញហើយពិចារណាសង្ខារ បានសម្រេចព្រះអរហន្ត។

៣.បុគ្គលបានអរូបសមាបត្តិទី៣កាលចេញហើយពិចារណាសង្ខារ បានសម្រេចព្រះអរហន្ត ។

៤. បុគ្គលបានអរូបសមាបត្តិទី៤ កាលចេញហើយពិចារណាសង្ខារ បានសម្រេចព្រះអរហន្ត ។ បុគ្គលទាំង៤ពួកនេះ លោកមិនចូលនិរោធសមាបត្តិជាប្រធានទេ ព្រោះហេតុនោះ ទើបឈ្មោះថាឧភតោភាគវិមុត្តដោយបរិយាយ (ន័យអម)

៥. ព្រះអនាគាមី ចូលនិរោធ ចេញមកវិញពិចារណាសង្ខារ ទើបបានសម្រេចជាព្រះអរហន្ត ។ ព្រះអនាគាមីអ្នកបានសមាបត្តិនោះហើយ កាលចេញចាកសមាបត្តិ (និរោធសមាបត្តិ) ក៏ចម្រើនវិបស្សនាសម្រេចព្រះអរហត្ត ព្រោះហេតុនោះ ទើបឈ្មោះថា ឧភតោភាគវិមុត្តសេដ្ឋបុគ្គល ដោយនិប្បរិយាយ (ន័យត្រង់)។

សួរថាៈ អរូបាវចរជ្ឈានក្តី រូបាវចរចតុត្ថជ្ឈានក្តី មានអង្គ២ដូចគ្នា គឺ ឧបេក្ខា និង ឯកគ្គតា បុគ្គលនោះធ្វើឈាននោះឱ្យទៅជាបទដ្ឋានបានសម្រេចអរហត្ត តើឈ្មោះថា ឧភតោភាគវិមុត្ត ឬទេ?

**ឆ្លើយថា**: មិនគប្បីយល់ដូច្នោះទេ ។

**សួរថា**: ព្រោះហេតុអ្វី ?

**ឆ្លើយថា** : ព្រោះភាវៈនៃអ្នកនោះ នៅមិនទាន់ផុតអំពីរូបកាយ ព្រោះថា រូបាវចរចតុត្ថជ្ឈាន នោះផុតអំពីកិលេសកាយ

ប៉ុណ្ណោះ, មិនបានផុតអំពីរូបកាយទេ ព្រោះហេតុដូច្នោះ អ្នកចេញចាកសមាបត្តិនោះហើយ សម្រេចព្រះអរហន្ត ទើបមិនឈ្មោះថា ឧភតោភាគវិមុត្ត, ចំណែកអរូបាវចរជ្ឈាន ផុតហើយអំពីនាមកាយផង អំពីរូបកាយផង ព្រោះហេតុដូច្នោះ អ្នកធ្វើអរូបាវចរជ្ឈាននោះឱ្យជាបាទ ហើយសម្រេចព្រះអរហន្ត គប្បីជ្រាបថា ឈ្មោះថា ***ឧភតោភាគវិមុត្តបុគ្គល*** ។

ចប់ឧភតោភាគវិមុត្តបុគ្គល

## (៣១). បញ្ញាវិមុត្តបុគ្គល

បុគ្គលខ្លះក្នុងលោកនេះ មិនបានវិមោក្ខ៨ ដោយនាមកាយទេ អាសវៈរបស់បុគ្គលនោះ ក៏អស់ទៅ ព្រោះឃើញដោយបញ្ញា នេះហៅថា **បុគ្គលជាបញ្ញាវិមុត្ត**។

អធិប្បាយ

## បញ្ញាវិមុត្តមាន៥ពួក

១. ព្រះអរហន្តដែលជាសុក្ខវិបស្សកៈ ។

២.៣.៤.៥. បុគ្គលចេញចាករូបជ្ឈានទាំង៤ ហើយពិចារណាដោយវិបស្សនា បានសម្រេចព្រះអរហត្ត ។

ក៏ព្រះអរហន្តទាំងនេះជាអ្នកមិនបានសមាបត្តិ៨ទេ។ ដោយហេតុនោះឯង ទើបលោកពោលពាក្យជាដើមថា : **ន ហេវ ខោ អដ្ឋវិមោក្ខេ** តែបណ្ដាអរូបាវចរជ្ឈានទាំងឡាយ សូម្បីកាលមានត្រឹមតែឈានមួយ ក៏ឈ្មោះថា ឧភតោភាគវិមុត្តបុគ្គល បានដូចគ្នាដែរ។

ចប់បញ្ញាវិមុត្តបុគ្គល

## (៣២). កាយសក្ខីបុគ្គល

បុគ្គលខ្លះ ក្នុងលោកនេះ បានវិមោក្ខ៨ ដោយនាមកាយ ទាំងអាសវៈពួកខ្លះ របស់បុគ្គលនោះ ក៏អស់ទៅ ព្រោះឃើញដោយបញ្ញា នេះហៅថា **បុគ្គលជាកាយសក្ខី** ។

អធិប្បាយ

ពាក្យថា **ឯកច្ចេ អាសវា** បានដល់ អាសវៈពួកខ្លះដែលប្រហារដោយមគ្គខាងក្រោម ៣ ។ បុគ្គលដែលមានសភាពដូច្នេះ ហៅថា **កាយសក្ខី** ។ បុគ្គលដែលបានពាល់ត្រូវនូវវិមោក្ខទាំង៨ជាមុន ហើយធ្វើនិរោធ គឺព្រះនិព្វានឱ្យច្បាស់ខាងក្រោយ សូម្បីបុគ្គលនេះ ក៏ឈ្មោះថា **កាយសក្ខី**ដែរ ។ កាយសក្ខីបុគ្គលនេះ មាន ៦ ជំពូក រាប់តាំងអំពី**សោតាបត្តិផល រហូតដល់អរហត្តមគ្គ** ។

ចប់កាយសក្ខីបុគ្គល

## (៣៣). ទិដ្ឋិប្បត្តបុគ្គល

បុគ្គលខ្លះក្នុងលោកនេះ ដឹងច្បាស់តាមពិតថា នេះទុក្ខ នេះហេតុនាំឱ្យកើតទុក្ខ នេះទីរលត់ទុក្ខ នេះជាបដិបទាទៅកាន់ទីរលត់ទុក្ខ ធម៌ទាំងឡាយដែលព្រះតថាគតសំដែងហើយ បុគ្គលនោះ

បានឃើញដោយល្អ បានប្រព្រឹត្តដោយល្អដោយបញ្ញាផង អាសវៈពួកខ្លះរបស់បុគ្គលនោះ ក៏អស់ទៅ ព្រោះឃើញដោយបញ្ញាផង នេះហៅថា **បុគ្គលជាទិដ្ឋិប្បត្តៈ** ។

អធិប្បាយ

# អរិយសច្ច៤

១ .**ទុក្ខសច្ច =** យថាភូតំ បជានាតិ សេចក្តីថា វៀរតណ្ហាចេញហើយ រមែងដឹងទុក្ខ គឺ ឧបាទានក្ខន្ធ៥ ដោយកិច្ច តាមសេចក្តីពិតថា ជាទុក្ខសច្ច។

២.**សមុទយសច្ច** = ក៏តណ្ហារមែងញុំាងទុក្ខឱ្យកើត ឱ្យកើតឡើង ឱ្យបង្កើត គឺប្រព្រឹត្តទៅ ទុក្ខនេះ រមែងកើតអំពីតណ្ហានោះ ព្រោះហេតុនោះ រមែងដឹងច្បាស់នូវតណ្ហានោះ តាមសេចក្តីពិតថា “អយំ ទុក្ខសមុទយោ = នេះជាដែនកើតឡើងនៃទុក្ខ ”។

៣. **ទុក្ខនិរោធអរិយសច្ច** = ក៏ព្រោះហេតុនៃទុក្ខនេះផង សមុទយនេះផង ដល់ព្រះនិព្វានហើយរមែងរលត់ទៅ រមែងស្ងប់រម្ងាប់ គឺរមែងដល់សេចក្តីមិនប្រព្រឹត្តទៅ ព្រោះហេតុដូច្នោះ រមែងដឹង

*ច្បាស់នូវព្រះនិព្វាននោះ តាមពិតថា អយំ ទុក្ខនិរោធោ នេះជាទីរលត់ទៅនៃទុក្ខ ។*

៤. **ទុក្ខនិរោធគាមិនីបដិបទា** = *មគ្គឯណាជាផ្លូវប្រកបដោយអង្គ៨ប្រការ ទុក្ខនេះរមែងដល់នូវសេចក្តីរលត់ទៅដោយមគ្គនោះ ព្រោះហេតុដូច្នោះ រមែងដឹងទូទៅនូវមគ្គនោះ តាមសេចក្តីពិតថា* **អយំ ទុក្ខនិរោធគាមិនីបដិបទា** = *នេះជាការបដិបត្តិឱ្យដល់នូវសេចក្តីរលត់ទុក្ខ ។*

## លំដាប់នៃការសម្តែង អរិយសច្ចទាំង៤

**ទុក្ខសច្ច** : *ទ្រង់ត្រាស់ទុក្ខសច្ចជាសច្ចដំបូង ព្រោះទុក្ខសច្ចជារបស់គ្រោតគ្រាត និងជារបស់សាធារណដល់សត្វទាំងឡាយ។*

**សមុទយសច្ច** : ***ត្រាស់សមុទយៈ****ជាសច្ចទី២ ព្រោះជាហេតុរបស់ទុក្ខសច្ច។*

**និរោធសច្ច** :***ត្រាស់និរោធសច្ច****ព្រោះការរលត់ហេតុ ទើបផលរលត់។*

**មគ្គសច្ច** : *ត្រាស់មគ្គជាទីបំផុតព្រោះដើម្បីជាឧបាយនៃនិរោធ។*

ម្យ៉ាងទៀត

**ទុក្ខសច្ច** : *ត្រាស់**ទុក្ខសច្ចជាសច្ចទី១** ព្រោះដើម្បីឱ្យសត្វសង្វេគអ្នកជាប់សុខក្នុងភព។*

**សមុទយសច្ច** : *ត្រាស់**សមុទយជាបន្ទាប់**ដើម្បីបញ្ជាក់ថា ទុក្ខកើតឡើងព្រោះសមុទយ មិនមែនព្រះឥស្សរ ព្រះជាម្ចាស់ជាដើមបង្កើតទេ។*

***និរោធសច្ច*** : *ត្រាស់**និរោធជាសច្ចទី៣** ដើម្បីលួងលោមចិត្តដោយបានឃើញនិស្សរណៈឱ្យកើតឡើងដល់បុគ្គល ដែលមានចិត្តសង្វេគ ព្រោះត្រូវទុក្ខនិងហេតុគ្របសង្កត់ ហើយស្វែងរកភាពចេញចាកទុក្ខ។*

***មគ្គសច្ច*** : *ត្រាស់**មគ្គជាសច្ចទី**បំផុត ព្រោះជាធម៌ញុំាងនិរោធឱ្យដល់ព្រមដើម្បីសម្រេចនិរោធ។*

## អរិយសច្ចៈមានត្រឹមតែ៤ មិនខ្វះ មិនលើស[៣]

*ក្នុងខថា មិនខ្វះ មិនលើសនោះ បើមានពាក្យ**សួរថា**=ក៏ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគជាម្ចាស់ ត្រាស់អរិយសច្ចៈទុក ៤*

---

[៣] *វិសុទ្ធិមគ្គ*

ប៉ុណ្ណោះ មិនខ្វះមិនលើស? **ឆ្លើយថា** : ព្រោះមិនមានសច្ចៈយ៉ាងដទៃ នឹងនាំចេញពីខណាមួយក៏មិនបាន ពិតណាស់ សច្ចៈដទៃក្រៃលែងជាងសច្ចទាំង៤នេះ ឬថាបណ្តាសច្ចៈទាំង៤នេះនឹងគប្បីនាំចេញទៅត្រឹមតែមួយខក៏មិនបានដែរ ដូចយ៉ាងដែល ត្រាស់ទុកមានជាអាទិ៍ថា ÷ ម្នាលភិក្ខុទាំងឡាយ សមណឬព្រាហ្មណ៍ ក្នុងលោកនេះគប្បីអាងថា ទុក្ខដែលព្រះសមណគោតមសម្តែងទុកនេះមិនមែនជាអរិយសច្ចៈ ទុក្ខដទៃជាអរិយសច្ចៈ យើងនឹងវៀរទុក្ខអរិយសច្ចៈនេះ ហើយបញ្ញត្តិ ទុក្ខអរិយសច្ចៈដទៃ ខនេះមិនមែនជាឋានៈដែលមានបានឡើយ ។ក៏ដូចដែលត្រាស់ទុកមានជាអាទិ៍យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ក៏សមណៈឬព្រាហ្មណ៍ណាមួយ នឹងគប្បីពោលយ៉ាងនេះថា នោះមិនមែនទុក្ខអរិយសច្ចៈ ខទី ១ ដែលព្រះសមណគោតមទ្រង់សំដែងទុក យើងនឹងលះទុក្ខអរិយសច្ចៈ ខទី ១នោះចេញ ហើយបញ្ញត្តិទុក្ខអរិយសច្ចៈ ខទីមួយយ៉ាងដទៃថ្មី ខនេះមិនមែនជាឋានៈដែលនឹងមានបានឡើយ។

ម្យ៉ាងទៀត ព្រះមានព្រះភាគជាម្ចាស់ កាលនឹងត្រាស់ប្រាប់សេចក្តីប្រព្រឹត្តទៅនៃទុក្ខ ក៏ត្រាស់ប្រាប់ព្រមទាំងហេតុ និងត្រាស់

ប្រាប់ការមិនប្រព្រឹត្តទៅ ក៏ត្រាស់ប្រាប់ព្រមទាំងឧបាយ (ជាគ្រឿងរំដោះចេញ) ព្រោះហេតុនោះ ទើបត្រាស់អរិយសច្ចៈ៤ ប៉ុណ្ណោះ។

ម្យ៉ាងទៀត ព្រះអង្គត្រាស់អរិយសច្ចៈ ៤ប៉ុណ្ណោះ សូម្បីដោយអំណាចនៃ **បរិញ្ញេយ្យធម៌** : ធម៌ដែលគួរត្រាស់ដឹង, **បហាតព្វធម៌** : ធម៌ដែលគួរលះបង់, **សច្ឆិកាតព្វធម៌** :ធម៌ដែលគួរធ្វើឱ្យជាក់ច្បាស់ , **ភាវេតព្វធម៌**:ធម៌ដែលគួរចម្រើន ។ និងត្រាស់ទុក៤ទៀត ដោយអំណាចនៃតណ្ហា វត្ថុដែលជាទីអាស្រ័យកើតរបស់តណ្ហា ការលត់តណ្ហា និងឧបាយជាគ្រឿងរលត់តណ្ហា។

ម្យ៉ាងទៀត ក៏ត្រាស់ទុកសូម្បីទាំង៤ ដោយអំណាចនៃសេចក្តីអាល័យ ហេតុដែលត្រេកអរក្នុងការអាល័យ ការដកឡើងនូវអាល័យ និងឧបាយជាហេតុដកឡើងនូវអាល័យ។

អរិយសច្ចទាំង៤នេះ ព្រះអង្គទ្រង់ត្រាស់ដឹងព្រមគ្នា ពេលទ្រង់ប្រថាប់ក្រោមពោធិមណ្ឌល ។ បុគ្គលដែលមានការត្រាស់ដឹងធម៌ ដោយបញ្ញាដែលខ្លួនប្រព្រឹត្តល្អហើយ ដែលមានសភាពបែបនេះ ឈ្មោះថា ទិដ្ឋិប្បត្តោ ។

ទិដ្ឋិប្បត្តបុគ្គលនេះ ក៏មាន៦ ដូចព្រះអរិយបុគ្គលឈ្មោះថា កាយសក្ខី ដែរ (ខុសគ្នាត្រង់ថា កាយសក្ខី មានសមាបត្តិទាំង៨ជាបាទ , ទិដ្ឋិប្បត្ត មានសមាបត្តិ៥ និងសុក្ខវិបស្សកៈ ) ។

ចប់ទិដ្ឋិប្បត្តបុគ្គល

## (៣៤). សទ្ធាវិមុត្តបុគ្គល

បុគ្គលខ្លះក្នុងលោកនេះដឹងច្បាស់តាមពិតថា នេះទុក្ខ នេះហេតុនាំឱ្យកើតទុក្ខ នេះធម៌រលត់ទុក្ខ នេះបដិបទាជាដំណើរទៅកាន់ធម៌រលត់ទុក្ខ ធម៌ទាំងឡាយដែលព្រះតថាគតសម្តែងហើយ បុគ្គលនោះបានឃើញដោយល្អ បានប្រព្រឹត្តដោយល្អ ដោយបញ្ញាផង អាសវៈពួកខ្លះ របស់បុគ្គលនោះក៏អស់ទៅ ព្រោះឃើញដោយបញ្ញាផង តែមិនដូចជាបុគ្គលជាទិដ្ឋិប្បត្តៈទេ នេះហៅថា **សទ្ធាវិមុត្ត** ។

អធិប្បាយ

ពាក្យថា “ **នោ ច ខោ យថា ទិដ្ឋិប្បត្តស្ស** ” អធិប្បាយថា អាសវៈទាំងឡាយរបស់សទ្ធាវិមុត្តបុគ្គល ជាធម្មជាតិអស់ទៅ មិនដូចគ្នានិងទិដ្ឋិប្បត្តបុគ្គលទេ ។

***សួរថា*** = *សេចក្តីផ្សេងគ្នាក្នុងការលះកិលេសនៃព្រះអរិយបុគ្គលទាំងពីរនោះ នៅមានឬ ?*

***ឆ្លើយថា*** = មិនមានទេ ។

***សួរថា*** = *បើដូច្នោះ ព្រោះហេតុអ្វីបានជាសទ្ធាវិមុត្តបុគ្គលមិនដូចគ្នានិងទិដ្ឋិប្បត្តបុគ្គល ។*

***ឆ្លើយថា*** = *ព្រោះសេចក្តីប្លែកផ្សេងគ្នាដោយធម៌ដែលលោកគប្បីសម្រេច ។ ក៏**ទិដ្ឋិប្បត្តបុគ្គល** លោកគ្របសង្កត់កិលេសទាំងឡាយបាន ដោយមិនលំបាក គឺមិនកម្រ ។ តែ**សទ្ធាវិមុត្តបុគ្គល**ជាអ្នកលំបាក ដោយសេចក្តីទុក្ខលំបាក ទើបអាចគ្របសង្កត់កិលេសទាំងឡាយបាន ព្រោះហេតុដូច្នោះ ទើបលោកមិនដល់ទិដ្ឋិប្បត្តបុគ្គលឡើយ ។*

*ម្យ៉ាងទៀត សេចក្តីប្លែកផ្សេងគ្នា សូម្បីដោយបញ្ញារបស់លោកពីរនោះ ក៏នៅមានដែរ ។*

**ទិដ្ឋិប្បត្តបុគ្គល** = *ក៏វិបស្សនាញាណនៃមគ្គ៣ ខាងលើរបស់* ***ទិដ្ឋិប្បត្ត*** *ជាគុណជាតខ្លាំងក្លា, ក្លៀវក្លា,ស្រស់ថ្លា, ប្រព្រឹត្តទៅ។ ប្រៀបដូចជា បុរសយកកាំបិតដ៏មុត កាប់ដើមចេកមិនឮសំឡេង*

ដាវដ៏មុតដូច្នោះ ។ យ៉ាងណា បញ្ញារបស់ទិដ្ឋិប្បត្ត ក៏មុតស្រួចយ៉ាង នោះដែរ ។

**សទ្ធាវិមុត្តបុគ្គល** = វិបស្សនាញាណមគ្គ៣ខាងលើ របស់សទ្ធាវិមុត្ត មិនខ្លាំងក្លា មិនក្លៀវក្លា, មិនស្រស់ថ្លាវិសេសឡើយ ។ ព្រោះហេតុនោះ ទើបលោកមិនដល់ទិដ្ឋិប្បត្តបុគ្គល ។ ប្រៀបដូចបុរសយកដាវ ដែលមានមុខរិល កាប់ដើមចេក រមែងបញ្ចេញសំឡេងឮថា“កដៈ កដៈ” យ៉ាងណា បញ្ញារបស់សទ្ធាវិមុត្តបុគ្គល ក៏មានសភាពដូច្នោះដែរ ។ ក៏លោកអាចារ្យហាមន័យនេះថា “**នោ** ” (**នោ ច ខោ យថា ទិដ្ឋិប្បត្តស្ស**) ដូច្នេះ ហើយលោកធ្វើការសន្និដ្ឋានថា ក៏សទ្ធាវិមុត្តបុគ្គល មិនដល់ទិដ្ឋិប្បត្តបុគ្គលទេ ព្រោះញាណដែលលោកគប្បីសម្រេចប្លែកផ្សេងគ្នានោះឯង ដូចដែលបានពោលហើយ ។

## បុព្វភាគរបស់សទ្ធាវិមុត្តបុគ្គល និងទិដ្ឋិប្បត្តបុគ្គល

ការអស់កិលេសរបស់ **សទ្ធាវិមុត្តបុគ្គល** រមែងមានក្នុងខណៈនៃមគ្គដែលជាបុព្វភាគចំណែកខាងដើម ដូចបុគ្គលអ្នកកំពុងជឿ ហើយស្ទង់មើល និងបង្អោនចិត្តជឿ ។ ដូចជាការកាត់ដើម

ចេកនិងសាស្រ្តាដែលមានមុខរឹល រមែងមានឮសំឡេង មិនលឿន រហ័ស និងកន្លែងដែលកាត់នោះមិនរាបស្មើដូច្នោះដែរ ។

ញាណជាគ្រឿងកាត់កិលេសរបស់**ទិដ្ឋិប្បត្តបុគ្គល** រមែងមានក្នុងខណៈនៃមគ្គដែលជាចំណែកខាងដើម មិនឃើត ជារបស់មុតប្រព្រឹត្តទៅ។ ញាណគឺបញ្ញារបស់ទិដ្ឋិប្បត្តបុគ្គលនោះ ប្រៀបដូចបុគ្គលកាលយកដាវដែលមុតកាត់ដើមចេក កន្លែងដែលត្រូវកាត់រមែងរាបស្មើ ដាវឆ្លងកាត់ទៅបានលឿនរហ័ស ធ្វើឱ្យមិនបានឮសំឡេង, គេមិនត្រូវប្រើសេចក្តីព្យាយាមខ្លាំង យ៉ាងណា, គប្បីជ្រាបថា មគ្គភាវនាដែលជាចំណែកខាងដើមរបស់ទិដ្ឋិប្បត្តបុគ្គលអ្នកមានសភាពបែបនេះ ក៏ដូច្នោះដែរ ។ **អយំ វុច្ចតិ** = បុគ្គលដែលមានសភាពបែបនេះ ព្រះអង្គទ្រង់ត្រាស់ថា សទ្ធាវិមុត្តបុគ្គល។ ក៏សទ្ធាវិមុត្តបុគ្គលនេះ មាន៦ ជំពូក ដូចនឹងកាយសក្ខីបុគ្គលដែរ ។

**ចប់សទ្ធាវិមុត្តបុគ្គល**

## (៣៨). ធម្មានុសារីបុគ្គល

បុគ្គលណា កំពុងប្រតិបត្តិ ដើម្បីធ្វើឱ្យជាក់ច្បាស់ នូវសោតាបត្តិផល មានឥន្ទ្រិយ គឺបញ្ញាដ៏ក្រៃលែង ចំរើនអរិយមគ្គ មានបញ្ញាជាគ្រឿងនាំ, មានបញ្ញាជាប្រធាន នេះហៅថា **បុគ្គលជាធម្មានុសារី** ។បុគ្គលកំពុងប្រតិបត្តិ ដើម្បីធ្វើឱ្យជាក់ច្បាស់ នូវសោតាបត្តិផល ឈ្មោះថា **ធម្មានុសារី** ឯបុគ្គលឋិតនៅក្នុងផល ឈ្មោះថា **ទិដ្ឋិប្បត្តៈ** ។

អធិប្បាយ

ពាក្យថា **បដិបន្នស្ស** = កំពុងប្រតិបត្តិ បានដល់ បុគ្គលអ្នកតាំង សោតាបត្តិមគ្គ ។

បុគ្គលឯណា រមែងនាំមកនូវបញ្ញា ព្រោះហេតុនោះ អ្នកនោះ ទើបឈ្មោះថា **បញ្ញាវាហី** : អ្នកមានប្រក្រតីនាំមកនូវបញ្ញា អធិប្បាយថា បញ្ញារមែងនាំបុគ្គលនេះទៅ ។ពាក្យថា បញ្ញា បុព្វង្គមំ បានដល់ ឃើញបញ្ញាជាបុរេចារិក គឺ ធ្វើបញ្ញាឱ្យជាប្រធាន ។ ពាក្យថា **ធម្មានុសារី** នេះ ជាឈ្មោះនៃបុគ្គលអ្នកតាំងនៅក្នុង**សោតាបត្តិមគ្គ**, តែកាលលោកសម្រេចផល ឈ្មោះថា **ទិដ្ឋិប្បត្តៈ** ។

ចប់ធម្មានុសារី

## (៣៦). សទ្ធានុសារីបុគ្គល

*បុគ្គលណា ប្រតិបត្តិ ដើម្បីធ្វើឱ្យជាក់ច្បាស់ នូវសោតាបត្តិផល មានឥន្ទ្រិយគឺសទ្ធា ដ៏ក្រៃលែង ចំរើនអរិយមគ្គ មានសទ្ធាជាគ្រឿងនាំ មានសទ្ធាជាប្រធាន នេះហៅថា **បុគ្គលជាសទ្ធានុសារី** ។បុគ្គលកំពុងប្រតិបត្តិដើម្បីធ្វើឱ្យជាក់ច្បាស់ នូវសោតាបត្តិផល ឈ្មោះថា **សទ្ធានុសារី** ។ឯបុគ្គលឋិតនៅក្នុងផល ឈ្មោះថា **សទ្ធាវិមុត្ត** ។*

*អធិប្បាយ*

*បុគ្គលឯណារមែងនាំមកនូវសទ្ធា ព្រោះហេតុនោះ បុគ្គលនោះទើបឈ្មោះថា **សទ្ធាវាហី** = អ្នកនាំមកនូវសទ្ធា*

*បទថា **សទ្ធាបុព្វង្គមំ** : ធ្វើសទ្ធាឱ្យជាបុរេចារិក គឺឱ្យជាប្រធាន មានន័យដូចធម្មានុសារីបុគ្គលហើយ។*

*ពាក្យថា **សទ្ធានុសារី** នេះ ជាឈ្មោះរបស់**សោតាបត្តិមគ្គ** ។ តែកាលលោកសម្រេច**ផលចិត្ត**ហើយ ឈ្មោះថា* **សទ្ធាវិមុត្ត** ។

**ធុរៈមាន២យ៉ាង :** ***សទ្ធាធុរៈ***(*សទ្ធានុសារី* ) និង ***បញ្ញាធុរៈ***(*ធម្មានុសារី* ) ។

**អភិនិវេស** : **ការអាស្រ័យមាន ២យ៉ាង គឺ** ១. សមថាភិនិវេស : *ភិក្ខុអង្គខ្លះ សម្រេចមគ្គនិងផលដោយអាស្រ័យ**សមថៈ*** ,២.វិបស្សនាភិ-និវេស : *ភិក្ខុអង្គខ្លះសម្រេចមគ្គនិងផលដោយអាស្រ័យ វិបស្សនា។*

**សីសះ គឺ ទីបំផុតមាន ២យ៉ាង បានដល់** ១. ***ឧភតោភាគវិមុត្ត*** : *ភិក្ខុមួយអង្គ សម្រេចធម៌ដល់ទីបំផុតដោយសមាបត្តិ ៨,* ២. **បញ្ញាវិមុត្ត** : *ភិក្ខុមួយអង្គ សម្រេចធម៌ដល់ទីបំផុត ដោយមិនមានសមាបត្តិ៨* ។ ***អធិប្បាយថា*** *លោកទាំងនោះរមែងសម្រេចធម៌ដោយ ធុរៈ២* , ***អភិនិវេស ២, និង សីសៈ ២*** *នេះឯង ។*

## សមថាភិនិវេស បញ្ញាធុរះ

*បណ្ដាលោកទាំងនោះ ភិក្ខុរូបណាបាន**សមាបត្តិ៨** ធ្វើ**បញ្ញាឱ្យជាធុ-រៈ** អាស្រ័យអំណាចសមថៈ ធ្វើអរូបសមាបត្តិយ៉ាងណាមួយឱ្យជាបទដ្ឋាន ហើយផ្ដើមតាំងវិបស្សនា សម្រេចព្រះអរហត្ត ភិក្ខុរូបនោះ **ក្នុងខណៈសោតាបត្តិមគ្គ** ឈ្មោះថា* **ធម្មានុសារី** *។ ក្នុងឋានៈ ៦ ខាងមុខ គឺតាំងអំពីសោតាបត្តិផល រហូតដល់អរហត្តមគ្គ ឈ្មោះថា* **កាយសក្ខី** *។ កាលសម្រេច**អរហត្តផល**ហើយ ឈ្មោះថា* **ឧភតោភាគវិមុត្ត** ។

## វិបស្សនាភិនិវេស បញ្ញាធុរៈ

មួយរូបទៀត ធ្វើបញ្ញាតែម្យ៉ាងប៉ុណ្ណោះ ឱ្យជាធុរៈ អាស្រ័យអំណាចនៃវិបស្សនា ពិចារណាសុទ្ធសង្ខារ ឬរូបាវចរជ្ឈានយ៉ាងណាមួយ សម្រេចព្រះអរហន្ត ។ សូម្បីភិក្ខុនេះ ក្នុងខណៈនៃ**សោតាបត្តិមគ្គ** ឈ្មោះថា **ធម្មានុសារី** ។ តែខណៈ ៦ ខាងមុខ គឺតាំងអំពីសោតាបត្តិផល រហូតដល់ អរហត្តមគ្គ ឈ្មោះថា **ទិដ្ឋិប្បត្ត** ។ កាលសម្រេច**អរហត្តផល** ឈ្មោះថា **បញ្ញាវិមុត្ត** ។

ឈ្មោះ ២យ៉ាង គឺ **បញ្ញាវិមុត្ត** និង**ទិដ្ឋិប្បត្ត** ក្រោយនេះ និងរួមជាមួយឈ្មោះមុនៗ ៣ទៀត គឺ **ធម្មានុសារី កាយសក្ខី** និង **ឧភតោភាគវិមុត្ត** ទើបត្រូវជា ៥ឈ្មោះ។

## សមថាភិនិវេស សទ្ធាធុរៈ

មួយរូបទៀត លោកបានសមាបត្តិ៨ ធ្វើសទ្ធាឱ្យជាធុរៈ អាស្រ័យអំណាចសមថៈ ធ្វើអរូបសមាបត្តិយ៉ាងណាមួយឱ្យជាបទដ្ឋាន ផ្ដើមតាំងវិបស្សនា សម្រេចព្រះអរហត្ត ។ ភិក្ខុនេះ ក្នុងខណៈនៃសោតាបត្តិមគ្គ ឈ្មោះថា **សទ្ធានុសារី** ។ ក្នុងឋានៈ៦ខាងមុខ ឈ្មោះថា **កាយសក្ខី** ។ កាលសម្រេចព្រះអរហត្តផល ឈ្មោះថា **ឧភ-**

**គោភាគវិមុត្ត** តែម្យ៉ាង ។ឈ្មោះម្យ៉ាងប៉ុណ្ណោះ គឺ **សទ្ធានុសារី** ដែលមានមកក្នុងទីនេះ រួមនឹងឈ្មោះ៥ខាងដើម ក៏ជា៦ ឈ្មោះដូចគ្នា ។

## វិបស្សនាកិច្ចរវាងសទ្ធាវិមុត្ត

ភិក្ខុមួយរូបទៀត ធ្វើសទ្ធានុសារី នេះឯងឱ្យជាធុរៈ អាស្រ័យអំណាចនៃវិបស្សនា ពិចារណាសង្ខារសុទ្ធ ឬរូបាវចរឈានយ៉ាងណាមួយ ហើយសម្រេចអរហត្ត ,សូម្បីភិក្ខុនេះ ក្នុងខណៈនៃសោតាបត្តិមគ្គ ឈ្មោះថា **សទ្ធានុសារី** ។ក្នុងខណៈ ៦ ខាងមុខគឺតាំងអំពីសោតាបត្តិផល រហូតដល់អហរត្តមគ្គ ឈ្មោះថា **សទ្ធាវិមុត្ត** ។ លុះបានសម្រេចនូវព្រះ**អរហត្តផល** ឈ្មោះថា **បញ្ញាវិមុត្ត** ។

ឈ្មោះម្យ៉ាងប៉ុណ្ណោះ គឺ សទ្ធាវិមុត្ត មិនធ្លាប់មានក្នុងទីនេះ ហើយរួមនឹងឈ្មោះ ៦ ខាងដើម ក៏ត្រូវជា ៧ឈ្មោះដូចគ្នា ។ព្រះអរិយបុគ្គលទាំង៧ពួកនេះឈ្មោះថា**ជាទក្ខិណេយ្យបុគ្គល**ដ៏ប្រសើរក្នុងលោក ។

**ចប់សទ្ធានុសារី**

## (៣៧). សត្តក្ខត្តុំបរមបុគ្គល

*បុគ្គលខ្លះ ក្នុងលោកនេះ ដល់នូវសោតៈ ព្រោះការអស់ទៅនៃសញ្ញោជនៈ៣មានសភាពមិនធ្លាក់ចុះក្នុងអបាយជាបុគ្គលទៀងមានការត្រាស់ដឹង ប្រព្រឹត្តទៅខាងមុខ បុគ្គលនោះស្ទុះទៅ អន្ទោលទៅ ក្នុងទេវតា និងមនុស្ស អស់វារៈ៧ដង ហើយធ្វើនូវទីបំផុតនៃវដ្តទុក្ខ នេះហៅថាបុគ្គល ជាសត្តក្ខត្តុំបរមៈ ។*

*អធិប្បាយ*

*ពាក្យថា* **សត្តក្ខត្តុំ** *បានដល់ ៧ដង អធិប្បាយថា ការកើតឡើងក្នុងភព ពោលគឺការកាន់យកនូវអត្តភាពមាន៧ជាតិ ជាយ៉ាងក្រៃលែងរបស់បុគ្គលនោះ ព្រោះហេតុនោះ បុគ្គលនោះ ទើបឈ្មោះថា* សត្តក្ខត្តុំ បរមោ : *អ្នកមាន ៧ជាតិជាយ៉ាងក្រៃលែង ព្រោះលោកមិនកាន់យកភពទី៨ អំពីភពទី៧ នោះទេ ,* **អរិយមគ្គ** *ឈ្មោះថា* **សោតោ** *=ក្រសែ ។*

*ពាក្យថា* **សោតោ** *: មគ្គមានអង្គ៨ ដែលជាអរិយៈ នេះគឺសម្មាទិដ្ឋិ ។ល។ សម្មាសមាធិប៉ុណ្ណោះ ឈ្មោះថា* សោតោ ។

ពាក្យថា **សោតាបន្នោ ហោតិ** : បុគ្គលឯណា ប្រកបដោយមគ្គមានអង្គ ៨ ដែលជាអរិយៈនេះ បុគ្គលនោះឯង ឈ្មោះថា **ព្រះសោតាបន្ន** ។សូម្បីក្នុងខណៈនៃមគ្គយ៉ាងនេះថា លោកអ្នកមានអាយុ មានឈ្មោះយ៉ាងនេះ ឬមានគោត្រយ៉ាងនេះ ក៏ឈ្មោះរបស់ផលដែលមគ្គឱ្យហើយ ព្រោះហេតុនោះ ព្រះសោតាបន្ន ទើបព្រះអង្គទ្រង់បំណាំងយកក្នុងខណៈនៃផល " ។

ពាក្យថា **និយតោ** = ទៀង គឺ ទៀងដោយនិយាមនៃមគ្គ ។

ពាក្យថា **សម្ពោធិបរាយនោ** : បានដល់ ភាពជាអ្នកមានការត្រាស់ដឹង ដែលនឹងប្រព្រឹត្តទៅក្នុងខាងមុខ ។ ពិតមែន ព្រះសោតាបន្ននោះ រមែងត្រាស់ដឹងដោយមគ្គដែលខ្លួនបានចំពោះហើយ ព្រោះហេតុដូច្នោះ ទើបលោកឈ្មោះថា **សម្ពោធិបរាយនោ** ។ ម្យ៉ាងទៀត ព្រះសោតាបន្ននោះ នឹងត្រាស់ដឹងដោយមគ្គខាងលើទាំង ៣ ដោយពិត ព្រោះហេតុនោះ លោកទើបឈ្មោះថា **សម្ពោធិបរាយនោ** ។

ពីរបទថា" **អយំ វុច្ចតិ** " បុគ្គលនេះ គឺអ្នកបែបនេះ លោកហៅថា **សត្តក្ខត្តុ បរមោ** = អ្នកមាន៧ជាតិយ៉ាងក្រៃលែង។ ក៏សត្តក្ខត្តុំ-

បរមបុគ្គល នេះគប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់ហើយដោយភពដែលលាយគ្នា ដោយអំណាចនៃទេវលោក និងមនុស្សលោកតាមកាលដែលសមគួរ ។

**ចប់សត្តក្ខត្តុំបរមបុគ្គល**

(៣៨). កោលំកោលបុគ្គល

បុគ្គលខ្លះក្នុងលោកនេះ ដល់នូវសោតៈ ព្រោះអស់ទៅនៃសញ្ញោជនៈ ៣ មានសភាពមិនធ្លាក់ចុះក្នុងអបាយ ជាបុគ្គលទៀងមានការត្រាស់ដឹងប្រព្រឹត្តទៅខាងមុខ បុគ្គលនោះ ស្ទុះទៅ អន្ទោលទៅ កាន់ត្រកូល ២ឬ ៣ហើយធ្វើទីបំផុតនៃវដ្តទុក្ខ នេះឈ្មោះថា **បុគ្គលជាកោលំកោលៈ** ។

អធិប្បាយ

បុគ្គលឯណា រមែងចេញអំពីត្រកូលទៅកាន់ត្រកូល ព្រោះហេតុនោះ បុគ្គលនោះ ទើបឈ្មោះថា **កោលំកោលៈ** ។ អធិប្បាយថា ក៏ឈ្មោះថា ការកើតក្នុងត្រកូលទាប ចាប់ផ្តើមអំពីការធ្វើឱ្យជាក់ច្បាស់នូវសោតាបត្តិផលទៅ រមែងមិនមាន, លោករមែងកើតក្នុងត្រកូលដែលមានភោគច្រើនតែម្យ៉ាង ។

*ពាក្យថា **ទ្វេ វា តីណិ វា កុលានិ** =ត្រកូល២ឬ៣ បានដល់ទៅកាន់ភព ២ ឬភព ៣ ដោយអំណាចនៃការកើតជាទេវតា និងមនុស្ស ។*

*សូម្បី**កោលំកោលបុគ្គល** នេះ ព្រះមានព្រះភាគជាម្ចាស់ត្រាស់ហើយដោយអំណាចនៃមិស្សកៈភព គឺភពដែលលាយឡំគ្នានុ៎ះឯង។ ក៏ក្នុងពាក្យថា **ទ្វេ វា តីណិ វា** " ត្រឹមតែទេសនាប៉ុណ្ណោះ ។ **កោលំ-កោលបុគ្គល** នោះឯង រមែងត្រាច់ទៅរហូតដល់ភព ទី ៦ ទើបធ្វើផ្លូវ គឺមគ្គដែលជាទីអស់ទៅនៃវដ្តទុក្ខបាន ។*

**ចប់កោលំកោលបុគ្គល**

## (៣៩). ឯកពីជីបុគ្គល

បុគ្គលខ្លះ ក្នុងលោកនេះ ដល់នូវសោតៈ ព្រោះអស់ទៅនៃសញ្ញោជនៈ មានសភាពមិនធ្លាក់ចុះ ក្នុងអបាយ ជាបុគ្គលទៀងមានការត្រាស់ដឹងប្រព្រឹត្តទៅខាងមុខ បុគ្គលនោះ កើតក្នុងភព ជារបស់មនុស្សតែម្តងទៀត ហើយធ្វើនូវទីបំផុតនៃវដ្តទុក្ខ នេះឈ្មោះថា **បុគ្គលជាឯកពីជី** ។

អធិប្បាយ

ឈ្មោះថា ពូជ គឺខន្ធ ដែលព្រះមានព្រះភាគត្រាស់ហើយ ក៏ព្រះសោតាបន្នអង្គណាមានពូជ គឺខន្ធមួយដងប៉ុណ្ណោះ គឺមានការកាន់យកអត្តភាពមួយដង ព្រះសោតាបន្ននោះ ឈ្មោះថា **ឯកពីជី** ។ ពាក្យថា **មានុស្សកំ ភវំ** : កើតក្នុងភពជារបស់មនុស្ស នេះត្រឹមតែជាទេសនាប៉ុណ្ណោះ ។តែនឹងពោលថា ញ៉ាំងទេវភពឱ្យកើត (ម្តងទៀត) ដូច្នេះខ្លះ ក៏សមគួរដូចគ្នា ។ ក៏ឈ្មោះទាំងនេះ ជាឈ្មោះនៃព្រះអរិយទាំងនោះ ដោយអំណាចនៃឈ្មោះដែលព្រះមានព្រះភាគទ្រង់កាន់យកហើយនុ៎ះឯង ។

*ពិតមែន **ព្រះសោតាបន្ន ៣ ពួក** អ្នកទៅដល់ទីមានប្រមាណប៉ុណ្ណោះៗ ឈ្មោះថា **សត្តក្ខត្តុំបរមបុគ្គល, កោលំកោលបុគ្គល , ឯកពីជីបុគ្គល** ព្រោះហេតុដូច្នោះ ឈ្មោះព្រះសោតាបន្នទាំងនោះទើបព្រះមានព្រះភាគទ្រង់កាន់យកហើយ ។ តែថាដោយកំណត់ជាក់លាក់ ពាក្យថា ព្រះសោតាបន្នរូបនេះជា សត្តក្ខត្តុំបរមៈ, កោលំកោលៈ និង ឯកពីជី រមែងមិនមានទេ ។*

***សួរថា***=*នរណាជាអ្នកកំណត់ប្រភេទព្រះអរិយបុគ្គលទាំងនោះ ?*

***ឆ្លើយថា*** = *មានវាទ ផ្សេងៗគ្នា ។*

*ព្រះថេរៈខ្លះ ពោលថា* “ **បុព្វហេតុ និយមេតិ** ”=*បុព្វហេតុរមែងកំណត់យ៉ាងពិតប្រាកដ ។*

*ព្រះថេរៈខ្លះពោលថា* “ **បឋមមគ្គោ និយមេតិ** ”= *មគ្គទីមួយកំណត់យ៉ាងពិតប្រាកដ ។*

*ព្រះថេរៈខ្លះពោលថា* “ **ឧបរិ តយោ មគ្គា និយមេន្តិ** ”= *មគ្គខាងលើ៣ កំណត់យ៉ាងពិតប្រាកដ ។*

ព្រះថេរៈខ្លះពោលថា “ **តិណ្ណំ មគ្គានំ វិបស្សនា និយមេតិ** ” = វិបស្សនានៃមគ្គទាំង ៣ កំណត់យ៉ាងពិតប្រាកដ ។

បណ្ដាវាទៈនៃព្រះថេរៈទាំងនោះ វាទៈថា **បុព្វហេតុ និយមេតិ** រមែងសំដៅសេចក្ដីថា **ឧបនិស្ស័យនៃបឋមមគ្គ**រមែងជាគុណជាតិដែលបុព្វហេតុធ្វើហើយ ដូច្នេះមានតែមគ្គខាងលើ៣ ប្រាសចាកឧបនិស្ស័យកើតឡើង ។

វាទៈថា **បឋមមគ្គោ និយមេតិ** = ដូច្នេះមានតែ មគ្គ៣ទៀត ជាធម្មជាតិគ្មានប្រយោជន៍ ។

វាទៈថា **ឧបរិ តយោ មគ្គា និយមេន្តិ** = ដូច្នេះមានតែ បឋមមគ្គនៅមិនទាន់កើតឡើងផង មគ្គខាងលើ ៣ កើតឡើងហើយ ។

វាទៈថា **តិណ្ណំ មគ្គានំ វិបស្សនា និយមេតិ** =ដែលប្រែថា វិបស្សនានៃមគ្គទាំង៣ កំណត់យ៉ាងពិតប្រាកដ រមែងត្រឹមត្រូវ។បើវិបស្សនានៃមគ្គ៣ មានកម្លាំង ព្រះសោតាបន្នក៏ឈ្មោះថា **ឯកពីជី** ។បើអន់ជាងវិបស្សនារបស់ឯកពីជី ក៏ឈ្មោះថា **កោលំកោលៈ**, បើអន់ជាងវិបស្សនារបស់កោលំកោលៈ នោះ ក៏ឈ្មោះថា **សត្តក្ខត្តុំបរមៈ** ដោយប្រការដូច្នេះ ។

# ព្រះសោតាបន្នក្រៅពី ៣ នេះ

មួយទៀត ព្រះសោតាបន្នអង្គខ្លះមានអធ្យាស្រ័យក្នុងវដ្ដៈ ជាអ្នកត្រេកអរក្នុងវដ្ដៈ រមែងត្រាច់ទៅក្នុងវដ្ដៈជារឿយៗ នោះឯងប្រាកដហើយ ។ **ក៏ជនទាំងនោះ មាន៧** [៤]**ពួក គឺ** ១. អនាថបណ្ឌិកសេដ្ឋី, ២, ឧបាសិកា វិសាខា, ៣.ចូឡរថទេវបុត្រ, ៤.មហារថទេវបុត្រ, ៥.អនេកវណ្ណទេវបុត្រ ,៦.ស្ដេចសក្កទេវរាជ,៧. នាគទត្តទេវបុត្រ ។

ជនទាំងនេះមានអធ្យាស្រ័យក្នុងវដ្ដៈ កើតក្នុងទេវលោក ៦ ជាន់តាំងអំពីដើម ជម្រះចិត្តឱ្យស្អាតក្នុងទេវលោកនោះឯង តាំងនៅក្នុងអកនិដ្ឋភព[5] ទើបបរិនិព្វាន ។**ជនទាំងនោះទ្រង់មិនកាន់យកក្នុងទីនេះឡើយ**, ។

ក៏ជនទាំងនោះព្រះអង្គទ្រង់មិនកាន់យកប៉ុណ្ណោះក៏ទេ ។ សូម្បីព្រះសោតាបន្នអង្គណាកើតក្នុងមនុស្សលោក ត្រាច់ទៅកាន់

---

[៤] ព្រះសោតាបន្នទាំង៧ពួកនេះ មានជាតិលើសពី៧។

[5] នៅក្នុងអដ្ឋកថាសក្កបញ្ហាសូត្រៈ បុគ្គល៧ពួក= អនាថបិណ្ឌិកសេដ្ឋី ,ឧបាសិកាវិសាខា , សក្កទេវរាជ នឹងទៅកើតក្នុងសុទ្ធាវាស៥តាមលំដាប់ ហើយបរិនិព្វានក្នុងជាន់អកនិដ្ឋកភូមិ ។

មនុស្សលោកនោះឯង អស់៧ជាតិហើយសម្រេចអរហត្តបរិនិព្វាន ក្តី (**ស្លាប់ពីមនុស្ស ទៅកើតមនុស្សហើយបរិនិព្វាន**), ព្រះសោតាបន្នអង្គណាកើតក្នុងទេវលោកទាំងឡាយ ត្រាច់ទៅមកៗ ក្នុងទេវលោកនោះឯង អស់៧ជាតិ ហើយសម្រេចអរហត្តក្តី ( **ស្លាប់ពីទេវតា ទៅកើតទេវតា ហើយបរិនិព្វាន**), ក៏ទ្រង់មិនកាន់យកដែរ ។

តែគប្បីជ្រាបថា ក្នុងទីនេះ ព្រះអង្គទ្រង់កាន់យកព្រះសោតាបន្នដែលឈ្មោះថា **សត្តក្ខត្តុំបរមៈ** និង **កោលំកោលៈ** ដោយអំណាចនៃភព ដែលលាយគ្នា ( មនុស្ស និងទេវតា ), និងព្រះសោតាបន្នអ្នកកើតក្នុងភពរបស់មនុស្សប៉ុណ្ណោះ ឈ្មោះថា **ឯកពីជី** ។

## ព្រះសោតាបន្ន ២៤ជំពូក

បណ្តាព្រះសោតាបន្នទាំងនោះ អង្គមួយៗ រមែងដល់ភាវៈ ៤ យ៉ាង ដោយអំណាចនៃទុក្ខាបដិបទាជាដើម ។ ពោលដោយសទ្ធាធុរៈ ព្រះសោតាបន្នមាន១២ ជំពូក គឺ ឈ្មោះថា **សត្តក្ខត្តុំបរមៈ** មាន ៤ជំពូក ឈ្មោះថា **កោលំកោលៈមាន** ៤ជំពូក , ឈ្មោះថា **ឯកពីជី** មាន៤ ជំពូក (៣ x ៤ = ១២) ដោយអំណាចបដិបទា៤ មានទុក្ខាបដិបទា ជាដើម ។

*ពោលដោយបញ្ញាធុរៈ គឺ **សត្តក្ខត្តុំបរមៈ** មាន៤ ជំពូក , **កោលំកោលៈមាន** ៤ ជំពូក , **ឯកពីជី** មាន ៤ ជំពូក (៣ x ៤ = ១២ ) ដោយអំណាចបដិបទា៤ មានទុក្ខាបដិបទា ជាដើម។ ( សទ្ធាធុរៈ ១២ + បញ្ញាធុរៈ ១២ = ២៤ ជំពូក )*

*ព្រោះហេតុដូច្នោះ **ព្រះសោតាបន្ន ២៤ ជំពូក**នេះ បណ្ឌិតគប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់ទុកហើយក្នុងឋាននេះ ដោយអំណាចនៃព្រះអរិយៈ អ្នកចូលទៅសម្លឹងធម៌ដែលតាំងនៅដោយ**សទ្ធា** ឬ**បញ្ញា**ក្នុងទីនេះដោយប្រការដូច្នេះ ។*

## ចប់ឯកពីជីបុគ្គល

## (៤០). សកទាគាមិបុគ្គល

*បុគ្គលខ្លះក្នុងលោកនេះ ជាសកទាគាមិបុគ្គល ព្រោះអស់ទៅនៃសញ្ញោជនៈ ៣ ព្រោះស្រាលស្តើងនៃរាគៈ ទោសៈ មោហៈ មកកាន់លោកនេះ អស់វារៈម្តងទៀត ហើយធ្វើនូវទីបំផុតនៃវដ្តទុក្ខនេះឈ្មោះថា **បុគ្គលជាសកទាគាមី** ។*

*អធិប្បាយ*

បុគ្គលឯណា រមែងមកម្តងទៀត ដោយអំណាចនៃបដិសន្ធិ ព្រោះហេតុនោះ បុគ្គលនោះ ឈ្មោះថា **សកទាគាមី** : អ្នកបដិសន្ធិម្តងទៀត ។

## ព្រះសកទាគាមីមាន ៥ ជំពូក

១. សម្រេចជាព្រះសកទាគាមី នៅក្នុង**មនុស្សលោក** ហើយបរិនិព្វានក្នុង**មនុស្សលោកនេះ**ឯង ។

២.សម្រេចជាព្រះសកទាគាមី នៅក្នុង**ទេវលោក** ហើយបរិនិព្វានក្នុង**ទេវលោក** ។

៣. សម្រេចជាព្រះសកទាគាមីនៅជា**មនុស្សនេះ** ហើយបរិនិព្វានក្នុង**ទេវលោកនោះឯង**។

៤. សម្រេចជាព្រះសកទាគាមី នៅក្នុង**ទេវលោក** ហើយបរិនិព្វានក្នុង**មនុស្សលោកនោះឯង**។

៥. ព្រះសកទាគាមី បានទៅកើតនៅក្នុង**ទេវលោកនោះ** ហើយ ត្រឡប់មកបរិនិព្វានក្នុង**មនុស្សលោកនេះ**វិញ ។

បណ្តាព្រះសកទាគាមី ទាំង៥ជំពូកនោះ ៤ជំពូកខាងដើម ទ្រង់មិនបំណងយកក្នុងទីនេះទេ។តែទ្រង់បំណងយកព្រះសកទាគាមីទី៥ តែមួយប៉ុណ្ណោះក្នុងនិទ្ទេសនេះ ។

**សួរថា:** ព្រះសកទាគាមីនេះ ខុសពីសោតាបន្នឯកពីជី ដូចម្តេច?

**ឆ្លើយថា:** ព្រះសោតាបន្នដែលមានឈ្មោះថា ឯកពីជី លោកមានបដិសន្ធិតែម្តងប៉ុណ្ណោះ, ចំណែកព្រះសកទាគាមី លោកមានបដិសន្ធិ ២ដង សេចក្តីនេះ ជាការធ្វើប្លែកផ្សេងពីគ្នា រវាងព្រះអរិយៈទាំងពីរពួកនេះ ។

## ចប់សកទាគាមិបុគ្គល

## (៤១). អនាគាមិបុគ្គល

បុគ្គលខ្លះក្នុងលោកនេះ ជាឱបបាតិកកំណើត ព្រោះអស់ទៅនៃសញ្ញោជនៈ ជាចំណែកខាងក្រោម ៥ ហើយបរិនិព្វាន ក្នុងសុទ្ធាវាសទេវលោកនោះ មានសភាពមិនត្រឡប់ ចាកលោកនោះវិញ នេះហៅថា បុគ្គលជាអនាគាមី ។

### អធិប្បាយ

*បុគ្គលណាមិនទាន់បានលះបង់គ្រឿងចង គឺ ឱរម្ភាគិយសញ្ញោជនៈ ទាំង៥[១] ទេ បុគ្គលនោះសូម្បីកើតក្នុងភវគ្គភូមិ ក៏ត្រូវតែគ្រឿងចងនោះ ទាញឱ្យធ្លាក់ទៅក្នុងកាមធាតុនោះដដែល ដូចត្រីដែលលេបផ្លែសន្ទូច និងដូចក្អែកដែលគេយកខ្សែវ័ងចងជើងទុក ព្រោះហេតុដូច្នោះ គ្រឿងចងទាំង៥ លោកទើបហៅថា ឱរម្ភាគិយ អធិប្បាយថា ឱរម្ភាគិយនេះជារបស់ខាងក្រោម គឺជាចំណែកខាងក្រោម ។*

*ពាក្យថា "* **ឱបបាតិកោ** *" បានដល់ អ្នកមានកំណើតជាឱបបាតិកៈ ។ សំដៅសេចក្ដីថា ការដេកក្នុងគភ៌របស់ព្រះអនាគាមីនោះ លោកផុតហើយ គឺថា លោកលែងមកកាន់កាមភពនេះដោយអំណាចបដិសន្ធិទៀតហើយ ។ តែថា ការមកដើម្បីជាប្រយោជន៍ មានការបានឃើញព្រះសាស្តា, ព្រះថេរៈ និងស្តាប់ព្រះធម៌ ដែលតាមធម្មតាមិនហាមទុកឡើយ ( អនាវត្តិធម្មោ តស្មាលោកា) ។ គឺលោកនិងបរិព្វានក្នុងសុទ្ធាវាសភូមិនោះ។*

---

[១] **ឱរម្ភាគិយសញ្ញោជនៈ៥**= សក្កាយទិដ្ឋិ, វិចិកិច្ឆា, សីលព្វតុមរាមាសៈ, កាមរាគៈ, បដិឃៈ ។

ពាក្យថា **អយំ វុច្ចតិ** ដោយសេចក្តីថា បុគ្គលមានសភាពបែបនេះ ព្រះអង្គទ្រង់ត្រាស់ថា ជាព្រះអនាគាមី ព្រោះមិនត្រឡប់មកទៀតដោយអំណាចនៃបដិសន្ធិ។

**ចប់អនាគាមិបុគ្គល**

## (៤២). អន្តរាបរិនិព្វាយិបុគ្គល

បុគ្គលខ្លះក្នុងលោកនេះ ជាឱបបាតិកំណើត ព្រោះអស់ទៅនៃសញ្ញោជនៈជាចំណែកខាងក្រោម ៥ ហើយបរិនិព្វាន ក្នុងសុទ្ធាវាស ទេវលោកនោះ មានសភាពមិនត្រឡប់ ចាកលោកនោះវិញ បុគ្គលនោះញុំាងអរិយមគ្គ ឱ្យកើតឡើង ក្នុងប្រមាណនៃអាយុ ដែលកើតក្នុងលំដាប់ ឬ ដែលមិនទាន់ដល់ពាក់កណ្តាល ដើម្បីលះបង់ នូវសញ្ញោជនៈខាងលើ នេះហៅថា **បុគ្គលជាអន្តរាបរិនិព្វាយី** ។

អធិប្បាយ

ពាក្យថា “**ឧប្បន្នំ វា សមនន្តរា**” សេចក្តីថា ជាកាលជាប់តគ្នានិងកាលកើតឡើងខ្លះ ( មានន័យថា កាលបន្ទាប់អំពីបដិសន្ធិមិនយូរប៉ុន្មាន ក៏សម្រេចជាព្រះអរហន្ត ហើយបរិនិព្វានតែម្តង)។

ពាក្យថា “ **អប្បត្តំ វា វេមជ្ឈំ  អាយុប្បមាណំ** ” សេចក្តីថា នៅមិនទាន់ដល់ពាក់កណ្តាលអាយុខ្លះ  អធិប្បាយថា នៅមិនទាន់ដល់ពាក់កណ្តាលអាយុលោករមែងញ៉ាំងអរិយមគ្គឱ្យកើតឡើង (សម្រេចព្រះអរហន្ត)  ហើយបរិនិព្វានទៅ ។

ពាក្យថា  **វេមជ្ឈំ  បត្តំ** : ដល់ពាក់កណ្តាលខ្លះ បណ្ឌិតគប្បីជ្រាបដោយការកំណត់នូវស័ព្ទថា  វា ( មានន័យថា  អង្គខ្លះបានសម្រេចជាព្រះអរហន្តនៅអាយុពាក់កណ្តាលហើយបរិនិព្វាន  ខ្លះ) ។ព្រះអនាគាមីអន្តរាបរិនិព្វាយី  ៣ [៧]  ជំពូកដែលសម្រេចហើយដោយប្រការដូច្នេះ ។

ពាក្យថា  “ **ឧបរិដ្ឋិមានំ សញ្ញោជនានំ** ” បានដល់ឧទ្ធម្ភាគិយសញ្ញោជនៈ ៥ ខាងលើ  ឬបានដល់កិលេស ៨ [៨] ។ បទថា  “ **បហានាយ** ”  ញ៉ាំងមគ្គឱ្យកើតឡើង  ដើម្បីប្រយោជន៍ដល់ការលះសញ្ញោជនៈទាំងនោះ ។

ចប់អន្តរាបរិនិព្វាយិបុគ្គល

---

[៧] បានសម្រេចជាជាព្រះអរហន្តបន្ទាប់ពីបដិសន្ធិហើយ , អាយុមិនទាន់ដល់ពាក់កណ្តាលក៏សម្រេចជាព្រះអរហន្ត, អាយុដល់ពាក់កណ្តាលក៏សម្រេចជាព្រះអរហន្ត។

[៨] លោភៈ,មោហៈ,មានៈ,ថីនៈ,ឧទ្ធច្ចៈ,អហិរិក,អនោត្តប្ប

# (៤៣). ឧបហច្ចបរិនិព្វាយី

បុគ្គលខ្លះក្នុងលោកនេះ ជាឱបបាតិកកំណើត ព្រោះអស់ទៅនៃសញ្ញោជនៈជាចំណែកខាងក្រោម៥ ហើយជាអ្នកបរិនិព្វានក្នុងសុទ្ធាវាសព្រហ្មលោកនោះ មានសភាពមិនត្រឡប់ចាកពីលោកនោះមកវិញ បុគ្គលនោះញ៉ាំងអរិយមគ្គឱ្យកើតឡើង ដើម្បីលះបង់នូវសញ្ញោជនៈខាងលើ ក្នុងកាលកន្លងពីពាក់កណ្ដាលអាយុជាប្រមាណខ្លះ នៅពេលជិតនឹងធ្វើកាលកិរិយាខ្លះ នេះហៅថា **បុគ្គលជាឧបហច្ចបរិនិព្វាយី** ។

## អធិប្បាយ

ពាក្យថា “ **ឧបហច្ចបរិនិព្វាយី** ” ព្រោះឈានកន្លងហួសពាក់កណ្ដាល៥០០មហាកប្បនៃអាយុ (សម្រេចអរហត្ត ហើយបរិនិព្វាន) ។

ពាក្យថា “ **ឧបហច្ច វា កាលកិរិយំ** ” ជិតនឹងធ្វើកាលកិរិយា អធិប្បាយថា ជិតកាលនឹងអស់អាយុ ( សម្រេចអរហត្ត ហើយបរិព្វាន ) ។

ពាក្យថា **អយំ វុច្ចតិ** សេចក្តីថា បុគ្គលទាំងនេះហៅថា ឧបហច្ចបរិនិព្វាយី ព្រោះឈានកន្លងហួសពាក់កណ្តាល ៥០០ មហាកប្បនៃអាយុ ១០០០ មហាកប្ប ជាប្រមាណក្នុងអវិហាភូមិទាំងឡាយមុន ហើយទើបតាំងនៅក្នុងកប្បទី ៦០០ មហាកប្ប ឬ ៧០០មហាកប្ប ឬ៨០០ មហាកប្ប ឬ៩០០ មហាកប្ប ឬ១០០០ មហាកប្ប យ៉ាងណាមួយមែនពិត ហើយទើបសម្រេចព្រះអរហត្តបរិនិព្វានដោយកិលេសបរិនិព្វាន ។៚

ចប់ឧបហច្ចបរិនិព្វាយិបុគ្គល

## (៤៤). អសង្ខារបរិនិព្វាយី

បុគ្គលខ្លះក្នុងលោកនេះ ជាឱបបាតិកកំណើត ព្រោះអស់ទៅនៃសញ្ញោជនៈជាចំណែកខាងក្រោម៥ ហើយជាអ្នកបរិនិព្វានក្នុងសុទ្ធាវាសព្រហ្មលោកនោះ មានសភាពមិនត្រឡប់ចាកពីលោកនោះមកវិញឡើយ បុគ្គលនោះញ៉ាំងអរិយមគ្គឱ្យកើតឡើងដោយអសង្ខារគឺដោយព្យាយាមបន្តិចបន្តួចប៉ុណ្ណោះ ដើម្បីលះបង់សញ្ញោជនៈខាងលើ នេះហៅថា **បុគ្គលជាអសង្ខារបរិនិព្វាយី** ។

# (៤៥). សសង្ខារបរិនិព្វាយី

បុគ្គលខ្លះក្នុងលោកនេះ ជាឱបបាតិកកំណើត ព្រោះអស់ទៅនៃសញ្ញោជនៈជាចំណែកខាងក្រោម៥ ហើយជាអ្នកបរិ-និព្វានក្នុងសុទ្ធាវាសព្រហ្មលោកនោះ មានសភាពមិនត្រឡប់ចាកពីលោកនោះមកវិញឡើយបុគ្គនោះញុំាងអរិយមគ្គឱ្យកើតឡើងដោយសសង្ខារ គឺដោយព្យាយាមខ្លាំងក្លា ដើម្បីលះបង់សញ្ញោ-ជនៈខាងលើ នេះហៅថា **បុគ្គលជាសសង្ខារបរិនិព្វាយី ។**

អធិប្បាយ

(អសង្ខារបរិនិព្វាយី និង សសង្ខារបរិនិព្វាយី)

**អសង្ខារបរិនិព្វាយី** = ព្រះអនាគាមីឯណា មិនធ្វើសេចក្តីព្យាយាមខ្លាំងក្លា ដោយមិនប្រញាប់ប្រញាល់ពេក មានទុក្ខតិចសម្រេចអរហត្ត ហើយបរិនិព្វាន ដោយកិលេសបរិនិព្វានតាមធម្ម-តា ព្រោះហេតុដូច្នោះ ទើបលោកឈ្មោះថា អសង្ខារបរិនិព្វាយី = អ្នកបរិនិព្វានតាមធម្មតា ដោយមិនធ្វើសេចក្តីព្យាយាមខ្លាំងក្លាទេ ។

**សសង្ខារបរិនិព្វាយី** = ព្រះអនាគាមីណា ធ្វើសេចក្តីព្យាយាមយ៉ាងខ្លាំងក្លា ដោយប្រញាប់ប្រញាល់បន្ទាន់ មិនយឺតយូរ មាន

សេចក្តីទុក្ខលំបាក សម្រេចអរហត្ត ហើយបរិនិព្វាន ដោយកិលេសបរិនិព្វានតាមធម្មតា ព្រោះហេតុដូច្នោះ ទើបលោកឈ្មោះថា សសង្ខារបរិនិព្វាយី = អ្នកបរិនិព្វានតាមធម្មតា ដោយការធ្វើសេចក្តីព្យាយាមយ៉ាងខ្លាំងក្លា ៕

ចប់អសង្ខារបរិនិព្វាយិបុគ្គល និង សសង្ខារបរិនិព្វាយិបុគ្គល

## (៤៦). ឧទ្ធំសោតោអកនិដ្ឋគាមិបុគ្គល

បុគ្គលខ្លះក្នុងលោកនេះ ជាឱបបាតិកកំណើត ព្រោះអស់ទៅនៃសញ្ញោជនៈជាចំណែកខាងក្រោម៥ ហើយជាអ្នកបរិនិព្វានក្នុងសុទ្ធាវាសព្រហ្មលោកនោះ មានសភាពមិនត្រឡប់ចាកពីលោកនោះមកវិញឡើយ បុគ្គលនោះច្យុតចាក**អវិហា** ទៅកាន់**អតប្បា** , ច្យុតចាកអតប្បា ទៅកាន់**សុទស្សា** , ច្យុតចាកសុទស្សា ទៅកាន់**សុទស្សី** , ច្យុតចាកសុទស្សី ទៅកាន់**អកនិដ្ឋភូមិ** ហើយញុំាងអរិយមគ្គ ឱ្យកើតឡើងក្នុងអកនិដ្ឋភូមិ ដើម្បីលះបង់សញ្ញោជនៈខាងលើ នេះហៅថា **បុគ្គលជា ឧទ្ធំសោតោអកនិដ្ឋគាមី** ។

អធិប្បាយ

## ក្រាសែមាន ២យ៉ាង

១. **ឧទ្ធំសោតោ** = ក្រសែ គឺ តណ្ហា ឬក្រសែ គឺវដ្ដៈ របស់ព្រះអនាគាមីមាននៅខាងលើ ព្រោះជាធម្មជាតនាំទៅខាងលើ ។

២. **មគ្គសោតោ** = ក្រសែ គឺមគ្គរបស់ព្រះអនាគាមីនោះមាននៅខាងលើ ព្រោះលោកទៅកាន់ភពខាងលើហើយទើបបាន ព្រោះហេតុដូច្នោះ ទើបលោកឈ្មោះថា ឧទ្ធំសោតោ = អ្នកមានក្រសែ គឺមគ្គខាងលើ ។

វិនិច្ឆ័យក្នុងពាក្យថា **អវិហា ចុតោ អតប្បំ គច្ឆតិ** = ព្រះអនាគាមីកាលនៅ **អវិហា** ដែលមានអាយុ១០០០មហាកប្ប មិនអាចសម្រេចអរហត្ត កាលអស់អាយុក៏បានទៅកើតក្នុង **អតប្បា , សុទស្សា ,សុទស្សី**[9] តាមលំដាប់ នៅរហូតដល់អស់អាយុ ក៏មិនអាចសម្រេចព្រះអរហត្តបាន ទើបទៅកើត **អកនិដ្ឋភូមិ**[10] **បានញ៉ាំងអរហត្តមគ្គឱ្យកើតឡើង** ក្នុងទីនោះ ។

## ឧទ្ធំសោតអកានិដ្ឋគាមី ៤ ពួក

[9] អតប្បា=មានអាយុ២០០០មហាកប្ប, សុទស្សា=មានអាយុ៤០០០មហាកប្ប,សុទស្សី=មានអាយុ៨០០០មហាកប្ប។

[10] អកនិដ្ឋភូមិ=មានអាយុ១៦០០០មហាកប្ប

**១. ឧទ្ធំសោតោអកនិដ្ឋគាមី =** *ព្រះអនាគាមីជម្រះព្រហ្មលោក*[11] *ទាំង ៤ ឱ្យស្អាត ចាប់ផ្តើមពីអវិហាភូមិ និងទៅកាន់អកនិដ្ឋភូមិ ទើបបរិនិព្វាន ។*

**២. ឧទ្ធំសោតោ ន អកនិដ្ឋគាមី =** *ព្រះអនាគាមីជម្រះព្រហ្មលោក ទាំង៣ ខាងក្រោមឱ្យស្អាតហើយតាំងនៅសុទស្សីទេវលោក ទើប បរិនិព្វាន ឈ្មោះថា* ឧទ្ធំសោតោ ន អកនិដ្ឋគាមី : *អ្នកមានក្រសែខាង លើ តែមិនទៅកាន់អកនិដ្ឋភូមិ ។*

**៣. ន ឧទ្ធំសោតោអកនិដ្ឋគាមី =** *នរណាទៅកាន់អកនិដ្ឋភូមិតែ ម្តង ហើយបរិនិព្វាន អង្គនោះឈ្មោះថា* ន ឧទ្ធំសោតោអកនិដ្ឋគាមី : *អ្នកមិនមានក្រសែខាងលើទេ តែទៅកាន់អកនិដ្ឋភូមិ ។*

**៤. ន ឧទ្ធំសោតោ ន អកនិដ្ឋគាមី =** *ព្រះអនាគាមីដែលតាំង នៅក្នុងព្រហ្មលោក ៤ ខាងក្រោម រមែងបរិនិព្វានក្នុងទីនោះៗ*[១២] *ឈ្មោះថា* ន ឧទ្ធំសោតោ ន អកនិដ្ឋគាមី : *អ្នកមិនមានក្រសែខាងលើ និងមិនទៅកាន់អកនិដ្ឋភូមិ ។*

## ព្រះអនាគាមីទាំងអស់ មាន ៤៨ ជំពូក

---

[11] *ពាក្យថា ទេវលោកក្នុងទីនេះ គឺបានដល់ ព្រហ្មសុទ្ធាវាសនោះឯង។*

[១២] កើតក្នុងទីណា បរិនិព្វានក្នុងទីនោះ ។

**អវិហាភូមិ** = ព្រះអនាគាមីជាអន្តរាបរិនិព្វាយី ៣ ជំពូក , ជាឧបហច្ចបរិនិព្វាយី ១ ជំពូក , ជាឧទ្ធំសោតោ ១ ជំពូក= សរុបទៅជា ៥ ក្នុង៥នេះត្រូវគុណនិង២ គឺ =អសង្ខារបរិនិព្វាយី ៥ , និងសសង្ខារបរិនិព្វាយី ៥ = ទៅជា ១០ ។ដូច្នេះ ព្រះអនាគាមីនៅក្នុងអវិហាភូមិ មាន ១០ ជំពូកយ៉ាងនេះឯង ។

សូម្បីអតប្បា ១០ ជំពូក , សុទស្សា ១០ ជំពូក , និងសុទស្សី ១០ ជំពូក (ដូចដែលបានពោលខាងដើមហើយ) = ដូច្នេះ **សរុបព្រះអនាគាមីទាំង៤ភូមិ ជា ៤០ ជំពូក** ។ តែព្រះអនាគាមីដែលឈ្មោះថា **ឧទ្ធំសោតោ** មិនមានក្នុងជាន់អកនិដ្ឋភូមិទេ , មានតែព្រះអនាគាមីដែលឈ្មោះថា **អន្តរាបរិនិព្វាយី ៣ ជំពូកប៉ុណ្ណោះ** ។

**អកនិដ្ឋភូមិ** = ឧបហច្ចបរិនិព្វាយី ១ ជំពូក , អន្តរាបរិនិព្វាយី ៣ =ទៅជា៤, ក្នុង៤នោះត្រូវគុណនិង២ គឺ អសង្ខារបរិនិព្វាយី ៤ និងសសង្ខារបរិនិព្វាយី៤ =ត្រូវជា ៨

ដូច្នេះសរុបទាំងន័យខាងដើម ៤០ជំពូក និង ន័យនេះ៨ ត្រូវជា ៤៨យ៉ាងនេះឯង ។

## សេចក្តីប្រៀបធៀបនិងព្រះអនាគាមី

**អន្តរាបរិនិព្វាយី ពួកទី១** = ដូចយ៉ាងដាងដែកវាយនូវចុងដែក ដែលក្តៅរហូតដល់ថ្ងៃ(ដែកតូចៗ) ត្រង់ដុំដែក ផ្កាភ្លើងកើតឡើង ហើយ ក៏រលត់ទៅ យ៉ាងណា, ព្រះអនាគាមីដែលមានសភាពបែប នេះ បណ្ឌិតគប្បីជ្រាបថា **អន្តរាបរិនិព្វាយី** ។

សួរថា: ព្រោះហេតុអ្វី?

ឆ្លើយថា :ព្រោះកិលេសរលត់ទៅមិនមានសល់ ក្នុងលំដាប់ ដែលកើតឡើងនោះឯង ។

**អន្តរាបរិនិព្វាយី ពួកទី២** = ដូចជាផ្កាភ្លើងធំ ដែលបាញ់ចេញទៅ កាន់អាកាស ហើយទើបរលត់ យ៉ាងណា , ព្រះអនាគាមីដែលមាន សភាពបែបនេះ បណ្ឌិតគប្បីជ្រាបថា **អន្តរាបរិនិព្វាយី** ។

សួរថា: ព្រោះហេតុអ្វី?

ឆ្លើយថា: ព្រោះលោកមានព្រះជន្មាយុ មិនទាន់បានដល់ ពាក់កណ្តាល ក៏បរិនិព្វាន ។

**អន្តរាបរិនិព្វាយី ពួកទី៣** = ផ្កាភ្លើងធំនោះ( សំដៅដល់ធំឡើងៗ ទៅជាលំដាប់ ) បាញ់ទៅកាន់អាកាស ហើយធ្លាក់មកលើផែនដី វិញតែមិនខ្ទប់ផែនដីទេ ក៏រលត់ទៅ យ៉ាងណា , ព្រះអនាគាមី

ដែលមានសភាពបែបនេះ  បណ្ឌិតគប្បីជ្រាបថា  ឈ្មោះថា **អន្តរាបរិនិព្វាយី** ។

សួរថាៈ  ព្រោះហេតុអ្វី ?

ឆ្លើយថាៈ ព្រោះដល់ពាក់កណ្ដាលនៃអាយុ  នៅឆ្ងាយពីការធ្វើកាលកិរិយា ហើយក៏បរិនិព្វានទៅ ។

**ឧបហច្ចបរិនិព្វាយី** = ដូចន័យទី៣ដែរ  តែផ្កាភ្លើង( ធំជាងមុន) ខ្ទប់នឹងផែនដីភ្លាម ក៏រលត់ទៅ យ៉ាងណា , ព្រះអនាគាមីដែលមានសភាពបែបនេះ  បណ្ឌិតគប្បីជ្រាបថា  **ឧបហច្ចបរិនិព្វាយី** ។

សួរថាៈ  ព្រោះហេតុអ្វី ?

ឆ្លើយថាៈព្រោះចូលជិតការធ្វើកាលកិរិយាហើយ បានញុំាងសេចក្ដីប្រព្រឹត្តទៅនៃអាយុឱ្យអស់ទៅ  ហើយទើបបរិនិព្វាន ។

**អសង្ខារបរិនិព្វាយី** =ដូចន័យទី៣ដែរ  ក្រមរផ្កាភ្លើងសាចធ្លាក់ទៅត្រង់ស្មៅ ឬត្រង់ឈើដែលមានចំនួនបន្តិចបន្តួច ហើយក៏រលត់ទៅ យ៉ាងណា , ព្រះអនាគាមីដែលមានសភាពបែបនេះ  បណ្ឌិតគប្បីជ្រាបថា  **អសង្ខារបរិនិព្វាយី** ។

សួរថាៈ ព្រោះហេតុអ្វី ?

ឆ្លើយថាៈ ព្រោះបរិនិព្វានដោយការប្រកបសេចក្តីព្យាយាម មានប្រមាណបន្តិចបន្តួច គឺដោយដំណើរការយ៉ាងសប្បាយ ។

**សសង្ខារបរិនិព្វាយី** = ដូចន័យទី៣ដែរ តែក្រមរផ្កាភ្លើងក៏ធ្លាក់ទៅត្រង់ចំគំនរឈើ ឬគំនរស្មៅធំ ហើយក៏ឆេះគំនរនោះអស់ទៅ ទើបរលត់ យ៉ាងណា , ព្រះអនាគាមីដែលមានសភាពបែបនេះ បណ្ឌិតគប្បីជ្រាបថា **សសង្ខារបរិនិព្វាយី** ។

សួរថាៈ ព្រោះហេតុអ្វី ?

ឆ្លើយថាៈ ព្រោះបរិនិព្វានដោយ ការធ្វើសេចក្តីព្យាយាមយ៉ាងខ្លាំងក្លា គឺដំណើរការទៅយ៉ាងម៉ឺងម៉ាត់ ។

**ឧទ្ធំសោតោអកនិដ្ឋគាមី** = ក្រមរផ្កាភ្លើងដទៃទៀតធ្លាក់លើគំនរស្មៅ ឬគំនរឈើដែលធំនោះ លុះកាលឆេះអស់ហើយ ផ្សែងដែលប្រាស់ចាកអណ្តាតភ្លើង ក៏កើតឡើង ហើយដុតឆេះរោងរបស់នាយជាងដែក រួចក៏រាលដាលទៅឆេះភូមិ ស្រុក ក្រុង និងដែន ដល់ច្រាំងសមុទ្រទើបរលត់ទៅ យ៉ាងណា , ព្រះអនាគាមីបែបនេះ គប្បីជ្រាបថា ឈ្មោះថា ឧទ្ធំសោតោអកនិដ្ឋគាមី ។

សួរថាៈ ព្រោះហេតុអ្វី ?

ឆ្លើយថាៈ ព្រោះលោកធ្វើការពង្រីកពូជ ក្នុងភពជាអនេក ហើយធ្វើឱ្យអស់រលីងដោយពន្លុះធម៌ដែលត្រឹមត្រូវទើបបរិនិព្វាន ។ ក៏ដុំដែកនោះឯង មានតូចខ្លះ ធំខ្លះ ដែលផ្សេងដោយចុងដែកស្រួចជាដើម ព្រោះហេតុនោះ ទើបលោកពោលទុកក្នុងព្រះសូត្រត្រង់វារៈទាំងអស់ថា “អយោកបល្លំ = ដុំដែក” ដូច្នេះ ។

**ចប់ឧទ្ធំសោតោអកនិដ្ឋគាមី**

## (៤៧). សោតាបន្នបុគ្គល

បុគ្គលប្រតិបត្តិដើម្បីលះបង់សញ្ញោជនៈ ៣ ប្រតិបត្តិដើម្បីធ្វើឱ្យជាក់ច្បាស់នូវសោតាបត្តិផល បុគ្គលដែលលះសញ្ញោជនៈ ៣នេះបានហើយ ហៅថា **បុគ្គលជាសោតាបន្នៈ** ។

## (៤៨). សកទាគាមិបុគ្គល

បុគ្គលប្រតិបត្តិដើម្បីធ្វើឱ្យស្រាលស្តើងកាមរាគៈ និងព្យាបាទ ប្រតិបត្តិដើម្បីធ្វើឱ្យជាក់ច្បាស់នូវសកទាគាមិផល បុគ្គលណាដែលមានកាមរាគៈនិងព្យាបាទស្រាលស្តើង នេះហៅថាបុគ្គលជាសកទាគាមី ។

## (៤៩). អនាគាមិបុគ្គល

បុគ្គលប្រតិបត្តិដើម្បីលះបង់កាមរាគៈ និងព្យាបាទ មិនឱ្យសេសសល់ ប្រតិបត្តិដើម្បីធ្វើឱ្យជាក់ច្បាស់នូវអនាគាមិផល បុគ្គលណាដែលលះបង់កាមរាគៈ និងព្យាបាទមិនឱ្យសេសសល់ នេះហៅថា បុគ្គលជាអនាគាមី ។

## (៩០). អរហាន្តបុគ្គល

*បុគ្គលប្រតិបត្តិដើម្បីលះបង់រូបរាគៈ អរូបរាគៈ មានៈ ឧទ្ធច្ចៈ និងអវិជ្ជា មិនឱ្យសេសសល់ ប្រតិបត្តិ ដើម្បីធ្វើឱ្យជាក់ច្បាស់នូវអរហត្តផល បុគ្គលណាដែលលះបង់ រូបរាគ អរូបរាគ មានៈ ឧទ្ធច្ច និងអវិជ្ជា មិនឱ្យសេសសល់ នេះហៅថា បុគ្គលជាព្រះអរហត្ត ។*

### អធិប្បាយ

*និទ្ទេសនៃព្រះអរិយបុគ្គល អ្នកបដិបត្តិដើម្បីធ្វើឱ្យជាក់ច្បាស់នូវសោតាបត្តិផលជាដើមមានសេចក្ដីងាយយល់ហើយ។*

*ពាក្យថា* “**អយំ វុច្ចតិ**” *សេចក្ដីថា បុគ្គលនេះ គឺអ្នកបែបនេះ លោកហៅថា ព្រះអរហន្ត ។ ក៏ពាក្យថា* ***ព្រះអរហន្ត*** *ក្នុងទីនេះ គប្បីជ្រាបថា មាន១២ ជំពូក ។*

## ព្រះអរហន្តមាន ១២ ជំពូក

*វិមោក្ខមាន ៣ យ៉ាង គឺ* **សុញ្ញតវិមោក្ខ ១, អនិមិត្តវិមោក្ខ ១, អប្បណិហិតវិមោក្ខ ១ ។**

**សុញ្ញតវិមោក្ខ មាន៤** = *ព្រះខីណាស្រព អ្នករួចផុតដោយសុញ្ញតវិមោក្ខ មាន៤ជំពូក ដោយអំណាចនៃបដិបទា ៤*[13] *យ៉ាង (ឈ្មោះថា* ***សុញ្ញតវិមោក្ខ*** *ព្រោះអ្នករួចផុតដោយការចម្រើន* ***អនត្តានុបស្សនា*** *គឺអ្នកពិចារណាបញ្ចក្ខន្ធដោយភាពជាទុក្ខ) ។*

**អនិមិត្តវិមោក្ខ មាន៤** = *ព្រះខីណាស្រព អ្នករួចផុតដោយ* ***អនិមិត្តវិមោក្ខ*** *មាន៤ ដោយអំណាចនៃបដិបទា ៤ យ៉ាង (ឈ្មោះថា* ***អនិមិត្តវិមោក្ខ*** *ព្រោះអ្នករួចផុតដោយការចម្រើន* ***អនិច្ចានុបស្សនា*** *។*

**អប្បណិហិតវិមោក្ខ មាន៤** = *ព្រះខីណាស្រព អ្នករួចផុតដោយ* ***អប្បណិហិតវិមោក្ខ*** *មាន៤ ដោយអំណាចនៃបដិបទា៤ យ៉ាង។ (ឈ្មោះថា* ***អប្បណិហិតវិមោក្ខ*** *ព្រោះអ្នករួចផុតដោយការចម្រើន* ***ទុក្ខានុបស្សនា*** *។*

---

[13] *បដិបទា៤យ៉ាង ៖* ***ទុក្ខា បដិបទា ទន្ធាភិញ្ញា*** *: បដិបទាជា ទុក្ខហើយត្រាស់ដឹងយឺតយូរ,* ***ទុក្ខាបដិបទា ខិប្បាភិញ្ញា*** *: បដិបទាជាទុក្ខ ត្រាស់ដឹងរហ័ស,* ***សុខាបដិបទា ទន្ធាភិញ្ញា*** *: បដិបទាជាសុខ ត្រាស់ដឹងយឺតយូរ,* ***សុខាបដិបទា ខិប្បាភិញ្ញា*** *: បដិបទាជាសុខ ត្រាស់ដឹងរហ័ស។បិ១៩ទំ១៦៣*

*ព្រោះហេតុដូច្នោះ បណ្ឌិតគប្បីជ្រាបថា* **ព្រះអរហន្តមាន ១២ ជំពូក** *ដោយប្រការដូច្នេះ ។*

**សូម្បីព្រះសកទាគាមីមាន១២ ជំពូក***ដូចគ្នានិងព្រះអរហន្តដែរ ។*

**ព្រះសោតាបន្ន មាន ២៤ ជំពូក** *គឺព្រះសោតាបន្ន ១២ ជំពូក គុណដោយធុរៈ ២ គឺ សទ្ធាធុរៈ និងបញ្ញាធុរៈ ។*

*ព្រះអនាគាមី មាន៤៨ ចំពូក ទាំងអស់នេះ កាលលោកផុតចាកលោកនេះហើយ រមែងមិនកើតក្នុងលទ្ធិខាងក្រៅ ព្រះពុទ្ធសាសនាឡើយ, រមែងកើតឡើងតែក្នុងសាសនានៃព្រះសព្វញ្ញូពុទ្ធជាម្ចាស់នេះប៉ុណ្ណោះ ។*

*ចប់បុគ្គលពួក ១ ត្រឹមតែប៉ុណ្ណេះ*

# ទុកនិទ្ទេស

**(បុគ្គល ពួក ២)**

## (១). បុគ្គលចូលចិត្តក្រោធជាដើម

១, **កោធនោ** = *បុគ្គលច្រើនទៅដោយសេចក្តីក្រោធ*

២, **ឧបនាហី** = *បុគ្គលចងសេចក្តីក្រោធទុក ។*

***អធិប្បាយ***

**កោធនោ =** *ទោសៈកាលកើតឡើងរមែងប្រទូស្តខ្លួនផងនិង ប្រទូស្តអ្នកទៃផង , តែនឹងប្រទូស្តអ្នកដទៃ ឬមិនប្រទូស្តក៏ដោយ កាលកើតឡើងក្នុងសន្តានរបស់បុគ្គលណា ក៏រមែងប្រទូស្តនឹងខ្លួនឯងដោយពិត ដោយហោចទៅសូម្បីត្រឹមតែធ្វើរូបគឺពណ៌សម្បុរផ្ទៃមុខគួរឱ្យស្អប់ ដូចជារបស់ស្មោកគ្រោក មានលាមកជាដើម ដែលបុគ្គលចាប់កាន់ដើម្បីចោលទៅលើអ្នកដទៃឱ្យប្រឡាក់ ទោះបីចោលត្រូវអ្នកដទៃក្តី ឬមិនត្រូវក្តី ក៏កាលខ្លួនជាអ្នកចាប់កាន់ គឺថាខ្លួននុ៎ះឯងជាអ្នកប្រឡាក់ដោយរបស់ស្មោកគ្រោកនោះដូច្នោះ ។* ***កោធៈ*** *មានលក្ខណៈ គឺការក្តៅក្រហាយ ឬ ការប្រទូសរ៉ាយ មានកិច្ច គឺចងអាឃាត ( ហើយ ) ផលដែលប្រាកដចេញមក គឺ ការប្រទូសរ៉ាយ។)*

**ឧបនាហី =** *បុគ្គលណាកាលចងសេចក្តីក្រោធទុក ក្នុងកាលមុនខាងក្រោយមកសេចក្តីក្រោធកើតឡើងម្តងទៀត ឈ្មោះថា ឧបនាហៈ ការចងសេចក្តីក្រោធ ។ ការមិនសម្តែងសេចក្តីប្លែកផ្សេងគ្នារវាង នៃសេចក្តីក្រោធខាងក្រោយ* (ឧបនាហី) *និងសេចក្តីក្រោធដែលកើតមុន*(*កោធនោ*) *ហើយធ្វើទុកដោយភាពជាមួយគ្នា ឈ្មោះថា សន្សំសេចក្តីក្រោធទុក។* ***ឧបនាហៈ*** *មានលក្ខណៈ គឺ ការ*

ចង់សេចក្ដីក្រោធ មាននាទី មិនព្រមលោសបោលពីការចង់ពៀរ (ហើយ ) ផលដែលប្រាកដ ចេញមក គឺក្រោធជាប់តគ្នារឿយៗ សមដូចពាក្យបុរាណាចារ្យពោល ទុកយ៉ាងនេះថា ក្រោធកើតមុន ឧបនាហទើបកើតជាខាងក្រោយជាដើម ។

ចប់បុគ្គលចូលចិត្តក្រោធជាដើម

## (២). បុគ្គលលុបគុណគេជាដើម

**១. មក្ខី** = បុគ្គលអ្នកលុបគុណគេ ។

**២. បលាសី =** បុគ្គលអ្នកប្រណាំងវាសនា។

អធិប្បាយ

**មក្ខី**=ការមើលងាយគុណគេ (បំបាត់គុណគេ) ដោយអំណាចនៃភាវៈជារបស់ប្រឡាក់ គឺថា បុគ្គលសូម្បីប្រព្រឹត្តទៅដោយអំណាចនៃការមើលងាយគុណរបស់អ្នកដទៃនោះ រមែងប្រឡាក់ទោសនោះមុន ដូចលាមកដែលជារបស់ខ្លួនឯង រមែងប្រឡាក់ខ្លួនឯងមុន ។ ភាវៈនៃបុគ្គលអ្នករឹងចចេសគ្រោតគ្រាត ឈ្មោះថាសភាពដែលមើលងាយ ។ **អធិប្បាយថា** : សូម្បីគុណមានប្រមាណតិច រមែងមើលមិនឃើញ ព្រោះអាស្រ័យការមើលងាយ មើល

ថោក ព្រោះហេតុដូច្នោះ ទើបសភាវៈនោះ ឈ្មោះថា ធ្វើសេចក្តីលុបបំបាត់គុណ(មើលងាយ)។ ពិតមែន ជា**គ្រហស្ថ**ក៏ដោយ ជា**ភិក្ខុ**ក៏ដោយ កាលអាស្រ័យនូវសេចក្តីក្រោធហើយ ដោយហេតុមានត្រឹមតែប្រមាណតិចប៉ុណ្ណោះ រមែងមើលងាយគុណ គឺភាវៈនៃបុគ្គលនោះ អាស្រ័យអ្នកដទៃរមែងមិនមានដល់គេ ព្រោះហេតុនៃសេចក្តីក្រោធ, ព្រោះហេតុដូច្នោះ ទើបឈ្មោះថា ជាការធ្វើនូវភាពជាអ្នកមើលងាយ និងហាក់ដូចជាជាន់ញាំញីសេចក្តីល្អរបស់អ្នកដទៃទុកដោយជើង។ ការធ្វើរបស់អ្នកនោះ ព្រះមានព្រះភាគជាម្ចាស់ ត្រាស់ហៅថា **មក្ខៈ**(សេចក្តីលុបគុណ) ។ ក៏កាលពោលដោយលក្ខណៈ **មក្ខៈ**នេះមានការលុបគុណរបស់អ្នកដទៃជាលក្ខណៈ, មានការញុាំងគុណរបស់អ្នកដទៃឱ្យវិនាសទៅជាកិច្ច , មានការកាត់រំលាយកិរិយាអាការដែលបុគ្គលដទៃធ្វើល្អហើយជាបច្ចុប្បដ្ឋាន (ជាផល)។

**បលាសី=**បុគ្គលណារមែងវាយឫកស្មើនឹងគេ ព្រោះហេតុនោះបុគ្គលនោះទើបឈ្មោះថា បលាសៈ (វាយឫកស្មើ) , អធិប្បាយថាសម្តែងគុណរបស់អ្នកដទៃរមែងធ្វើគុណទាំងឡាយស្រដៀងនឹងគុណធមិរបស់ខ្លួន (ប្រៀបធៀបគុណគ្នា) ,ផ្លូវរបស់បុគ្គលអ្នកវាយ

ឬកស្មើនឹងអ្នកដទៃ ឈ្មោះថា **បលាសាយ** ។ ពិតមែនបុគ្គលអ្នកវាយឫកស្មើរមែងមិនឲ្យធុរៈការងារដល់បុគ្គលទីពីរ រមែងញុំាងគុណរបស់ខ្លួនឱ្យរីកចេញទៅស្មើៗ គឺថា ព្រះសូត្រទាំងឡាយ ឬការកៈទាំងឡាយចំនួនច្រើន ដែលភិក្ខុដទៃសូម្បីនាំមកហើយ ក្នុងពេងសន្ទនាធម៌ និងពោលពង្រីកសេចក្ដីចេញទៅ នូវគុណរបស់ខ្លួនឲ្យស្មើៗនឹងអ្នកដទៃថា "ក្នុងវាទៈរបស់លោក និងវាទៈរបស់យើងហេតុដែលប្លែកផ្សេងគ្នា ឈ្មោះថាមានឬ?, ពាក្យរបស់ពួកយើងក៏ដូចជាមួយនឹងលោកនោះឯង ប្រៀបដូចមាសដែលបុគ្គលបំបែកចេញហើយក៏ជាមាសនោះឯងមិនមែនឬ?" ។ **បឡាសៈ** មានលក្ខ-ណៈ គឺ ការចាប់យកជាគូប្រណាំងប្រជែង ( ការវ៉ៃឫក) មាននាទី ការធ្វើគុណរបស់ខ្លួនឲ្យស្មើនឹងគុណ របស់អ្នកដទៃហើយ ផលដែលប្រាកដចេញមក គឺ ការប្រាកដដោយការពេញចិត្តប្រមាណ (វ៉ៃតម្លៃ) ប្រៀបគុណរបស់អ្នកដទៃ ។

ចប់បុគ្គលលុបគុណគេជាដើម

## (៣). បុគ្គលមានសេចក្តីប្រណែនជាដើម

**ឥស្សុកី =** បុគ្គលមានសេចក្តីប្រណែនក្នុងលាភ សក្ការៈ។

**មច្ឆរី =** បុគ្គលមានសេចក្តីកំណាញ់។

អធិប្បាយ

***ឥស្សុកី*** = ការប្រណែនក្នុង***លាភសក្ការៈ*** ការធ្វើសេចក្តី***គោរពរាប់អាន សំពះ*** និងការ***បូជា*** របស់បុគ្គលដទៃជាដើម យ៉ាងណា ឥស្សាឯណាដែលមានក្នុងខណៈខឹងក្រោធ ចងគំនុំក្នុងសម្បត្តិរបស់អ្នកដទៃ ក្នុងវត្ថុទាំងឡាយមានលាភជាដើមរបស់ពួកជនដទៃនោះ ថា "លាភជាដើមទាំងឡាយនោះនឹងមានប្រយោជន៍អ្វីដល់បុគ្គលនេះ"។

**លាភោ =** ***លាភ*** បានដល់ ការបានចំពោះនូវបច្ច័យ ៤ មានចីវរជាដើម "ដ្បិតថា បុគ្គលអ្នកមានឥស្សា រមែងខឹងចងគំនុំចំពោះលាភរបស់បុគ្គលដទៃនោះ មិនប្រាថ្នាថា "ប្រយោជន៍អ្វីដោយលាភដល់បុគ្គលនេះ"។

**សក្ការោ =** ***សក្ការៈ*** ការបានបច្ច័យ៤នោះឯង ដែលល្អ ដែលបុគ្គលធ្វើល្អហើយ ។

**គរុការោ =** ***ការធ្វើសេចក្តីគោរពរាប់អាន*** *បានដល់ ការធ្វើឱ្យជាទីស្រឡាញ់ពេញចិត្ត ។*

**វន្ទនំ =** *ការថ្វាយបង្គំ បានដល់ ការថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ។*

**បូជនា =** *ការបូជា បានដល់ ការបូជាដោយរបស់ក្រអូប និងផ្កាឈើជាដើម។*

## លក្ខណៈឥស្សាមានពីរយ៉ាង

**១.យរាវាស=***យរាវាសខ្លះអាស្រ័យសេចក្តីព្យាយាមធ្វើដូច (ការងារដែលបុរសគប្បីធ្វើ) របស់ខ្លួនដោយអាជីព យ៉ាងណានីមួយក្នុងការងារទាំងឡាយ មានការធ្វើស្រែ និងលក់ដូរជាដើមរមែងបាន ពាហនៈ ឬ រតនៈ ដែលល្អ, មនុស្សម្នាក់ទៀត មានសេចក្តីប្រាថ្នាឲ្យបុគ្គលនោះសូន្យចាកលាភ មិនត្រេកអរដោយការបានលាភរបស់បុគ្គលនោះ គិតតែថា "កាលណាហ្ន៎ មនុស្សនេះនឹងអស់អំពីសម្បត្តិនេះ ជាមនុស្សកំព្រា ត្រាច់ទៅ" ដូច្នេះ ។ កាលបុគ្គលម្នាក់នោះ សូន្យចាកសម្បត្តិនោះដោយហេតុយ៉ាងណាមួយក៏ពេញចិត្ត ។*

**២.បញ្ជិត=** *បញ្ជិតមួយរូបអ្នកមានចិត្តឥស្សា ឃើញបញ្ជិតរូបដទៃទៀត ដល់ព្រមដោយការបានបច្ច័យជាដើមដែលកើតឡើង ព្រោះអាស្រ័យសុតៈបរិយត្តិជាដើមរបស់ខ្លួន ក៏គិតថា “កាលណាហ្ន៎ លោករូបនេះសូន្យពីលាភទាំងនេះ” កាលណាឃើញភិក្ខុរូបនោះសូន្យដោយហេតុយ៉ាងនោះ កាលនោះក៏មានចិត្តត្រេកអរ ។ បណ្ឌិតគប្បីជ្រាបថា មានការច្រណែនសម្បត្តិរបស់បុគ្គលដទៃជាលក្ខណៈដោយប្រការដូច្នេះ។* ***ឥស្សា*** *មានលក្ខណៈ គឺការឈ្នានីសចំពោះសម្បត្តិអ្នកដទៃ ឬក៏ទ្រាំមិនបានចំពោះសម្បត្តិអ្នកដទៃនោះ មាននាទីគឺការមិនត្រេកអរនឹងសម្បត្តិរបស់អ្នកដទៃនោះហើយ ផលដែលប្រាកដចេញមក គឺការបែរមុខចេញអំពីសម្បត្តិរបស់អ្នកដទៃ ។*

**មច្ឆរិយៈ សេចក្តីកំណាញ់៥យ៉ាង គឺ** *កំណាញ់អាវាស១ កំណាញ់ត្រកូល១ កំណាញ់លាភ១ កំណាញ់សេចក្តីសរសើរ១ កំណាញ់ធម៌១។*

***កំណាញ់អាវាស*** = *គឺសេចក្តីកំណាញ់ទីអាស្រ័យយ៉ាងណា១ សូម្បីកុដិតូច។*

***កំណាញ់ត្រកូល*** = *គឺ មានការកំណាញ់ត្រកូលដែលជាញាតិនិងឧបដ្ឋាក។*

***កំណាញ់លាភ*** = ***លាភ*** *បានដល់ បច្ច័យបួន កាលភិក្ខុអ្នកមានសីលរូបដទៃ បាននូវបច្ច័យបួននោះឯង ភិក្ខុអ្នកកំណាញ់គិតថា "បច្ច័យសូមកុំបានដល់ភិក្ខុនេះឡើយ" ដូច្នេះ រមែងជា* ***លាភមច្ឆរិយ*** *(កំណាញ់លាភ) , តែភិក្ខុណាញាំងសទ្ធាទេយ្យ (របស់ដែលគេប្រគេនដោយសទ្ធា ) ឲ្យធ្លាក់ចុះក្តី , រមែងធ្វើបច្ច័យដែលបានមកឲ្យវិនាស ដោយអំណាចនៃការមិនបរិភោគ ឬបរិភោគមិនល្អជាដើមក្តី មិនឱ្យសូម្បីវត្ថុដែលនឹងដល់ការផ្អូមរលួយដល់ភិក្ខុដទៃក្តី , ភិក្ខុអ្នកមិនឱ្យឃើញភិក្ខុនោះហើយគិតថា "បើភិក្ខុរូបនេះមិនបានបច្ច័យនេះ ភិក្ខុរូបដទៃដែលមានសីលគប្បីបាន គប្បីបរិភោគ " ដូច្នេះមិនឈ្មោះថា មច្ឆរិយៈទេ ។*

***កំណាញ់សេចក្តីសរសើរ***= *សរីរវណ្ណៈ (សម្បុរនៃសរីរៈ)ក្តី គុណវណ្ណៈ (ការសរសើរគុណគឺសេចក្តីល្អ)ក្តី ឈ្មោះថា* ***វណ្ណៈ*** *ក្នុងវណ្ណៈទាំងពីរនោះបុគ្គលអ្នកកំណាញ់* ***សរីរៈវណ្ណៈ*** *កាលមានមនុស្សនិយាយថា "បុគ្គលដទៃ គួរជ្រះថ្លា មានរូបស្អាត"ដូច្នេះ មិនប្រាថ្នានិងពោលដល់បុគ្គលនោះ ។ បុគ្គលអ្នកកំណាញ់គុណវណ្ណៈ ការសរសើរគុណគឺសេចក្តីល្អ រមែងមិនប្រាថ្នានឹងគុណ សេចក្តីល្អ*

*របស់អ្នកដទៃដោយសីល ដោយធុតង្គ ដោយបដិបទា និងដោយអាចារៈ ។*

***សេចក្តីកំណាញ់ធម៌ =*** *ពាក្យថា **ធម៌** បានដល់ ព្រះ**បរិយត្តិ និងបដិវេធ**, ក្នុងធម៌ទាំងពីរនោះ ព្រះអរិយទាំងឡាយ រមែងមិនកំណាញ់បដិវេធទេ ,លោករមែងប្រាថ្នាដល់ការចាក់ធ្លុះ ព្រមទាំងទេវលោក ក្នុងធម៌ដែលខ្លួនបានចាក់ធ្លុះហើយ,គឺរមែងប្រាថ្នាថា "សូមសត្វដទៃចូរដឹងការចាក់ធ្លុះធម៌នោះ" ដូច្នេះ។ ឈ្មោះថា ធម្មមច្ឆរិយ (កំណាញ់ធម៌) មានតែក្នុងតន្តិធម៌(ធម៌ដែលជាគម្ពីរ) ប៉ុណ្ណោះ បុគ្គលដែលប្រកបដោយតន្តិធម៌នោះ រមែងដឹងគម្ពីរដែលអាថ៌កំបាំង ឬកថាមគ្គយ៉ាងណា មិនប្រាថ្នានឹងឱ្យមនុស្សដទៃដឹងគម្ពីរ ឬកថាមគ្គនោះ តែថា ភិក្ខុណាគិតសញ្ជឹងដល់បុគ្គល ឬគិតសញ្ជឹងដល់ធម៌ដោយការអនុគ្រោះធម៌ មិនឱ្យការអនុគ្រោះបុគ្គល ភិក្ខុនេះមិនឈ្មោះថា ធម្មមច្ឆរិយ។*

*ក្នុងខនៃ បុគ្គលខ្លះជាមនុស្សឡេះឡោះ គឺពេលខ្លះជាសមណៈពេលខ្លះជាព្រាហ្មណ៍ ពេលខ្លះជាគ្រហស្ថ ក៏ភិក្ខុណាមិនឲ្យដោយគិតថា "បុគ្គលនេះ និងទម្លាយសន្តិធម៌ដែលល្អិតសុខុមជាធម៌ដ៏ក្រៃលែងជាប្រពៃណីតៗគ្នាមក ឱ្យច្របូកច្របល់"ដូច្នេះ **ភិក្ខុនេះគិតសញ្ជឹងដល់បុគ្គលហើយ** ឈ្មោះថា រមែងមិនឱ្យ ដោយត្រកងធម៌*

ទុក ។ ចំណែកភិក្ខុណា រមែងមិនឱ្យដោយគិតថា “**ធម៌នេះល្អិតសុខុម គឺបុគ្គលនេះរៀនយក និងព្យាករណ៍អរហត្តផល និងរមែងសម្តែងខ្លួន ឱ្យដល់សេចក្តីវិនាស**” ភិក្ខុនេះគិតសញ្ជឹងដោយធម៌ ហើយ ឈ្មោះថា រមែងមិនឱ្យដោយ ការត្រកងបុគ្គល។ តែបុគ្គលណា រមែងមិនឲ្យដោយគិតថា បើបុគ្គលនេះរៀនធម៌នេះ នឹងអាចទំលាយលទ្ធិ របស់ពួកយើងដូច្នេះ បុគ្គលនេះ ឈ្មោះថា ជាអ្នកកំណាញ់ធម៌

## ផលនៃសេចក្តីកំណាញ់

**កំណាញ់អាវាស** = បុគ្គលច្រើនទៅដោយសេចក្តី**កំណាញ់អាវាស**(ទីលំនៅ) រមែងទៅកើតជាយក្ស ឬជាប្រេតហើយនឹងយកក្បាលទូលសំរាមហើយទៅ។

**កំណាញ់ត្រកូល** = កាលត្រកូលនោះធ្វើទាន និងរាប់អានបុគ្គលដទៃ កាលគេឃើញក៏គិតថា “ត្រកូលរបស់យើងនេះបែកហើយហ្ន៎”ដូច្នេះ លោហិតនឹងហូរដូចទឹកចេញពីមាត់ខ្លះ មានការធ្លុះពោះខ្លះ,ពោះវៀនធំទាំងឡាយ ក៏នឹងដាច់ជាកំណាត់តូច ធំចេញមកខ្លះ។

***កំណាញ់លាភ***= កំណាញ់ក្នុងលាភជារបស់សង្ឃ ជាគណៈ ឬជាបុគ្គល ក៏បរិភោគគ្រឿងប្រើប្រាស់របស់បុគ្គលរមែងកើតជាយក្ស ឬប្រេត ឬជាពស់វែកធំ។

***សរីរវណ្ណគុណមច្ឆរិយ*** និង ***បរិយត្តិធម្មមច្ឆរិយ*** = បុគ្គលរមែងសរសើរវណ្ណៈរបស់ខ្លួន,មិនសរសើរវណ្ណៈរបស់អ្នកដទៃ កាលនឹងពោលទោសនោះៗ ដោយពាក្យថា “នេះវណ្ណៈអ្វី?” កាលមិនឱ្យបរិយត្តិអ្វីដល់នរណាៗ រមែងជាអ្នកមានសម្បុរអាក្រក់ និងជាអ្នកល្ងង់ខ្លៅ ។ ម្យ៉ាងទៀត បុគ្គលរមែងត្រូវភ្លើងឆេះក្នុងខ្ទះលោហៈដោយសេចក្តីកំណាញ់អាវាស,រមែងជាអ្នកមានលាភតិចដោយសេចក្តីកំណាញ់ត្រកូល, រមែងកើតក្នុងគូថនរក ដោយសេចក្តី***កំណាញ់លាភ***, បុគ្គលកាលកើតគ្រប់ៗភព រមែងមិនមានវណ្ណៈល្អដោយការ***កំណាញ់វណ្ណៈ***,រមែងកើតក្នុងកុក្កុលនរកដោយការ***កំណាញ់ធម៌*** ។ **មច្ឆរិយៈ** មានលក្ខណៈ ការលាក់លៀមសម្បត្តិរបស់ខ្លួន មាននាទីគឺការមិនសប្បាយចិត្ត ក្នុងកាលសម្បត្តិរបស់ខ្លួនមានអ្នកដទៃ រួមប្រើប្រាស់ជាមួយហើយ ផលដែលប្រាកដចេញមក គឺការចង្អៀតចង្អល់ចិត្ត។

ចប់បុគ្គលមានសេចក្តីច្រណែនជាដើម

## (៤). បុគ្គលមានសេចក្ដីអួតអាងជាដើម

***សឋោ*** = *បុគ្គលជាអ្នកអួតអាង ។*

***មាយាវី***=*បុគ្គលមានមាយា,ព្រះសម្មាសម្ពុទ្ធត្រាស់ថា បុគ្គលខ្លះក្នុងលោកនេះប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត តំកល់ទុកនូវសេចក្ដីប្រាថ្នាដ៏លាមកព្រោះហេតុបិទបាំងនោះ ប្រាថ្នាថា កុំឱ្យគេស្គាល់អញ, ពោលវាចាថា កុំឱ្យគេស្គាល់អញ ត្រិះរិះថា កុំឱ្យគេស្គាល់អញ ។*

*អធិប្បាយ*

**សឋោ =** *ការអួតនូវអ្វីដែលខ្លួនមិនមានពិត ព្យាយាមបិទបាំងការពិត សម្ដែងហាក់ដូចជាខ្លួនមានពិត នេះហៅថា* ***សាឋេយ្យ*** (*អួតអាង*)។ *ការអួតនោះដែលអ្នកណាៗ មិនអាចដើម្បីដឹងនូវការពោលកន្លងរបស់អ្នកប្រកប ដោយអាការៈណា អាការៈនោះ រមែងដូចនឹងយក្ខិណីដែលក្លែងភេទជាស្ត្រីដើម្បីចាប់ពួកឈ្មួញរទេះស៊ីដូច្នោះដែរ។* ***សាឋេយ្យ*** *មានលក្ខណៈ ការពេញចិត្តបើកបង្ហាញគុណដែលខ្លួនឯងមិនមាន មាននាទី ការប្រមូលមកនូវគុណដែលខ្លួនឯងមិនមានទាំងនោះហើយផលដែលប្រាកដចេញមក គឺធ្វើ*

គុណដែលខ្លួនឯងមិនមានទាំងនោះឲ្យប្រាកដចេញមក សូម្បីដោយអាការតាមផ្លូវកាយ ។

**មាយាវី** = ការបោកប្រាស់ដោយកាយ បានដល់ ភិក្ខុឈានកន្លងព្រះបញ្ញត្តិដែលដឹងខ្លួនឯង ធ្វើឱ្យជាភារៈធ្ងន់, រមែងនិយាយហាក់ដូចជាថា ខ្លួនជាអ្នកចូលដល់ស្ងប់ដោយប្រាថ្នានឹងឱ្យអ្នកដទៃដឹងថា " **ឈ្មោះថា** ឋានៈ គឺការកន្លងព្រះបញ្ញត្តិរមែងមិនមានដល់ខ្លួន" នេះហៅថា **វាចំ ភាសតិ** ការបោកប្រាស់ដោយវាចា។ ការបោកប្រាស់ដោយកាយ ភិក្ខុនោះរមែងធ្វើវត្តបដិបត្តិដោយផ្លូវកាយ ដោយគិតថា "នរណាៗកុំដឹងបាបកម្មនេះដែលយើងធ្វើហើយ"។លក្ខណៈនេះឈ្មោះថា មាយា ការលាក់ពុត ហាក់ដូចជាលេងកល ព្រោះការបិទបាំងទោសដែលខ្លួនដឹង។ សត្វទាំងឡាយធ្វើបាបហើយ ក៏នៅកន្លងល្មើស គឺធ្វើបាបទៀត ព្រោះភាពជាអ្នកបិទបាំងទុកដោយសភាវៈណា សភាវៈនោះឈ្មោះថា លាក់ពុត, ឈ្មោះថា កន្លង ព្រោះកន្លងដោយឱ្យឃើញការប្រព្រឹត្តទៅដោយអាការៈដទៃ ដោយការធ្វើផ្លូវកាយ និងវាចា ។ សត្វទាំងឡាយមែងធ្វើនូវការឆបោក ដោយសភាពណា សភាពនោះ ឈ្មោះថា បោកបញ្ឆោត។ អធិប្បាយថា រមែងធ្វើឱ្យទទេ ចាកប្រយោជន៍។ ឈ្មោះថា បង្កប់ ព្រោះញ៉ាំងបាបទាំងឡាយ ឱ្យកើតច្របូកច្របល់គ្នា

ទៅដោយពាក្យថា “**យើងរមែងមិនធ្វើយ៉ាងនេះ**”។ ឈ្មោះថា **បំពួន** ព្រោះការមិនសង្រួមដោយកាយជាដើម។ **មាយា** មានលក្ខណៈ ការបិទបាំងបាបដែលខ្លួនឯងធ្វើហើយ មាននាទី លាក់លៀមបាប ដែលខ្លួនឯងធ្វើហើយនោះហើយផល ដែលប្រាកដចេញមក គឺ ការបិទបាំងបាបដែលខ្លួនឯងធ្វើនោះ ។

ចប់បុគ្គលមានសេចក្ដីអួតអាងជាដើម

## (៨). អហិរិកាបុគ្គលជាដើម

**អហិរិកោ** = *បុគ្គលមិនខ្មាស់បាប ។*

**អនោត្តប្បី** = *បុគ្គលមិនខ្លាចបាប។*

*អធិប្បាយ*

**អហិរិក**= *បុគ្គលឈ្មោះថា អហិរិកៈ ព្រោះអត្ថថា មិនខ្មាស គឺ មិនរង្កៀស (ទុច្ចរិត មានកាយទុច្ចរិតជាដើម ) ភាវៈនៃអហិរិកៈ ឈ្មោះថា អហិរិក្កៈ (ភាពជាបុគ្គលដែលមិនខ្មាស ឬភាវៈជាពួកធម៌ដែលមិនខ្មាស),អហិរិក្កៈនុ៎ះឯង ជាអហិរិកៈ។*

**អនោត្តប្ប**= *បុគ្គលឈ្មោះថា អនោត្តប្បៈ ព្រោះមិនខ្លាចផលរបស់ទុច្ចរិត មានកាយទុច្ចរិតជាដើម ។ ចំពោះធម៌ពីរយ៉ាងនេះ លោកមានការប្រៀបធៀបដូច្នេះថា* ***អហិរិកៈ*** *មានលក្ខណៈដូចជ្រូកស្រុកមិនខ្ពើមលាមកដូច្នោះ។* ***អនោត្តប្បៈ*** *មានលក្ខណៈដូចសត្វមមាចមិនខ្លាចភ្លើងដូច្នោះ។ ព្រោះហេតុនោះបុរាណាចារ្យទាំងឡាយ ទើបពោលដល់អហិរិកៈ និងអនោត្តប្បៈទុកជាបុគ្គលាធិដ្ឋានថា ៖*

ជិគុច្ឆតិ នាហិរិកោ បាបា គូថាវ សូករោ
ន ភាយ តិ អនោត្តប្បី សលភោ វិយ បាវកា ។

*បុគ្គលអ្នកមិនមានហិរិ រមែងមិនខ្មាសខ្ពើមបាប ដូចជ្រូកមិនខ្ពើមលាមក , បុគ្គលអ្នកមិនមានឱត្តប្បៈ រមែងមិនខ្លាចបាបដូចមមាចមិនខ្លាចភ្លើងដូច្នោះ ។ក្នុងធម៌ពីរយ៉ាងនេះលោកមានឧបមាដូចជាទារក លូកដៃទៅក្នុងរណ្តៅលាមកដែលមានសត្វអាសិរ្ពិស ក្នុងពេលនោះ ឈ្មោះថា មិនខ្ពើមវត្ថុដែលស្មោកគ្រោកផង ឈ្មោះថាមិនខ្លាចទោសរបស់អាសិរ្ពិសផង យ៉ាងណា ក្នុងពេលដែលបុគ្គលធ្វើបាប ពេលនោះឈ្មោះថា មិនខ្ពើមនឹងវត្ថុស្មោកគ្រោក គឺបាបនោះដោយអហិរិកៈផង ឈ្មោះថា មិនខ្លាចទោសរបស់បាបនោះ ដោយអនោត្តប្បៈផងដូច្នោះ ព្រោះហេតុនោះ ធម៌ទាំងពីរនេះទើបប្រព្រឹត្តទៅជាគូនិងគ្នា។*

*ចប់អហិរិកបុគ្គល គឺអ្នកមិនមានហិរិ*

## (៦). បុគ្គលប្រែដៅក្រជាដើម

**ទុព្វចោ**= *បុគ្គលប្រដៅក្រ។*

**បាបមិត្តោ** = *បុគ្គលមានមិត្តអាក្រក់។*

## ***អធិប្បាយ***

**ទុព្វចោ**=*ការពោលប្រដៅក្នុងបុគ្គលនេះ ដែលច្រើនតែកាន់យកខាងខុស ត្រេកអរតែក្នុងធម៌ដែលជាសឹកសត្រូវ ការមិនអើពើ*

មិនគោរព មិនទទួលស្តាប់បង្គាប់ ហេតុនោះ បុគ្គលនេះទើបឈ្មោះថា ទុព្វចោ ( អ្នកប្រដៅក្រ ) អំពើរបស់បុគ្គលដែលប្រដៅក្រនោះ ឈ្មោះថា ទោវចស្សំ, ភាវៈរបស់ទោវចស្សៈនោះ ឈ្មោះថា **ទោវចស្សតា** ( ភាវៈនៃអំពើរបស់អ្នកប្រដៅក្រ, ភាពជាអ្នកប្រដៅក្រ ) ។

## ធម៌១៦ធាំឲ្យប្រដៅក្រ[14]

១. **បាបិច្ឆតា** = ភាពជាអ្នកប្រាថ្នាលាមក។

២.**អត្តុក្កំសកបរវម្ភកតា**=ភាពជាអ្នកលើកខ្លួនបន្តុះបង្អាប់អ្នកដទៃ។

៣. **កោធនតា** = ភាពជាអ្នកមានសេចក្តីក្រោធ។

៤. **កោធហេតុ ឧបនាហិតា**= ភាពជាអ្នកចងសេចក្តីក្រោធទុកព្រោះក្រោធជាហេតុ។

៥. **កោធហេតុ អភិសង្គិតា**= ភាពជាអ្នកចងសេចក្តីក្រោធដ៏មានកម្លាំង ព្រោះក្រោធជាហេតុ។

៦. **កោធហេតុ កោធសាមន្តវាចានិច្ឆារណតា**= ភាពជាអ្នកបញ្ចេញវាចាជិតសេចក្តីក្រោធ ព្រោះក្រោធជាហេតុ។

៧. **ចោទកំ បដិប្ផរណតា**= កាលអ្នកដទៃចោទហើយ ក៏ជាអ្នកខឹងតបនិងអ្នកចោទវិញ។

---

[14] អនុមានសូត្រ បិដកលេខ ២០ ទំព័រ៣៥៤

៨.ចោទកំ **អបសាបនតា**=ភាពជាអ្នកត្រឡប់រុករានចំពោះអ្នកចោទ ។

៩.ចោទកស្ស **បច្ចារោបនតា**=ភាពជាអ្នកត្រឡប់ចោទ ប្រកាន់ចំពោះអ្នកចោទ។

១០.**អញ្ញេន អញ្ញំបដិចរណតា**= ភាពជាអ្នកបិទបាំងរឿងដទៃដោយរឿងដទៃ ។

១១. **អបទានេន ន សម្បាយនតា=** ភាពជាអ្នកមិនឆ្លើយតប ដោយសេចក្ដីប្រព្រឹត្តរបស់ខ្លួន ។

១២. **មក្ខិបឡាសិតា**= ភាពជាអ្នករមិលគុណ និងវាយឫកស្មើ។

១៣.**ឥស្សុកើមច្ឆរិតា**=ភាពជាអ្នកមានសេចក្ដីច្រណែន និងកំណាញ់ ។

១៤. **សឋមាយាវិកា**= ភាពជាអ្នកអួតអាង និងលាក់ពុត ។

១៥. **ថទ្ធាតិមានិកា**= ភាពជាអ្នករឹងត្អឹង មើលងាយអ្នកដទៃ។

១៦. **សន្ទិដ្ឋិ បរាមាសិ អាធានគ្គាហិ ទុប្បដិនិស្សគ្គិតា**=ភាពជាអ្នកស្ទាត់នូវទិដ្ឋិរបស់ខ្លួនប្រកាន់មាំ ដែលគេលះបង់បានដោយក្រ ។

**បាបមិត្តោ=** គឺការសេព ការជិតដិតនិងគ្នា ការត្រូវគំនិតគ្នា ការគប់រកគ្នា ការស្រេបគំនិតគ្នាសេចក្ដីស្រឡាញ់គ្នា ការជិតស្និទ្ធនិងគ្នា

ភាពនៃបុគ្គលមូលមិត្រនិងគ្នា នឹងមនុស្សដែលមិនមានសទ្ធា ទ្រុស្ត សីល ចេះដឹងតិច ជាមនុស្សកំណាញ់ គ្មានប្រាជ្ញា” ។

## សត្វទាំងឡាយត្រូវគ្នាដោយធាតុ[15]

សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្បែរភ្នំគិជ្ឈកូដ ជិតក្រុងរាជគ្រឹះ។ ក្នុងសម័យនោះឯង ព្រះសារីបុត្តមានអាយុ កំពុង ចង្រ្កមក្នុងទីជិតព្រះមានព្រះភាគ ជាមួយនឹងភិក្ខុទាំងឡាយច្រើនរូប ព្រះមហាមោគ្គល្លានមានអាយុ កំពុងចង្រ្កមក្នុងទីជិតព្រះមានព្រះភាគ ជាមួយនឹងភិក្ខុទាំងឡាយច្រើនរូប ព្រះមហាកស្សបមានអាយុ កំពុងចង្រ្កម ក្នុងទីជិតព្រះមានព្រះភាគ ជាមួយនឹងភិក្ខុទាំងឡាយច្រើនរូប ព្រះអនុរុទ្ធមានអាយុ កំពុងចង្រ្កម ក្នុងទីជិតព្រះមានព្រះភាគជាមួយនឹងភិក្ខុទាំងឡាយច្រើនរូប ព្រះបុណ្ណមន្តានីបុត្តមានអាយុ កំពុងចង្រ្កម ក្នុងទីជិតព្រះមានព្រះភាគ ជាមួយនឹងភិក្ខុទាំងឡាយច្រើនរូប ព្រះឧបាលិមានអាយុ កំពុងចង្រ្កម ក្នុងទីជិតព្រះមានព្រះភាគ ជាមួយនឹងភិក្ខុទាំងឡាយច្រើនរូប ព្រះអានន្ទមានអាយុកំពុងចង្រ្កម ក្នុងទីជិតព្រះមានព្រះភាគ ជាមួយនឹងភិក្ខុ

---

[15] បិដក ភាគ ៣២ - ទំព័រទី ៣៣

ទាំងឡាយច្រើនរូប ទេវទត្ត កំពុងចង្រ្កម ក្នុងទីជិតព្រះមានព្រះភាគ ជាមួយនឹងភិក្ខុទាំងឡាយច្រើនរូបដែរ។

គ្រានោះឯង ព្រះមានព្រះភាគ ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ឃើញសារីបុត្ត កំពុងចង្រ្កម ជាមួយនឹងពួកភិក្ខុច្រើនរូប ដែរឬ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលថា ព្រះករុណា ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងអស់នុ៎ះ ជាអ្នកមានបញ្ញាច្រើន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ឃើញមហាមោគ្គល្លាន កំពុងចង្រ្កម ជាមួយនឹងពួកភិក្ខុច្រើនរូប ដែរឬ។ ព្រះករុណា ព្រះអង្គ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងអស់នុ៎ះ ជាអ្នកមានឫទ្ធិច្រើន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ឃើញមហាកស្សប កំពុងចង្រ្កម ជាមួយនឹងពួកភិក្ខុច្រើនរូប ដែរឬ។ ព្រះករុណា ព្រះអង្គ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងអស់នុ៎ះ ជាធុតវាទ (អ្នកពោលពាក្យកំចាត់បង់កិលេស) ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ឃើញអនុរុទ្ធកំពុងចង្រ្កម ជាមួយនិងពួកភិក្ខុច្រើនរូប ដែរឬ។ ព្រះករុណា ព្រះអង្គ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងអស់នុ៎ះ ជាអ្នកបានទិព្វចក្ខុ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ឃើញបុណ្ណមន្តានីបុត្ត កំពុងចង្រ្កម ជាមួយនឹងពួកភិក្ខុច្រើនរូប ដែរឬ។ ព្រះករុណា ព្រះ

អង្គ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងអស់នុ៎ះ ជាធម្មកថិក ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ឃើញឧបាលិ កំពុងចង្រ្កម ជាមួយនឹងពួកភិក្ខុច្រើនរូប ដែរឬ។ ព្រះករុណា ព្រះអង្គ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងអស់នុ៎ះ ជាវិនយធរ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ឃើញអានន្ទ កំពុងចង្រ្កម ជាមួយនឹងពួកភិក្ខុច្រើនរូប ដែរឬ។ ព្រះករុណា ព្រះអង្គ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងអស់នុ៎ះជាពហុស្សូត ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ឃើញទេវទត្ត កំពុងចង្រ្កម ជាមួយនឹងពួកភិក្ខុច្រើនរូប ដែរឬ។ ព្រះករុណា ព្រះអង្គ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងអស់នុ៎ះ ជាអ្នកមានសេចក្តីប្រាថ្នាលាមក។

ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយ ត្រូវគ្នា សមគ្នាដោយ-ធាតុ គឺពួកជនមានអធ្យាស្រ័យថោកទាប ត្រូវគ្នា សមគ្នាជាមួយនឹងពួកជនមានអធ្យាស្រ័យថោកទាប ពួកជនមានអធ្យាស្រ័យល្អ ត្រូវគ្នា សមគ្នា ជាមួយនឹងពួកជនមានអធ្យាស្រ័យល្អ ម្នាលភិក្ខុទាំងឡាយ សូម្បីក្នុងអតីតកាល សត្វទាំងឡាយ ត្រូវគ្នា សមគ្នា ដោយធាតុ គឺពួកជនមានអធ្យាស្រ័យថោកទាប ត្រូវគ្នា សមគ្នា ជាមួយនឹងពួកជនមានអធ្យាស្រ័យថោកទាប ពួកជនមានអធ្យាស្រ័យល្អ ត្រូវគ្នា សមគ្នា ជាមួយនឹងពួកជនមានអធ្យាស្រ័យ

ល្អ។ ម្នាលភិក្ខុទាំងឡាយ សូម្បីក្នុងអនាគតកាល សត្វទាំងឡាយ នឹងត្រូវគ្នា នឹងសមគ្នាដោយធាតុ គឺពួកជនមានអធ្យាស្រ័យថោកទាប នឹងត្រូវគ្នា នឹងសមគ្នា ជាមួយនិងពួកជនមានអធ្យាស្រ័យថោកទាប ពួកជនមានអធ្យាស្រ័យល្អ នឹងត្រូវគ្នា នឹងសមគ្នា ជាមួយនឹងពួកជនមានអធ្យាស្រ័យល្អ។ ម្នាលភិក្ខុទាំងឡាយ សូម្បីក្នុងបច្ចុប្បន្នកាលនេះ សត្វទាំងឡាយ ត្រូវគ្នា សមគ្នា ដោយធាតុ គឺពួកជនមានអធ្យាស្រ័យថោកទាបត្រូវគ្នា សមគ្នាជាមួយនឹងពួកជនមានអធ្យាស្រ័យថោកទាប ពួកជនមានអធ្យាស្រ័យល្អ ត្រូវគ្នា សមគ្នា ជាមួយនឹងពួកជនមានអធ្យាស្រ័យល្អ។

ចប់បុគ្គលប្រដៅក្រជាដើម

## (៧). បុគ្គលមានទ្វារមិនបានរក្សាក្នុងឥន្ទ្រិយជាដើម

**១.ឥន្ទ្រិយេសុ អគុត្តទ្វារោ**= បុគ្គលមានទ្វារមិនបានរក្សាក្នុងឥន្ទ្រិយទាំងឡាយ ។

**២ . ភោជនេ អមត្តញ្ញូ**= បុគ្គលមិនដឹងប្រមាណក្នុងភោជន ។

អធិប្បាយ

**ឥន្ទ្រិយេសុ អគុត្តទ្វារោ**= បុគ្គលខ្លះ ក្នុងលោកនេះឃើញរូបដោយចក្ខុ ជាអ្នក**កាន់យកនិមិត្ត កាន់យកអនុព្យញ្ជនៈ** អភិជ្ឈានិងទោមនស្ស ជាអកុសលដ៏លាមក គប្បីគ្របសង្កត់បុគ្គលដែលមិនសង្រួមក្នុងចក្ខុន្ទ្រិយនុ៎ះ ព្រោះហេតុមិនសង្រួមក្នុងចក្ខុន្ទ្រិយណា មិនប្រតិបត្តិ ដើម្បីសង្រួមចក្ខុន្ទ្រិយនោះ មិនរក្សាចក្ខុន្ទ្រិយ មិនដល់នូវសង្រួមចក្ខុន្ទ្រិយ ។ សូម្បីឥន្ទ្រិយដទៃក៏មានសភាពដូចគ្នា។

បទថា **និមិត្តគ្គាហី**= អ្នកកាន់យកនិមិត្ត បានដល់ រមែងកាន់យកនិមិត្តថា ជាស្ត្រី ជាប្រុស ឬនិមិត្តដែលជាទីតាំងនៃកិលេសមានសេចក្តីសម្គាល់ថាល្អជាដើម ដោយអំណាចនៃឆន្ទរាគៈ , មិនតាំងនៅក្នុងរូបដែលគ្រាន់តែជាការឃើញប៉ុណ្ណោះ ។

បទថា **អនុព្យញ្ជនគ្គាហី**= ជាអ្នកកាន់យកដោយអនុព្យញ្ជនៈ ” បានដល់ កាន់យកកិរិយាអាការៈ ដៃជើង ការញញឹម ការសើច

ការនិយាយ ការក្រឡេកមើល ការងាកមើលឆ្វេងស្តាំជាដើម ដែលបានពោលហារថា “**អនុព្យញ្ជនៈ**” ព្រោះជាគ្រឿងប្រាកដរបស់កិលេសទាំងឡាយ **គឺព្រោះនឹងធ្វើកិលេសឱ្យប្រាកដ** ។

បទថា “**យត្វាធិករណមេនំ** = ព្រោះហេតុមិនបានសង្រួមនូវចក្ខុន្ទ្រិយណា” មានសេចក្តីអធិប្បាយថា អកុសលធម៌ទាំងឡាយ មានអភិជ្ឈាជាដើមរមែងកើតឡើង ដល់អ្នកមិនបានសង្រួមក្នុងទ្វារនេះដោយ **សតិ** ។

បទថា “**តស្ស សំវរាយ ន បដិបជ្ជតិ** = មិនបដិបត្តិដើម្បីសង្រួមនូវឥន្ទ្រិយនោះ ” សេចក្តីថា មិនបដិបត្តិដើម្បីប្រយោជន៍ដល់ការបិទនូវចក្ខុន្ទ្រិយជាដើមនោះ ដោយទ្វារ គឺសតិ , ក៏បុគ្គលយ៉ាងនេះឯងហៅថា អ្នកមិនរក្សាចក្ខុន្ទ្រិយ, មិនសម្រេចការសង្រួមចក្ខុន្ទ្រិយជាដើម ។

គប្បីជ្រាបថា សំវរៈក្តី អសំវរៈក្តី រមែងមិនកើតក្នុងចក្ខុន្ទ្រិយ ក៏ពិតមែន, ព្រោះថា សតិ ឬការវង្វេងសតិរមែងកើតឡើង ព្រោះអាស្រ័យចក្ខុបសាទ ក៏ពិតមែនហើយ តែថាក្នុងកាលណា រូបារម្មណ៍មិនមកដល់ចក្ខុ, ក្នុងកាលនោះ កាលបើភវង្គចិត្តកើតរលត់ ២ វារៈហើយ កិរិយាមនោធាតុ ក៏ញ៉ាំងអាវជ្ជនកិច្ចឱ្យសម្រេច ហើយក៏រលត់លំដាប់នោះ, ចក្ខុវិញ្ញាណក៏ញ៉ាំងទស្សនកិច្ចឱ្យសម្រេច

ហើយរលត់, បន្ទាប់ពីនោះ វិបាកមនោធាតុ ក៏ញុំាងសម្បដិច្ឆន្ន-កិច្ចឱ្យសម្រេចហើយក៏រលត់, បន្ទាប់មក វិបាកាហេតុកមនោ-វិញ្ញាណធាតុ ក៏ញុំាងសន្តីរណកិច្ចឱ្យសម្រេចហើយក៏រលត់, បន្ទាប់មកទៀត មនោវិញ្ញាណធាតុដែលជាអហេតុកកិរិយា ក៏ញុំាងវោដ្ឋ-ព្វនកិច្ចឱ្យសម្រេច ហើយក៏រលត់ ។ ក្រោយពីនោះមក ជវនចិត្តរមែងស្ទុះទៅ, សំវរៈក្តី អសំវរៈក្តីនឹងមាននៅក្នុងសម័យនៃភវង្គនោះ ក៏មិនមែន, ឬនឹងមានក្នុងសម័យនៃអាវជ្ជនចិត្តជាដើម សម័យណាមួយក៏មិនមែន ។ តែក្នុងខណៈជវនចិត្ត ភាពជាអ្នកទ្រុស្តសីលខ្លះ ការភ្លេចសតិខ្លះ ការមិនដឹងខ្លះ ការមិនអត់ធន់ខ្លះ ការខ្ជិលច្រអូសខ្លះ រមែងកើតឡើង, អសំវរៈរមែងមាន ។ ក៏អសំវរៈនោះយ៉ាងនេះ ទើបត្រាស់ហៅថា អសំវរៈក្នុងចក្ខុន្ទ្រិយ ។ ព្រោះហេតុអ្វី? ព្រោះកាលបើអសំវរៈនោះ កំពុងមាន សូម្បីទ្វារក៏មិនបាន ឃុំគ្រង សូម្បីភវង្គ វិថីចិត្ត មានអាវជ្ជនចិត្តជាដើម រមែងជាការដែលមិនបានឃុំគ្រង ដូចជាអ្វី? ដូចជាទ្វារទាំងបួនទិសរបស់នគរដែលគេមិនបានបិទទុក ដល់ខាងក្នុងផ្ទះ ឬស៊ុំទ្វារ និងបន្ទប់ជាដើម និងបិទទុកយ៉ាងល្អ ក៏ដោយ ក៏នៅតែមិនបានរក្សាដដែល មិនបានឃុំគ្រងវត្ថុទាំងអស់ ទុកខាងក្នុងព្រះនគរឡើយ ព្រោះពួកចោរចូលទៅតាមទ្វារនគរ គប្បីធ្វើតាមសេចក្តីប្រាថ្នាបាន យ៉ាងណា, កាល

បើការទ្រុស្តសីលជាដើម កើតឡើងហើយក្នុងជវ៉ន កាលបើអសំវ-រៈនោះកំពុងមាន រមែងជាការដែលមិនបានឃុំគ្រង សូម្បីទ្វារ សូម្បីភវង្គ សូម្បីវិថីចិត្ត មានអាវជ្ជនជាដើម ក៏យ៉ាងនោះដែរ សូម្បីមានជាអាទិ៍ថា ស្តាប់សំឡេងហើយ ដោយសោតៈ ដូច្នេះក៏ន័យនេះដែរ ។

បទថា **យា ឥមេសំ=** ឥន្ទ្រិយទាំងនេះណា សេចក្តីថា ការមិនឃុំគ្រងឯណា,ការមិនរក្សាឯណាការមិនសង្រួមឯណានៃឥន្ទ្រិយទាំង ៦នេះអធិប្បាយថា ការមិនឃាំង ការមិនបិទឥន្ទ្រិយទាំង ៦ នេះ ។

**ភោជនេ អមត្តញ្ញូ=** បុគ្គលខ្លះមិនបានពិចារណា មិនធ្វើដោយឧបាយប្រាជ្ញា ក៏បរិភោគអាហារដើម្បីលេង ដើម្បីស្រវឹង ដើម្បីប្រដាល់ ដើម្បីស្អិតស្អាង ការមិនសន្តោស ការមិនដឹងប្រមាណសេចក្តីមិនពិចារណាក្នុងភោជននោះណា នេះហៅថា មិនដឹងប្រមាណក្នុងភោជន។

ចប់បុគ្គលមានទ្វារមិនបានរក្សាក្នុងឥន្ទ្រិយជាដើម

## (៨). បុគ្គលភ្លេចស្មារតីជាដើម

**១ . មុដ្ឋស្សតិ** = *បុគ្គលភ្លេចស្មារតី។*

**២ . អសម្បជានោ** = *បុគ្គលមិនដឹងខ្លួន*

*អធិប្បាយ*

**មុដ្ឋស្សតិ** = *ការគ្មានស្មារតី ការនឹកមិនឃើញ ការភ្លេចស្មារតី ការរលឹកមិនបាន ការមិនបានចាំទុក ការភ្លេចភ្លាំង បានដល់ នាមក្ខន្ធ៤ ដែលវៀរចាកសតិ ។ សេចក្តីអធិប្បាយ ដូច* **ឥន្ទ្រិយេសុ អគុត្តទ្វារោ** *ខាងដើមហើយ ។*

**អសម្បជានោ** = *ការមិនដឹង ការមិនឃើញ ការមិនចាក់ធ្លុះ នូវធម៌តាមសេចក្តីពិតថា នេះទុក្ខ នេះហេតុនាំឱ្យកើតទុក្ខ នេះទីរំលត់ទុក្ខ ( គឺព្រះនិព្វាន ) នេះធម៌នាំឱ្យទៅកាន់ទីរំលត់ទុក្ខ (គឺអរិយមគ្គមានអង្គ៨) ទាំងអស់នេះហៅថា ការមិនដឹងខ្លួន បានដល់ អវិជ្ជា ដែលកើតក្នុងអកុសលចិត្តុប្បាទ។*

*ចប់បុគ្គលភ្លេចស្មារតីជាដើម*

## (៩). បុគ្គលវិបត្តិចាកសីលជាដើម

**១. សីលវិបន្នោ** = *បុគ្គលវិបត្តិសីល។*

**២. ទិដ្ឋិវិបន្នោ**= *បុគ្គលវិបត្តិទិដ្ឋិ*

*អធិប្បាយ*

**សីលវិបន្នោ**= *ការប្រព្រឹត្តល្មើសប្រកបដោយកាយ ការប្រព្រឹត្តល្មើសប្រកបដោយវាចា ការប្រព្រឹត្តល្មើសប្រកបដោយកាយនិងវាចា ភាពនៃបុគ្គលទ្រុស្តសីលទាំងអស់ ក៏ឈ្មោះថា វិបត្តិចាកសីលដែរ។*

### វិបត្តិនៃសីល

**សីលវិបត្តិរបស់ភិក្ខុ** *បានដល់ ភិក្ខុត្រូវអាបត្តិបារាជិក៤ និងសង្ឃាទិសេស១៣ នេះហៅថា* **សីលវិបត្តិ** ។ **អាចារវិបត្តិ** *បានដល់ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ បាចិត្តិយៈ បាដិទេសនីយៈ ទុក្កដ ទុព្ភាសិត នេះហៅថា អាចារវិបត្តិ*[៦]។

**សីលវិបត្តិរបស់ឃរាវាស** = *ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចុះសីលវិបត្តិ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល*

---

[៦] *បិដកលេខ ១៣ ទំព័រ២១៨*

ពួកមួយ ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ។ បេ។ ពោលពាក្យឥត ប្រយោជន៍។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សីលវិបត្តិ ។ ម្នាល ភិក្ខុទាំងឡាយ ព្រោះហេតុតែសីលវិបត្តិ បានជាសត្វទាំងឡាយ លុះ បែកធ្លាយរាងកាយ បន្ទាប់អំពីមរណៈ ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ក៏មាន [១៧] ។

## ទោសនៃសីលវិបត្តិ[១៨]

បុគ្គលទ្រុស្តសីល ព្រោះហេតុជាអ្នកទ្រុស្តសីល ទើបមិនជាទី ស្រលាញ់នៃទេវតានិងមនុស្សទាំងឡាយ , ជាអ្នកមិនគួរដល់កិរិយា ប្រៀនប្រដៅនៃសព្រហ្មចារីទាំងឡាយ,ជាអ្នកដល់ហើយនូវសេចក្ដីទុក្ខ ព្រោះកិរិយាតិះដៀលនូវភាពនៃខ្លួន ជាអ្នកទ្រុស្តសីល ទាំងឡាយ, ជាអ្នកក្ដៅក្រហាយព្រោះសេចក្ដីសរសើរបុគ្គលអ្នក មានសីលទាំងឡាយ , ម្យ៉ាងទៀត ជាអ្នកមានសម្បុរអាក្រក់ ដូចសាដក (សំពត់) ដែលបុគ្គលត្បាញហើយដោយសំបកធ្មៃ ព្រោះភាព នៃខ្លួនជាអ្នកទ្រុស្តសីលនោះ ។ ម្យ៉ាងទៀតជនទាំងឡាយណាដល់

---

[១៧] បិដក ភាគ ៤១ - ទំព័រទី ៤១៧ = ព្រះអង្គសម្ដែងវិបត្តិ៣យ៉ាង គឺ សីលវិបត្តិ, ចិត្តវិបត្តិ(ចិត្តប្រកបដោយទោសៈ) ទិដ្ឋិវិបត្តិ ។

[១៨] វិសុទ្ធិមគ្គ ។

នូវទិដ្ឋានុគតិ កាន់តាមបែបរបស់បុគ្គលទ្រុស្តសីលនោះ , ជនទាំង នោះនឹងប្រសព្វទុក្ខ ព្រោះកិរិយានាំមកនូវទុក្ខក្នុងអបាយអស់កាល ដ៏យូរ, ជាបុគ្គលឥតតម្លៃព្រោះបុគ្គលនោះ, បើទទួលនូវទេយ្យធម៌ របស់ជនទាំងឡាយណា មិនធ្វើនូវទេយ្យធម៌របស់ជនទាំងនោះឱ្យ មានផលច្រើន ជាបុគ្គលដែលគេជម្រះបានដោយក្រ ដូចជារណ្តៅ លាមក ដែលរាប់មកយូរឆ្នាំទៅហើយ, ជាអ្នកឃ្លាតចាកប្រយោជន៍ ទាំងពីរ ដូចជាកំណាត់ឧសដែលដុតនូវសាកសព, សូម្បីកាលប្តេ-ជ្ញានូវភាពនៃខ្លួនជាភិក្ខុ ក៏នៅតែមិនមែនជាភិក្ខុដដែល, ដូចលា ដែលជាប់តាមហ្វូងគោ ជាអ្នកមានសេចក្តីតក់ស្លុតជានិច្ច ដូចជា បុរសអ្នកមានពៀរនឹងគ្នាសព្វកាល ជាអ្នកមិនគួរដល់ការនៅរួម ដូចសាកសពដែលស្លាប់ហើយ សូម្បីប្រកបហើយដោយគុណ មានសុតៈជាដើម ក៏ជាអ្នកមិនគួរដល់ការបូជារបស់សព្រហ្មចារី ទាំងឡាយ ដូចជាភ្លើងក្នុងព្រៃស្មសាន ដែលមិនគួរដល់កិរិយាបូជា នៃព្រាហ្មណ៍ទាំងឡាយ ជាអ្នកអភ័ព្វក្នុងការត្រាស់ដឹងនូវគុណ វិសេស, ដូចជាមនុស្សខ្វាក់ជាអ្នកអភ័ព្វក្នុងការឃើញរូប,ជាអ្នក អស់សង្ឃឹមក្នុងព្រះសទ្ធម្ម ដូចជាចណ្ឌាលកុមារ ដែលអស់សង្ឃឹម ក្នុងរាជ្យសម្បត្តិ, សូម្បីសម្គាល់ថា អញបានសេចក្តីសុខហើយ

ដូច្នេះក៏នៅតែទុក្ខពិតៗ ព្រោះភាពនៃខ្លួនមានចំណែកនៃសេចក្ដីទុក្ខដែលទ្រង់សម្ដែងហើយក្នុងអគ្គិក្ខន្ធបរិយាយសូត្រ។

**ទិដ្ឋិវិបន្នោ** = ព្រះដ៏មានព្រះភាគត្រាស់ ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ចុះទិដ្ឋិវិបត្តិ តើដូចម្ដេច។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ ជាមិច្ឆាទិដ្ឋិ មានសេចក្ដីយល់វិបរិតថា ទានដែលបុគ្គលឲ្យហើយ មិនមានផល ការបូជាធំ តូច មិនមានផល។ បេ។ ពួកសមណព្រាហ្មណ៍ ធ្វើឲ្យជាក់ច្បាស់ នូវលោកនេះ និងលោកខាងមុខ ដោយប្រាជ្ញាដ៏ឧត្ដម ដោយខ្លួនឯង ហើយប្រកាសក្នុងលោក ក៏មិនមាន។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទិដ្ឋិវិបត្តិ[៧៩] ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែទិដ្ឋិវិបត្តិ បានជាសត្វទាំងឡាយ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណៈ ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ក៏មាន ។

**ទិដ្ឋិវិបត្តិនេះ បានដល់ ទិដ្ឋិ៦២ដែលព្រះមានព្រះភាគត្រាស់ហើយក្នុងព្រហ្មជាលសូត្រ។**

---

[៧៩] បិដក ភាគ ៤១ - ទំព័រទី ៤១៧

**វចនត្ថរបស់ទិដ្ឋិក្នុងគម្ពីរធម្មសង្គណី ៖** ព្រៃស្តុក គឺ ទិដ្ឋិ(ទិដ្ឋិគ-ហន)=ព្រោះទិដ្ឋិនោះឯងជាវត្ថុដែលកន្លងផុតទៅបានដោយលំបាក ដូចជាព្រៃស្តុក ស្មៅស្តុក ភ្នំស្តុក។

ផ្លូវឆ្ងាយ គឺទិដ្ឋិ (ទិដ្ឋិកន្តារ) ព្រោះជាវត្ថុដែលគួររវាំង និងមានភ័យចំពោះមុខ ដូចចោរកន្តារ(ផ្លូវលំបាកព្រោះចោរ), កន្តារសត្វកាច(ផ្លូវលំបាកព្រោះសត្វកាច), កន្តារខ្សាច់(ផ្លូវលំបាកព្រោះវាលខ្សាច់), កន្តារទឹក(ផ្លូវលំបាកព្រោះទឹក), កន្តារទុព្ភិក្ខភ័យ(ភ័យព្រោះអត់អាហារ)។

ការយល់ខុសជាសត្រូវដល់សម្មាទិដ្ឋិ (ទិដ្ឋិវិសូកាយិក) ព្រោះជាទិដ្ឋិដែលទម្លាយ និងជំទាស់ជាមួយសម្មាទិដ្ឋិ ដោយពិតហើយការយល់ខុសកើតឡើងរមែងទម្លាយនិងជំទាស់ជាមួយសម្មាទិដ្ឋិ។

ការប្រែប្រួលនៃទិដ្ឋិ (ទិដ្ឋិវិប្ផន្ទិត) គឺការប្រែប្រួលខុសនៃទិដ្ឋិ ព្រោះពេលខ្លះក៏កាន់យកនូវសភាពទៀង ពេលខ្លះក៏កាន់យកសភាពសូន្យដោយពិតហើយ អ្នកមានការយល់ខុសច្រើនតាំងនៅក្នុងការយល់តែម្យ៉ាងមិនបាន ពេលខ្លះក៏ស្របតាមសភាពទៀង ពេលខ្លះក៏ស្របតាមសភាពសូន្យ។

ទិដ្ឋិសំយោជនៈ បានដល់ ទិដ្ឋិគឺសំយោជនៈព្រោះជាគ្រឿងចង ។

សេចក្តីប្រកាន់ (គាហៈ) គឺសភាពប្រកាន់អារម្មណ៍ទុកយ៉ាងមាំ ដូចក្រពើជាដើមចាប់ខាំមនុស្សទុកយ៉ាងមាំ ។

សភាពតាំងមាំ (បដិគ្គាហោ) ព្រោះតាំងទុកដោយចំពោះ ដោយពិតហើយ ការតាំងមាំនេះ រមែងប្រកាន់ទុកដោយតាំងមាំ ដោយការប្រព្រឹត្តិទៅយ៉ាងមានកម្លាំង។

ការប្រកាន់មាំ(អភិនិវេស) គឺ សភាពប្រកាន់មាំ ដោយសភាពជារបស់ទៀងជាដើម។

ការចាប់ប្រកាន់ខុស (បរាមាស) គឺសភាវៈដែលកន្លងផុតពីសភាវធម៌ ហើយកាន់យកដោយប្រការដទៃ ដោយសភាពទៀងជាដើម។

ផ្លូវអាក្រក់ (កុម្មគ្គ) គឺផ្លូវដែលគួរស្អប់ខ្ពើម ព្រោះនាំការវិនាសមកឱ្យ ឬជាផ្លូវនៃអបាយដែលជាបណ្ឌិតស្អប់ខ្ពើម។

ផ្លូវខុស(មិច្ឆាបថ) ព្រោះជាផ្លូវទៅតាមផ្លូវខុស(គឺផ្លូវមិនពិត) ឧបមាដូចជាអ្នកវង្វេងទិស សូម្បីកាន់យកថាផ្លូវនេះ ជាផ្លូវទីភូមិឯណោះ ក៏មិនញុំាងបុគ្គលនោះឱ្យដល់ភូមិស្រុកបានឡើយ យ៉ាង

ណាមិញ បុគ្គលអ្នកមានមិច្ឆាទិដ្ឋិសូម្បីកាន់យកថា នេះជាផ្លូវទៅកាន់សុគតិក៏មិនអាចឱ្យដល់សុគតិភូមិក៏យ៉ាងនោះដែរ ទើបឈ្មោះថា មិច្ឆាបថ (ផ្លូវខុស) ព្រោះតាមផ្លូវមិនពិត។

ចប់បុគ្គលវិបត្តិចាកសីលជាដើម

## (១០). បុគ្គលមានសញ្ញោជនខាងក្នុងជាដើម

**១. អជ្ឈត្តសំយោជនោ=** *បុគ្គលមានសញ្ញោជនៈខាងក្នុង។*

**២. ពហិទ្ធាសំយោជនោ=** *បុគ្គលមានសញ្ញោជនៈខាងក្រៅ។*

*អធិប្បាយ*

*ពាក្យថា* ***សញ្ញោជនៈ*** *មានន័យថា ធម៌ទាំងឡាយមានលោភជាដើម រមែងប្រកប គឺចងសត្វទុក ដូច្នេះ មានពាក្យអធិប្បាយថា ប្រកប គឺចងសត្វទាំងឡាយឱ្យជាប់ជាមួយទុក្ខក្នុងវដ្តៈ។ គឺចងភ្នែកជាមួយរូបហើយញុំាងសត្វឱ្យត្រេកអរនិងរូប សូម្បីចងត្រចៀកជាមួយសម្លេងក៏មានន័យដូចគ្នា ។រួមសេចក្តីថា ចងអាយតនខាងក្នុងគឺភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ឱ្យជាប់ជាមួយអាយ-តនខាងក្រៅ គឺរូប សម្លេង ក្លិន រស ផោដ្ឋព្វៈ និងធម្មារម្មណ៍។ព្រោះហេតុនោះទើបព្រះមានព្រះភាគទ្រង់ត្រាស់ថា* ***“ឥធ ភិក្ខវេ ភិក្ខុ ចក្ខុញ្ច បជានាតិ រូបេ ច បជានាតិ យញ្ច តទុភយំ បដិច្ច ឧប្បជ្ជតិ សញ្ញោជនំ តញ្ច បជានាតិ*** *ប្រែថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់នូវភ្នែកផង ដឹងច្បាស់នូវរូបទាំងឡាយផងមួយវិញទៀត សំយោជនៈណាអាស្រ័យនូវភ្នែក និងរូបទាំងពីរនោះហើយកើតឡើង ក៏ដឹងច្បាស់នូវសំយោជនៈនោះផង” ដូច្នេះ។*

**អជ្ឈត្តសំយោជនោ =** *សូម្បីគ្រឿងចងទាំងពីរនេះ បណ្ឌិតគប្បីសម្ដែងការឧបមា ដោយរោងកូនគោ ពិតមែន ព្រះសោតាបន្ន និងព្រះសកទាគាមី ដែលតាំងជីវិតនៅក្នុងកាមលោកនេះ ប្រៀបដូចកូនគោដែលគេចងឱ្យដេកនៅក្នុងរោងរបស់វាដូច្នោះ។ គ្រឿងចងគឺសំយោជនៈ នៃព្រះសោតាបន្ន និងសកទាគាមីទាំងនេះ តាំងនៅក្នុងកាមលោកនេះ សូម្បីខ្លួនលោក ក៏តាំងនៅក្នុងភពនេះដូចគ្នា។ បើព្រះសោតាបន្ននិងព្រះសកទាគាមី តាំងនៅក្នុងរូបភព ឬ អរូបភពក៏ប្រៀបដូចនឹងកូនគោដែលចងទុក ខាងក្នុងរោងរបស់វា តែខ្លួនវាដេកនៅខាងក្រៅរោង ព្រោះថា គ្រឿងចងនៃព្រះសោតាបន្ន និងព្រះសកទាគាមីទាំងនោះ តាំងនៅក្នុងកាមលោកនេះ តែលោកនៅក្នុងព្រហ្មលោក។*

**ពហិទ្ធាសំយោជនោ=** *ព្រះអនាគាមី អ្នកនៅក្នុងរូបភព ប្រៀបដូចនិងកូនគោ ដែលគេចងទុកខាងក្រៅរោង ខ្លួនវាក៏ដេកនៅខាងក្រៅរោងដែរ ព្រោះថា គ្រឿងចង គឺសំយោជនៈនៃព្រះអនាគាមីនោះនៅខាងក្រៅអំពីកាមលោក សូម្បីខ្លួនលោកក៏តាំងនៅខាងក្រៅកាមលោកដូចគ្នា ។ ចំណែកព្រះអនាគាមី អ្នកស្ថិតនៅក្នុងកាមលោកនេះ ប្រៀបដូចនិងកូនគោ ដែលគេចងខាងក្រៅរោង តែខ្លួន*

ដេកនៅខាងក្នុងរោង ព្រោះថាគ្រឿងចង របស់អនាគាមីនោះ នៅក្នុងរូបភពនិងអរូបភព តែលោកនៅក្នុងកាមភពនេះ។

ចប់បុគ្គលមានសញ្ញោជនខាងក្នុងជាដើម

## (១១). បុគ្គលមិនក្រោធជាដើម

**១. អក្កោធនោ=** *បុគ្គលមិនមានសេចក្ដីក្រោធ។*

**២ . អនុបនាហី=** *បុគ្គលមិនចងសេចក្ដីក្រោធទុក។*

## អធិប្បាយ

**អក្កោធនោ=** *ការមិនកាចសាហាវ ការមិនអាក្រក់ជូជាតិ ពោលគឺ ទន់ភ្លន់ ត្រជាក់ ដែលចាត់បានថា ជាសភាវៈចូលទៅធ្វើឱ្យស្ងប់រម្ងាប់នូវសេចក្ដីក្ដៅក្រហាយនៃចិត្ត គឺបានដល់ អទោសៈនោះឯងដែលដល់នូវឋានៈជាមូល ហៅថា អទោសមូល, ដល់នូវឋានៈជាកម្មបទ ហៅថា អព្យាបាទ , ដល់នូវឋានៈជាព្រហ្មវិហារ ហៅថាមេត្តា។ អទោសនោះអាចធ្វើឱ្យមានកំលាំងរហូតដល់យកឈ្នះសេចក្ដីក្រោធឈ្នះពៀរវេរាបានដោយការចម្រើននូវមេត្តា។*

**អនុបនាហី=** *ការមិនមានការចងសេចក្ដីក្រោធដែលនឹងកើតតទៅទៀត មិនមានភាពគុំគួនដែលនឹងឱ្យទោសៈចិត្តប្បាទកើតម្ដងទៀត នេះឈ្មោះថា ការមិនចងសេចក្ដីក្រោធទុក។ បទថាៈ* **បហី-**

នោ បានដល់ សេចក្តីក្រោធបុគ្គលលះបានហើយ ដោយវិក្ខម្ភន-ប្បហាន ដោយតទង្គប្បហាន ឬក៏ដោយសមុច្ឆេទប្បហាន។

ចប់បុគ្គលមិនក្រោធជាដើម

## (១២). បុគ្គលមិនលុបគុណគេជាដើម

**១. អមក្ខី=** បុគ្គលមិនលុបគុណគេ។

**២. អបឡាសី =**បុគ្គលមិនប្រណាំងវាសនា។

អធិប្បាយ

**១. អមក្ខី =** បណ្តាធម៌ទាំងនោះ ការលុបគុណគេ តើដូចម្តេច ។ ការលុបគុណ អាការលុបគុណ ភាពនៃសេចក្តីលុបគុណ ការវេ-ឃ្នើស អំពើវេឃ្នើស ណានេះហៅថា បុគ្គលលុបគុណគេ ។ បុគ្គលដែលលះបង់ការលុបគុណនេះ ហៅថា បុគ្គលមិនលុបគុណគេ ។

**២.អបឡាសី =** បណ្តាធម៌ទាំងនោះ ការប្រណាំងវាសនា តើដូចម្តេច ។ ការប្រណាំងវាសនា អាការប្រណាំងវាសនា ភាពនៃការប្រណាំងវាសនា សេចក្តីប្រណាំងវាសនា អាការប្រណាំងវាសនា ហេតុជាទីតាំងនៃវិវាទ សេចក្តីកាន់យកជាគូ ការមិនលះបង់ ណានេះហៅថា ការប្រណាំងវាសនា ។បុគ្គលដែលលះបង់ការប្រណាំងវាសនា នេះហៅថា បុគ្គលមិនប្រណាំងវាសនា ។

ចប់បុគ្គលមិនលុបគុណគេជាដើម

## (១៣). បុគ្គលមិនមានសេចក្តីប្រណែនជាដើម

១. **អនិស្សុកី** = បុគ្គលមិនមានសេចក្តីប្រណែន។

២. **អមច្ឆរី** = បុគ្គលមិនមានសេចក្តីកំណាញ់។

## អធិប្បាយ

**អនិស្សុកី** = បុគ្គលមិនមានសេចក្តីប្រណែន តើដូចម្តេច ។ បណ្តាធម៌ទាំងនោះ សេចក្តីប្រណែនតើដូចម្តេច ។ ការប្រណែន អាការប្រណែន ភាពនៃសេចក្តីប្រណែន ការឈ្នានីស អាការឈ្នានីស ភាពនៃសេចក្តីឈ្នានីស ក្នុងលាភ សក្ការៈ ការគោរព ការរាប់អាន ការថ្វាយបង្គំ និងការបូជា របស់បុគ្គលដទៃណា នេះហៅថា សេចក្តីប្រណែន ។ បុគ្គលដែលលះបង់សេចក្តីប្រណែននេះ នេះហៅថា បុគ្គលមិនមានសេចក្តីប្រណែន ។

២. **អមច្ឆរី** = បុគ្គលមិនមានសេចក្តីកំណាញ់ តើដូចម្តេច ។ បណ្តាធម៌ទាំងនោះ សេចក្តីកំណាញ់តើដូចម្តេច ។ សេចក្តីកំណាញ់ ៥យ៉ាង គឺ កំណាញ់អាវាស ១ កំណាញ់ត្រកូល ១ កំណាញ់លាភ ១ កំណាញ់សេចក្តីសរសើរ ១ កំណាញ់ធម៌ ១ ការកំណាញ់អាការកំណាញ់ ភាពនៃសេចក្តីកំណាញ់ សេចក្តីប្រាថ្នាខ្លាំង សេចក្តី

កំណាញ់រឹង សេចក្តីស្វិតស្វាញ ចិត្តហួងហែងមិនរើសមុខ ណាដែលមានសភាពដូច្នេះ នេះហៅថា សេចក្តីកំណាញ់។ បុគ្គលដែលលះបង់សេចក្តីកំណាញ់នេះ នេះហៅថា បុគ្គលមិនមានសេចក្តីកំណាញ់ ។ ការសប្បាយរីករាយនឹងសម្បត្តិរបស់អ្នកដទៃដែលគេបាន គឺជាតួនៃមុទិតាចេតសិក ដែលជាសត្រូវនិងឥស្សា (ច្រណែន) ។ មុទិតា មានការត្រេកអរនឹងសម្បត្តិរបស់អ្នកដទៃជាលក្ខណៈ ។

ចប់បុគ្គលមិនមានសេចក្តីច្រណែនជាដើម

# (១៤). បុគ្គលមិនអួតអាងជាដើម

១. **អសឋោ** = បុគ្គលមិនមានអំនួត ។

២. **អមាយាវី** = បុគ្គលមិនមានមាយា។

## អធិប្បាយ

១. **អសឋោ** = បុគ្គលជាអ្នកមិនអួតអាង តើដូចម្តេច ។ បណ្តាធម៌ទាំងនោះ សេចក្តីអួតអាង តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកអួតអាង អែបអប មានការអួតអាង អាការអួតអាង ភាពនៃការអួតអាង សេចក្តីរឹងរូស សេចក្តីរឹងត្អឹង ការបោកប្រាស់ សេចក្តីបោកប្រាស់ ណា នេះហៅថា សេចក្តីអួតអាង ។ បុគ្គលដែលលះបង់សេចក្តីអួតអាងនេះ នេះហៅថា បុគ្គលជាអ្នកមិនអួតអាង ។

២.**អមាយាវី** = បុគ្គលមិនមានមាយា តើដូចម្តេច ។ បណ្តាធម៌ទាំងនោះ មាយា តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត តាំងទុកនូវសេចក្តីប្រាថ្នាដ៏លាមក ព្រោះហេតុបិទបាំងទុច្ចរិតនោះ ប្រាថ្នាថា កុំឱ្យគេស្គាល់អញ ត្រិះរិះថា កុំឱ្យគេស្គាល់អញ ពោលពាក្យថា កុំឱ្យគេស្គាល់អញ ព្យាយាមដោយកាយថា កុំឱ្យគេស្គាល់អញ មាយា ភាពនៃបុគ្គលមានមាយា ការបិទបាំងទោស ការ

*បញ្ឆោត ការបំភាន់ ការបោះចោលនូវបាប(សម្ដែងអាការហាក់ដូចជាខ្លួនបោះចោលនូវបាប) ការរក្សាទុកនូវទោស ការលាក់ ការលាក់ភ្ជិត ការបិទបាំងនូវបាប ការបិទបាំងភ្ជិត អំពើមិនរាក់ អំពើមិនធ្វើឱ្យប្រាកដ ការបិតបាំងជិត កិរិយាដ៏លាមក ណា ដែលមានសភាពដូច្នេះ នេះហៅថា មាយា ។ បុគ្គលដែលលះបង់មាយានេះ នេះហៅថា បុគ្គលមិនមានមាយា ។*

ចប់បុគ្គលមិនអួតអាងជាដើម

## (១៥). បុគ្គលមានសេចក្តីខ្មាសបាបជាដើម

**១. ហិរិមា** = *បុគ្គលមានសេចក្តីខ្មាសបាប។*

២. **ឱត្តប្បី** = *បុគ្គលមានសេចក្តីខ្លាចបាប។*

### *អធិប្បាយ*

**១.ហិរិមា**= *បុគ្គលមានសេចក្តីខ្មាសបាប តើដូចម្ដេច ។ បណ្ដាធម៌ទាំងនោះ សេចក្តីខ្មាសបាប តើដូចម្ដេច ធម្មជាតណា ដែលបុគ្គលខ្មាស ដោយអំពើ ដែលគេត្រូវខ្មាស ខ្មាសដោយការគប់ប្រសព្វនិងធម៌ជាអកុសលដ៏លាមក នេះហៅថា សេចក្តីខ្មាសបាប ។ បុគ្គលប្រកបដោយសេចក្តីខ្មាសបាបនេះ ឈ្មោះថា បុគ្គលមានសេចក្តីខ្មាសបាប។*

២.**ឱត្តប្បី**= បុគ្គលមានសេចក្ដីខ្លាចបាប តើដូចម្ដេច ។ បណ្ដាធម៌ទាំងនោះ សេចក្ដីខ្លាចបាប តើដូចម្ដេច ។ ធម្មជាតណា ដែលបុគ្គលខ្លាច ដោយអំពើដែលគេត្រូវខ្លាច ខ្លាចដោយការភប់ប្រសព្វ និងធម៌ជាអកុសលធម៌ដ៏លាមក នេះហៅថា សេចក្ដីខ្លាចបាប ។ បុគ្គលប្រកបដោយសេចក្ដីខ្លាចបាបនេះ ឈ្មោះថា បុគ្គលមានសេចក្ដីខ្លាចបាប ។

***សេចក្ដីអធិប្បាយក្នុងអភិធម្មត្ថសង្គហៈ*** ៖ ធម៌ទាំងពីរនេះរមែងប្រព្រឹត្តទៅជាមួយគ្នាជានិច្ច គឺចិត្តដួងណាមានហិរិ ចិត្តដួងនោះមានឱត្តប្ប, ចិត្តដួងណាមានឱត្តប្បៈចិត្តដួងនោះមានហិរិ។ ដើម្បីងាយក្នុងការកំណត់ធម៌ទាំងពីរនេះឱ្យផ្សេងគ្នា សូមលើកធម៌ទាំងពីរនេះជាឧបមាដូច្នេះថា ៖

**ហិរិ** = មានការប្រព្រឹត្តទៅដូចជាកុលស្ត្រី, ប្រៀបដូចជាកុលស្ត្រីប្រារព្ធនូវចរិយាមារយាទ សេចក្ដីប្រព្រឹត្តល្អអស់កាលដ៏យូររបស់ខ្លួន កើតសេចក្ដីគោរពក្នុងខ្លួនឡើងហើយក៏រមែងវៀសនូវអំពើជាមន្ទិលដល់ខ្លួនមានការប្រព្រឹត្តកន្លងចិត្តស្វាមីជាដើមរមែងមិនធ្វើនូវកម្មដូច្នោះ សូម្បីក្នុងទីកំបាំងឡើយ យ៉ាងណាមិញ, ហិរិដែលកើតឡើងព្រោះប្រារព្ធហេតុខាងក្នុង មានភាវៈជាបុគ្គលខ្ពង់ខ្ពស់ដោយជាតិត្រកូលជាដើមរបស់ខ្លួន កើតនូវសេចក្ដីគោរព

ក្នុងខ្លួនឡើងហើយ រមែងខ្ពើមនូវអំពើបាប ជាហេតុឱ្យបុគ្គលមិនធ្វើបាប សូម្បីក្នុងទីកំបាំង ក៏យ៉ាងនោះដែរ។

**ឱត្តប្ប =** មានការប្រព្រឹត្តទៅដូចស្ត្រីពេស្យា, ប្រៀបដូចជាស្ត្រីពេស្យាដែលអាស្រ័យនូវរូបកាយសម្រាប់ចិញ្ចឹមជីវិត ប្រារព្ធដល់ការដែលបុគ្គលដទៃតិះដៀល ឬប្រមាថមើលងាយ កើតនូវសេចក្ដីគោរពក្នុងបុគ្គលដទៃហើយ ក៏រមែងតក់ស្លុតចំពោះការដែលបុគ្គលដទៃដឹងនូវការប្រព្រឹត្តអាក្រក់របស់ខ្លួនហើយតិះដៀល ទើបមិនធ្វើកម្មនោះៗ ក្នុងទីវាលឡើយ យ៉ាងណាមិញ, ឱត្តប្បៈដែលកើតឡើង ព្រោះបុគ្គលប្រារព្ធហេតុខាងក្រៅ មានបុគ្គលដទៃតិះដៀលជាដើម កើតនូវសេចក្ដីគោរពក្នុងបុគ្គលដទៃហើយ រមែងតក់ស្លុតចំពោះបាបទុច្ចរិតទាំងឡាយ ជាហេតុឱ្យបុគ្គលវៀរចាកមិនធ្វើនូវបាបនោះៗ ក៏យ៉ាងនោះដែរ។

ចប់បុគ្គលមានសេចក្ដីខ្មាសបាបជាដើម

## (១៦). បុគ្គលប្រដៅងាយជាដើម

**១. សុវចោ** = បុគ្គលប្រដៅងាយ ។

**២. កល្យាណមិត្តោ** =បុគ្គលមានមិត្តល្អ។

### អធិប្បាយ

**សុវចោ=** *ភាពនៃបុគ្គលដែលអ្នកដទៃងាយក្នុងការប្រដៅ ភាពនៃបុគ្គលប្រកបដោយការទទួលបង្គាប់ ចំពោះសហធម្មិកដែលស្តីប្រដៅ នេះហៅថា* ***សោវចស្សតា*** *(ភាពនៃបុគ្គលដែលគេប្រដៅបានដោយងាយ)។* ***សុវចោ*** *អង្គធម៌បានដល់ កាយមុទុតា ចិត្តមុទុតាចេតសិក (ភាពទន់នៃកាយ ភាពទន់នៃចិត្ត) ដែលជាបដិបក្ខនិង ទិដ្ឋិ និងមានះ ដែលជាអ្នកធ្វើភាពរឹងត្អឹងនៃកាយនិងចិត្ត។*

ធម៌១៦ជាំឱ្យប្រៃដោងាយ[20]

*១. មិនលុះក្នុងអំណាចនៃសេចក្តីប្រាថ្នាលាមក ។*

*២. មិនលើកខ្លួន មិនបន្ទោសបង្អាប់អ្នកដទៃ ។*

*៣. មិនមានសេចក្តីក្រោធគ្របសង្កត់។*

*៤.ជាអ្នកមិនក្រោធ មិនចងគំនុំទុកព្រោះសេចក្តីក្រោធជាហេតុ ។*

*៥.ជាអ្នកមិនក្រោធ មិនជេរប្រទេចព្រោះសេចក្តីក្រោធជាហាតុ ។*

*៦. ជាអ្នកមិនក្រោធ មិនបញ្ចេញវាចាជិតសេចក្តីក្រោធ ។*

*៧. ត្រូវអ្នកដទៃចោទហើយ មិនខឹងតបនឹងអ្នកចោទវិញ។*

*៨. ត្រូវអ្នកដទៃចោទហើយ ក៏មិនបណ្តេញអ្នកចោទវិញ។*

*៩. ត្រូវអ្នកដទៃចោទហើយ ក៏មិននិយាយគ្របសង្កត់ដល់អ្នកចោទវិញ។*

---

[20] *អនុមានសូត្រ បិ.២០ ទំ.៣៩៨*

១០. ត្រូវអ្នកដទៃចោទហើយ ក៏មិននិយាយបន្ទែបន្ទប់នូវអ្នកចោទ ដោយហេតុដទៃ ឬហេតុផ្សេងៗ មិននិយាយគេចកែ ដោយសំដីខាងក្រៅ មិនធ្វើសេចក្តីក្រោធ សេចក្តីប្រទូស្ត និងសេចក្តីអាក់អន់ចិត្តឱ្យប្រាកដឡើង។

១១. អ្នកដទៃចោទហើយ ក៏ឆ្លើយមិនទាល់ក្នុងដំណើររបស់ខ្លួន ។

១២. មិនលុបគុណគេ មិនប្រទូស្តវាសនា ។

១៣. មិនច្រណែន មិនកំណាញ់ ។

១៤. ជាអ្នកមិនអួតអាង មិនមានពុតមាយា ។

១៥. ជាអ្នកមិនរឹងរូសមិនមើលងាយគេ ។

១៦.ជាអ្នកមិនប្រកាន់យកតាមតែសេចក្តីឃើញរបស់ខ្លួនមិនប្រកាន់មាំ លះបង់ទិដ្ឋិបានដោយងាយ ។

**កល្យាណមិត្ត =** បុគ្គលណាមានសទ្ធា មានសីល ជាពហុស្សូត មានចាគៈ មានបញ្ញា ការសេពគប់ ការសេពដោយស្និទ្ធស្នាល ការសេពដោយត្រូវគំនិតគ្នា សេចក្តីស្រឡាញ់ជិតដិតនឹងគ្នា ភាពនៃបុគ្គលមូលមិត្តជាមួយគ្នា ចំពោះបុគ្គលទាំងនោះណា នេះហៅថា កល្យាណមិត្តតា(ភាពនៃបុគ្គលមានមិត្តល្អ)។

ចប់បុគ្គលប្រដៅងាយជាដើម

# (១៧). បុគ្គលមានទ្វាររក្សាហើយក្នុងឥន្ទ្រិយទាំងឡាយ ជាដើម

**១ .ឥន្ទ្រិយេសុ គុត្តទ្វារោ=** *បុគ្គលមានទ្វាររក្សាហើយ ក្នុងឥន្ទ្រិយទាំង៦។*

**២ .ភោជនេ មត្តញ្ញូ =** *បុគ្គលអ្នកដឹងប្រមាណក្នុងភោជន។*

## *អធិប្បាយ*

**ឥន្ទ្រិយេសុ គុត្តទ្វារោ =** *បុគ្គលមានសេចក្តីរក្សាក្នុងឥន្ទ្រិយ តើដូចម្តេច ។ បណ្តាធម៌ទាំងនោះ ភាពនៃបុគ្គលមានទ្វាររក្សាក្នុងឥន្ទ្រិយ តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ* ***ឃើញរូបដោយចក្ខុ*** *ហើយជាអ្នកមិនកាន់យកនិមិត្ត មិនកាន់យកអនុព្យញ្ជនៈ អភិជ្ឈា និងទោមនស្ស ជាអកុសលធម៌ដ៏លាមក គប្បីគ្របសង្កត់បុគ្គលដែលមិនសង្រួមចក្ខុន្ទ្រិយនុ៎ះ ព្រោះហេតុមិនសង្រួមក្នុងចក្ខុន្ទ្រិយណាក៏ប្រតិបត្តិដើម្បីសង្រួមក្នុងចក្ខុន្ទ្រិយនោះ រក្សាចក្ខុន្ទ្រិយ ដល់នូវសេចក្តីសង្រួមក្នុងចក្ខុន្ទ្រិយ( សូម្បីសោតទ្វារ ឃានទ្វារ ជិវ្ហាទ្វារ កាយទ្វារ និងមនោទ្វារក៏មានអត្ថដូចគ្នា)។*

*បទថា* **ចក្ខុនា :** *ដោយចក្ខុ" ជាដើម គប្បីជ្រាបដោយន័យដែលពោលហើយនោះចុះ ។* ***ន និមិត្តគ្គាហី ហោតិ*** *= ជាអ្នកមិនកាន់យកនិមិត្ត" បានដល់ រមែងមិនកាន់យកនិមិត្ត មានប្រការតាម*

ដែលបានពោលហើយ ដោយអំណាចឆន្ទរាគៈ ។ សូម្បីបទដ៏សេស គប្បីជ្រាបដោយន័យផ្ទុយគ្នានឹងពាក្យដែលបានពោលហើយនោះ មានប្រការដូច្នេះចុះ ។

ក៏ពាក្យដែលខ្ញុំបានពោលទុកខាងក្រោយថា “ កាលបើភាពជាអ្នកទ្រុស្តសីលជាដើម កើតក្នុងជវនចិត្ត កាលបើអសំវរៈនោះកំពុងមាន សូម្បីទ្វារក៏រមែងជាការដែលមិនបានឃុំគ្រង សូម្បីភវង្គ សូម្បីវិថីចិត្តទាំងឡាយ មានអាវជ្ជនៈចិត្តជាដើមក៏ជាការមិនបានឃុំគ្រង” យ៉ាងណា ក្នុងអធិការនេះ ក៏យ៉ាងនោះដែរ , កាលបើសីលជាដើម កើតឡើងក្នុងជវនចិត្តនោះ សូម្បីទ្វារក៏ជាការដែលបានឃុំគ្រងហើយ សូម្បីភវង្គ សូម្បីវិថីចិត្តទាំងឡាយ មានអាវជ្ជនៈចិត្តជាដើម ក៏រមែងជាការដែលបានឃុំគ្រងហើយ , ដូចជាអ្វី? ដូចជាទ្វារព្រះនគរដែលបិទល្អហើយ ខាងក្នុងផ្ទះមិនបានបិទទុក ក៏ពិតមែន, ក៏ប៉ុន្តែថា សម្ភារវត្ថុទាំងអស់ខាងក្នុង ព្រះនគរ ក៏រមែងជាការដែលបានរក្សាល្អហើយ ឃុំគ្រងល្អហើយដែរ , ព្រោះកាលបើទ្វារព្រះនគរបិទហើយ ពួកចោរក៏ចូលទៅមិនបាន , យ៉ាងណា កាលបើសីលជាដើម កើតក្នុងជវនចិត្តហើយ សូម្បីទ្វារក៏ជាការដែលបានឃុំគ្រងហើយ សូម្បីភវង្គ សូម្បីវិថីចិត្តទាំងឡាយមានអាវជ្ជនៈជាដើមក្តី ក៏រមែងជាការដែលបានឃុំគ្រងហើយ យ៉ាងនោះដែរ,

ព្រោះហេតុដូច្នោះ សំវរៈស្ងួម្បីកើតនៅក្នុងជវនចិត្ត ក៏ព្រះមានព្រះភាគត្រាស់ថា "**សំវរៈក្នុងចក្ខុន្ទ្រិយ**" ។

សូម្បីបទមានជាអាទិ៍ថា បានឮសំឡេងដោយសោតៈជាដើម ក៏មានន័យដូចគ្នានេះដែរ ។

**២. ភោជនេ មត្តញ្ញូ=** ភិក្ខុកាលទទួលបិណ្ឌបាតដើម្បីបរិភោគ ត្រូវពិចារណាដោយអង្គ១២ដោយឧបាយនៃប្រាជ្ញា យ៉ាងនេះថា ៖

អង្គ១២របស់ភិក្ខុអ្នកឆាន់អាហារ

១. មិនឆាន់ដើម្បីនឹងលេង ។

២.មិនឆាន់ដើម្បីឲ្យកើតបុរិសមានះស្រវឹងដូចអ្នកចម្បាប់ប្រដាល់ ។

៣. មិនឆាន់ដើម្បីប្រដាប់តាក់តែងរាងកាយដូចស្ត្រីក្នុងបុរី។

៤. មិនឆាន់ដើម្បីធ្វើឲ្យផូរផង់ពណ៌សម្បុរដូចអ្នកលេងរបាំ ។

៥. ឆាន់ចង្ហាន់នេះគ្រាន់តែឲ្យតាំងនៅនៃរាងកាយប៉ុណ្ណោះ ។

៦. ដើម្បីញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅ ។

៧. ដើម្បីបំបាត់បង់នូវសេចក្តីលំបាក គឺសេចក្តីស្រេកឃ្លាន។

៨. ដើម្បីទំនុកបម្រុងនូវព្រហ្មចារ្យ។

៩. ឆាន់ចង្ហាន់ដោយធ្វើទុកក្នុងចិត្តថា អាត្មាអញនឹង កំចាត់បង់នូវវេទនាចាស់ គឺសេចក្តីស្រេកឃ្លាន ដែលមានហើយផង ។

១០. មិនញុំាំងវេទនាថ្មី គឺ ឆ្អែតហួសប្រមាណឲ្យកើតឡើងផង ។

១១. ការតាំងនៅនៃជីវិតនឹងមានដល់អាត្មាអញ។

១២, ការមិនមានទោស និងការនៅជាសុខ ។

បណ្តាអង្គទាំង១២នេះ អង្គ៤ខាងដើមជាអង្គហាមប្រាម អង្គ៨បន្ទាប់ជាអង្គដែលអ្នកដឹងប្រមាណក្នុងការបរិភោគអាហារ។

## ការពិចារណាបច្ច័យចែកជា២ កាល

**១.បដិលាភកាល** = ពិចារណាក្នុងកាលបានបច្ច័យគឺពិចារណាដោយអំណាចធាតុមនសិការៈ និងបដិកូលមនសិការៈ ។

**២.បរិភោគកាល** = ពិចារណាក្នុងកាលបរិភោគបច្ច័យ គឺពិចារណាដោយអំណាចធាតុមនសិការៈ និងបដិកូលមនសិការៈ។

**ពាក្យថា ធាតុវសេន វា** បានដល់ ជាប់ដោយអំណាចនៃមនសិការថា ជាធាតុ យ៉ាងនេះថា "បច្ច័យមានដុំបាយជាដើម និងបុគ្គលអ្នកបរិភោគ ប្រើប្រាស់បច្ច័យ មានដុំបាយជាដើម នេះណា , នេះត្រឹមតែជាធាតុ ដែលប្រព្រឹត្តទៅតាមបច្ច័យប៉ុណ្ណោះ" ។

ពាក្យថា **ធាតុវសេន វា** បានដល់ គប្បីឃើញសេចក្តីយ៉ាងនេះថា នេះត្រឹមតែជាធាតុ មានបឋវីធាតុជាដើម មិនមែនសត្វ មិន

មែនជីវៈ គឺដុំបាយជាដើម និងបុគ្គលអ្នកបរិភោគដុំបាយជាដើមនោះ ដែលពិចារណា តាំងទុកដោយធាតុមនសិការៈ។

ពាក្យថា **បដិកូលវសេន វា** បានដល់ ជាប់ដោយអំណាចនៃសេចក្ដីសម្គាល់ថា ជារបស់បដិកូល ក្នុងបិណ្ឌបាត គឺក្នុងអាហារប៉ុណ្ណោះ, ម្យ៉ាងទៀត ជាប់ដោយអំណាចនៃមនសិការៈ ថា ជាបដិកូលយ៉ាងនេះថា“**ក៏បច្ច័យមានចីវរជាដើមទាំងអស់ពួកនេះ មិនទាន់គួរខ្ពើមរអើមទេ, តែល្មមមកប៉ះត្រូវកាយស្អុយនេះហើយ ក៏ក្លាយជារបស់គួរខ្ពើមរអើមក្រៃពេក**”។

ពិតមែន ការបរិភោគរបស់ភិក្ខុ អ្នកបរិភោគបច្ច័យមានចីវរជាដើម ការ**ពិចារណាដោយអំណាចធាតុ** ឬ**ដោយអំណាចជារបស់បដិកូល** សូម្បីក្នុងបដិលាភកាលដែលខ្លួនតាំងទុកហើយ បរិភោគឱ្យលើសអំពីបដិលាភកាលនោះទៅ មិនមានទោសឡើយ សូម្បីក្នុងបរិភោគកាល។

បទថា “**អយំ វុច្චតិ** = នេះហៅថា ការបរិភោគដោយការពិចារណា ប្រព្រឹត្តទៅដោយអំណាចនៃការដឹងនូវប្រមាណដែលគួរស្វែងរកការទទួលនិងការបរិភោគ នេះហៅថា**ភោជនេ មត្តញ្ញុតា**។

ចប់បុគ្គលមានទ្វាររក្សាហើយក្នុងឥន្ទ្រិយទាំងឡាយជាដើម

## (១៨). បុគ្គលមានសតិតាំងមាំជាដើម

**១. ឧបដ្ឋិតស្សតិ=** *បុគ្គលមានស្មារតីតាំងកល់មាំ។*

**២. សម្បជានោ=** *បុគ្គលអ្នកដឹងខ្លួន។*

***អធិប្បាយ***

**ឧបដ្ឋិតស្សតិ= សរណំ សតិ អសម្មោសោ** *ប្រែថា សេចក្តីរឭកបាន ឈ្មោះថា សតិ បានដល់មិនវង្វេង អធិប្បាយថា រមែងមិនវង្វេង (មិនភាន់ច្រឡំ)នូវធម៌ជាកុសល ធម៌ជាអកុសល ធម៌ដែលមានទោស ធម៌ដែលគ្មានទោស ធម៌ថោកទាប ធម៌ប្រណីត ធម៌ខ្មៅ ធម៌ស ធម៌សមរម្យ រមែងមិនវង្វេងធម៌ក្នុងធម៌ទាំងឡាយថា* ***"នេះគឺសតិប្បដ្ឋាន៤ ,នេះគឺសម្មប្បធាន៤ ,នេះគឺ ឥទ្ធិបាទ៤ ,នេះគឺឥន្ទ្រិយ ៥ ,នេះគឺពលៈ៥, នេះគឺពោជ្ឈង្គ៧, នេះគឺអរិយមគ្គមានអង្គ៨, នេះគឺសមថៈ ,នេះគឺវិបស្សនា ,នេះគឺវិជ្ជា ,នេះគឺវិមុត្តិ"*** [៧] *ដូច្នេះ។*

**សម្បជានោ =** *បញ្ញិន្ទ្រិយ៍ (បញ្ញា)* ***មានសេចក្តីអធិប្បាយថា :*** *បញ្ញាដែលដឹងច្បាស់ថា នេះជាទុក្ខ (ទុក្ខសច្ចៈ) , ដឹងច្បាស់តាមពិតថា នេះជាហេតុនាំឱ្យកើតទុក្ខ ( ទុក្ខសមុទយសច្ចៈ), ដឹងច្បាស់តាមពិតថា នេះជាសភាវៈរំលត់ទុក្ខ (ទុក្ខនិរោធអរិយសច្ចៈ), ដឹងច្បាស់*

---

[៧] *អភិធម្មត្ថសង្គហៈបរិច្ឆេទ*

*តាមពិតថា នេះជាបដិបទាឱ្យបានដល់នូវធម៌រំលត់ទុក្ខ (ទុក្ខនិរោធ-គាមិនីបដិបទាអរិយសច្ចៈ) ។ និងបញ្ញាដែលដឹងច្បាស់ក្នុងខន្ធដែលជាចំណែកខាងដើម ដឹងច្បាស់ក្នុងខន្ធដែលជាចំណែកខាងចុង ដឹងច្បាស់ក្នុងចំណែកខាងដើមនិងខាងចុង ដឹងច្បាស់ក្នុងពួកធម៌ដែលកើតឡើង ព្រោះអាស្រ័យបច្ច័យនោះៗ(បដិច្ចសមុប្បាទធម៌) និងបញ្ញាការដឹងច្បាស់ ការសន្សំ ការប្រមូល ការពិចារណា...និងដឹងច្បាស់ កម្មស្សកតាបញ្ញា(មើលក្នុងទិដ្ឋិសម្បន្នោ)។*

ចប់បុគ្គលមានសតិតាំងមាំជាដើម

## (១៩). បុគ្គលបរិបូណ៌ដោយសីលជាដើម

១. **សីលសម្បន្នោ** = *បុគ្គលបរិបូណ៌ដោយសីល។*

២. **ទិដ្ឋិសម្បន្នោ** = *បុគ្គលបរិបូណ៌ដោយទិដ្ឋិ។*

*អធិប្បាយ*

**សីលសម្បន្នោ**= *ការមិនប្រព្រឹត្តល្មើសប្រកបដោយកាយ ការមិនប្រព្រឹត្តល្មើសប្រកបដោយវាចា ការមិនប្រព្រឹត្តល្មើសប្រកបដោយកាយ និងដោយវាចា នេះហៅថា បុគ្គលបរិបូណ៌*

ដោយសីល ។ ការសង្រួមក្នុងសីលទាំងអស់ ក៏ឈ្មោះថា ការបរិបូ-ណ៌ដោយសីលដែរ។ **នេះហៅថា បរិបូណ៌ដោយសីល។**

## អានិសង្សសីល១៧ យ៉ាង[២២]

១.ជាទីស្រលាញ់ ជាទីពេញចិត្ត ជាទីគោរព ជាទីសរសើររបស់ពួកសព្រហ្មចារីទាំងឡាយ។

២. រមែងបាននូវបច្ច័យ៤ មានចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ។

៣.ភិក្ខុអ្នកបរិបូណ៌ដោយសីល ប្រើប្រាស់បច្ច័យរបស់អ្នកណា អ្នកនោះរមែងបានបុណ្យច្រើន បានអានិសង្សច្រើន ។

៤.រមែងអនុគ្រោះដល់ញាតិនិងសាលោហិតដែលលះលោកនេះទៅហើយ ឱ្យរួចផុតពីអបាយ។

៥. រមែងគ្របសង្កត់នូវសេចក្តីអផ្សុក[២៣] និងសេចក្តីត្រេកអរ[២៤]

៦. គ្របសង្កត់នូវអារម្មណ៍ដែលគួរឱ្យខ្លាច គួរឱ្យស្ញើប។

៧. រមែងបាននូវរូបជ្ឈានទាំង៤ដោយមិនលំបាក ។

---

[២២] អាកង្ខេយ្យសូត្រ បិដកលេខ២០ ទំព័រ២០៥។

[២៣] សេចក្តីអផ្សុកក្នុងអធិកុសលធម៌ ឬ ក្នុងសេនាសនស្ងាត់។

[២៤] បានដល់ តម្រេកក្នុងបញ្ចកាមគុណ។

៨. រមែងបាននូវអរូបជ្ឈានទាំង៤ដោយមិនលំបាក។

៩. រមែងបាននូវសោតាបន្នបុគ្គល។

១០. រមែងបាននូវសកទាគាមិបុគ្គល ។

១១. រមែងបាននូវអនាគាមិបុគ្គល។

១២. រមែងបាននូវឥទ្ធិវិធញ្ញាណច្រើនប្រការ។

១៣. រមែងបាននូវទិព្វសោតធាតុដ៏បរិសុទ្ធិ។

១៤.រមែងបាននូវបរចិត្តវិជ្ជា(ដឹងចិត្តអ្នកដទៃដោយចិត្តរបស់ខ្លួន

១៥.រមែងបាននូវបុព្វេនិវាសញ្ញាណ(រលឹកជាតិធ្លាប់អាស្រ័យនៅ)

១៦. រមែងបាននូវទិព្វចក្ខុដ៏បរិសុទ្ធកន្លងចក្ខុមនុស្សធម្មតា។

១៧. រមែងបាននូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ មិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ (បានជាព្រះអរហន្ត)។

**ទិដ្ឋិសម្បន្នោ** = ការយល់ថា ទានដែលបុគ្គលឲ្យហើយមានផល , ការបូជាធំមានផល, ការបូជាតូចមានផល, ផលវិបាក នៃកម្មដែលបុគ្គលធ្វើល្អនិងអាក្រក់មាន, លោកនេះមាន, លោកខាងមុខមាន, មាតាបិតាមានគុណ, ពួកសត្វជាឱបបាតិកកំណើតមាន, ពួកសមណព្រាហ្មណ៍ក្នុងលោកនេះ ជាអ្នកប្រព្រឹត្តល្អ ប្រតិបត្តិត្រូវដែលធ្វើឲ្យជាក់ច្បាស់នូវលោកនេះ និងលោកខាងមុខ ដោយបញ្ញា

ដ៏ឧត្តម ដោយខ្លួនឯង ហើយសម្តែងបាន មាន ។ ការដឹង ការដឹងច្បាស់ ។ល។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវណា ដែលមានសភាពដូច្នេះ ការបរិបូណ៌ ដោយទិដ្ឋិ ការឃើញត្រូវទាំងអស់ ក៏ឈ្មោះថាបរិបូណ៌ដោយទិដ្ឋិដែរ **បុគ្គលប្រកបដោយការបរិបូណ៌ដោយទិដ្ឋិនេះ ឈ្មោះថាអ្នកបរិបូណ៌ដោយទិដ្ឋិ ។**

## អត្ថាអធិប្បាយ អធិសីល អធិចិត្ត អធិបញ្ញា[25]

**សីល** = សីល មានសីល ៥ សីល ១០ ឈ្មោះថា សីលប៉ុណ្ណោះ។ ពិតមែន សីលនោះ កាលព្រះពុទ្ធឧប្បត្តិឡើងហើយក៏ដោយ មិនឧប្បត្តិឡើងក៏ដោយ ប្រព្រឹត្តទៅនៅក្នុងលោក។ កាលព្រះពុទ្ធឧប្បត្តិឡើងហើយ ព្រះពុទ្ធទាំងឡាយក្តី ព្រះសាវ័កទាំងឡាយក្តី រមែងដឹកនាំមហាជនឱ្យសមាទានក្នុងសីលនោះ ។ កាលព្រះពុទ្ធមិនទាន់បានឧប្បត្តិឡើង ព្រះបច្ចេកពុទ្ធ សមណៈព្រាហ្មណ៍ពួកកម្មវាទីប្រព្រឹត្តប្រកបដោយធម៌ ព្រះបាទចក្រពត្តិមហារាជ និងព្រះមហាសត្ត រមែងដឹកនាំមហាជនឱ្យសមាទាន (ក្នុងសីលនោះ) ។ ពួកសមណព្រាហ្មណ៍អ្នកជាបណ្ឌិតក៏រមែងសមាទាន (សីលនោះ) សូម្បីដោយខ្លួនឯង ។ សមណៈព្រាហ្មណ៍ជា

[25] អដ្ឋកថា សមន្តប្បាសាទិកា

ដើមទាំងនោះ កាលបំពេញកុសលធម៌នោះឱ្យបរិបូណ៌ហើយ រមែងសោយសម្បត្តិក្នុងពួកទេវនិងពួកមនុស្ស ។

**អធិសីល** = ចំណែកបាតិមោក្ខសំវរសីល លោកហៅថា អធិសីល ។ ពិតមែន បាតិមោក្ខសំវរសីលនោះ ជាសីលដ៏ក្រៃលែង និងខ្ពស់បំផុត ជាងបណ្តាលោកិយសីលទាំងអស់ ដូចព្រះអាទិត្យក្រៃលែងជាងពន្លឺទាំងឡាយ ដូចភ្នំសិនេរុ ខ្ពស់ជាងភ្នំទាំងឡាយដូច្នោះ រមែងប្រព្រឹត្តទៅបាន ចំពោះពុទ្ធុប្បាទកាលប៉ុណ្ណោះ ក្រៅពុទ្ធុប្បាទកាលមិនប្រព្រឹត្តទៅទេ ។ ដោយថា សត្វដទៃមិនអាចលើកបញ្ញត្តិនោះឡើងតាំងទុកបាន។ ក៏ព្រះពុទ្ធទាំងឡាយប៉ុណ្ណោះទ្រង់កាត់ក្រសែផ្លូវនៃការប្រព្រឹត្តវិនាសអស់ពីផ្លូវកាយទ្វារ និងវចីទ្វារ បានដាច់ខាត ដោយប្រការទាំងពួងហើយ ទើបទ្រង់បញ្ញត្តិសីលសំវរៈនោះទុក ដែលសមគួរដល់ការប្រព្រឹត្តកន្លងនោះៗ ។ មួយទៀត សីលដែលសម្បយុត្តដោយមគ្គនិងផលប៉ុណ្ណោះ ឈ្មោះថា សីលដ៏ក្រៃលែងជាងបាតិមោក្ខសំវរៈ ។

**ចិត្ត** = កាមាវចរកុសលចិត្ត ៨ និងសមាបត្តិចិត្ត ៨ ចំណែកលោកិយរួមចូលតែមួយគប្បីជ្រាបថា **ចិត្ត**ប៉ុណ្ណោះ, និងក្នុងកាលដែលព្រះពុទ្ធទ្រង់ឧប្បត្តិឡើង ឬមិនឧប្បត្តិឡើង ចិត្តនោះក៏ប្រព្រឹត្ត

ទៅ និងការសមាទាន ក៏គប្បីជ្រាបដោយន័យដែលពោលទុកហើយក្នុងសីលនុ៎ះឯង។

**អធិចិត្ត=** ចំណែកសមាបត្តិចិត្ត ៨ ដែលជាបាទនៃវិបស្សនា លោកហៅថា អធិចិត្ត ។ ពិតមែន អដ្ឋសមាបត្តិនោះជាចិត្តដ៏ក្រៃលែងនិងខ្ពស់បំផុតជាងលោកិយចិត្តទាំងអស់ ដូចអធិសីលក្រៃលែងជាង បណ្ដាសីលទាំងឡាយ ដូច្នោះ និងមាននៅចំពោះក្នុងពុទ្ធុប្បាទកាលប៉ុណ្ណោះ ក្រៅពុទ្ធុប្បាទកាលមិនមានទេ ។

**បញ្ញា=** កម្មស្សកតាញាណ[៦] (បញ្ញាដែលដឹងថា សត្វមានកម្មជារបស់ខ្លួន )ដែលប្រព្រឹត្តទៅដោយន័យមានជាដើមថា ទានដែលឱ្យហើយមានផល ការបូជាធំមានផល ឈ្មោះថា បញ្ញា ។ ពិតមែន កាលព្រះពុទ្ធឧប្បត្តិឡើងហើយក៏ដោយ មិនបានឧប្បត្តិឡើងក៏ដោយ បញ្ញានោះ ប្រព្រឹត្តទៅក្នុងលោក ។ កាលព្រះពុទ្ធឧប្បត្តិឡើងហើយ ព្រះពុទ្ធទាំងឡាយក្ដី ព្រះសាវ័កទាំងឡាយក្ដី រមែងដឹកនាំមហាជនឱ្យសមាទានក្នុងបញ្ញានោះ ។ កាលព្រះពុទ្ធមិនទាន់កើតឡើង ព្រះបច្ចេកពុទ្ធ សមណព្រាហ្មណ៍ ពួកកម្មវាទី

---

[៦] បណ្ដាកុសលកម្ម និងអកុសលកម្ម អកុសលធម៌ទាំងអស់ប៉ុណ្ណោះមិនមែនជារបស់ខ្លួន ព្រោះទម្លាយប្រយោជន៍ និងធ្វើឱ្យកើតអនត្ថៈ គឺមិនជាប្រយោជន៍មកឱ្យ។អដ្ឋកថា អដ្ឋសាលិនី

ប្រព្រឹត្តប្រកបដោយធម៌ ព្រះបាទចក្រពត្តិមហារាជ និងព្រះមហាពោធិសត្វរមែងដឹកនាំមហាជនឱ្យសមាទាន(ក្នុងបញ្ញានោះ) សត្វទាំងឡាយអ្នកជាបណ្ឌិតក៏សមាទាន សូម្បីដោយខ្លួនឯង ។ ពិតមែនអង្កុរទេវបុត្រ(កាលនៅជាមនុស្ស) បានថ្វាយទានអស់មួយម៉ឺនឆ្នាំ ។ វេលាមព្រាហ្មណ៍ ព្រះវេស្សន្តរ និងពួកមនុស្សជាបណ្ឌិតដទៃជាច្រើន ក៏បានថ្វាយ មហាទានហើយ ។ វេលាមព្រាហ្មណ៍ជាដើមទាំងនោះ កាលបំពេញកុសលធម៌នោះឱ្យបរិបូណ៌ហើយ ក៏បានសោយសម្បត្តិក្នុងពួកទេវតា និងក្នុងពួកមនុស្ស ។

**អធិបញ្ញា** = ចំណែកវិបស្សនាញាណ ដែលជាគ្រឿងកំណត់អាការៈ គឺត្រៃលក្ខណ៍លោកហៅថា អធិបញ្ញា ។ ពិតមែន អធិបញ្ញានោះ ជាបញ្ញាដ៏ក្រៃលែង និងខ្ពស់បំផុតជាងបណ្ដាលោកិយបញ្ញាទាំងអស់ ដូចអធិសីលនិងអធិចិត្ត ក្រៃលែងជាងនិងខ្ពស់បំផុតជាងបណ្ដាសីលនិងចិត្តទាំងឡាយ ដូច្នោះក្រៅព្រះពុទ្ធុប្បាទកាលហើយមិនប្រព្រឹត្តទៅក្នុងលោកទេ ។ ក៏បញ្ញាដែលសម្បយុត្តដោយមគ្គនិងផលនុ៎ះឯង ជាបញ្ញាដ៏ក្រៃលែងសូម្បីជាងវិបស្សនាញាណ ។

ចប់បុគ្គលបរិបូណ៌ដោយសីលជាដើម

# (២០). ទ្វេ បុគ្គលា ទុល្លភា លោកស្មឹ

(*បុគ្គល ២ ពួករកបានដោយក្រក្នុងលោក*)

១. **បុព្វការី** = *បុគ្គលជាបុព្វការី ។*

២. **កតញ្ញូកតវេទី** = *បុគ្គលជាកតញ្ញូ និងកតវេទី។*

*អធិប្បាយ*

**បុព្វការី** = *អ្នកធ្វើឧបការៈមុន។*

**កតញ្ញូកតវេទី** = *ការប្រកាសឧបការគុណដែលបុគ្គលដទៃធ្វើហើយ គឺធ្វើឧបការគុណឱ្យប្រាកដ។*

**បុគ្គល២ពួកនេះសម្ដែងដោយ៖** *អាគារិយបុគ្គល(គ្រហស្ថ), អនាគារិយបុគ្គល(បព្វជិត)។*

**គ្រហស្ថទាំងឡាយ**= *មាតា បិតា ឈ្មោះថា* **បុព្វការី** (*អ្នកធ្វើឧបការៈមុន*) ។ *បុត្តអ្នកប្រតិបត្តិ និងអភិវាទជាដើម ឈ្មោះថា* **កតវេទី** (*អ្នកដឹងឧបការគុណដែលបុព្វការីជនធ្វើហើយ*)។

**បព្វជិតទាំងឡាយ** = *អាចារ្យនិងឧបជ្ឈាយ៍ ឈ្មោះថា* **បុព្វការី** ។ *អន្តេវាសិក (អ្នកនៅរួមជាមួយអាចារ្យ) និងសទ្ធិវិហារិក(អ្នកនៅរួមជាមួយឧបជ្ឈាយ៍)អ្នកប្រតិបត្តិចំពោះអាចារ្យ និងឧបជ្ឈាយ៍ ឈ្មោះថា* **កតវេទី**។

**ន័យមួយទៀត** បុគ្គលណា កាលអ្នកដទៃមិនបានធ្វើឧបការៈទេ មិនសម្លឹងដល់ឧបការៈដែលអ្នកដទៃធ្វើក្នុងខ្លួន ហើយធ្វើឧបការៈអ្នកនោះមុនក៏ ឈ្មោះថា **បុព្វការី** ។

**មូលហេតុបុព្វការី និង កតញ្ញូកតវេទី ក្រក្នុងលោក**

**បុព្វការី**=មាតា និងបិតាមួយពួក អាចារ្យនិងឧបជ្ឈាយ៍មួយពួក ឧបការីបុគ្គលនោះ ឈ្មោះថារកបានដោយលំបាក ព្រោះភាវនៃសត្វទាំងឡាយ **ត្រូវតណ្ហាគ្របសង្កត់** ។

**កតញ្ញូកតវេទី** = បុគ្គលដែលប្រតិបត្តិដោយប្រពៃក្នុងមាតានិងបិតា ឬក្នុងអាចារ្យនិងឧបជ្ឈាយ៍ទាំងឡាយ កតញ្ញូកតវេទី បុគ្គលនោះ ឈ្មោះថា រកបានដោយលំបាក ព្រោះភាវៈនៃសត្វទាំងឡាយ **ត្រូវអវិជ្ជាគ្របសង្កត់** ។

បុគ្គលឯណា ដឹងឧបការៈ ដែលអ្នកដទៃធ្វើចំពោះខ្លួន ប្រកាសនូវឧបការៈដែលប្រព្រឹត្តទៅតាមសមគួរដល់ឧបការៈ ដែលអ្នកដទៃធ្វើហើយ អ្នកនោះ ឈ្មោះថា **កតញ្ញូកតវេទី** ។

ម្យ៉ាងទៀត បុគ្គលដែលមានមេត្តា ស្រឡាញ់រាប់អានដោយមិនមានហេតុ ឈ្មោះថា **បុព្វការី**។ បុគ្គលមេត្តាស្រឡាញ់រាប់អានដោយមានហេតុ ឈ្មោះថា **កតញ្ញូកតវេទី**។ ព្រះសម្មាសម្ពុទ្ធ ឈ្មោះថា **បុព្វការី** ។ អរិយសាវក ឈ្មោះថា **កតញ្ញូកតវេទី**។

***អដ្ឋកថាទុកនិបាត*** = *បណ្ដាបុគ្គល២ពួកនោះ បុព្វការីជនរមែងធ្វើសេចក្ដីសម្គាល់ថា "យើងជាអ្នកឱ្យបំណុល" ។ កតញ្ញូកតវេទីបុគ្គលដែលធ្វើតបជំនួសខាងក្រោយវិញ រមែងធ្វើសេចក្ដីសម្គាល់ថា "យើងជាអ្នកសងបំណុល"។*

ចប់បុគ្គល២ពួករកបានដោយក្រក្នុងលោក

## (២១). ទ្វេ បុគ្គលា ទុត្តប្បយា

## (បុគ្គល២ពួកគេចំអែតបានដោយក្រ)

**១. យោ ច លទ្ធំ លទ្ធំ និក្ខិបតិ**= *បុគ្គលដែលទុករបស់ដែលខ្លួនរកបានហើយបានហើយ។*

**២. យោ ច លទ្ធំ លទ្ធំ វិសជ្ជេតិ**= *បុគ្គលដែលលះបង់នូវរបស់ដែលខ្លួនរកបានហើយៗ។*

*អធិប្បាយ*

***បុគ្គលទី១***= *ភិក្ខុឯណា អាស្រ័យត្រកូលឧបដ្ឋាក ឬត្រកូលញាតិ កាលបើចីវរដែលគេប្រគេនចាស់ហើយ ក៏ប្រមូលចីវរដែលត្រកូលទាំងនោះប្រគេនហើយមិនប្រើប្រាស់ កាន់យកចីវរដែលត្រកូលទាំងនោះប្រគេនហើយជាញឹកញាប់ ក៏សន្សំទុកនោះឯង។*

**បុគ្គលទី២=** ភិក្ខុឯណាលះចីវរដែលខ្លួនបានហើយៗ ដោយន័យនុ៎ះៗឯង ប្រគេនដល់ភិក្ខុដទៃ សូម្បីបានរឿយៗក៏ធ្វើយ៉ាងនោះឯង ។

**បុគ្គល ២ ពួកនេះ** នរណាមួយបង្អោននាំបច្ច័យចូលទៅប្រគេនទាំងវេទេះ ក៏មិនអាចដើម្បីឱ្យឆ្អែតបាន ព្រោះហេតុដូច្នោះ ទើបឈ្មោះថា ដែលនរណាមួយឲ្យឆ្អែតបានដោយលំបាក។

ចប់បុគ្គល២ពួកគេចម្អែតបានដោយក្រ

## (២២). ទ្វេ បុគ្គលា សុតប្បយា

(បុគ្គល២ពួកគេចម្អែតបានដោយងាយ)

១. **យោ ច លទ្ធំ លទ្ធំ ន និក្ខិបតិ** = បុគ្គលដែលមិនទុកនូវរបស់ដែលខ្លួនរកបានហើយបានហើយ ។

២.**យោ ច លទ្ធំ លទ្ធំ ន វិសជ្ជេតិ** = បុគ្គលដែលមិនលះបង់នូវរបស់ដែលខ្លួនរកបានហើយបានហើយ។

អធិប្បាយ

**បុគ្គលទី១ =** ភិក្ខុណា មានចីវរចាស់ហើយ បានសំពត់សាដកអំពីត្រកូលឧបដ្ឋាក ឬត្រកូលញាតិ ធ្វើឲ្យបានជាចីវរប្រើប្រាស់

កើត មិនព្រមបោះចោល សូម្បីប៉ះហើយ ក៏នៅប្រើដណ្តប់បាន កាលត្រកូលទាំងនោះប្រគេនថ្មីក៏មិនព្រមប្រញាប់ទទួលដោយ រហ័ស(មានការពិចារណាជាមុន)នេះពួកមួយ។

**បុគ្គលទី២** = ពាក្យថា “**ន វិស្សជ្ជេតិ**” បានដល់ ធ្វើឱ្យជារបស់ខ្លួន មិនឱ្យដល់អ្នកដទៃ តែកាលបើមានអតិរេកលាភ (របស់សល់) ក៏មិនប្រមូលទុក រមែងប្រគេនដល់ភិក្ខុដទៃ សេចក្តីនេះ មានអធិប្បាយទុកដូច្នេះថា ភិក្ខុណាប្រើចីវរដែលបានហើយៗដោយខ្លួនឯង រមែងមិនប្រគេនដល់ភិក្ខុដទៃ (សេចក្តីថា លោកទទួលតែម្តងប្រើរហូតដល់ខូច ប្រើលែងកើត ទើបលោកទទួលម្តងទៀត)។ សូម្បីភិក្ខុទាំងពីររូបនេះ នរណាមួយក៏អាចឲ្យឆ្អែតបានដោយងាយ ព្រោះហេតុដូច្នោះទើបឈ្មោះថា **សុត្តប្បយា** ដែលអ្នកដទៃឲ្យឆ្អែតបានដោយងាយ។

ចប់បុគ្គល២ពួកគេចម្អែតបានដោយងាយ

## (២៣). ទ្វិន្នំ បុគ្គលានំ អាសវា វឌ្ឍន្តិ

(អាសវៈរបស់បុគ្គល២ពួក រមែងចម្រើន)

**១. យោ ច ន កុក្កុច្ចាយិតព្វំ កុក្កុច្ចាយតិ**= បុគ្គលដែលរង្កៀសសង្ស័យនូវវត្ថុដែលមិនត្រូវរង្កៀសសង្ស័យ។

**២. យោ ច កុក្កុច្ចាយិតព្វំ ន កុក្កុច្ចាយតិ**=បុគ្គលដែលមិនរង្កៀសសង្ស័យនូវវត្ថុដែលត្រូវរង្កៀសសង្ស័យ។

អធិប្បាយ

**បុគ្គលទី១ = បទថា : ន កុក្កុច្ចាយិតព្វំ កុក្កុច្ចាយិតិ** សេចក្តីថា រមែងប្រព្រឹត្តមិនចូលចិត្តវត្ថុដែលមិនគួរស្អប់ ដូចភិក្ខុបានសាច់ជ្រូកហើយប្រព្រឹត្តមិនចូលចិត្តថា ជាសាច់ខ្លាឃ្មុំ, បានសាច់ម្រឹគហើយប្រព្រឹត្តមិនចូលចិត្តថា ជាសាច់ខ្លាដំបង( សម្គាល់កប្បិយមំសៈថា ជាអកប្បិយមំសៈទៅវិញ) , កាលបើភត្តកាលនៅមានរមែងប្រព្រឹត្តមិនចូលចិត្តថាជា ភត្តកាលមិនមាន (សម្គាល់ថា ភត្តកាលថាមិនមែនភត្តកាលទៅវិញ), (ភត្ត) មិនត្រូវហាម តែប្រព្រឹត្តមិនចូលចិត្តថា យើងត្រូវហាម(ភត្ត), កាលល្អងធូលីមិនធ្លាក់ចូលទៅក្នុងបាតទេ តែប្រព្រឹត្តមិនចូលចិត្តថា ល្អងធូលីធ្លាក់ចូលទៅហើយ , កាលគេមិនធ្វើសាច់ត្រីឧទ្ទិសចំពោះ ក៏ប្រព្រឹត្តមិនចូលចិត្តថា គេធ្វើសាច់ត្រីឧទ្ទិសចំពោះយើង។

**បុគ្គលទី២ = បទថា កុក្កុច្ចាយិតព្វំ ន កុក្កុច្ចាយតិ** សេចក្តីថា រមែងមិនប្រព្រឹត្ត មិនចូលចិត្ត វត្ថុដែលគួរប្រព្រឹត្តមិនចូលចិត្ត ដូចភិក្ខុបានសាច់ខ្លាឃ្មុំហើយ រមែងមិនប្រព្រឹត្ត មិនចូលចិត្តថា ជា

សាច់ខ្លាឃ្មុំ ។ល។ លុះកាលគេធ្វើសាច់ត្រីឧទ្ទិស គឺចោះចំពោះខ្លួន តែមិនប្រព្រឹត្ត មិនចូលចិត្តថា គេធ្វើសាច់ត្រីឧទ្ទិសចំពោះយើង ។

ចំណែកក្នុង **អដ្ឋកថា អង្គុត្តរនិកាយ** លោកពោលពាក្យទុកមានប្រមាណប៉ុណ្ណេះថា ពាក្យថា “ **ន កុក្កុច្ចាយិតព្វំ** ” បានដល់ ការមិនតាំងទុកការមិនពិចារណានូវចំណែកដែលជារបស់សង្ឃ ឈ្មោះថា ដែលនរណាមួយមិនគប្បីរង្កៀស រមែងរង្កៀសវត្ថុនោះ ។ ពាក្យថា “ **កុក្កុច្ចាយិតព្វំ**” សេចក្តីថា ការតាំងទុក ការពិចារណានូវវត្ថុដែលជារបស់សង្ឃនោះ ទ្រុះឯងរមែងមិនរង្កៀសរបស់នោះ។

ពាក្យថា “ **ឥមេសំ**” សេចក្តីថា អាសវៈទាំងឡាយ រមែងចម្រើនយ៉ាងពិតប្រាកដដល់បុគ្គលទាំង ២ នេះ ទាំងពេលថ្ងៃ ទាំងពេលយប់ ដូចស្មៅ និងវល្លិជាដើម រីកលូតលាស់ល្អចម្រើនក្នុងភូមិភាគដែលល្អ។ ក្នុងធមិស បណ្ឌិតគប្បីជ្រាបដោយន័យនេះថា ភិក្ខុឯណាបានកប្បិយមំសៈ គឺសាច់ដែលសមគួរហើយ ក៏ទទួលយកសាច់ដែលសមគួរនោះឯង ឈ្មោះថា រមែងប្រព្រឹត្តមិនចូលចិត្តវត្ថុដែលមិនគួរប្រព្រឹត្ត មិនគួរចូលចិត្ត ។

ចប់អាសវៈរបស់បុគ្គល២ពួក រមែងចម្រើន

## (២៤). ទ្វិន្នំ បុគ្គលានំ អាសវា ន វឌ្ឍន្តិ

(អាសវៈរបស់បុគ្គល២ពួក រមែងមិនចម្រើន)

១. **យោ ច ន កុក្កុច្ចាយិតព្វំ ន កុក្កុច្ចាយតិ** = បុគ្គលដែលមិនរង្កៀសសង្ស័យ នូវវត្ថុដែលមិនត្រូវរង្កៀសសង្ស័យ។

២. **យោ ច កុក្កុច្ចាយិតព្វំ កុក្កុច្ចាយតិ** = បុគ្គលដែលរង្កៀសសង្ស័យ នូវវត្ថុដែលត្រូវរង្កៀសសង្ស័យមួយ។

អធិប្បាយ

**បុគ្គលទី១**=ភិក្ខុបានរបស់គួររង្កៀសសង្ស័យហើយរង្កៀសសង្ស័យលោកមិនបរិភោគ។

**បុគ្គលទី២**= ភិក្ខុបានរបស់គួរដល់ការបរិភោគ ហើយសម្គាល់ថា ជារបស់គួរដល់ការបរិភោគ។

អាសវៈរបស់លោកទាំងពីរនេះមិនចម្រើនឡើងឡើយ ។

ចប់អាសវៈរបស់បុគ្គល២ពួក រមែងមិនចម្រើន

## (២៥). ហីជាធិមុត្តោ ច បណីតាធិមុត្តោ ច

(បុគ្គលថោកទាប និង បុគ្គលខ្ពង់ខ្ពស់)

១ .**ហីនាធិមុត្តោ** = បុគ្គលមានអធ្យាស្រ័យថោកទាប ។

២. **បណីតាធិមុត្តោ**= បុគ្គលមានអធ្យាស្រ័យខ្ពង់ខ្ពស់។

**បុគ្គលទី១**= បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកទ្រុស្តសីលមានធម៌លាមក បុគ្គលនោះ តែងសេពគប់ ចូលទៅអង្គុយជិតបុគ្គលដទៃ

ដែលទ្រុស្តសីល មានធម៌លាមកដែរ នេះហៅថា **បុគ្គលមានអធ្យាស្រ័យថោកទាប។**

## បុគ្គលថោកទាប[27]

បុគ្គលណា មានសេចក្តីក្រោធ ចងសេចក្តីក្រោធទុក (គុំនុំ) ជាបុគ្គលបាប លុបគុណគេ ប្រាសចាកសម្មាទិដ្ឋិ មានមាយា អ្នកចូរដឹងបុគ្គលនោះថា ជាបុគ្គលថោកទាប។

បុគ្គលណា ក្នុងលោកនេះ បៀតបៀននូវសត្វ ដែលមានកំណើតម្តង ឬមានកំណើតពីរដង ឬបុគ្គលណា មិនមានសេចក្តីអាណិតចំពោះសត្វ អ្នកចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប។

បុគ្គលណា សម្លាប់ ឬឡោមរឹបជាន់នូវអ្នកស្រុក ឬអ្នកនិគម ដែលអ្នកផងដឹងច្បាស់ ជាអ្នកសង្កត់សង្កិនគេ អ្នកចូរដឹងបុគ្គលនោះថាជាបុគ្គលថោកទាប។ បុគ្គលណា កាន់យកទ្រព្យក្នុងស្រុក ឬក្នុងព្រៃដែលបុគ្គលប្រកាន់ថាជារបស់អញ ជាទ្រព្យដែលគេមិនឲ្យ ដោយអាការលួច អ្នកចូរដឹងបុគ្គលនោះថាជាបុគ្គលថោកទាប។

---

[27] បិដក ភាគ ៥៤ - ទំព័រទី ៤៣

បុគ្គលណា បុលទ្រព្យគេ យកមកប្រើប្រាស់ ហើយគេចកែថា (អញ) មិនចំពាក់បំណុលអ្នកទេ អ្នកចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប។

បុគ្គលណា សម្លាប់អ្នកដទៃ ដែលដើរក្នុងផ្លូវ ដោយប្រាថ្នាទ្រព្យរបស់ណាមួយ ដណ្តើមយកទ្រព្យរបស់ណាមួយ អ្នកចូរដឹងបុគ្គលនោះថាជាបុគ្គលថោកទាប។

បុគ្គលណា គេសួរជាបន្ទាល់ និយាយកុហក ព្រោះហេតុនៃខ្លួនក្តី ព្រោះហេតុនៃបុគ្គលដទៃក្តី ព្រោះហេតុនៃទ្រព្យក្តី អ្នកចូរដឹងបុគ្គលនោះថាជាបុគ្គលថោកទាប។

បុគ្គលណា ប្រព្រឹត្តខុសចំពោះប្រពន្ធ របស់ពួកញាតិឬសម្លាញ់ ដោយការកំហែង ឬដោយការស្រឡាញ់ស្មគ្រចិត្ត អ្នកចូរដឹងបុគ្គលនោះថាជាបុគ្គលថោកទាប។

បុគ្គលណា ជាអ្នកស្តុកស្តម្ភ តែមិនចិញ្ចឹមមាតាឬបិតាដែលចាស់ជរា មានវ័យកន្លងហើយ អ្នកចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប។

បុគ្គលណា ប្រហារមាតា ឬបិតា បងប្អូនប្រុស បងប្អូនស្រី ឬម្តាយក្មេក ឬក៏ជេរប្រទេចដោយវាចា អ្នកចូរដឹងបុគ្គលនោះ ថាជា

បុគ្គលថោកទាប។

បុគ្គលណា កាលដែលគេសួរចំពោះហេតុមានប្រយោជន៍ ហើយពន្យល់ប្រាប់ហេតុដែលគ្មានប្រយោជន៍ បង្ហាញដោយពាក្យបិទបាំង អ្នកចូរដឹងបុគ្គលនោះថាជាបុគ្គលថោកទាប។

បុគ្គលណា បានធ្វើបាបកម្ម ហើយប្រាថ្នាថា អ្នកផងកុំគប្បីដឹងនូវអញ បុគ្គលណា មានការងាររបិទបាំង អ្នកចូរដឹងបុគ្គលនោះថាជាបុគ្គលថោកទាប។

បុគ្គលណា ទៅកាន់ត្រកូលញាតិមិត្តដទៃ ទាំងបានបរិភោគភោជនដ៏ស្អាត ហើយមិនបានបូជាគេ ដែលមកកាន់ផ្ទះរបស់ខ្លួនវិញអ្នកចូរដឹងបុគ្គលនោះថាជាបុគ្គលថោកទាប។

បុគ្គលណា បញ្ឆោតព្រាហ្មណ៍ក្តី សមណៈក្តី ឬអ្នកសូមឯទៀតក្តី ដោយពាក្យកុហក អ្នកចូរដឹងបុគ្គលនោះថាជាបុគ្គលថោកទាប។

បុគ្គលណា ជេរសមណៈ ឬព្រាហ្មណ៍ដោយវាចាក្តី មិនឲ្យភោជន ក្នុងវេលាភត្តកាល ដែលគួរទំនុកបម្រុងក្តី អ្នកចូរដឹងបុគ្គលនោះថាជាបុគ្គលថោកទាប។

បុគ្គលណា ក្នុងលោកនេះ ត្រូវមោហៈរួបរឹតហើយ កាល

ស្វែងរកចំពោះទ្រព្យណាមួយ ក៏និយាយបោកប្រាស់ ដោយពាក្យមិនពិតអ្នកចូរដឹងបុគ្គលនោះថាជាបុគ្គលថោកទាប។

បុគ្គលណា លើកតម្កើងខ្លួនឯង ឬបន្ទុះបង្អាប់ពួកជនដទៃ តែខ្លួនជាអ្នកសាបសូន្យ (ចាកគុណវុឌ្ឍិ) ព្រោះការតម្កើង និងការបន្ទុះបង្អាប់របស់ខ្លួនអ្នកចូរដឹងបុគ្គលនោះថាជាបុគ្គលថោកទាប។

បុគ្គលណា កោងកាចក្តី ស្វះរកន្ទ្រឹសក្តី មានសេចក្តីប្រាថ្នាអាក្រក់ក្តី កំណាញ់ក្តី អំនួតក្តី មិនអៀនខ្មាសក្តី មិនខ្លាចបាបក្តី អ្នកចូរដឹងបុគ្គលនោះថាជាបុគ្គលថោទាប។

បុគ្គលណា ជេរប្រទេចព្រះពុទ្ធ ឬសាវ័ករបស់ព្រះពុទ្ធ ឬបរិ-ព្វាជក ឬក៏គ្រហស្ថអ្នកចូរដឹងបុគ្គលនោះថាជាបុគ្គលថោកទាប។

បុគ្គលណា មិនមែនជាអរហន្តទេ តែប្តេជ្ញា(ខ្លួន)ថាជាអរហន្តបុគ្គលនោះជាចោរក្នុងលោកព្រមទាំងព្រហ្មលោកនេះឯងជាបុគ្គលថោកទាបបំផុត។

បុគ្គលថោកទាបទាំងនេះឯង តថាគតបានប្រកាសហើយ បុគ្គលមិនមែនថោកទាប ព្រោះជាតិ មិនមែនជាព្រាហ្មណ៍ព្រោះជាតិទេ

បុគ្គលថោកទាបព្រោះកម្ម ជាព្រាហ្មណ៍ក៏ព្រោះកម្ម ។ អ្នកទាំងឡាយ ចូរដឹងនូវសេចក្តីនោះ ដោយពាក្យនេះចុះ ដូចឧទាហរណ៍នេះឯង កូនរបស់មនុស្សចណ្ឌាល មានឈ្មោះប្រាកដថា សោបាកមាតង្គៈ មាតង្គកុមារនោះ បាននូវយសដ៏ប្រសើរ ដែលគេបានដោយក្រក្រៃលែង ពួកក្សត្រ ព្រាហ្មណ៍ជាច្រើន តែងមកកាន់ទីបំរើរបស់កុមារនោះ។ មាតង្គកុមារនោះ ឡើងកាន់យាន គឺសមាបត្តិ ៨ អាចឲ្យទៅកាន់ទេវលោក ប្រាសចាកធូលី គឺកិលេសជាផ្លូវធំ នឿយណាយនឹងកាមរាគហើយទៅកើតក្នុងព្រហ្មលោក។

ជាតិ មិនមែនឃាត់មាតង្គៈនោះ ចាកការកើតក្នុងព្រហ្មលោកទេ។ ពួកព្រាហ្មណ៍ ជាផៅពង្សព្រោះមន្ត កើតក្នុងត្រកូលអ្នករៀនមន្ត ពួកព្រាហ្មណ៍ទាំងនោះ រមែងប្រាកដក្នុងបាបកម្មទាំងឡាយរឿយ ៗទុគ្គតិដែលអ្នកជងគួរតិះដៀល ក្នុងបច្ចុប្បន្នក៏មានក្នុងបរលោកក៏មាន (ព្រោះបាបកម្មជាបច្ច័យ)។ ជាតិ មិនមែនឃាត់ពួកព្រាហ្មណ៍ទាំងនោះ ចាកទុគ្គតិ ឬចាកការតិះដៀលទេ។ បុគ្គលមិនមែនថោកទាប ព្រោះជាតិ មិនមែនជាព្រាហ្មណ៍ ព្រោះជាតិទេ បុគ្គលថោកទាប ព្រោះកម្ម ជាព្រាហ្មណ៍ ក៏ព្រោះកម្មដែរ ។ (វសលសូត្រ)

**បុគ្គលទី២ =** បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកមានសីល មានធម៌ល្អ បុគ្គលនោះ តែងសេពគប់ ចូលទៅអង្គុយជិតបុគ្គលដទៃដែលមានសីលមានធម៌ល្អ នេះហៅថា**បុគ្គលមានអធ្យាស្រ័យខ្ពង់ខ្ពស់។**

ចប់បុគ្គលថោកទាបនិងបុគ្គលខ្ពង់ខ្ពស់

(២៦). តិណ្ណោ ច តារេតា ច

១.បុគ្គលឆ្លងដោយខ្លួនឯង ។ ២.បុគ្គលញ៉ាំងឱ្យគេឆ្លង។

អធិប្បាយ

**បុគ្គលទី១. បច្ចេកសម្ពុទ្ធា យេ ច តថាគតស្ស សាវកា អរហន្តោ តិណ្ណា = ព្រះបច្ចេកពុទ្ធ ព្រះអរហន្ត ជាសាវករបស់ព្រះតថាគត នេះហៅថា ឆ្លងដោយខ្លួនឯង** ។ អធិប្បាយថា ព្រះបច្ចេកពុទ្ធក្តី ព្រះសាវករបស់ព្រះពុទ្ធក្តី លោកទាំងអស់នោះឆ្លងហើយ គឺបរិបូណ៌ហើយដោយលោកុត្តរធម៌៩ប្រការ តែមិនអាចដើម្បីឱ្យគេឆ្លងដោយធម៌របស់លោកបាន។ តែទេវតាក្តី មនុស្សក្តី បានត្រាស់ដឹងធម៌ ព្រោះព្រះសាវករបស់ព្រះពុទ្ធទាំងនោះសម្តែងហើយ ។ តែកាលសាវកសម្តែង មិនមែនលោកសម្តែងពាក្យសម្តីរបស់ខ្លួនឯង

*ទេ, គឺលោកសម្តែងធម្មកថា ធ្វើឱ្យជាពាក្យរបស់ព្រះពុទ្ធជាម្ចាស់ទាំងឡាយប៉ុណ្ណោះ។*

***បុគ្គលទី២. សម្មាសម្ពុទ្ធោ តិណ្ណោ ច តារេតា ច = ព្រះសម្មាសម្ពុទ្ធ ឈ្មោះថាឆ្អែតដោយព្រះអង្គឯងញ៉ាំងគេឱ្យឆ្អែតផង។***

*បុគ្គលទាំងនោះ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ប៉ុណ្ណោះ ឈ្មោះថា ញ៉ាំងបុគ្គលដទៃឱ្យឆ្អែតដោយប្រការដូច្នេះ ដូចយ៉ាង ថាកាលព្រះរាជាបញ្ជាថា "អ្នកទាំងឡាយចូរឱ្យវត្ថុ និងវត្ថុដល់បុគ្គលឈ្មោះឯណោះ" ដូច្នេះ រាជបុរសនាំរបស់មកឱ្យដល់បុគ្គលឈ្មោះឯណោះ ក៏ពិតមែនហើយ,ប៉ុន្តែព្រះរាជាប៉ុណ្ណោះ ឈ្មោះថា ជាអ្នកឱ្យរបស់នោះសូម្បីរបស់ដែលជនទាំងឡាយណាបានហើយជនទាំងនោះរមែងទទួលយកដោយគិតថា "ឋានន្តរៈ ដែលព្រះរាជា ទ្រង់ប្រទានហើយដល់យើង សម្បត្តិគឺឥស្សរិយយស ដែលព្រះរាជាទ្រង់ព្រះរាជទានហើយដល់យើងប៉ុណ្ណោះ" តែកាន់យកដោយសេចក្តីគិតថា "ឋានន្តរៈជាដើមដែលរាជបុរសទាំងឡាយឲ្យដោយយើងមិនមាន"យ៉ាងណា សេចក្តីឧបមាជាគ្រឿងញ៉ាំងពីឧបមេយ្យ ឲ្យដល់ព្រមនេះបណ្ឌិតគប្បីជ្រាបដូច្នោះចុះ។*

ចប់ តិណ្ណោ ច តារេតា ច

ចប់បុគ្គលពួក២ត្រឹមតែប៉ុណ្ណោះ

# តិកមាតិកា

(បុគ្គល ពួក៣)

## (៧). បុគ្គលមិនមានសេចក្ដីសង្ឃឹមជាដើម

**១. និរាសោ=** បុគ្គលមិនមានបំណង ។

**២. អាសំសោ=** បុគ្គលមានបំណង ។

**៣. វិគតាសោ=** បុគ្គលប្រាសចាកបំណង ។

## អធិប្បាយ

**១. និរាសោ=** បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកទ្រុស្តសីល មានធម៌ដ៏លាមក មានមារយាទគឺបុគ្គល គប្បីរលឹកដោយសេចក្ដីរង្កៀស ដោយអំពើមិនស្អាត បិទបាំងអំពើ មិនមែនសមណ តែប្ដេជ្ញាខ្លួនថាជាសមណៈ មិនមែនព្រហ្មចារី តែប្ដេជ្ញាខ្លួនថាជាព្រហ្មចារី ជាអ្នកស្អុយក្នុង មានចិត្តទទឹកដោយរាគៈ ជ្រោកជ្រាកដោយកិលេស បុគ្គល នោះ បានឮដំណឹងថា ភិក្ខុឈ្មោះនេះ បានធ្វើឲ្យជាក់ច្បាស់សម្រេច ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន នូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ បុគ្គលនោះ មិនមានសេចក្ដីត្រិះរិះ

យ៉ាងនេះថា កាលណាហ្ន៎ អាត្មាអញ នឹងបាន ធ្វើឲ្យជាក់ច្បាស់ សម្រេច ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្ន នូវចេតោ វិមុត្តិ បញ្ញាវិមុត្ត ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ នេះហៅថា បុគ្គល មិនមានបំណង ។

**អដ្ឋកថា** = ដូចយ៉ាងថា កូនមនុស្សចណ្ឌាល សូម្បីបានឮថា ខត្តិយកុមារឈ្មោះឯណោះ ចូរអភិសេកក្នុងរាជសម្បត្តិ ក៏ព្រោះជនទាំងឡាយ អ្នកកើតខាងក្រោយក្នុងត្រកូលណា រមែងដល់ការអភិសេកខ្លួន , មិនបានកើតក្នុងត្រកូលនោះ ទើបមិនបានគិតយ៉ាងនេះថា សូម្បីយើងនោះក៏នឹងគប្បីដល់ការអភិសេកដូចខត្តិយកុមារដោយពិតៗ យ៉ាងណា ភិក្ខុទ្រុស្តសីលជាដើម ក៏មិនមានការគិតថា "សូម្បីអាត្មាអញក៏នឹងបានជាព្រះអរហន្តដូចភិក្ខុនោះដែរ" យ៉ាងនេះឡើយ។

បទថា **ទុស្សីលោ**= បុគ្គលដែលមិនមានសីល។

បទថា **បាបធម្មោ**= អ្នកមានបាបធម៌។

ម្យ៉ាងទៀត **អ្នកទ្រុស្តសីល** ព្រោះសេចក្តីវិបត្តិនៃសីល។ **អ្នកមានធម៌លាមក** ព្រោះវិបត្តិនៃទិដ្ឋិ ។ ម្យ៉ាងទៀង **អ្នកទ្រុស្តសីល**

ព្រោះដាច់សេចក្តីសង្រួមតាមកាយទ្វារ និងវចីទ្វារ។ **អ្នកមានធមិដ៏លាមក**=ព្រោះដាច់សេចក្តីសង្រួមតាមមនោទ្វារ។ **អ្នកទ្រុស្តសីល** ព្រោះភាពជាអ្នកមានការផាររមិនស្អាត ។**អ្នកមានធមិដ៏លាមក**= ព្រោះភាពជាអ្នកមានអធ្យាស្រ័យមិនស្អាត។ **អ្នកទ្រុស្តសីល**= ព្រោះវៀរចាកកុសលសីលអ្នកមានធមិលាមក ព្រោះប្រកបដោយអកុសលសីល។

**២.អាសំសោ** = បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកមានសីល មានធមិល្អ ... បុគ្គលនោះ បានឮដំណឹងថា ភិក្ខុឈ្មោះនេះ បានធ្វើឲ្យជាក់ច្បាស់សម្រេចដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯងក្នុងបច្ចុប្បន្ន នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ បុគ្គលនោះតែងតែមានសេចក្តីត្រិះរិះ យ៉ាងនេះថា កាលណាហ្ន៎ អាត្មាអញនឹងបានធ្វើឲ្យជាក់ច្បាស់សម្រេចដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន នូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ។

**អដ្ឋកថា** = ដូចយ៉ាងថា កុមារអ្នកសុជាតិ គឺកើតល្អហើយ ខណៈស្តាប់ពាក្យថា ខត្តិយកុមារឈ្មោះឯណោះ គេអភិសេកហើយ

ព្រោះហេតុដែលខ្លួនកើតក្នុងត្រកូលនោះ ទើបមានសេចក្ដីត្រិះរិះថា "សូម្បីយើងក៏គប្បីដល់ការអភិសេក ដូចកុមារនោះដោយពិតៗ" យ៉ាងណា ភិក្ខុអ្នកមានសីលខណៈបានឮថា ភិក្ខុឈ្មោះឯណោះ បានសម្រេចអរហត្តហើយ ព្រោះហេតុនៃសីលរបស់លោកតាំងនៅល្អហើយ គួរនឹងសម្រេចអរហត្ត ក៏យ៉ាងនោះដែរ។ នេះហៅថា **បុគ្គលអ្នកមានបំណង។**

**៣. វិគតាសោ** = បំណងរបស់ព្រះខីណាស្រពមិនមានឡើយ ព្រោះលោកបានសម្រេចហើយ ។ ដូចយ៉ាងថា ព្រះរាជាដែលបានអភិសេកហើយ បានឮដំណឹងថា ខត្តិយកុមារឯណោះ គេបានអភិសេកហើយ ដូច្នេះក្ដី ក៏មិនមានសេចក្ដីត្រិះរិះថា សូម្បីយើង ក៏គប្បីគេអភិសេកដែរ ដូច្នេះឡើយ ព្រោះព្រះរាជាមិនអាចអភិសេកពីរដង មិនមានស្វេតច្ឆត្រពីរដងឡើយ។ នេះហៅថា **បុគ្គលប្រាសចាកបំណង។**

ចប់បុគ្គលមិនមានសេចក្ដីសង្ឃឹមជាដើម

## (២). តយោ គិលានូបមា បុគ្គលា

**( បុគ្គល ៣ ពួកប្រៀបដោយបុគ្គលមានជំងឺ )**

១.បុគ្គលខ្លះក្នុងលោកនេះឈឺទោះបានភោជនជាទីសប្បាយក្តី មិនបានក្តី បានភេសជ្ជៈជាទីសប្បាយក្តី មិនបានក្តី បានឧបដ្ឋាកសមគួរ[២៨]ក្តី មិនបានក្តី ក៏មិនអាចជាសះស្បើយពីរោគបានឡើយ ។ យ៉ាងណា បុគ្គលខ្លះក្នុងលោកនេះ ទោះបានឃើញតថាគតក្តី មិនបានឃើញក្តី ទោះបានស្តាប់ធម្មវិន័យដែលតថាគតសំដែងក្តី មិនបានស្តាប់ក្តី ក៏នៅតែមិនបានត្រាច់ចុះកាន់សម្មត្តនិយាមធម៌ (មគ្គ ផល និព្វាន) ក្នុងកុសលធម៌ទាំងឡាយបានឡើយ។

២.បុគ្គលខ្លះក្នុងលោកនេះឈឺ ទោះបានភោជនជាទីសប្បាយក្តី មិនបានក្តី។ល។ ក៏សះស្បើយចាកអាពាធនោះបានដែរ យ៉ាងណា បុគ្គលខ្លះក្នុងលោកនេះ ទោះបានឃើញតថាគតក្តី មិនបានឃើញក្តី ។ល។ ក៏គង់ត្រាច់ចុះសម្មត្តនិយាមធម៌ ក្នុងកុសលធម៌ទាំងឡាយបាន ។

៣.បុគ្គលខ្លះក្នុងលោកនេះឈឺ លុះតែបានភោជនជាទីសប្បាយ មិនមែនមិនបានទេ បានភេសជ្ជៈជាទីសប្បាយ មិនមែន

---

[២៨] **បុគ្គលសមគួរជាឧបដ្ឋាក**=ជាបណ្ឌិត១ ជាអ្នកឈ្លាស់វៃ១ មិនខ្ជិលច្រអូស១។ អដ្ឋកថា

មិនបានទេ។ល។ យ៉ាងណា ភិក្ខុក្នុងសាសនានេះក៏ដូចគ្នា លុះតែបានស្តាប់ធម៌ដែលតថាគតសម្តែង មិនមែនមិនបានស្តាប់ទេ។ល។ ទើបត្រាច់ចុះ**សម្មត្តនិយាមធម៌ ក្នុងកុសលធម៌ទាំងឡាយ**បាន ព្រោះតែអាស្រ័យបុគ្គលនេះ បានជា**ព្រះមានព្រះភាគទ្រង់អនុញ្ញាតធម្មទេសនា** មិនមែនតែអាស្រ័យបុគ្គលនេះទេ ទើបព្រះមានព្រះភាគសម្តែង សូម្បីបុគ្គលដទៃ ក៏ទ្រង់សម្តែងដែរ។

**អដ្ឋកថា**

**គិលានុបដ្ឋាកោ អនុញ្ញាតោ** = សេចក្តីថា បុគ្គលណាដែលភិក្ខុសង្ឃគប្បីឱ្យព្រោះហេតុដូច្នោះ បុគ្គលនោះ ទើបឈ្មោះថា **អនុញ្ញា-តោ** : អ្នកដែលភិក្ខុសង្ឃអនុញ្ញាតហើយ ។ ក៏បុគ្គលជាអ្នកឈឺនោះ កាលមិនអាចដើម្បីញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅតាមធម្មតារបស់ខ្លួន ភិក្ខុសង្ឃគប្បីអបលោកឱ្យភិក្ខុ ឬសាមណេរមួយអង្គបដិបត្តិទំនុកបម្រុងភិក្ខុ ដែលអាពាធនេះ កាលមិនដូច្នោះ ភិក្ខុនោះគឺជាភារៈរបស់សង្ឃទាំងអស់។

បទថា **អញ្ញេបិ គិលានា ឧបដ្ឋាតព្វា** = *សេចក្តីថា បុគ្គលជាអ្នកឈឺ២ជំពូក សូម្បីក្រៅពីនេះ (បុគ្គល២ពួកខាងដើម) ភិក្ខុសង្ឃក៏គួរជាឧបដ្ឋាកដែរ។*

***សួរថា*** : *ព្រោះហេតុអ្វី?*

***ឆ្លើយថា*** : *បុគ្គលឯណា ជាអ្នកឈឺដល់ទីបំផុតហើយ អ្នកនោះកាលមិនមាននរណាឧបដ្ឋាក ក៏គប្បីអន់ចិត្តថា "ប្រសិនបើភិក្ខុ ឬសាមណេរ គប្បីបដិបត្តិយើង សេចក្តីសុខនឹងគប្បីមានដល់យើង តែពួកគេមិនបដិបត្តិយើងទេ" ដូច្នេះ ហើយគប្បីទៅកាន់អបាយ ។ ក៏អ្នកឈឺនោះកាលបើភិក្ខុសាមណេរ ទំនុកបម្រុងយើងហើយ គេរមែងមានសេចក្តីគិតថាយ៉ាងនេះថា " កិច្ចឯណាដែលសង្ឃគប្បីធ្វើ កិច្ចទាំងអស់នោះ ភិក្ខុសង្ឃក៏ធ្វើហើយ តែយើងមានកម្មវិបាក " ភិក្ខុដែលអាពាធនោះ ញុំាំងមេត្តាចិត្តឱ្យតាំងឡើងក្នុងភិក្ខុសង្ឃ ហើយកើតក្នុងឋានសួគ៌ ។*

*មួយទៀត ភិក្ខុឯណា មានអាពាធបន្តិចបន្តួច បានឧបដ្ឋាកក៏ដោយ មិនបានក៏ដោយ រមែងសះស្បើយអំពីរោគបាន ភិក្ខុដែលអាពាធបន្តិចបន្តួចនោះ សូម្បីវៀរចាកភេសជ្ជៈ ព្យាធិក៏អាចស្ងប់*

*រម្ងាប់បាន តែថាបើគេធ្វើភេសជ្ជៈឲ្យឆាន់ អាពាធបន្តិចបន្តួចនោះក៏រមែងស្ងប់រម្ងាប់បានដោយឆាប់រហ័ស ។ លំដាប់នោះ អ្នកជំងឺដែលសះស្បើយអំពីរោគហើយនោះ គេអាចដើម្បីរៀនពុទ្ធវចនៈ ឬធ្វើសមណៈធម៌ដោយហេតុនេះ ទើបលោកពោលទុកថា “**ភិក្ខុសង្ឃគប្បីឧបដ្ឋាកអ្នកជំងឺស្ងួម្បីដទៃ**” ។*

*បទថា* **និយាមំ កុសលេសុ ធម្មេសុ សម្មត្តំ** = *បានដល់ សម្មត្តធម៌ ពោលគឺមគ្គនិយាមក្នុងកុសលធម៌ទាំងឡាយ ព្រះមានព្រះភាគទ្រង់ត្រាស់ដល់បុគ្គលដែលមានបទយ៉ាងក្រៃលែង* **(បទបរមបុគ្គល[29])** *ដោយខនេះ (បុគ្គលទី១)។ ទ្រង់កាន់យក* **ឧគ្ឃដិតញ្ញូបុគ្គល** *ដូចជាព្រះនាលកត្ថេរក្នុងព្រះសាសនាដោយវារៈទី ២ និងទ្រង់កាន់យក***ឧគ្ឃដិតញ្ញូបុគ្គល***ដែលមានបច្ចេកពោធិញ្ញាណ ដែលលោក*

---

29 *បុគ្គល៤ពួក=១.***ឧគ្ឃដិតញ្ញូបុគ្គល***= បុគ្គលដែលត្រាស់ដឹងធម៌ត្រឹមតែស្តាប់មាតិកាធម៌,២.***វិបច្ចិតញ្ញូបុគ្គល***= បុគ្គលដែលត្រាស់ដឹងធម៌ ដោយចែកមាតិកាធម៌ឱ្យពិស្តារ,៣.***នេយ្យបុគ្គល***= បុគ្គលដែលត្រាស់ដឹងធម៌ដោយព្យាយាមចម្រើនយ៉ាងខ្លាំងក្លា ,៤.***បទបរមបុគ្គល*** = *បុគ្គលនេះទោះខំប្រឹងប្រែងយ៉ាងណា ក៏មិនអាចត្រាស់ដឹងធម៌ក្នុងជាតិនេះបានទេ(បានត្រឹមឧបនិស្ស័យត្រាស់ដឹងធម៌ជាតិក្រោយប៉ុណ្ណោះ)។*

បានឱវាទក្នុងសំណាក់នៃព្រះបច្ចេកពុទ្ធទាំងឡាយមួយដងក្នុងពុទ្ធន្តរ ហើយទើបចាក់ធ្លុះសច្ចធម៌ គឺសម្រេចជាព្រះបច្ចេកពុទ្ធ។ ព្រះអង្គទ្រង់ពោលដល់**វិបចិតញ្ញូបុគ្គល** ដោយវារៈទី៣។ **ក៏នេយ្យបុគ្គល** រមែងជាអ្នកអាស្រ័យវិបចិតញ្ញូបុគ្គលនោះឯង។

បទថា **ធម្មទេសនា អនុញ្ញាតា** សេចក្តីថា ព្រះអង្គទ្រង់អនុញ្ញាតព្រះធម៌ទេសនាមួយខែ១៨ដង ។

បទថា **អញ្ញេសម្បិ ធម្មោ ទេសេតព្វោ** សេចក្តីថា ព្រះធម្មកថិកគួរពោលធម៌ដល់ជនទាំងឡាយ សូម្បីក្រៅអំពីនេះ។

***សួរថា*** : ព្រោះហេតុអ្វី?

***ឆ្លើយថា*** : ព្រោះបទបរមបុគ្គលសូម្បីមិនអាចចាក់ធ្លុះធម៌ក្នុងអត្តភាពនេះ តែក៏នឹងជាបច្ច័យទៅក្នុងអនាគតក្នុងកាលខាងមុខ។

ម្យ៉ាងទៀត អ្នកជំងឺឯណា បានឃើញរូបតថាគតក្តី មិនបានឃើញក្តី, និងបានស្តាប់ធម្មវិន័យក្តី មិនបានក្តី, គេរមែងត្រាស់ដឹងធម៌បាន , អ្នកជំងឺនោះកាលមិនបានត្រាស់ដឹងធម៌នៅឡើយ, តែកាលបានបច្ច័យសមគួរហើយក៏នឹងត្រាស់ដឹងធម៌ បានដោយឆាប់រហ័សនោះតែម្តង ព្រោះហេតុដូច្នោះ ព្រះធម្មកថិកទាំងឡាយ គប្បី

*សម្តែងធម៌ដល់ជនទាំងនោះដោយហេតុ ដែលបានពោលមកនេះ ។*
***តែថា ត្រូវសម្តែងធម៌ដល់បុគ្គលទី៣ជារឿយៗ៕***

ចប់បុគ្គល ៣ ពួកប្រៀបដោយបុគ្គលមានជំងឺ

## (៣). បុគ្គលជាកាយសក្ខីជាដើម

**១.បុគ្គលជាកាយសក្ខី**(*មានកាយជាបន្ទាល់*)*ព្រោះជាអ្នកបាន សមាបត្តិ៨ ដោយនាមកាយ ហើយអស់អាសវៈពួកខ្លះ* (*ចាប់តាំង ពីសោតាបត្តិផល រហូតដល់អរហត្តមគ្គ ជាសទ្ធាធុរៈ និងបញ្ញាធុរៈ*)។

**២.បុគ្គលជាទិដ្ឋិប្បត្ត**(*សម្រេចដោយទិដ្ឋិ គឺបញ្ញា*) *ព្រោះជាអ្នកបាន រូបឈាន៤ និងពិចារណាបកិណ្ណកសង្ខារ ហើយអស់អាសវៈពួក ខ្លះ*(*ចាប់ពីសោតាបត្តិផល រហូតដល់អរហត្តមគ្គ ជាបញ្ញាធុរៈ*)។

*៣.**បុគ្គលជាសទ្ធាវិមុត្ត** (រួចស្រឡះចាកអាសវៈដោយសទ្ធា) ដូច ន័យទី២ដែរ តែជាសទ្ធាធុរៈ សេចក្តីពិស្តារ ខ្ញុំបានអធិប្បាយហើយ ក្នុងបុគ្គលពួក១។*

ចប់បុគ្គលជាកាយសក្ខីជាដើម

## (៤). បុគ្គលមានវាចាដូចលាមកជាដើម

**១. គូថភាណី =** *បុគ្គលមានសំដីដូចលាមក។*

**២. បុប្ផភាណី =** បុគ្គលមានសំដីដូចផ្កាឈើ។

**៣. មធុភាណី =** បុគ្គលមានសម្តីដូចទឹកឃ្មុំ។

អធិប្បាយ

**១. គូថភាណី =** បុគ្គលអ្នកនិយាយកុហក ទោះក្នុងទីប្រជុំក្តី ទៅក្នុងបរិស័ទក្តី ទៅកណ្តាលនៃញាតិក្តី ទៅក្នុងកណ្តាលនៃពួកសេនាក្តី ទៅក្នុងកណ្តាលនៃរាជត្រកូលក្តី បើមានគេនាំទៅសួរជាសាក្សីថា នែបុរសអើយ ចូរមកអាយ អ្នកដឹងនូវហេតុណា ចូរនិយាយនូវហេតុនោះចុះ បុគ្គលនោះ កាលគេមិនដឹងសោះ និយាយថាដឹង ឬកាលដឹងនិយាយថា មិនដឹងវិញ កាលមិនឃើញ និយាយថាឃើញ ឬ កាលឃើញ និងយាយថា មិនឃើញវិញ បុគ្គលជាអ្នកពោលពាក្យកុហក ដោយដឹងខ្លួន ព្រោះហេតុនៃខ្លួនក្តី ព្រោះហេតុនៃបុគ្គលដទៃក្តី ព្រោះហេតុនៃអាមិសៈបន្តិចបន្តួចក្តី ដោយប្រការដូច្នេះ នេះហៅថា បុគ្គលមានសម្តីដូចលាមក ។

ដូចយ៉ាងថា លាមកមិនជាទីពេញចិត្តដល់មហាជន យ៉ាងណា ពាក្យនិយាយរបស់បុគ្គលពោលពាក្យកុហកនេះ ក៏មិនជាទីពេញចិត្តដល់ទេវតា និងមនុស្សទាំងឡាយ ដូច្នោះដែរ។

**២.បុប្ផភាណី** = បុគ្គលខ្លះក្នុងលោកនេះ បានលះបង់មុសាវាទ វៀរចាកមុសាវាទ ទោះទៅទីប្រជុំក្តី ទៅក្នុងបរិស័ទក្តី ទៅក្នុងកណ្តាលនៃពួកញាតិក្តី ទៅក្នុងកណ្តាលនៃពួកសេនាក្តី ទៅក្នុងកណ្តាលនៃពួករាជត្រកូលក្តី បើមានគេនាំទៅសួរជាសាក្សីថា នែបុរសអើយ ចូរមកអាយ អ្នកដឹងហេតុណា ចូរនិយាយនូវហេតុនោះចុះ បុគ្គលនោះ កាលមិនដឹង និយាយថាមិនដឹង, ឬកាលដឹងនិយាយថា ដឹង, កាលមិនឃើញនិយាយថា មិនឃើញ, កាលឃើញ និយាយថាឃើញ, បុគ្គលមិនពោលមុសាវាទដោយដឹងខ្លួនព្រោះហេតុនៃខ្លួនក្តី ព្រោះហេតុនៃអាមិសៈបន្តិចបន្តួចក្តី ដោយប្រការដូច្នេះ នេះហៅថា បុគ្គលមានសម្តីដូចផ្កា ។

ដូចយ៉ាងថា ផ្កាម្លិះទាំងឡាយ ទាំងដែលកំពុងក្រពុំ ឬកំពុងរីករមែងជាទីស្រឡាញ់ ជាទីប្រាថ្នារបស់មហាជន យ៉ាងណា វាចារបស់បុគ្គលនេះ ក៏រមែងជាទីស្រឡាញ់ពេញចិត្តរបស់ទេវតា និងមនុស្សទាំងឡាយយ៉ាងនោះដែរ។ អដ្ឋកថា ។

**៣. មធុភាណី=** បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកពោលវាចា មិនមានទោស ដែលនាំមកនូវសេចក្តីសុខដល់ត្រចៀក គួរជាទី

ស្រឡាញ់ ពេញហឫទ័យជាវាចាអ្នកក្រុង ជាទីត្រេកអរនៃជនច្រើន ជាទីពេញចិត្តនៃជនច្រើន នេះហៅថាបុគ្គលមានសំដីដូចទឹកឃ្មុំ។

អដ្ឋកថា

***សុខដល់ត្រចៀក***=ព្រោះជាវាចាពីរោះដោយព្យញ្ជនៈ អធិប្បាយថា : មិនធ្វើការចាក់ត្រចៀកឱ្យកើតឡើង។

***គួរជាទីស្រឡាញ់***= វាចាណា មិនញុំាងសេចក្តីក្រោធឲ្យកើតឡើងក្នុងសរីរៈទាំងអស់ រមែងញុំាងសេចក្តីស្រឡាញ់ឲ្យកើត ព្រោះជាវាចាពីរោះដោយអត្ថ ព្រោះហេតុនោះ វាចានោះទើបឈ្មោះថា **បេមនីយា** គួរជាទីស្រឡាញ់។

***ពេញហឫទ័យ***= វាចាណា រមែងទៅកាន់ហឫទ័យមិនមានអ្វីមកប៉ះខ្ទប់ចូលទៅកាន់ចិត្ត ដោយសប្បាយ ព្រោះហេតុនោះ វាចានោះទើប ឈ្មោះថា **ហទយង្គមា** ពេញហឫទ័យ។

***វាចាអ្នកក្រុង***=វាចាណា ជារបស់អ្នកនៅក្នុងក្រុង ព្រោះជាវាចាដែលសម្បូរដោយគុណ ព្រោះហេតុនោះ វាចានោះ ទើបឈ្មោះថា បោរីវាចាអ្នកក្រុង(សម្តីអ្នកបុរី)។ វាចាឯណា ដែលពោលហៅថា ម្នាលកុមារដ៏ល្អ ដូចនារីដែលមានវឌ្ឍនធម៌ដ៏ល្អ សូម្បីវាចានេះក៏

ហៅថា បោរីវាចា ដែរ វាចាណាជារបស់មានហើយដល់អ្នកក្រុងសូ-
ម្បីវាចានោះក៏ឈ្មោះថា បោរីវាចា ដែរ អធិប្បាយថា : ជាពាក្យសម្ដី
របស់អ្នកក្រុង ។ ពិតមែនហើយ អ្នកក្រុងទាំងឡាយ មានពាក្យសម្ដី
ដែលគួរសម   រមែងពោលហៅបុគ្គលដែលសមគួរជាឪពុកថា
"**ឪពុក**" ហៅអ្នកសមគួរជាម៉ែថា "**ម៉ែ**" និងពោលហៅអ្នកសមគួរ
ជាបង ជាប្អូន ថា " **បងប្រុស, ប្អូនប្រុស, បងស្រី, ប្អូនស្រី**"ដូច្នេះ។

**វាចាជាទីពេញចិត្តរបស់មនុស្សចំនួនច្រើន** = ពាក្យសម្ដី ឯណា
ដែលពោលមកហើយបែបនេះ រមែងជាទីស្រឡាញ់ពេញចិត្តដល់
ជនជាចំនួនច្រើន   ព្រោះហេតុដូច្នោះ  វាចានោះទើបឈ្មោះថា
**ពហុជនកន្តា** = វាចាជាទីពេញចិត្តរបស់មនុស្សចំនួនច្រើន។

**វាចាជាទីពេញចិត្តដល់ជនជាចំនួនច្រើន** = វាចាឯណាជាទី
ញុំាងចិត្តឲ្យសប្បាយរីករាយ គឺធ្វើសេចក្ដីចម្រើនដល់ចិត្ត របស់
ជនជាចំនួនច្រើន ដោយសេចក្ដី ជាវាចាដែលពេញចិត្តនោះឯង
ព្រោះហេតុដូច្នោះ  វាចានោះ  ទើបឈ្មោះថា **ពហុជនមនាបា** =
វាចាជាទីពេញចិត្តដល់ជនជាចំនួនច្រើន។

ទាំងនេះហៅថា **មធុភាណី**= អ្នកមានវាចាដូចទឹកឃ្មុំ។ អធិប្បាយថា ជាវាចាពីរោះស្ដាប់ទាំង២ ដូចយ៉ាងថា ធម្មតាចតុមធុរស គឺរស់ផ្សំដោយវត្ថុ ៤យ៉ាង មានប្រេង ធ្វើពីទឹកដោះសត្វ១ ប្រេងល្ង១ ទឹកឃ្មុំ១ និងទឹកត្នោត១ កាលលាយច្របល់គ្នាហើយ បានក្លាយជារសដ៏ប្រណិត យ៉ាងណា ពាក្យសំដីរបស់បុគ្គលនេះក៏ជារបស់ពីរោះដល់ទេវតានិងមនុស្សទាំងឡាយដូច្នោះដែរ។

ចប់បុគ្គលមានវាចាដូចលាមកជាដើម

## (៥). បុគ្គលមានចិត្តប្រៀបដោយដំបៅជាដើម

**១. អរុកូបមចិត្តោ**= បុគ្គលមានចិត្តប្រៀបដោយដំបៅ ។

**២. វិជ្ជូបមចិត្តោ**= បុគ្គលមានចិត្តប្រៀបដោយផ្លេកបន្ទោរ។

**៣ . វជិរូបមចិត្តោ**= បុគ្គលមានចិត្តប្រៀបដោយពេជ្រ។

អធិប្បាយ

**១.អរុកូបមចិត្តោ**=ធម្មតាដំបៅដែលត្រូវអង្កត់ឈើ ឬអំបែង.... ពាល់ត្រូវហើយ រមែងហូរចេញវត្ថុបដិកូល ៣យ៉ាង មានទឹកខ្ទុះជាដើមតាមធម្មតារបស់ខ្លួន យ៉ាងណា បុគ្គលដែលត្រូវគេស្ដីថា តែ

បន្តិបន្តួច ក៏ខឹង ព្យាបាទ តតប ធ្វើសេចក្តីក្រោធ ការប្រទូស្ត និង សេចក្តីមិនត្រេកអរ ឱ្យប្រាដក ក៏យ៉ាងនោះដែរ។

**២. វិជ្ជូបមចិត្តោ=** បុរសអ្នកមានចក្ខុ រមែងដើរទៅក្នុងទីងងឹត ដោយផ្លេកបន្ទោរបាន យ៉ាងណា កិលេសទាំងឡាយដែលសោតាបត្តិមគ្គ គប្បីប្រហារប្រៀបដូចងងឹត, ការកើតឡើងនៃសោតាបត្តិមគ្គ ប្រៀបដូចផ្លេកបន្ទោរ, ការឃើញព្រះនិព្វានក្នុងខណៈនៃសោតាបត្តិមគ្គប្រៀបដូចការឃើញរូបដោយជុំវិញ របស់បុរសដែលមានចក្ខុក្នុងចន្លោះនៃផ្លេកបន្ទោរ ។ សូម្បីសកទាគាមីអនាគាមីក៏មានសភាពដូចគ្នានេះដែរ។

**៣.វជិរូបមចិត្តោ =** បណ្ឌិតគប្បីជ្រាបក្នុងអរហត្តមគ្គ ប្រៀបដូចពេជ្រ ។ កិលេសទាំងឡាយ ដែលអរហត្តមគ្គគប្បីប្រហារ ប្រៀបដូចដុំកែវមណី ឬដុំថ្ម បណ្ឌិតគប្បីជ្រាបកិលេសទាំងឡាយ ត្រូវកាត់ដោយអរហត្តមគ្គញាណ ប្រៀបដូចការមិនមាននៃភាវៈដែលដុំកែវមណី ឬដុំថ្ម ដែលត្រូវគ្រាប់ពេជ្រប្រហារហើយ មិនចម្រើនឡើង, បណ្ឌិតគប្បីជ្រាបថា កិលេសទាំងឡាយត្រូវអរហត្តមគ្គកាត់ដាច់ហើយ មិនកើតឡើងទៀត ប្រៀបដូចដុំកែវមណី ឬដុំថ្ម ដែលគ្រាប់ពេជ្រប្រហារដាច់ទៅហើយ មិនដុះឡើងទៀតទេ។ នេះហៅ

ថា បុគ្គលមានចិត្តប្រៀបដោយពេជ្រ ។ អធិប្បាយថា អ្នកមានចិត្តដូចពេជ្រ ព្រោះជាអ្នកអាចដើម្បីធ្វើការដកហូតឡើងនូវកិលេសទាំងឡាយបាន៕

ចប់បុគ្គលមានចិត្តប្រៀបដោយដំបៅជាដើម

## (៦). បុគ្គលដែលមានភ្នែកខ្វាក់ជាដើម

១. **អន្ធោ = *បុគ្គលខ្វាក់*** (ភ្នែកទាំងពីរ) ព្រោះមិនមានបញ្ញាចក្ខុជាគ្រឿងរួបរួមភោគទ្រព្យដែលប្រព្រឹត្តទៅក្នុងទិដ្ឋធម្មិកភព (បច្ចុប្បន្នភព) និងមិនមានបញ្ញាចក្ខុជាគ្រឿងញុំាងប្រយោជន៍ឱ្យសម្រេចក្នុងសម្បរាយិកភព(ភពខាងមុខ) ។អធិប្បាយថា មិនបានបំពេញបុណ្យជាទីពឹងសម្រាប់ភពខាងមុខ។

**២.ឯកចក្ខុ = *បុគ្គលមានភ្នែកម្ខាង*** ព្រោះមានបញ្ញាចក្ខុជាគ្រឿងរួបរួម រកភោគសម្បត្តិបានក្នុងភពនេះ , តែមិនមានបញ្ញាចក្ខុដែលជាគ្រឿងញុំាងប្រយោជន៍ឱ្យសម្រេចក្នុងភពខាងមុខឡើយ។

**៣. ទ្វិចក្ខុ = *បុគ្គលមានភ្នែកទាំងពីរ*** ព្រោះមានបញ្ញាចក្ខុជាគ្រឿងរួបរួមទ្រព្យសម្បត្តិក្នុងភពនេះផង និង មានបញ្ញាចក្ខុដែលជាគ្រឿងញុំាងប្រយោជន៍ឱ្យសម្រេចក្នុងភពខាងមុខផង។

ចប់បុគ្គលដែលមានភ្នែកខ្វាក់ជាដើម

## (៧). បុគ្គលមានបញ្ញាដូចក្អមផ្កាប់

**១. អវកុជ្ជបញ្ញោ** = បុគ្គលមានបញ្ញាដូចក្អមផ្កាប់ ។

**២. ឧច្ឆង្គបញ្ញោ** = បុគ្គលមានបញ្ញាដូចជាថ្នក់លេច។

**៣. បុថុបញ្ញោ** = បុគ្គលមានបញ្ញាក្រាស់។

### អធិប្បាយ

**១. អវកុជ្ជបញ្ញោ** = បុគ្គលខ្លះក្នុងលោកនេះទៅអារាមដើម្បីស្តាប់ធម៌ ពេលលោកសម្តែងព្រះធម៌ពីរោះបទដើម ពីរោះបទកណ្តាល ពីរោះបទចុង ប្រកបដោយអត្ថ និងព្យញ្ជនៈ ប្រកាសនូវព្រហ្មចរិយៈ ដ៏បរិបូណ៌បរិសុទ្ធសព្វគ្រប់ ចំពោះបុគ្គលនោះ តែបុគ្គលនោះ អង្គុយលើអាសនៈ មិនបានយកចិត្តទុកដាក់នូវចំណែកខាងដើម ចំណែកកណ្តាល ចំណែកខាងចុងនៃកថានោះទេ បើទុកជាក្រោកចាកអាសនៈនោះហើយ ក៏មិនធ្វើទុកក្នុងចិត្ត នូវចំណែកជាខាងដើម មិនធ្វើទុកក្នុងចិត្ត នូវចំណែកកណ្តាល មិនធ្វើទុកក្នុងចិត្តនូវចំណែកខាងចុង នៃកថានោះ ដូចជាក្អមផ្កាប់ បុគ្គល

យកទឹកទៅចាក់ដាក់ក្នុងក្អមនោះ តែងកំពប់ហូរខ្ចាយចេញ ដក់នៅមិនបាន យ៉ាងណា បុគ្គលនោះក៏យ៉ាងនោះដែរ។

**២. ឧច្ឆង្គបញ្ញោ =** បុគ្គលខ្លះក្នុងលោកនេះទៅអារាមដើម្បីស្ដាប់ធម៌ក្នុងសម្នាក់នៃពួកភិក្ខុរឿយៗ ។ល។ បុគ្គលនោះ អង្គុយលើអាសនៈ បានយកចិត្តទុកដាក់នូវចំណែកខាងដើម ចំណែកកណ្ដាល ចំណែកខាងចុងនៃកថានោះ តែលុះក្រោកចាកអាសនៈនោះហើយ ក៏មិនធ្វើទុកក្នុងចិត្ត នូវចំណែកខាងដើម មិនធ្វើទុកក្នុងចិត្ត នូវចំណែកកណ្ដាល មិនធ្វើទុកក្នុងចិត្ត នូវចំណែកខាងចុង នៃកថានោះ។ បុរសយកវត្ថុដែលគួរទំពារស៊ីផ្សេងៗ គឺល្ង អង្ករ នំអន្សម ផ្លែពុទ្រា ដាក់ចុះក្នុងថ្នក់ កាលបុរសនោះក្រោកចាកទីអង្គុយនោះ រមែងជ្រុះខ្ចាត់ខ្ចាយ ព្រោះតែភ្លេចស្មារតី យ៉ាងណា ភិក្ខុនោះក៏យ៉ាងនោះដែរ។

**៣.បុថុបញ្ញោ=** បុគ្គលខ្លះក្នុងលោកនេះទៅកាន់អារាម ដើម្បីស្ដាប់ធម៌ ក្នុងសំណាក់ភិក្ខុរឿយៗ ពួកភិក្ខុសម្ដែងធម៌ មានពីរោះបទដើម ពីរោះបទកណ្ដាល។ល។ លុះក្រោកឡើងចាកអាសនៈនោះហើយ ក៏តែងតែធ្វើទុកក្នុងចិត្តនូវចំណែកខាងដើម ធ្វើទុកក្នុងចិត្តនូវចំណែកកណ្ដាល ធ្វើទុកក្នុងចិត្តនូវចំណែកជាខាងចុង នៃ

កថានោះផង ក្អមផ្កាវ បុគ្គលយកទឹកទៅចាក់ដាក់ក្នុងក្អមនោះ ទឹកក៏ដក់នៅ មិនកំពប់ខ្ចាយចេញឡើយ យ៉ាងណាបុគ្គលនោះក៏យ៉ាងនោះដែរ។

## លម្អ ៣ យ៉ាង

## ដោយន័យនៃព្រះធម្មទេសនា

ភិក្ខុទាំងឡាយ កាលសំដែងធម៌ដល់យើង រមែងសំដែងធម៌ឲ្យល្អ ឱ្យច្រើន មិនឲ្យមានទោសនោះឯង ទាំងក្នុងពាក្យផ្តើមគ្រាដំបូង ទាំងក្នុងពាក្យដែលមានត្រង់កណ្តាល និងទាំងក្នុងពាក្យដែលពោលទុកក្នុងទីបំផុត។ ម្យ៉ាងទៀត ក្នុងទីនេះ សេចក្តីល្អ នៃព្រះធម៌ទេសនា ដែលជាខាងដើម កណ្តាលនិងទីបំផុត ព្រមទាំងសេចក្តីល្អទាំង ៣ យ៉ាងនោះ ជាលម្អនៃព្រះសាសនាក៏មាន។ ក្នុងបណ្តាសេចក្តីល្អនៃទេសនា និងសេចក្តីល្អនៃព្រះសាសនានោះ គប្បីជ្រាប សេចក្តីល្អនៃ**ទេសនា**មុន គឺ

### ព្រះគាថាបួនបទ ដោយន័យទេសនា

បទដំបូង *ហៅថា ជាសេចក្តីល្អខាងដើម ។*

ពីរបទតមក *ហៅថា ជាសេចក្តីល្អត្រង់កណ្តាល ។*

មួយបទចុងក្រោយ *ហៅថា ជាសេចក្តីល្អក្នុងទីបំផុត ។*

លំអដោយន័យព្រះសូត្រដែលមាន

រឿងតែមួយ និទាន *ជាសេចក្តីល្អខាងដើម ។*

អនុសន្ធិ *គឺការតភ្ជាប់ ជាសេចក្តីល្អត្រង់កណ្តាល ។*

វាចាដែលពោលចុងក្រោយ*ហៅថា* "***ឥទមវោច***" *ជាសេចក្តីល្អក្នុងទីបំផុត ។*

ចំពោះព្រះសូត្រដែលមានអនុសន្ធិច្រើនគឺមានរឿងច្រើន (អនេកានុសន្ធិ)

អនុសន្ធិដំបូង *ជាសេចក្តីល្អខាងដើម ។ តអំពីនោះ* អនុសន្ធិមួយក្តី ច្រើនៗអនុសន្ធិក្តី *ជាសេចក្តីល្អត្រង់កណ្តាល ។*

អនុសន្ធិចុងក្រោយ *ជាសេចក្តីល្អក្នុងទីបំផុត។ គប្បីជ្រាបន័យរបស់ព្រះធម្មទេសនា ត្រឹមតែប៉ុណ្ណោះ។*

ដោយន័យនៃព្រះសាសនា

សីល *ជាសេចក្តីល្អខាងដើម ។*

សមាធិ  ជាសេចកក្តីល្អត្រង់កណ្តាល។

វិបស្សនា  ជាសេចក្តីល្អក្នុងទីបំផុត ។

ម្យ៉ាងទៀត

សមាធិ   ជាសេចក្តីល្អខាងដើម។

វិបស្សនា ជាសេចក្តីល្អត្រង់កណ្តាល។

មគ្គ ជាសេចក្តីល្អក្នុងទីបំផុត។

ម្យ៉ាងទៀត

វិបស្សនា ជាសេចក្តីល្អខាងដើម។

មគ្គ ជាសេចក្តីល្អត្រង់កណ្តាល។

ផល ជាសេចក្តីល្អក្នុងទីបំផុត ។

ម្យ៉ាងទៀត

មគ្គ ជាសេចក្តីល្អខាងដើម។

ផល ជាសេចក្តីល្អត្រង់កណ្តាល។

និព្វាន ជាសេចក្តីល្អក្នុងទីបំផុត ។

**ម្យ៉ាងទៀត លោកចាប់ជាគូៗ គឺ៖**

សីល  និង  សមាធិ  ចាត់ជាសេចក្តីល្អខាងដើម ។

វិបស្សនា និង មគ្គ ចាត់ជាសេចក្ដីល្អត្រង់កណ្ដាល ។

ផល និង ព្រះនិព្វាន ចាប់ជាសេចក្ដីល្អក្នុងទីបំផុត។

ភិក្ខុកាលសម្ដែងធម៌ ត្រូវតែជាអ្នកសម្ដែងធម៌ឱ្យមានប្រយោជន៍(**សត្ថំ**) ។ សម្ដែងធម៌ធ្វើឱ្យមានអក្សរបរិបូណ៌ (**សព្យញ្ជនំ**)។ សម្ដែងធម៌ធ្វើឱ្យបរិបូណ៌សព្វគ្រប់ កុំឱ្យខ្វះខាតឡើយ (**កេវលបរិបុណ្ណំ**) ។ សម្ដែងធម៌ឱ្យបរិសុទ្ធ ឱ្យប្រាជក គឺឱ្យបាត់សេចក្ដីស្រពេចស្រពិល (**បរិសុទ្ធំ**) ។ ក៏កាលសម្ដែងធម៌យ៉ាងនោះ ឈ្មោះថា រមែងប្រកាសអដ្ឋង្គិកមគ្គ ដែលសង្គ្រោះដោយត្រៃសិក្ខា គឺ សីល សមាធិ និងបញ្ញា ដែលលោកអ្នកប្រសើរប្រព្រឹត្តហើយ (**ព្រហ្មចរិយំ បកាសេន្តិ** )។

ចប់បុគ្គលមានបញ្ញាដូចក្អមផ្កាប់

## (៨) . បុគ្គលមានរាគៈមិនទាន់ប្រាសចេញជាដើម

១. **កាមេសុ ច ភវេសុ ច អវីតរាគោ** = បុគ្គលខ្លះមិនប្រាសចាកតម្រេកក្នុងកាមនិងភពក៏មាន ។ អធិប្បាយថា: ព្រះ**សោតាបន្ន** និងព្រះ**សកទាគាមី** នៅមិនទាន់ប្រាសចាករាគៈ ក្នុងកាមគុណទាំង៥ និងភពទាំង៣, សូម្បីបុថុជ្ជនក៏ដូច្នោះដែរ ។ តែសម្រាប់បុថុជ្ជនទ្រង់

មិនកាន់យក ព្រោះមិនជាទព្វបុគ្គលទេ។ ដូចនាយជាងឈើ អ្នកឈ្លាសជំនាញ ចូលទៅកាន់ព្រៃដើម្បីត្រូវការទព្វសម្ភារៈ រមែងនាំយកតែឈើដែលសំខាន់ៗប៉ុណ្ណោះ។

២. **កាមេសុ វីតរាគោ ភវេសុ អវីតរាគោ** = បុគ្គលខ្លះប្រាសចាកតម្រេកក្នុងកាមតែមិនទាន់ប្រាសចាកតម្រេកក្នុងភពក៏មាន។ អធិប្បាយថា : ព្រះ**អនាគាមី** ប្រាសចាករាគៈក្នុងបញ្ចកាមគុណ គឺ រូប សម្លេង ក្លិន រស និងផោដ្ឋព្វ ដែលគួរស្រលាញ់ គួរប្រាថ្នា។ តែមិនទាន់ប្រាសចាករាគៈក្នុងរូបភព និងអរូបភព។

៣. **កាមេសុ ច ភវេសុ ច វីតរាគោ** = បុគ្គលខ្លះប្រាសចាកតម្រេកក្នុងកាមផង ប្រាសចាកតម្រេកក្នុងភពផងក៏មាន បានដល់ ព្រះ**អរហន្ត**ប្រាសចាករាគៈ ដោយប្រការទាំងពួង។

ចប់បុគ្គលមានរាគៈមិនទាន់ប្រាសទៅជាដើម

## (៩). បុគ្គលប្រៀបដូចគំនូសថ្មជាដើម

**១. បាសាណលេខូបមោ** = បុគ្គលប្រៀបដោយគំនូសថ្ម ។

អធិប្បាយថា:បុគ្គលដែលមានសេចក្តីក្រោធរឿយៗ។ហើយកើតអស់កាលជានិច្ច សេចក្តីក្រោធរបស់បុគ្គលនេះ ដូចជាគំនូសថ្ម

តាំងនៅអស់កាលដ៏យូរ សេចក្តីឧបមានេះយ៉ាងណា បុគ្គលនោះក៏យ៉ាងនោះដែរ។

**២. បឋវីលេខូបមោ =** បុគ្គលប្រៀបដោយគំនូសដី ។

អធិប្បាយថា : សេចក្តីក្រោធរបស់បុគ្គលនេះ កើតហើយឆាប់រលុប ដូចគំនូសដីដែលឆាប់រលុបដោយខ្យល់ ឬទឹកដូច្នោះដែរ។

**៣. ឧទកលេខូបមោ =** បុគ្គលប្រៀបដោយគំនូសទឹក ។

អធិប្បាយថា : បុគ្គលនេះទុកជាគេនិយាយដោយពាក្យដ៏រឹងរូសក្តី ទុកជាគេនិយាយពាក្យអាក្រក់ក្តី ទុកជាគេនិយាយដោយពាក្យមិនជាទីគាប់ចិត្តក្តី ក៏នៅតែស្រស់ស្រាយផង រីករាយផង រួសរាយផង គំនូសទឹកតែងឆាប់រលប់ទៅ ជាគំនូសមិនឋិតនៅអស់កាលជាយូរអង្វែង យ៉ាងណា បុគ្គលនោះក៏យ៉ាងនោះដែរ នេះហៅថា បុគ្គលប្រៀបដោយគំនូសទឹក។

ចប់បុគ្គលប្រៀបដូចគំនូសថ្មជាដើម

## (១០). តយោ ទោត្តក្កូបមា បុគ្គលា

### (បុគ្គល ៣ ពួកប្រៀបដោយសំពត់សំបកឈើ)

**១. នវោបិ បោត្ថកោ =** ***សំពត់សម្បកឈើនៅថ្មី*** *ជាសំពត់មានពណ៌អាក្រក់ផងមានសម្ជស្សរើងផង មានតម្លៃតិចផង*[30]។

**២. មជ្ឈិមោបិ បោត្ថកោ=*សំពត់សម្បកឈើជាកណ្តាល*** *ជាសំពត់មានពណ៌អាក្រក់ផងមានសម្ជស្សរើងផង មានតម្លៃតិចផង*[៣១]។

**៣. ជិណ្ណោបិ បោត្ថកោ =** ***សំពត់សម្បកឈើចាស់*** *សំពត់មានពណ៌អាក្រក់ ផងមានសម្ជស្សរើងផង មានតម្លៃតិចផង។ ពួកជនតែងយកសំពត់សម្បកឈើ ដែលចាស់ទៅជូតឆ្នាំង ឬយកសំពត់សម្បកឈើចាស់នោះ ទៅចោលលើសម្រាម។*

## *អធិប្បាយ*

**ទុព្វណ្ណោ = *ជាសំពត់មានពណ៌អាក្រក់ ប្រសិនបើភិក្ខុថ្មី*** *ជាអ្នកទ្រុស្តសីល មានធម៌ដ៏លាមក អំពើនេះ ចំពោះ**ភិក្ខុ**នោះមានពណ៌*

---

[៣០] *សំពត់ដែលមានតម្លៃមិនខ្ពស់ គឺមានតម្លៃត្រឹម១ហាបណៈ (១កហាបណៈ=៤បាត) ។*

[៣១] *កាលបើលក់ក្នុងតម្លៃខ្ពស់ បានត្រឹមពាក់កណ្តាល ម្យ៉ាងទៀតក្នុងវេលាសំពត់នោះចាស់ហើយ ក៏មានតម្លៃត្រឹមតែ១មាសកៈ(១មាសកៈ=១បាទ)ឬត្រឹម១កាកណិកៈ (១កាកណិកៈ=តម្លៃសាច់ដែលក្អែកស៊ីម្តង ជាតម្លៃទាបបំផុតក្នុងសម័យនោះ)។អដ្ឋកថា*

គឺសីលអាក្រក់ សំពត់សំបកឈើនោះ មានពណ៌អាក្រក់ មានឧបមាយ៉ាងណាមិញ បុគ្គលនេះក៏មានឧបមេយ្យយ៉ាងនោះដែរ។

**ទុក្ខសម្ផស្សោ = មានសម្ផ័ស្សរឹងផង** បើពួកជនណាមួយ ទៅសេពគប់ចូលទៅអង្គុយជិត តែងដល់នូវការប្រព្រឹត្តតាម នូវទិដ្ឋិរបស់លោក, បុគ្គលអ្នកសេពគប់នោះប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខអស់ការជាយូរអង្វែង ដល់ជនទាំងនោះ អំពើនេះ ព្រោះបុគ្គលនោះមានសម្ផស្សជាទុក្ខ សំពត់សំបកឈើនោះមានសម្ផ័ស្សរឹង មានឧបមាយ៉ាងណាមិញ បុគ្គលនេះក៏មានឧបមេយ្យយ៉ាងនោះដែរ។

**អប្បគ្ឃោ = មានតម្លៃតិច** បុគ្គលនេះបើ ទទួលចីវរ បិណ្ឌបាត្រ សេនាសនៈនិងគិលានប្បច្ចយភេសជ្ជបរិក្ខារ របស់ជនពួកណា ការទទួលនោះ ជាអំពើមិនមានផលច្រើន មិនមានអានិសង្សច្រើនដល់ជនពួកនោះឡើយ អំពើនេះ ព្រោះបុគ្គលនោះមានតម្លៃតិច សំពត់សំបកឈើ មានតម្លៃតិច មានឧបមាយ៉ាងណាមិញ បុគ្គលនេះ មានឧបមេយ្យយ៉ាងនោះដែរ។

សូម្បីភិក្ខុ**កណ្តាលក្តី** ភិក្ខុជា**ថេរក្តី**ក៏មានន័យដូចគ្នាដែរ។

ពួកជនតែងយកសម្បកឈើ ដែលចាស់ទៅជូតផ្ទាំង ឬយកសំពត់សម្បកឈើចាស់នោះ ទៅចោលលើសម្រាម= ភិក្ខុជាថេរៈនេះ មានសភាពយ៉ាងនេះ និយាយក្នុងកណ្តាលជំនុំសង្ឃ ពួកភិក្ខុនាំគ្នានិយាយយ៉ាងនេះ និងភិក្ខុជាថេរៈនោះថា ប្រយោជន៍អ្វីដោយពាក្យដែលលោកជាមនុស្សល្ងង់មិនឈ្លាស ពោលហើយលោកសម្គាល់នូវពាក្យដែលគេគប្បីពោលចុះ ភិក្ខុនោះក៏ខឹង អន់ចិត្ត បើសង្ឃលើកទោស ដោយវាចាមានសភាពយ៉ាងណា ក៏បញ្ចេញនូវវាចាមានសភាពយ៉ាងនោះ ដូចជាសំពត់សំបកឈើដែលគេចោលលើគំនរសំរាម ។ នេះបុគ្គល ៣ ពួក ប្រៀបដោយសំពត់សំបកឈើ រមែងមានក្នុងពួកភិក្ខុ។

**អដ្ឋកថា**

ពាក្យថា **ភិក្ខុថ្មី** បានដល់ ឧបសម្បទ បាន៥វស្សាចុះមក សូម្បីមានអាយុ ៦០ ក៏ហៅថា អ្នកថ្មីដែរ នេះហៅថា នវភិក្ខុ ។

ពាក្យថា **ភិក្ខុកណ្តាល** គឺភិក្ខុដែលឧបសម្បទបានរាប់ពី៥វស្សា ដល់៩វស្សា ហៅថា មជ្ឈិមភិក្ខុ ។

ពាក្យថា **ភិក្ខុជាថេរៈ** ឧបសម្បទចាប់ពី ១០ វស្សាឡើងទៅ ហៅថា ព្រះថេរៈ ។

*បទថា* ***ទុព្វណ្ណតាយ*** *សេចក្ដីថា ព្រោះមានវណ្ណៈមិនស្អាត ដោយវណ្ណៈនៃសរីរៈខ្លះ ដោយវណ្ណៈនៃគុណខ្លះ ។ ក៏វណ្ណៈនៃសរីរៈ របស់ភិក្ខុទ្រុស្តសីល អង្គុយក្នុងកណ្ដាលបរិស័ទ រមែងមិនរុងរឿង ព្រោះភាពនៃខ្លួនមិនមានអំណាច , សម្រាប់វណ្ណៈ គឺគុណសេចក្ដី ល្អរបស់ភិក្ខុទ្រុស្តសីលនោះ ក៏មិនចាំបាច់ពោលឡើយ។*

ចប់បុគ្គល ៣ ពួកប្រៀបដោយសំពត់សំបកឈើ

## (១១). តយោ កាសិកវត្ថូបមា បុគ្គលា

*(បុគ្គល ៣ ពួកប្រៀបដោយ សំពត់ កាសិក:)*

**១. នវម្បិ កាសិកវត្ថំ =** ***សំពត់កាសិកៈថ្មី*** *ជាសំពត់មានពណ៌ល្អ ផង មានសម្ផស្សទន់ផង មានតម្លៃច្រើនផង។*

**២. មជ្ឈិមម្បិ កាសិកវត្ថំ =** ***សំពត់កាសិកៈជាកណ្ដាល*** *ជាសំពត់ មានពណ៌ល្អផង មានសម្ផស្សទន់ផង មានតម្លៃច្រើនផង។*

**៣. ជិណ្ណម្បិ កាសិកវត្ថំ =** ***សំពត់កាសិកៈចាស់*** *ជាសំពត់មានពណ៌ ល្អផង មានសម្ផស្សទន់ផង មានតម្លៃច្រើនផង ពួកជនតែងយក សំពត់កាសិកៈដែលចាស់ហើយ ធ្វើជាសំពត់ សម្រាប់វេចរតនៈ*

វត្ថុបាន ឬតម្កល់ទុកនូវសំពត់នោះ ក្នុងទូសម្រាប់ដាក់នូវគ្រឿងក្រអូប។

## អធិប្បាយ

**សំពត់កាសិកៈថ្មី ជាសំពត់មានពណ៌ល្អ** = ប្រសិនបើភិក្ខុបួសថ្មី ជាអ្នកមានសីល មានកល្យាណធម៌ អំពើនេះ ព្រោះភិក្ខុនោះ មានពណ៌គឺសីលល្អ សំពត់កាសិកៈនោះ មានពណ៌ល្អ មានឧបមាយ៉ាងណាមិញ បុគ្គលនោះ ក៏មានឧបមេយ្យយ៉ាងនោះដែរ ។

**មានសម្ផស្សទន់ផង** = បើពួកជនណាមួយ សេព គប់ ចូលទៅអង្គុយជិត តែងដល់នូវការប្រព្រឹត្តតាមនូវទិដ្ឋិរបស់បុគ្គលនោះ ការសេព គប់ ជាដើមនោះ តែងប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខ ដល់ជនពួកនោះ អស់កាលជាយូរអង្វែង អំពើនេះ ព្រោះបុគ្គលនោះមានសម្ផស្សជាសុខ សំពត់កាសិកៈនោះ មានសម្ផស្សទន់ មានឧបមាយ៉ាងណាមិញ បុគ្គលនេះ ក៏មានឧបមេយ្យយ៉ាងនោះដែរ ។

**មានតម្លៃច្រើន** =បុគ្គលនេះបើទទួលចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ របស់ជនពួកណា ការទទួលនោះ

*រមែងមានផលច្រើន មានអានិសង្សច្រើន ដោយជនពួកនោះ អំពើនេះ ព្រោះបុគ្គលនោះមានតម្លៃច្រើន សំពត់កាសិកៈ មានតម្លៃច្រើន មានឧបមាយ៉ាងណាមិញ បុគ្គលនោះ ក៏មានឧបមេយ្យយ៉ាងនោះដែរ។*

*សូម្បីភិក្ខុ**កណ្តាលក្តី** ភិក្ខុជា**ថេរក្តី**ក៏មានន័យដូចគ្នា។*

**សំពត់កាសិកៈដែលចាស់ហើយ ធ្វើជាសំពត់ សម្រាប់រេចកែវបាន ឬតម្កល់ទុកនូវសំពត់នោះ ក្នុងទូសម្រាប់ដាក់នូវគ្រឿងក្រអូប** = *បើភិក្ខុជាថេរៈ មានសភាពបែបនេះ និយាយក្នុងកណ្តាលជំនុំសង្ឃ ពួកភិក្ខុនាំគ្នានិយាយយ៉ាងនេះ នឹងភិក្ខុជាថេរៈនោះថា បពិត្រលោកមានអាយុ លោកជាអ្នកសទ្ធាតិច ពោលនូវធម៌ផង នូវវិន័យផង ពាក្យនោះ របស់ភិក្ខុជាថេរៈនោះ គួរយកទុកដាក់ក្នុងចិត្តបាន ដូចជាសំពត់កា-សិកៈ គួរយកទុកដាក់ក្នុងទូ សម្រាប់ដាក់នូវវត្ថុមានក្លិនក្រអូប។ នេះបុគ្គល ៣ ពួក ប្រៀបដោយសំពត់កាសិកៈ រមែងមានក្នុងពួកភិក្ខុ។*

**អដ្ឋកថា**

**សំពត់ដែនកាសី** = *សំពត់សាច់ល្អិតដែលគេត្បាញដោយអំបោះ ដែលគេកាន់យកកប្បាស ៣ ប្រភេទ ហើយក្រងចូលគ្នា*

*ហៅថា សំពត់ដែនកាសី។ សំពត់ដែលគេត្បាញថ្មីនោះ រាប់តម្លៃមិនបានទេ,ដែលប្រើប្រាស់ពាក់កណ្ដាលចាស់ ពាក់កណ្ដាលថ្មី មានតម្លៃ ១ពាន់ខ្លះ ៣០ពាន់ខ្លះ ,តែក្នុងវេលាដែលចាស់ហើយ ក៏នៅតែមានតម្លៃដល់ទៅ ៨ ពាន់ក៏មាន ១០ពាន់ក៏មាន។*

*ពីរបទថា* **តេសន្តំ ហោតិ** *សេចក្ដីថា ការសេពរបស់បុគ្គលទាំងនោះរមែងប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខរហូតអស់កាលយូរ ដូចបុគ្គលទាំងឡាយអ្នកសេពគប់ព្រះសម្មាសម្ពុទ្ធជាដើម។ ព្រោះថា សត្វទាំងឡាយ ដែលអាស្រ័យព្រះសម្មាសម្ពុទ្ធមួយអង្គហើយ រមែងរួចផុតចាក អាសវក្កិលេស រហូតដល់សម័យសព្វថ្ងៃ រាប់ប្រមាណមិនបាន សត្វទាំងឡាយដែលអាស្រ័យព្រះសារីបុត្ត និងព្រះមហាមោគ្គលានត្ថេរ និងព្រះអសីតិមហាសាវក ហើយទៅកាន់ឋានសួគ៌ក៏ប្រមាណមិនបានដូចគ្នា , សូម្បីសត្វដែលដើរទៅតាមទិដ្ឋានុគតិ គឺតាមគំរូរបស់ព្រះអរិយៈទាំងនោះ រហូតដល់សព្វថ្ងៃនេះ ក៏ប្រមាណមិនបាន។*

*ពីរបទថា* **អាធេយ្យំ គច្ឆតិ** *សេចក្ដីថា ពាក្យរបស់ព្រះថេរៈនោះ អាស្រ័យអត្ថ រមែងដល់នូវភាពជារបស់ដែលបុគ្គលគប្បីប្រមូលរក្សាទុក គឺដាក់ទុកលើក្បាលដែលជាអវយវៈខ្ពស់បំផុត និង*

ក្នុងបេះដូង ដូចគ្នានឹងសំពត់ដែនកាសីដែលមានតម្លៃរាប់ប្រមាណមិនបាន រមែងដល់ភាពជារបស់ដែលបុគ្គលគប្បីរក្សាទុក គឺដាក់ទុកក្នុងហិបសម្រាប់ដាក់របស់ក្រអូបដូច្នោះដែរ។

ចប់បុគ្គលពពួកប្រៀបដូចសំពត់កាសិក:

## (១២). បុគ្គលដែលគេប្រមាណបានដោយងាយ

១.**សុប្បមេយ្យោ** = *បុគ្គលដែលគេប្រមាណបានដោយងាយ។*

២. **ទុប្បមេយ្យោ** = *បុគ្គលដែលគេប្រមាណបានដោយក្រ។*

៣. **អប្បមេយ្យោ** = *បុគ្គលដែលគេប្រមាណមិនបាន។*

### *អធិប្បាយ*

១.**សុប្បមេយ្យោ**=*បុគ្គលខ្លះក្នុងលោកនេះជាអ្នករាយមាយលើកកម្ពស់ មានចិត្តឃ្លេងឃ្លោង មានមាត់រឹង មានវាចារាត់រាយ ភ្លេចស្មារតី មិនដឹងខ្លួន មានចិត្តមិនតម្កល់មាំ មានចិត្តភ័ន្តច្រឡំ មានឥន្ទ្រីយ៍ប្រាកដ នេះហៅថា បុគ្គលដែលគេប្រមាណបានដោយងាយ។*

២.**ទុប្បមេយ្យោ**=*បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកមិនរាយមាយមិនលើកកម្ពស់ មានចិត្តមិនឃ្លេងឃ្លោង មានមាត់មិនរឹង មានវាចា*

មិនរាត់រាយ មានស្មារតីតម្កល់មាំ មានសេចក្តីដឹងខ្លួន មានចិត្តតម្កល់មាំ មានចិត្តមូល ក្នុងអារម្មណ៍តែមួយ មានឥន្ទ្រិយ៍សង្រួមហើយ នេះហៅថាបុគ្គលដែលគេប្រមាណបានដោយក្រ ។

***អដ្ឋកថា:*** *ព្រោះបុគ្គលប្រភេទនេះ នរណាមួយលំបាកកំណត់ថា "អ្នកនេះជាព្រះអនាគាមី ឬក៏ព្រះអរហន្តហ្ន៎" ព្រោះហេតុដូច្នោះ បុគ្គលនេះ ទើបឈ្មោះថា ទុប្បមេយ្យោ។*

៣. **អប្បមេយ្យោ =** *បុគ្គលខ្លះក្នុងលោកនេះ បានធ្វើឲ្យជាក់ច្បាស់ សម្រេច ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្ន នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ហើយសម្រេចសម្រាន្តនៅ នេះហៅថាបុគ្គលដែលគេប្រមាណមិនបាន។*

***អដ្ឋកថា:*** *បុគ្គលណាមួយមិនអាចប្រមាណអាកាសបាន យ៉ាងណា នរណាមួយ ក៏មិនអាចប្រមាណនៃព្រះខីណាស្រពបានដូច្នោះដែរ។*

ចប់បុគ្គលដែលគេប្រមាណបានដោយងាយ

## (១៣). បុគ្គលមិនគួរសេពគប់ជាដើម

**១. បុគ្គលោ ន សេវិតព្វោ ន ភជិតព្វោ ន បយិរុបាសិតព្វោ =** *បុគ្គលខ្លះមិនគួរសេពគប់ មិនគួរគប់រក មិនគួរចូលទៅអង្គុយជិត វៀរលែងតែមានសេចក្តីអាណិត វៀរលែងតែមានសេចក្តីអនុគ្រោះក៏មាន។*

**២. បុគ្គលោ សេវិតព្វោ ភជិតព្វោ បយិរុបាសិតព្វោ=** *បុគ្គលខ្លះគួរសេពគប់ គួរគប់រក គួរចូលទៅអង្គុយជិតក៏មាន។*

**៣. បុគ្គលោ សក្កត្វា គរុកត្វា សេវិតព្វោ =** *បុគ្គលខ្លះ គួរធ្វើសក្ការៈ គួរគោរព គួរសេពគប់ គួរចូលទៅអង្គុយជិតក៏មាន ។*

### *អធិប្បាយ*

**អដ្ឋកថា**

បុគ្គលទី១. ***ពាក្យថា*** **ហីនោ ហោតិ សីលេន =** *ជាអ្នកថោកទាបជាង ដោយសីល អធិប្បាយថា បុគ្គលណារក្សាសីល ៥, បុគ្គលដែលរក្សាសីល១០ មិនគប្បីសេពគប់ ។ ចំណែកបុគ្គលណារក្សាសីល១០ បុគ្គលដែលរក្សាចតុប្បារិសុទ្ធិសីលមិនគប្បីសេពគប់ ។*

បទថា **អញ្ញត្រ អនុទយោ អញ្ញត្រ អនុកម្បា** = វៀរចាកសេចក្ដីអាណិត និងសេចក្ដីអនុគ្រោះ អធិប្បាយថា ក៏បុគ្គលបែបនេះដែលនរណាម្នាក់ មិនគួរសេពគប់ដើម្បីប្រយោជន៍របស់ខ្លួនឯង , តែថា ការចូលទៅរកគេដោយអំណាចនៃសេចក្ដីអាណិត និងអនុគ្រោះ ក៏សមគួរ ។

**បុគ្គលទី២.** បុគ្គលនេះ ជាអ្នកស្មើគ្នាដោយ សីល សមាធិ និងបញ្ញា ។ព្រោះសីលកថាក្ដី សមាធិកថាក្ដី បញ្ញាកថាក្ដី រមែងជាទីសប្បាយដល់ពួកគេ ។ តែថា កាលមានបុគ្គលទ្រុស្ដសីល មានពាក្យដែលពោលនិយាយដល់សីល និងបុគ្គលដែលទ្រុស្ដសីល (នោះ) រមែងជាពាក្យសម្ដីដែលពោលដោយលំបាក ព្រោះហេតុដូច្នោះ សីលកថា ក៏រមែងមិនមាន ។ សូម្បីពាក្យដែលពោលដល់សមាធិ និងបញ្ញា ក៏មានន័យដូចគ្នា ។ ក៏ភិក្ខុពីរអង្គអ្នកមានសមាធិ រមែងពោលពណ៌នាអំពីគុណនៃសមាធិ , អ្នកមានបញ្ញាក៏រមែងពោលពណ៌នាអំពីគុណនៃបញ្ញា , គេទាំងពីរនោះ រមែងមិនស្គាល់ដល់ការឈានកន្លងរហូតអស់រាត្រី ឬរហូតថ្ងៃ បានទេ (ព្រោះអង្គអ្នកមានសមាធិពោលសរសើរតែសមាធិ មិនពោលសរសើរបញ្ញា អង្គអ្នកមានបញ្ញាពោលសរសើរបញ្ញា មិនពោល

សរសើរសមាធិ ដូច្នេះលោកទាំងពីរមិនមានធម៌ជាទីសប្បាយរួមគ្នា) ។

បុគ្គលទី៣. បុគ្គលោ សក្កត្វា គរុកត្វា សេវិតព្វោ = បុគ្គលនេះជាអ្នកច្រើនដោយ សីល សមាធិ និងបញ្ញា ។ ព្រោះបុគ្គលដែលគិតថា អញនឹងបំពេញសីលក្ខន្ធ សមាធិក្ខន្ធ និងបញ្ញាខន្ធ ដែលមិនទាន់បរិបូណ៌ ឬនឹងអនុគ្រោះនូវសីលក្ខន្ធ សមាធិក្ខន្ធ និងបញ្ញាខន្ធដែលបរិបូណ៌ហើយ ដោយបញ្ញាក្នុងទីនោះៗ ។ បុគ្គលដែលមានសភាពបែបនេះ គេគួរធ្វើសក្ការៈ គួរគោរព ហើយគួរសេព គប់រកចូលទៅអង្គុយជិត។

ចប់បុគ្គលមិនគួរសេពគប់ជាដើម

## (១៤). បុគ្គលដែលគួរខ្ពើមជាដើម

១ . បុគ្គលោ ជិគុច្ឆិតព្វោ ន សេវិតព្វោ ន ភជិតព្វោ ន បយិរុ-បាសិតព្វោ = បុគ្គលដែលគេគួរខ្ពើម មិនគួរសេពគប់ មិនគួររាប់រក មិនគួរចូលទៅអង្គុយជិតក៏មាន ។

២. បុគ្គលោ អជ្ឈុបេក្ខិតព្វោ ន សេវិព្វោ ន ភជិតព្វោ ន បយិរុបាសិតព្វោ = បុគ្គលខ្លះគួរគេ រមិលមើល តែមិនគួរសេព, មិនគួរគប់រក,មិនគួរចូលទៅអង្គុយជិតក៏មាន ។

៣.**បុគ្គលោ សេវិតព្វោ ភជិតព្វោ បយិរុបាសិតព្វោ** = *បុគ្គលខ្លះគួរគេសេព,គួរគប់រក ,គួរចូលទៅអង្គុយជិតក៏មាន ។*

*អធិប្បាយ*

**បុគ្គលទី១** = *បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកទ្រុស្តសីល មានធមិដ៏លាមក មានមារយាទ គឺបុគ្គលគប្បីរលឹកដោយសេចក្ដីរង្កៀសដោយអំពើមិនស្អាត បិទបាំងអំពើទុក មិនមែនជាសមណៈ ប្ដេជ្ញាខ្លួនថាជាសមណៈ មិនមែនជាព្រហ្មចារី ប្ដេជ្ញាខ្លួនថាជា ព្រហ្មចារីជាអ្នកស្អុយក្នុង មានចិត្តទទឹកដោយរាគៈ ជ្រោកជ្រាកដោយកិលេស ដែលបុគ្គលបែបនេះ គេគប្បីខ្ពើម មិនគួរសេពគប់ មិនគួរគប់រក មិនគួរចូលទៅអង្គុយជិត ដំណើរនោះព្រោះហេតុអ្វី? ព្រោះថា បុគ្គលមិនដល់នូវការប្រព្រឹត្តតាម នូវទិដ្ឋិរបស់បុគ្គលបែបនេះ ក៏ពិតមែនហើយ តែកិត្តិស័ព្ទដ៏អាក្រក់ នៃបុគ្គលនោះ គេរមែងខ្ចរខ្ចាយថា បុរសបុគ្គលនេះ មានមិត្តអាក្រក់ មានសម្លាញ់អាក្រក់ ងាកទៅរក បុគ្គលអាក្រក់ ពស់នៅក្នុងរណ្ដៅលាមក មិនចឹកស៊ី ក៏ពិតមែនហើយ តែលាមក គង់ប្រឡាក់នូវពស់នោះ យ៉ាងណាមិញ បុគ្គលនោះក៏ដូច្នោះដែរ។*

**បុគ្គលទី២ =**បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកក្រោធ ច្រើនដោយការចង្អៀតចង្អល់ សូម្បីតែគេស្តីថាបន្តិចបន្តួច ក៏ខ្នាក់ចិត្ត ខឹងព្យាបាទ តតប ធ្វើសេចក្តីក្រោធ។ល។ បុគ្គលនេះគួរគេ រមិលមើល តែមិនគួរសេព មិនគួរគប់ មិនគួរចូលទៅអង្គុយជិត ។ ព្រោះហេតុអ្វី? ព្រោះថា អ្នកផងគេតែងគិតថា អ្នកនេះមុខជានឹងជេរអញ នឹងផ្តាសាអញ ឬនឹងធ្វើអំពើមិនជាប្រយោជន៍ដល់អាត្មាអញពុំខាន ព្រោះហេតុនោះ បុគ្គលបែបនេះ គួរគេសំឡឹងមើល តែមិនគួរសេព មិនគួរគប់ មិនគួរចូលទៅអង្គុយជិត។

**អត្ថន័យក្នុងព្រះអដ្ឋកថា :** បុគ្គលដែលច្រើនទៅដោយសេចក្តីក្រោធ កាលបុគ្គលដទៃ ចូលទៅជិតហើយ រមែងក្រោធតាមបុគ្គលនោះដែរ ទោះបីចៀសចេញទៅ ក៏នៅតែក្រោធទៀតនោះឯង លោកឧបមាដូចជា ភ្លើងគំនរចំបើង កាលបុគ្គលចូលទៅជិតហើយ រមែងដល់នូវសេចក្តីក្តៅក្រហាយក៏យ៉ាងនោះដែរ។ ព្រោះហេតុនោះបានជាគេ (អ្នកក្រោធនោះ) បុគ្គលគប្បីព្រងើយកន្តើយហើយមិនគួរសេពគប់

**បុគ្គលទី៣ =** បុគ្គលខ្លះជាអ្នកមានសីល មានធម៌ល្អ បុគ្គលបែបនេះ ដែលគេគួរសេព គួរគប់រក គួរចូលទៅអង្គុយជិត។

ដំណើរនោះ ព្រោះហេតុអ្វី ។ បុគ្គលមិនដល់នូវការប្រព្រឹត្តតាម នូវទិដ្ឋិរបស់បុគ្គលបែបនេះ ក៏ពិតមែនហើយ តែកិត្តិស័ព្ទដ៏ល្អនៃបុគ្គលនោះ តែងខ្ចរខ្ចាយល្បីទៅថា បុរសបុគ្គលនេះ មានសំឡាញ់ល្អ ផាកទៅរកបុគ្គលល្អ ព្រោះហេតុនោះ បុគ្គលបែបនេះ គួរគេសេព គួរគប់រក គួរចូលទៅអង្គុយជិត។

**អដ្ឋកថា**

បទថា **សហាយោ**= អ្នកទៅព្រមគ្នា គឺត្រាច់ទៅជាមួយគ្នា ។

បទថា **កណ្យាណសម្បវង្កោ** = អ្នករួមក្រុមក្នុងបុគ្គលល្អ អ្នកមានធមិចម្រើន, អធិប្បាយថា អ្នកមានចិត្តបង្អោនទៅ គឺត្រេកអរពេញចិត្តក្នុងមិត្តអ្នកមានកល្យាណធមិនោះ ។

ចប់បុគ្គលដែលគួររង្កៀសជាដើម

## (១៥). បុគ្គលមានប្រក្រតីធ្វើឱ្យបរិបូណ៌ក្នុងសីលជាដើម

**១. បុគ្គលោ សីលេសុ បរិបូរីការី សមាធិស្មឹ មត្តសោការី បញ្ញាយ មត្តសោការី**=បុគ្គលខ្លះ ធ្វើឱ្យពេញលេញក្នុងសីល តែធ្វើបន្តិចបន្តួចក្នុងសមាធិ ធ្វើបន្តិចបន្តួចក្នុងបញ្ញាក៏មាន។ បានដល់ ព្រះ**សោតាបន្ន និងព្រះ**សកទាគាមី។

២. បុគ្គលោ សីលេសុ ច បរិបុរីការី សមាធិស្មិញ្ច បរិបូរីការី បញ្ញាយ មត្តសោការី = *បុគ្គលខ្លះធ្វើឱ្យពេញចិត្តក្នុងសីលផងធ្វើ ពេញលេញក្នុងសមាធិផង តែធ្វើបន្តិចបន្តួចក្នុងបញ្ញាក៏មាន បានដល់* ***ព្រះអនាគាមី។***

៣. បុគ្គលោ សីលេសុ ច បរិបុរីការី សមាធិស្មិញ្ច បរិបូរីការី បញ្ញាយ ច បរិបូរីការី = *បុគ្គលខ្លះធ្វើឱ្យពេញលេញក្នុងសីលផង ធ្វើពេញលេញក្នុងសមាធិផង ធ្វើពេញលេញក្នុងបញ្ញាផងក៏មាន បានដល់* ***ព្រះអរហន្ត។***

*អធិប្បាយ*

**អដ្ឋកថា** =*ព្រះអរិយសាវកមិនប្រព្រឹត្តកន្លងមហាសីល គឺអាបត្តិបារាជិក៤ ដែលជាខាងដើម នៃមគ្គព្រហ្មចរិយៈ គឺជាអាទិព្រហ្មចរិ-យៈ និងលោកចេញចាកអាបត្តិតូចៗតាមលំដាប់ ដែលត្រូវហើយ។ ព្រះអរិយសាវកទាំងនោះ រមែងបំពេញសីលរបស់លោកឱ្យបរិបូ-ណ៌ ព្រោះហេតុនោះ ទើបឈ្មោះថា* **សីលេសុ បរិបូរីការីនោ** *អ្នកមានប្រក្រតីធ្វើឱ្យបរិបូណ៌ក្នុងសីល ។ ម្យ៉ាងទៀត លោកទាំងនោះ នៅមានកាមច្ឆន្ទៈ និងព្យាបាទទាំងឡាយ ដែលជាសត្រូវដល់សមាធិ និងបញ្ញា ព្រោះហេតុដូច្នោះហើយទើប*

លោក ឈ្មោះថា “**សមាធិស្មឹ បញ្ញាយ ច មត្តសោការិនោ** = ល្មមប្រមាណក្នុងសមាធិ និងបញ្ញា”។

***សីលនៅក្នុងព្រះសូត្រដទៃទៀត*** *ព្រះដ៏មានបុណ្យក៏ត្រាស់ថា បុគ្គលដែលបរិបូណ៌ក្នុងសីល តែល្មមប្រមាណក្នុង សមាធិ និងល្មមប្រមាណក្នុងបញ្ញា (ព្រះសោតាបន្ន) ភិក្ខុនោះក៏នៅត្រូវអាបត្តិតូចនិងតូចតាមលំដាប់ដែរ (វៀរអាបត្តិបារាជិកចេញ ក្រៅពីនោះគឺ ចាប់ពីអាបត្តិសង្ឃាទិសេស តាមលំដាប់រហូតដល់អាបត្តិទុក្កដាសិត ហៅថា អាបត្តិតូច និងតូចតាមលំដាប់) ”ទាំងនោះខ្លះ នៅចេញចាកអាបត្តិខ្លះ។ ហេតុនោះនឹងជាអ្វី ម្នាលភិក្ខុទាំងឡាយ តថាគតនៅតែមិនឱ្យឈ្មោះថា អភ័ព្វក្នុងការត្រូវអាបត្តិហើយចេញចាកអាបត្តិនោះទេ។ ពួកសិក្ខាបទណា ជាខាងដើមនៃមគ្គព្រហ្មចារ្យ សមគួរដល់មគ្គព្រហ្មចារ្យទី ៤ , ភិក្ខុនោះជាអ្នកត្រូវមានសីលជាប់មិនដាច់ , មានសីលតាំងនៅជង់ , សមាទានសិក្សាក្នុងសិក្ខាបទទាំងនោះ ។ ភិក្ខុនោះនៅតែបាន* ***សោតៈ*** *(សោតាបត្តិមគ្គ) ព្រោះការអស់ទៅនៃសញ្ញោជនៈ ៣ មានសភាពមិនធ្លាក់ចុះទៅកាន់អបាយ ជាអ្នកទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅខាងមុខ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ធ្វើឱ្យបរិបូណ៌ក្នុងសីល*

។លៈ។ ភិក្ខុនោះនៅតែបានសកទាគាមី ព្រោះអស់សញ្ញោជនៈ ៣ ព្រោះតែស្រាលស្តើង រាគៈ ទោសៈ និង មោហៈ មកកាន់លោកនេះ ម្តងទៀត ក៏ធ្វើនូវទីបំផុតនៃទុក្ខបាន។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ ធ្វើឱ្យបរិបូណ៌ក្នុងសីល ធ្វើឱ្យបរិបូណ៌ក្នុងសមាធិ ធ្វើឱ្យល្មមប្រមាណក្នុងបញ្ញា ។លៈ។ សមាទានសិក្សា ក្នុងសិក្ខាបទទាំងនោះ ។ ភិក្ខុនោះជាអនាគាមី ព្រោះអស់ទៅសំយោជនៈ ៥ ជាចំណែកខាងក្រោម មិនត្រឡប់មកលោកនេះទៀតឡើយ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ ធ្វើឱ្យបរិបូណ៌ក្នុងសីល ធ្វើឱ្យបរិបូណ៌ក្នុងសមាធិ និងធ្វើឱ្យបរិបូណ៌ងក្នុងបញ្ញា ភិក្ខុនោះនៅតែត្រូវអាបត្តិ ក្នុងសិក្ខាបទ តូចនិងតូច បន្ទាប់នោះខ្លះ។លៈ។ សមាទានសិក្សាក្នុងសិក្ខាបទទាំងនោះ។ ភិក្ខុនោះ នៅតែធ្វើឱ្យជាក់ច្បាស់ គឺជាអ្នកចូលដល់នូវការអស់ទៅនៃអាសវក្កិលេសទាំងឡាយ (ព្រះអរហន្ត)" ដូច្នេះ។

ចប់បុគ្គលមានប្រក្រតីធ្វើឱ្យបរិបូណ៌ក្នុងសីលជាដើម

## (១៦). តយោ សត្ថារោ

## ( បុគ្គលជាគ្រូមាន ៣ ពួក )

១. ឥធេកច្ចោ សត្ថា កាមានំ បរិញ្ញំ បញ្ញាបេតិ ន រូបានំ បរិញ្ញំ បញ្ញាបេតិ ន វេទនានំ បរិញ្ញំ បញ្ញាបេតិ = *គ្រូខ្លះក្នុងលោកនេះ បញ្ញត្តិនូវការកំណត់កាម តែមិនបញ្ញត្តនូវការកំណត់រូប មិនបញ្ញត្តនូវការកំណត់វេទនាបានដល់ គ្រូនោះជាអ្នកបាននូវរូបាវចរសមាបត្តិ ដោយការបញ្ញត្តិនោះ ដោយសេចក្តីថា សាស្តានោះ(អន្យតិរ្ថិយ) មានប្រក្រតីបាននូវរូបជ្ឈាន ។*

២. ឥធ បនេកច្ចោ សត្ថា កាមានញ្ច បរិញ្ញំ បញ្ញាបេតិ រូបានញ្ច បរិញ្ញំ បញ្ញាបេតិ ន វេទនានំ បរិញ្ញំ បញ្ញាបេតិ = *គ្រូខ្លះក្នុងលោកនេះ បញ្ញត្តិនូវការកំណត់កាមផង បញ្ញត្តិនូវការកំណត់រូបផង តែមិនបញ្ញត្តនូវការកំណត់វេទនា បានដល់ គ្រូនោះជាអ្នកបាន នូវអ-រូបាវចរសមាបត្តិ ដោយការបញ្ញត្តិនោះ។*

៣. ឥធ បនេកច្ចោ សត្ថា កាមានញ្ច បរិញ្ញំ បញ្ញាបេតិ រូបានញ្ច បរិញ្ញំ បញ្ញាបេតិ វេទនានញ្ច បរិញ្ញំ បញ្ញាបេតិ = *គ្រូខ្លះក្នុងលោកនេះ បញ្ញត្តិនូវការកំណត់កាមផង បញ្ញត្តិនូវការកំណត់រូបផង បញ្ញត្តិនូវការកំណត់វេទនាផង បានដល់ គ្រូនោះគឺជាព្រះសម្មាសម្ពុទ្ធ ដោយការបញ្ញត្តិនោះ។*

*អធិប្បាយ*

***អដ្ឋកថា*** : *ពួកអន្យតិរ្ថិយនោះ កាលបើបញ្ញត្តិការលះកាមទាំងឡាយ រមែងអាចដល់**រូបភព** ។ កាលបើបញ្ញត្តិការលះរូបទាំងឡាយ រមែងអាចដល់**អរូប** ។ កាលបញ្ញត្តិការលះវេទនាទាំងឡាយ រមែងពោលអាចដល់អសញ្ញាភព, កាលបើគេបញ្ញត្តិដោយពេញចិត្ត គប្បីបញ្ញត្តិយ៉ាងនេះ ឈ្មោះថា រមែងមិនអាចដើម្បីបញ្ញត្តិបាន ដោយប្រពៃឡើយ ។*

*ចំណែកព្រះសម្មាសម្ពុទ្ធជាម្ចាស់រមែងលះ(បហានបរិញ្ញា) កាមទាំងឡាយ ដោយ**អនាគាមិមគ្គ**, រមែងបញ្ញត្តិការ**លះរូប** និង**វេទនា**ទាំងឡាយ ដោយ**អរហត្តមគ្គ**។ ជនទាំងពីរពួកខាងដើម ជាសាស្តាខាងក្រៅព្រះពុទ្ធសាសនា ពួកទីបី ជាព្រះពុទ្ធសាសនា។*

ចប់បុគ្គលជាគ្រូមាន ៣ ពួក

## (១៧). អបរេបិ តយោ សត្ថារោ

## *(បុគ្គលជាគ្រូបីពួកដទៃទៀត)*

**១. ឥធេកច្ចោ សត្ថា ទិដ្ឋេ ចេវ ធម្មេ អត្តានំ សច្ចតោ ថេតតោ បញ្ញ-បេតិ អភិសម្បរាយញ្ច អត្តានំ សច្ចតោ ថេតតោ បញ្ញបេតិ** = *គ្រូខ្លះក្នុងលោកនេះ បញ្ញត្តិនូវខ្លួន ក្នុងបច្ចុប្បន្ន ថាទៀង ថាមាំមួន បញ្ញត្តិនូវខ្លួនក្នុង*

*បរលោក ថាទៀង ថាមាំមួនផង។ គ្រូនោះ បណ្ឌិតគប្បីយល់ថា ជា* ***សស្សតវាទ****(អ្នកពោលថាទៀង)។*

២. ឥធ បនេកច្ចោ សត្ថា ទិដ្ឋេ ចេវ ធម្មេ អត្តានំ សច្ចតោ ថេតតោ បញ្ញាបេតិ នោ ច ខោ អភិសម្បរាយំ អត្តានំ អត្តានំ សច្ចតោ ថេតតោ បញ្ញាបេតិ= *គ្រូខ្លះក្នុងលោកនេះ បញ្ញត្តិនូវខ្លួន ក្នុងបច្ចុប្បន្ន ថាទៀង ថាមាំមួន តែមិនបញ្ញត្តិនូវខ្លួនក្នុងបរលោក ថាទៀង ថាមាំមួនឡើយ ។ គ្រូនោះ បណ្ឌិតគប្បីយល់ថាជា* ***ឧច្ចេទវាទ*** *(អ្នកពោលថា ដាច់សូន្យ)*

៣. ឥធ បនេកច្ចោ សត្ថា ទិដ្ឋេ ចេវ ធម្មេ អត្តានំ សច្ចតោ ថេតតោ ន បញ្ញាបេតិ អភិសម្បរាយញ្ច អត្តានំ សច្ចតោ ថេតតោ ន បញ្ញាបេតិ = *គ្រូខ្លះក្នុងលោកនេះ មិនបញ្ញត្តិ នូវខ្លួនក្នុងបច្ចុប្បន្ន ថាទៀងថាមាំមួនផង មិនបញ្ញត្តិខ្លួនក្នុងបរលោកថាទៀងថាមាំមួនផង។ គ្រូនោះ បណ្ឌិតគប្បីយល់ថា គ្រូនោះគឺជា****ព្រះសម្មាសម្ពុទ្ធ*** *ដោយការបញ្ញត្តិនោះ។*

*ចប់បុគ្គលជាគ្រូ ៣ពួកដទៃទៀត*

## ចប់បុគ្គលពួក៣ ត្រឹមតែប៉ុណ្ណោះ

## ចតុក្កនិទ្ទេស

(បុគ្គលពួក៤)

## (១). បុគ្គលជាអសប្បុរសជាដើម

**១. អសប្បុរិសោ =** បុគ្គលជាអសប្បុរស បានដល់ បុគ្គលអ្នកសំលាប់សត្វ លួចទ្រព្យគេ ប្រព្រឹត្តខុសក្នុងកាម និយាយកុហក ផឹកទឹកស្រវឹង គឺសុរានិងមេរ័យ នេះហៅថា អសប្បុរស។

**២. អសប្បុរិសេន អសប្បុរិសតរោ =** បុគ្គលជាអសប្បុរស ក្រៃលែងជាងអសប្បុរស បានដល់ អ្នកប្រព្រឹត្តទ្រុស្តសីល ដោយខ្លួនឯងហើយ បបួលគេឱ្យប្រព្រឹត្តទ្រុស្តសីលដែរ។

**៣. សប្បុរិសោ =** បុគ្គលជាសប្បុរស បានដល់ បុគ្គលអ្នកវៀរចាកការសំលាប់សត្វ វៀរចាកការលួចទ្រព្យគេ វៀរចាកការប្រព្រឹត្តខុសក្នុងកាមេ វៀរចាកការនិយាយកុហក វៀរចាកការផឹកទឹកស្រវឹង គឺសុរានិងមេរ័យ នេះហៅថា សប្បុរស(បុរសខ្ពង់ខ្ពស់)។

**៤. សប្បុរិសេន សប្បុរិសតរោ =** បុគ្គលជាសប្បុរសក្រៃលែងជាងសប្បុរស បានដល់ អ្នកប្រព្រឹត្តរក្សាសីលហើយ បបួលគេឱ្យរក្សាផង (ឧត្តមបុរស ក្រៃលែងជាងឧត្តមបុរស)។

ចប់បុគ្គលជាអសប្បុរសជាដើម

## (២). បុគ្គលអាក្រក់ជាដើម

**១.បាបោ=** *បុគ្គលអាក្រក់ បានដល់ អ្នកប្រកបដោយអកុសលកម្មបថ ១០ ។*

**២.បាននបេន បាបតរោ=***បុគ្គលអាក្រក់ក្រៃលែងជាងបុគ្គលអាក្រក់ បានដល់ អ្នកប្រព្រឹត្តអកុសលកម្មបទ១០ហើយ បបួលគេឱ្យប្រព្រឹត្តអកុសលកម្មបថ១០ផងដែរ។*

**៣. កល្យាណោ =** *បុគ្គលល្អ បានដល់ អ្នកប្រព្រឹត្តកុសលកម្មបថ១០។*

***៤. កល្យាណេន កល្យាណតរោ =*** *បុគ្គលល្អក្រៃលែងជាងបុគ្គលល្អ បានដល់ អ្នកប្រព្រឹត្តកុសលកម្មបទ១០ដោយខ្លួនឯងផង បបួលគេឱ្យប្រព្រឹត្តកុសលកម្មបថ១០ ផងដែរ។*

## (៣). បុគ្គលមានធម៌អាក្រក់ជាដើម

***១.បាបធម្មោ*** = *បុគ្គលមានធម៌អាក្រក់*

***២.បាបធម្មេន បាបធម្មតរោ*** = *បុគ្គលមានធម៌អាក្រក់ ក្រៃលែងជាងបុគ្គលមានធម៌អាក្រក់*

***៣.កល្យាណធម្មោ*** = *បុគ្គលមានធម៌ល្អ*

**៤.កល្យាណធម្មេន កល្យាណធម្មតរោ** = បុគ្គលមានធម៌ល្អក្រៃលែងជាងបុគ្គលមានធម៌ល្អ

បណ្ឌិតគប្បីចែកឱ្យពិស្តារដូចបុគ្គលពួកបួនខាងដើមចុះ។

ចប់បុគ្គលអាក្រក់ជាដើម

## (៤). បុគ្គលប្រកបដោយទោសជាដើម

**១. សាវជ្ជោ = បុគ្គលប្រកបដោយទោស** សេចក្តីថា បុគ្គលប្រព្រឹត្តទុច្ចរិត ដោយកាយ ដោយវាចា ដោយចិត្តជាទោស ដូចជាសាកសពដែលពេញដោយរបស់បដិកូល មានលាមក និងសាកសពជាដើម នេះហៅថា **អន្ធបុថុជ្ជន** ។

**២. វជ្ជពហុលោ = បុគ្គលច្រើនដោយទោស** សេចក្តីថា កាយកម្ម វចីកម្ម មនោកម្មរបស់គេប្រកបដោយទោសមានចំនួនច្រើន ។ ចំណែក កាយកម្ម វចីកម្ម មនោកម្មដែលមិនមានទោសមានចំនួនតិច ។ អធិប្បាយថា បុគ្គលដែលសមាទានឧបោសថសីលតាមធម្មតារបស់គេ ក្នុងជនបទ និងនិគមនោះៗ មិនបានប៉ុន្មានផង ក៏ដាច់ទៅ បានដល់ **លោកិយបុថុជ្ជន ដែលធ្វើកុសលក្នុងចន្លោះៗ។**

**៣. អប្បវជ្ជោ = *បុគ្គលមានទោសតិច*** *សេចក្តីថា បុគ្គលនេះមានកាយកម្ម វចីកម្ម មនោកម្ម ច្រើនដោយមិនមានទោស អធិប្បាយថា កាយសុចរិត វចីសុចរិត មនោសុចរិតរបស់បុគ្គលនេះច្រើនជាង កាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត បានដល់* ***ព្រះសោតាបន្ន, ព្រះសកទាគាមី និងព្រះអនាគាមី ។***

**៤. អនវជ្ជោ = *បុគ្គលមិនមានទោស*** *សេចក្តីថា បុគ្គលនេះប្រព្រឹត្តកាយកម្ម វចីកម្ម មនោកម្ម ប្រកបដោយសុចរិតតែម្យ៉ាង។ បានដល់* ***ព្រះខីណាសស្រព ។***

ចប់បុគ្គលមានទោសជាដើម

## (៥). ឧគ្ឃដិតញ្ញូបុគ្គលជាដើម

**១. ឧគ្ឃដិតញ្ញូបុគ្គល=** *បុគ្គលណា មានការត្រាស់ដឹងមគ្គនិងផល តំណាលគ្នានឹងវេលានៃធម៌ដែលធម្មកថិកបង្ហើបសំដែង សេចក្តីថាបុគ្គលនេះ ស្តាប់ត្រឹមតែមាតិកា ដូចន័យថា* **ចត្តារោ សតិបដ្ឋានា** *ជាដើមហើយ ក៏បានសម្រេចមគ្គនិងផល។ បុគ្គលនេះហៅថា ឧគ្ឃដិតញ្ញូ ព្រោះជាអ្នកវាងវៃត្រឹមតែលើកមាតិកាធម៌ឡើងសម្តែងប៉ុណ្ណោះ ក៏ត្រាស់ដឹងភ្លាម។*

**២. វិបញ្ចិតញ្ញូបុគ្គល =** *បុគ្គលណា កាលធម្មកថិកសំដែងចែក អត្ថនៃភាសិតដែលសង្ខេបឱ្យពិស្តារ ទើបមានការត្រាស់ដឹង នូវមគ្គ និងផលបាន។*

**៣. នេយ្យបុគ្គល=** *បុគ្គលណាលុះរៀន បាលី( ពុទ្ធវចនៈ ) រៀន អដ្ឋកថា ធ្វើទុកក្នុងចិត្ត ដោយឧបាយនៃប្រាជ្ញា សេព គប់រក ចូលទៅអង្គុយជិត និងកល្យាណមិត្ត តាមលំដាប់យ៉ាងនេះ ទើបត្រាស់ដឹងនូវមគ្គនិងផលបាន។*

**៤. បទបរមបុគ្គល =** *បុគ្គលណា ទុកជាស្តាប់ច្រើនក៏ដោយ ពោលច្រើនក៏ដោយ ចងចាំច្រើនក៏ដោយ បង្រៀនច្រើនក៏ដោយ ក៏មិនមានការត្រាស់ដឹងនូវមគ្គនិងផលក្នុងជាតិនោះដែរ។*

*អដ្ឋកថា :* ***ន តាយ ជាតិយា ធម្មាភិសមយោ ហោតិ*** = *បទបរមបុគ្គលនោះ មិនអាចដើម្បីនឹងធ្វើឈាន វិបស្សនា មគ្គ និង ផលឱ្យកើតឡើង បានក្នុងអត្តភាពនេះឡើយ។*

ចប់ឧគ្ឃដិតញ្ញូបុគ្គលជាដើម

## (៦). បុគ្គលអ្នកឆ្លើយ៤យ៉ាង

១. យុត្តប្បដិភាណោ នោ មុត្តប្បដិភាណោ = *បុគ្គលមានប្រាជ្ញាគួរ តែមានប្រាជ្ញាមិនរួសរាន់ សេចក្តីថា បុគ្គលនេះកាលគេសួរប្រស្នា ហើយ ដោះស្រាយដោយមានហេតុផល តែត្រូវគិត១សន្ទុះសិន។*

២. មុត្តប្បដិភាណោ នោ យុត្តប្បដិភាណោ = *បុគ្គលមានប្រាជ្ញា រួសរាន់ តែប្រាជ្ញាមិនគួរ សេចក្តីថា បុគ្គលនេះកាលគេសួរប្រស្នា ហើយ ក៏ដោះស្រាយយ៉ាងរួសរាន់ តែមិនសមហេតុផល។*

៣. យុត្តប្បដិភាណោ ច មុត្តប្បដិភាណោ =*បុគ្គលមានប្រាជ្ញាគួរ ទាំងមានប្រាជ្ញារួសរាន់ សេចក្តីថា បុគ្គលនេះ កាលគេសួរប្រស្នា ហើយ ដោះស្រាយដោយមានហេតុផលផង ទាំងរួសរាន់ផង។*

៤. នេវ យុត្តប្បដិភាណោ នោ មុត្តប្បដិភាណោ = *បុគ្គលមាន ប្រាជ្ញាមិនគួរ ទាំងមានប្រាជ្ញាមិនរួសរាន់ សេចក្តីថា បុគ្គលនេះ កាលគេសួរប្រស្នាហើយ ក៏ពោលដោះស្រាយមិនសមហេតុផល ផង ទាំងមិនរហ័សផង។*

ចប់បុគ្គលអ្នកឆ្លើយ៤យ៉ាង

## (៧). ចត្តារោ ធម្មកថិកា បុគ្គលា

## (បុគ្គលជាធម្មកថិក៤យ៉ាង)

១.ធម្មកថិកខ្លះ ក្នុងលោកនេះសម្ដែងធម៌តិចទេ តែប្រកបដោយប្រយោជន៍ ឯបរិស័ទរបស់ធម្មកថិកនោះជាអ្នកមិនឈ្លាស ចំពោះធម៌ដែលប្រកបដោយប្រយោជន៍ទាំងមិនប្រកបដោយប្រយោជន៍

២.ធម្មកថិកខ្លះ ក្នុងលោកនេះសម្ដែងធម៌តិចទេ តែប្រកបដោយប្រយោជន៍ ឯបរិស័ទរបស់ធម្មកថិកនោះ ជាអ្នកឈ្លាសចំពោះធម៌ដែលប្រកបដោយប្រយោជន៍ ទាំងមិនប្រកបដោយប្រយោជន៍។

៣.ធម្មកថិកខ្លះក្នុងលោកនេះសម្ដែងធម៌ច្រើនតែឥតប្រយោជន៍ ទាំងបរិស័ទរបស់ភិក្ខុនោះក៏មិនឈ្លាស។ល។

៤.ធម្មកថិកខ្លះក្នុងលោកនេះសម្ដែងធម៌ច្រើនផងទាំងប្រកបដោយប្រយោជន៍ទៀត ឯបរិស័ទរបស់ធម្មកថិកនោះជាអ្នកឈ្លាស។ល។

ចប់បុគ្គលជាធម្មកថិក៤យ៉ាង

## (៨). ចត្តារោ វលាហកូបមា បុគ្គលា

## (បុគ្គលឧបមានឹងមេឃ៤យ៉ាង)

## មេឃ៤យ៉ាង

១. មេឃខ្លះផ្គរ តែឥតភ្លៀង។

២. មេឃខ្លះភ្លៀង តែឥតផ្គរ។

៣. មេឃខ្លះទាំងផ្គរ ទាំងភ្លៀង ។

៤. មេឃខ្លះមិនទាំងផ្គរ មិនទាំងភ្លៀង ។

អធិប្បាយ

## បុគ្គលឧបមាដឹងមេឃ៤យ៉ាង

**បុគ្គលទី១** =បុគ្គលខ្លះក្នុងលោកនេះ បានតែពោល តែមិនធ្វើ។

**សេចក្តីក្នុងព្រះអដ្ឋកថា** =មេឃកាលផ្គរកើតឡើងហើយ ពួកអ្នកស្រុកគិតថា កាលផ្គរហើយនឹងភ្លៀង ក៏បានយកពូជស្រូវពីផ្ទះទៅសាបព្រោះ កាលភ្លៀងមិនធ្លាក់ ពូជស្រូវទាំងឡាយក៏វិនាសអស់ទុព្ភិក្ខភ័យក៏កើតឡើង។ សេចក្តីនេះយ៉ាងណា កាលភិក្ខុពោលថាអាត្មា នឹងបំពេញគន្ថធុរៈ វិបស្សនាធុរៈជាដើមហើយ ពួកអ្នកស្រុកអាស្រ័យសេចក្តីជ្រះថ្លា ទើបពោលនឹងភិក្ខុនោះថា ពួកខ្ញុំទាំងឡាយនឹងទំនុកបម្រុងលោកម្ចាស់ តែកាលដល់វេលាហើយ ភិក្ខុនោះមិន

ធ្វើទៅវិញ ។ ពួកអ្នកស្រុកមិនបានទំនុកបម្រុងបច្ច័យដល់ភិក្ខុនោះ ទាំងពួកអ្នកស្រុកក៏មិនបានបុណ្យព្រោះការទំនុកបម្រុងនោះ។

**បុគ្គលទី ២ =**បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកធ្វើតែឥតពោល។

**សេចក្តីក្នុងព្រះអដ្ឋកថា =**មេឃកាលមិនផ្គរ តែភ្លៀងធ្លាក់ ពួកអ្នកស្រុកយកពូជពីផ្ទះទៅសាបព្រោះ នៅទីទំនាបដោយគិតថា មេឃនឹងរាំង តែពេលភ្លៀងធ្លាក់មកបានប្រមូលយកពូជស្រូវទៅកាន់មហាសមុទ្រអស់ ទុព្ភិក្ខភ័យក៏កើតឡើង ។ សេចក្តីនេះយ៉ាងណា ភិក្ខុកាលមិនពោលថា អាត្មា នឹងបំពេញគន្ថធុរៈ វិបស្សនាធុរៈជាដើមទេ តែកាលដល់ពេលវេលាហើយ គេរមែងញ៉ាំងធុរៈទាំងនោះឱ្យសម្រេច។ ភិក្ខុទាំងនោះមិនបានលាភ ទាំងពួកអ្នកស្រុកក៏មិនបានបុណ្យ។

**បុគ្គលទី ៣ =**បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកពោលផង ធ្វើផង ។

**សេចក្តីក្នុងព្រះអដ្ឋកថា=** មេឃផ្គរផង ភ្លៀងផង ទើបរាប់ថា ជាសេចក្តីចម្រើន ព្រោះថា ភិក្ខុនោះបានលាភដែលពួកអ្នកស្រុកទំនុកបម្រុង ទាំងពួកអ្នកស្រុកក៏បានបុណ្យ ព្រោះការទំនុកបម្រុង។

**បុគ្គលទី៤ =** *បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកមិនពោលផង មិនធ្វើផង។*

**សេចក្ដីក្នុងព្រះអដ្ឋកថា =** *កាលមេឃមិនផ្គរ ទាំងមិនភ្លៀង ពួកអ្នកស្រុកក៏មិនបានយកពូជទៅសាបព្រោះ ទុព្ភិក្ខក៏រមែងកើតឡើងដែរ ។ សេចក្ដីនេះយ៉ាងណា ភិក្ខុខ្លះក្នុងសាសនានេះ ទាំងមិនពោល ទាំងមិនធ្វើ ក៏មិនបានលាភ ទាំងទាយកមិនបានបុណ្យដែរ។*

ចប់បុគ្គលឧបមានិងមេឃ៤យ៉ាង

## (៤). ចត្តារោ មូសិកូបមា បុគ្គលា

*( បុគ្គល៤ពួកឧបមានឹងកណ្ដុរ)*

## កណ្ដុរ៤ពួក

១. **គាធំ កត្តា នោ វសិតា =** ធ្វើរន្ធ តែមិននៅ ។

២. **វសិតា នោ គាធំ កត្តា =** គ្រាន់តែនៅ តែមិនធ្វើរន្ធ ។

៣.**គាវំ កត្តា ច វសិតា ច =** ធ្វើរន្ធផង នៅផង ។

៤.**នេវ គាធំ កត្តា នោ វសិតា =** រន្ធក៏មិនធ្វើ នៅក៏មិននៅ។

## បុគ្គលឧបមានឹងកណ្ដុរ៤ពួក

**បុគ្គលទី១ =** *ភិក្ខុខ្លះក្នុងសាសនានេះរៀនព្រះបរិយត្តិធម៌ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្មៈ វេទល្លៈ តែមិនចាក់ធ្លុះអរិយសច្ចៈទាំង៤។*

***អដ្ឋកថាៈ*** *កណ្ដុរប្រភេទនេះគ្រាន់តែធ្វើរន្ធ តែមិននៅរន្ធដ៏ជ្រៅដែលខ្លួនធ្វើ ទៅនៅទីដទៃដែលជាឱកាសរបស់អមិត្ត មានសត្វឆ្មាជាដើម យ៉ាងណា ភិក្ខុនោះក៏ដូចគ្នា រៀនព្រះបរិយត្តិហើយ តែមិនបានចាក់ធ្លុះសច្ចធម៌ទាំង៤នៅឡើយ។ កាលបើប្រព្រឹត្តទៅដូច្នេះ ក្នុងលោកាមិសទាំងឡាយ គេរមែងទៅកាន់អំណាចរបស់អមិត្តទាំងឡាយ ពោលគឺមច្ចុមារ កិលេសមារ និងទេវបុត្តមារដូច្នោះ។*

**បុគ្គលទី២ =** *ភិក្ខុខ្លះក្នុងសាសនានេះ មិនរៀនព្រះបរិយត្តិធម៌ តែដឹងច្បាស់នូវអរិយសច្ចៈទាំង៤។*

***អដ្ឋកថាៈ*** *កណ្ដុរមិនធ្វើរន្ធដោយខ្លួនឯង តែនៅក្នុងរន្ធដែលអ្នកដទៃជីកហើយ វារមែងរក្សាជីវិតទុកបាន យ៉ាងណាបុគ្គលក្នុងលោកនេះ មិនបានរៀនធម៌ទេ តែស្ដាប់ធម្មកថិកសម្ដែងហើយក៏ចាក់ធ្លុះសច្ចៈធម៌ទាំង៤ ឈានកន្លងអំណាចរបស់មារទាំង៣បានដូច្នោះ។*

**បុគ្គលទី ៣ =** *ភិក្ខុខ្លះក្នុងសាសនានេះ រៀនព្រះបរិយត្តិធម៌ ទាំងដឹងច្បាស់អរិយសច្ចទាំង៤។*

**បុគ្គលទី៤ =** *ភិក្ខុខ្លះក្នុងសាសនានេះ មិនរៀនព្រះបរិយត្តិធម៌ ទាំងមិនដឹងច្បាស់អរិយសច្ចទាំង៤ទៀត។*

*បណ្ឌិតគប្បីឧបមាបុគ្គលទី៣ និងទី៤ដូចន័យខាងដើមចុះ។*

ចប់បុគ្គលឧបមានឹងកណ្ដុរ៤ពួក

## (១០). ចត្តារោ អម្ពូបមា បុគ្គលា

## *(បុគ្គល ៤ ពួកឧបមានឹងផ្លែស្វាយ)*

## ផ្លែស្វាយ៤ពួក

១. **អាមំ បក្កវណ្ណី=** *ស្វាយខ្ចី តែសម្បុរទុំ។*

២. **បក្កំ អាមវណ្ណី =** *ស្វាយទុំ តែមានសម្បុរខ្ចី។*

៣. **អាមំ អាមវណ្ណី=** *ស្វាយខ្ចី មានសម្បុរខ្ចី*

៤. **បក្កំ បក្កវណ្ណី =** *ស្វាយទុំ មានសម្បុរទុំ*

## បុគ្គល ៤ ពួកឧបមាដូចផ្លែស្វាយ

១. បុគ្គលខ្លះក្នុងលោកនេះ មានឥរិយាបថគួរជាទីជ្រះថ្លា តែមិនដឹងច្បាស់ថា នេះទុក្ខ នេះហេតុនាំឱ្យកើតទុក្ខ នេះនិរោធ(ព្រះនិព្វាន) នេះនិរោធគាមិនីបដិបទា (ស្វាយខ្ចី តែសម្បុរទុំ)។

២.បុគ្គលខ្លះក្នុងលោកនេះ មានឥរិយាបថមិនគួរជាទីជ្រះថ្លា តែបុគ្គលនោះ ដឹងច្បាស់អរិយសច្ចធម៌ទាំង៤ ។

៣. បុគ្គលខ្លះក្នុងលោកនេះ មានឥរិយាបថតូចធំ មិនគួរជាទីជ្រះថ្លាផង ទាំងមិនដឹងអរិយសច្ចធម៌ទាំង៤ផង។

៤. បុគ្គលខ្លះក្នុងលោកនេះ មានឥរិយាបថគួរជាទីជ្រះថ្លាផង ទាំងដឹងច្បាស់អរិយសច្ចធម៌ទាំង៤ផង។

**អដ្ឋកថា:** ស្វាយខ្ចី ដូចជា បុថុជ្ជន ។ ស្វាយទុំ ដូចជា ព្រះអរិយបុគ្គល។

ចប់បុគ្គល ៤ ពួកឧបមាដូចផ្លែស្វាយ

## (១១) .ចត្តារោ កុម្ភូបមា បុគ្គលា

## (បុគ្គល៤ពួក ឧបមាដូចក្អម)

១. **តុច្ឆោ បិហិតា** = បុគ្គលប្រៀបដូច ក្អមទទេតែគ្របជិត។

២. **បូរោ វិវដោ** = បុគ្គលប្រៀបដូច ក្អមមានទឹកពេញ តែបើកចំហ។

៣. **តុច្ឆោ វិវដោ**= *បុគ្គលប្រៀបដូច ក្អមទទេហើយបើកចំហ។*

៤. **បូរោ បិហិតោ** = *បុគ្គលប្រៀបដូច ក្អមមានទឹកពេញហើយគ្រប ជិត។*

******បុគ្គលប្រៀបដូចក្អម៤ពួកនេះ មានសេចក្តីដូចបុគ្គលឧបមានិង ផ្លែស្វាយ៤ពួកដែរ។*

ចប់បុគ្គល៤ពួកឧបមាដូចក្អម

## (១២). ចត្តារោ ឧទករហទូបមា បុគ្គលា

## (*បុគ្គល ៤ ពួកឧបមាដូចអន្លង់ទឹក*)

### អន្លង់ទឹក ៤ យ៉ាង

១. **ឧត្តានោ គម្ភីរោភាសោ** = *អន្លង់ទឹករាក់ តែមានរស្មីជ្រៅ។*

២. **គម្ភីរោ ឧត្តានោភាសោ** =*អន្លង់ទឹកជ្រៅ តែមានរស្មីរាក់។*

៣. **ឧត្តានោ ឧត្តានោ ភាសោ** =*អន្លង់ទឹករាក់ មានរស្មីរាក់។*

៤. **គម្ភីរោ គម្ភីរោភាសោ** =*អន្លង់ទឹកជ្រៅ មានរស្មីជ្រៅ។*

### បុគ្គល ៤ ពួកប្រៀបដូចអន្លង់ទឹក

១.មានឥរិយាបថគួរជ្រះថ្លា(មានរស្មីជ្រៅ) *តែមិនដឹងអរិសច្ចធម៌ ទាំង៤(អន្លង់ទឹករាក់)* ។

២.មានឥរិយាបថមិនគួរជ្រះថ្លា(មានរស្មីរាក់)តែដឹងច្បាស់នូវអរិយសច្ចធម៌ទាំង៤(អន្លង់ទឹកជ្រៅ)។

៣.មានឥរិយាបថមិនគួរជ្រះថ្លាផង(មានរស្មីរាក់) ទាំងមិនដឹងច្បាស់អរិយសច្ចធម៌ទាំង៤ផង(អន្លង់ទឹករាក់) ។

៤. មានឥរិយាបថគួរជ្រះថ្លាផង(មានរស្មីជ្រៅ)ទាំងដឹងច្បាស់អរិយសច្ចធម៌ទាំង៤ផង(អន្លង់ទឹកជ្រៅ) ។

**អដ្ឋកថា:** ក៏កាលបើទឹកប្រមាណត្រឹមជង្គង់ តែអន្លង់ទឹកមានផ្ទៃទឹកមិនប្រាជក ព្រោះមានពណ៌ទឹកដែលលាយគ្នា ឬព្រោះជាទឹកល្អក់ ឈ្មោះថា **ទឹករាក់មានរស្មីជ្រៅ**។ ក៏សូម្បីទឹកជ្រៅប្រមាណ ៣ ឬ៤ជួរបុរសអន្លង់ទឹកមានផ្ទៃទឹកប្រាកដ ព្រោះជាទឹកថ្លា ទើបឈ្មោះថា **ជាទឹកជ្រៅមានស្រមោលរាក់**។

សេចក្តីអធិប្បាយដូចបុគ្គលដែលឧបមានឹងផ្លែស្វាយ៤ពួកដែរ។

ចប់បុគ្គល ៤ ពួកប្រៀបដូចអន្លង់ទឹក

## (១៣) ចត្តារោ ពលិពទ្ទូបមា បុគ្គលា

### (បុគ្គល ៤ ពួកប្រៀបដូចគោបម្រើ)

គោបម្រើ៤ពួក

១. សកគរវចណ្ណោ នោ បរគរវចណ្ណោ = *គោបម្រើកាចក្នុងហ្វូងគោរបស់ខ្លួន មិនកាចក្នុងហ្វូងគោដទៃ។*

២. បរគរវចណ្ណោ នោ សកគរវចណ្ណោ = *កាចក្នុងហ្វូងដទៃតែមិនកាចក្នុងហ្វូងរបស់ខ្លួន។*

៣. សកគរវចណ្ណោ ច បរគរវចណ្ណោ ច = *កាចក្នុងហ្វូវគោរបស់ខ្លួនផងកាចក្នុងហ្វូងគោដទៃផង។*

៤. នេវ សកគរវចណ្ណោ នោ បរគរវចណ្ណោ = *មិនកាចក្នុងហ្វូងគោរបស់ខ្លួន ទាំងមិនកាចក្នុងហ្វូងគោដទៃ។*

## បុគ្គល ៤ពួក ប្រៀបដូចគោបម្រើ

***បុគ្គលទី១*** = *បុគ្គលខ្លះក្នុងលោកនេះ បៀតបៀនចាក់ដោតបក្ខពួករបស់ខ្លួន មានការស្រែកហៅ ដោយពាក្យសម្តីច្រូគោះបោះបោក តែជាអ្នកស្ងប់ស្ងៀមប្រព្រឹត្តបន្ទាបខ្លួនក្នុងបក្ខពួកអ្នកដទៃ ។*

***បុគ្គលទី២*** = *បុគ្គលខ្លះក្នុងលោកនេះ មិនហ៊ានបៀតបៀនចាក់ដោតបក្ខពួករបស់ខ្លួន តែហ៊ានបៀតបៀនក្នុងបក្ខពួករបស់អ្នកដទៃ ។*

**បុគ្គលទី៣** = បុគ្គលខ្លះក្នុងលោកនេះ ហ៊ានបៀតបៀនចាក់ដោតបក្ខពួករបស់ខ្លួនផង ហ៊ានបៀតបៀនចាក់ដោតបក្ខពួករបស់អ្នកដទៃផង ។

**បុគ្គលទី៤** = បុគ្គលខ្លះក្នុងលោកនេះ មិនហ៊ានបៀតបៀនចាក់ដោតបក្ខពួករបស់ខ្លួនផង មិនហ៊ានបៀតបៀនចាក់ដោតបក្ខពួករបស់អ្នកដទៃផង ។

ចប់បុគ្គល ៤ពួក ប្រៀបដូចគោបម្រើ

## (១៤) .ចត្តារោ អាសីវិសូបមា បុគ្គលា

### (បុគ្គល ៤ ពួកប្រៀបដូចអាសិរពិស)

### អាសិរពិស៤ពួក

**១.អាគតវិសោ នោ ឃោរវិសោ =** អាសិរពិសមានពិសរួសរាន់(ចឹកភ្លាម មានពិសជ្រាបចូលសរីរៈយ៉ាងរហ័សភ្លាម) តែមានពិសមិនកាចពន្លឹក((មានពិសមិនសាហាវផង ទាំងបៀតបៀនមិនយូរ)។

**២.ឃោរវិសោ នោ អាគតសោ=**មានពិសកាចដ៏ពន្លឹក (មានពិសកាចសាហាវ) តែមានពិសមិនរួសរាន់ (ជ្រាបចូលសរីរៈមិនរហ័ស)។

**៣.អាគតវិសោ ច ឃោរវិសោ ច =** *មានពិសរួសរាន់ (ពិសជ្រាបចូលសរីរៈយ៉ាងរហ័ស) ទាំងមានពិសដ៏ពន្លឹក (មានពិសដ៏សា-ហាវផង ដល់នូវសេចក្តីទុក្ខដ៏យូរផង) ។*

**៤. នេវ អាគតវិសោ នោ ឃោរវិសោ =** *មិនមានពិសរួសរាន់ (ពិសជ្រាបចូលទៅក្នុងកាយមិនរហ័ស) ទាំងមិនមានពិសដ៏ពន្លឹក (ពិសក៏មិនកាចសាហាវ) ។*

## បុគ្គល៤ពួកប្រៀបដូចអាសិរពិស

***បុគ្គលទី១*** *=បុគ្គលខ្លះក្នុងលោកនេះ មានសេចក្តីក្រោធកើតឡើងរឿយៗ តែសេចក្តីក្រោធរបស់គេ ធាប់បាត់(អាសិរពិសមានពិសរួសរាន់ មានពិសមិនពន្លឹក)។*

***បុគ្គលទី២=*** *បុគ្គលខ្លះក្នុងលោកនេះ មានសេចក្តីក្រោធ មិនសូវកើតឡើងរឿយៗទេ តែសេចក្តីក្រោធរបស់គេនោះ កើតម្តងៗ ហើយតាំងនៅអស់កាលយូរ (មានពិសដ៏ពន្លឹក មានពិសមិនរួសរាន់)។*

***បុគ្គលទី៣***=*បុគ្គលខ្លះក្នុងលោកនេះ មានសេចក្តីក្រោធកើតឡើងរឿយៗ សេចក្តីក្រោធរបស់គេនោះ កើតម្តងៗហើយតាំងនៅអស់កាលយូរ*(មានពិសរួសរាន់ ទាំងមានពិសដ៏ពន្លឹក)។

***បុគ្គលទី៤*** =*បុគ្គលខ្លះក្នុងលោកនេះ មានសេចក្តីក្រោធ មិនសូវកើតឡើងរឿយៗទេ ថែមទាំងសេចក្តីក្រោធរបស់គេនោះ មិនត្រាំអស់កាលយូរទៀត* (មិនមានពិសរួសរាន់ ទាំងមិនមានពិសដ៏ពន្លឹក)

ចប់បុគ្គល៤ពួកប្រៀបដូចអាសិរពិស

## (១៥). បុគ្គលមិនគួរតិះដៀលជាដើម

**១. បុគ្គលមិនស្ទង់មើល មិនពិចារណា ហើយសរសើបុគ្គលដែលគួរតិះដៀល** *សេចក្តីថា បុគ្គលខ្លះក្នុងលោកនេះពោលសរសើរពួកតិរ្ថិយ និងពួកសាវ័ករបស់តិរ្ថិយ ដែលប្រតិបត្តិអាក្រក់ ប្រតិបត្តិខុស ថាជាអ្នកប្រតិបត្តិល្អ ប្រតិបត្តិត្រូវទៅវិញ។*

**២. បុគ្គលមិនស្ទង់មើល មិនពិចារណា ក៏តិះដៀលបុគ្គលដែលគួរសរសើរ** *សេចក្តីថា បុគ្គលខ្លះក្នុងលោកនេះតិះដៀលព្រះពុទ្ធ និងសាវ័-ករបស់ព្រះពុទ្ធដែលប្រតិបត្តិល្អ ប្រតិបត្តិត្រូវ ថាជាអ្នកប្រតិបត្តិអាក្រក់ទៅវិញ។*

**៣. បុគ្គលមិនស្ទង់មើល មិនពិចារណា ហើយសម្តែងសេចក្តីជ្រះថ្លា ក្នុងក្នុងទីដែលមិនគួរជ្រះថ្លា** = *បុគ្គលខ្លះក្នុងលោកនេះញុំាងសេចក្តីជ្រះថ្លាឱ្យកើតឡើង ក្នុងផ្លូវប្រតិបត្តិអាក្រក់ ក្នុងផ្លូវប្រតិបត្តិខុស ថាជាផ្លូវប្រតិបត្តិល្អ ថាជាផ្លូវប្រតិបត្តិត្រូវទៅវិញ។*

**៤. បុគ្គលមិនស្ទង់មើល មិនពិចារណា ហើយសម្តែងសេចក្តីមិនជ្រះថ្លា ក្នុងទីដែលគួរជ្រះថ្លា** = *បុគ្គលខ្លះក្នុងលោកនេះញុំាងសេចក្តីមិនជ្រះថ្លាឱ្យកើតឡើង ក្នុងផ្លូវប្រតិបត្តិល្អ ក្នុងផ្លូវប្រតិបត្តិត្រូវ ថាជាផ្លូវប្រតិបត្តិអាក្រក់ ថាជាផ្លូវប្រតិបត្តិខុសទៅវិញ ។*

ចប់បុគ្គលមិនគួរតិះដៀលជាដើម៤ពួក

## (១៦). បុគ្គលគួរតិះដៀលជាដើម

*១.បុគ្គលស្ទង់មើលពិចារណា តិះដៀលបុគ្គលដែលគួរតិះដៀល ។*

*២.បុគ្គលស្ទង់មើល ពិចារណាសរសើរបុគ្គលដែលគួរសរសើរ។*

*៣.បុគ្គលស្ទង់មើល ពិចារណា ញុំាងសេចក្តីមិនជ្រះថ្លាឱ្យកើតក្នុងទីដែលប្រតិបត្តិអាក្រក់ ប្រតិបត្តិខុស ។*

*៤.បុគ្គលស្ទង់មើល ពិចារណា ញុំាងសេចក្តីជ្រះថ្លាឱ្យកើតឡើងក្នុងទីដែលគួរជ្រះថ្លា ។*

** មានសេចក្ដីផ្ទុយពីបុគ្គលមិនគួរតិះដៀលជាដើម៤យ៉ាង ។*

ចប់បុគ្គលគួរតិះដៀលជាដើម

## (១៧). បុគ្គលពោលតិះដៀលតាមកាលដែលគួរជាដើម

១. បុគ្គលខ្លះក្នុងលោកនេះ មានទោសគួរតិះដៀលផង មានគុណគួរសរសើរផង = *បុគ្គលពោលតិះដៀលតែទោស គុណគួរសរសើរមាន មិនសរសើរ ។*

២. បុគ្គលខ្លះក្នុងលោកនេះ មានទោសគួរតិះដៀលផង មានគុណគួរសរសើរផង = *បុគ្គលពោលសរសើរតែគុណ តែទោសគួរតិះដៀលមាន មិនតិះដៀល ។*

៣. បុគ្គលខ្លះក្នុងលោកនេះ មានទោសគួរតិះដៀលផង មានគុណគួរសរសើរផង *សេចក្ដីថា បុគ្គលពោលតិះដៀលនូវទោសដែលមានពិត តាមកាលដែលគួរ ពោលសរសើរនូវគុណដែលមានពិត តាមកាលដែលគួរ ។*

៤. បុគ្គលមិនពោលតិះដៀល នូវបុគ្គលដែលគួរតិះដៀល ពិតប្រាកដតាមកាលគួរផង មិនពោលសរសើរនូវបុគ្គលដែលគួរសរសើរ ពិតប្រាកដតាមកាលគួរផង *សេចក្ដីថា បុគ្គលខ្លះក្នុងលោកនេះ ទោសគួរតិះដៀល*

មាន តែមិនតិះដៀលតាមកាលដែលគួរទេ គុណគួរសរសើរមាន តែមិនសរសើរតាមកាលដែលគួរទេ ។

ចប់បុគ្គលពោលតិះដៀលតាមកាលដែលគួរជាដើម

## (១៨). បុគ្គលចិញ្ចឹមជីវិត៤ពួក

**១. ឧដ្ឋានផលូបជីវី នោ បុញ្ញផលូបជីវី =** បុគ្គលចិញ្ចឹមជីវិតដោយផលនៃការព្យាយាម តែមិនចិញ្ចឹមជីវិតដោយបុណ្យ ។

**២. បុញ្ញផលូបជីវី នោ ឧដ្ឋានផលូបជីវី =** បុគ្គលចិញ្ចឹមជីវិតដោយផលបុណ្យ មិនចិញ្ចឹមជីវិតដោយព្យាយាមទេ ។

**៣. ឧដ្ឋានផលូបជីវី ច បុញ្ញផលូបជីវី =** បុគ្គលចិញ្ចឹមជីវិតដោយផលនៃការព្យាយាម ទាំងចិញ្ចឹមជីវិតដោយផលបុណ្យ ។

**៤. នេវ ឧដ្ឋានផលូបជីវី នោ បុញ្ញផលូបជីវី =** បុគ្គលមិនចិញ្ចឹមជីវិតដោយផលនៃការព្យាយាម ទាំងមិនចិញ្ចឹមជីវិតផលនៃបុណ្យ ។

អធិប្បាយ

**បុគ្គលទី១** = បុគ្គលនេះខំសង្វាត ប្រឹងប្រែង ព្យាយាម ការចិញ្ចឹមជីវិតទើបអាចចំរើនបាន។

**បុគ្គលទី២**=បានដល់ ពួកទេវតាជាន់បរនិម្មិតវសវត្តីឡើងទៅ។

**បុគ្គលទី៣** = *បុគ្គលនេះខំសង្វាត ប្រឹងប្រែង ព្យាយាម ការចិញ្ចឹមជីវិតទើបកើនចម្រើនឡើង ទាំងកើនចម្រើនឡើង ដោយផលនៃបុណ្យ បុគ្គលនេះ បានដល់ ព្រះមហាក្សត្រ ព្រាហ្មណមហាសាល និងទេវតាទាំងឡាយតាំងពីភុម្មទេវតារហូតដល់ ទេវតាជាន់និម្មានរតីជាទីបំផុត ។ ព្រោះទេវតា និងមនុស្សទាំងនោះ សូម្បីទាំងអស់រមែងសោយផលនៃសេចក្ដីព្យាយាម និងផលនៃបុណ្យ ។*

**បុគ្គលទី៤** = *បានដល់ ពួកសត្វនរក ។ សត្វនរកទាំងឡាយមិនអាចដើម្បីធ្វើអាជីពឱ្យកើតឡើង ដោយសេចក្ដីព្យាយាមបានឡើយ ទាំងអាជីពអ្វីៗ ដែលនឹងកើតឡើងដល់សត្វនរកទាំងនោះដោយផលនៃបុណ្យក៏មិនមាន។*

ចប់បុគ្គលចិញ្ចឹមជីវិត៤ពួក

## (១៩). បុគ្គល៤ពួកមកពីងងឹត ទៅងងឹតជាដើម

**១. តមោ ហោតិ តមបរាយនោ** = *បុគ្គលមកងងឹត ទៅងងឹត។*

**២. តមោ ហោតិ ជោតិបរាយនោ** = *បុគ្គលមកងងឹត ទៅវិញមានពន្លឺ ។*

**៣. ជោតិ ហោតិ តមបរាយនោ** = *បុគ្គលមកភ្លឺ ទៅវិញងងឹត។*

**៤. ជោតិ ហោតិ ជោតិបរាយនោ** = *បុគ្គលមកភ្លឺ ទៅវិញក៏ភ្លឺ ។*

## អធិប្បាយ

**បុគ្គលទី១** = បុគ្គលខ្លះក្នុងលោកនេះ កើតក្នុងត្រកូលទាប គឺ ត្រកូលចណ្ឌាលក្តី ត្រកូលអ្នកនេសាទក្តី ត្រកូលអ្នកត្បាញដែនក្តី ត្រកូលជាងរថក្តី ត្រកូលអ្នកចាក់សម្រាមក្តី ជាត្រកូលខ្សត់ មានបាយទឹកនិងភោជនតិចក្តី ប្រព្រឹត្តចិញ្ចឹមជីវិតបានដោយលំបាក ដែលជាត្រកូលរកបាយនិងសំពត់ស្លៀកដណ្តប់បានដោយក្រ បុគ្គលនោះឯង ជាមនុស្សមានសម្បុរអាក្រក់ លំបាកមើល ជាបុគ្គលតឿ មានអាពាធច្រើន គឺខ្វាក់ឬក្ញែង ខ្ចកឬខ្វិន ជាអ្នកមិនបានបាយ ទឹក សំពត់ យាន ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីសម្នាក់អាស្រ័យ និងគ្រឿងប្រទីប បុគ្គលនោះ ថែមទាំងប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត បុគ្គលនោះលុះប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិត្តដោយចិត្តហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងអបាយភូមិ ទុគ្គតិ វិនិបាត និងនរក បុគ្គលងងឹតមានងងឹតប្រព្រឹត្តទៅខាងមុខយ៉ាងនេះឯង ។

**បុគ្គលទី២** = បុគ្គលខ្លះក្នុងលោកនេះ កើតក្នុងត្រកូលទាប គឺ ត្រកូលចណ្ឌាលក្តី ត្រកូលអ្នកនេសាទក្តី ត្រកូលអ្នកត្បាញដែនក្តី

ត្រកូលជាធំរថក្តី។ល។ តែបុគ្គលនោះជាអ្នកប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងកើតសុគតិសួគ៌ទេវលោក បុគ្គលងងឹត មានពន្លឺប្រព្រឹត្តទៅខាងមុខយ៉ាងនេះឯង។

**បុគ្គលទី៣=** បុគ្គលខ្លះក្នុងលោកនេះ កើតក្នុងត្រកូលខ្ពង់ខ្ពស់ ត្រកូលខត្តិយមហាសាលក្តី ត្រកូលព្រាហ្មណមហាសាលក្តី ត្រកូលគហបតិមហាសាលក្តី ជាត្រកូលស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើន មានមាសនិងប្រាក់ច្រើន មានទ្រព្យនិងគ្រឿងប្រើប្រាស់ច្រើន មានទ្រព្យនិងស្រូវច្រើន បុគ្គលនោះ មានរូបល្អ គួររមិលមើល គួរជ្រះថ្លា ប្រកបដោយសម្បុរនៃសរីរៈល្អក្រៃលែង ជាអ្នកបានបាយ ទឹក សំពត់ កម្រង គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីសម្នាក់អាស្រ័យ និងគ្រឿងប្រទីប តែបុគ្គលនោះ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត បុគ្គលនោះ លុះប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្តហើយ លុះដល់បែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក បុគ្គលភ្លឺ មានងងឹតប្រព្រឹត្តទៅខាងមុខយ៉ាងនេះឯង ។

**បុគ្គលទី៤** = បុគ្គលខ្លះក្នុងលោកនេះ កើតក្នុងត្រកូលខ្ពង់ខ្ពស់ ត្រកូលខត្តិយមហាសាលក្តី ត្រកូលព្រាហ្មណមហាសាលក្តី ត្រកូលគហបតិមហាសាលក្តី ជាត្រកូលស្តុកស្តម្ភ ។ល។ ហើយប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងកើតសុគតិសួគ៌ទេវលោក បុគ្គលភ្លឺ មានពន្លឺប្រព្រឹត្តទៅខាងមុខយ៉ាងនេះឯង។

## (២០). បុគ្គលឱនចុះហើយ ឱនចុះទៀតជាដើម

**១. បុគ្គលោ ឱណតោណតោ ហោតិ**= បុគ្គលឱនចុះហើយ ឱនចុះទៀត។

**២. បុគ្គលោ ឱណតុណ្ណតោ ហោតិ** = បុគ្គលឱនចុះហើយងើបឡើងវិញ។

**៣.បុគ្គលោ ឧណ្ណតោណតោ ហោតិ** = បុគ្គលងើបឡើងហើយ ឱនចុះទៅវិញ ។

**៤. បុគ្គលោ ឧណ្ណតុណ្ណតោ ហោតិ** = បុគ្គលងើបឡើងហើយ ងើបឡើងទៀត។

ទេព្យក្នុងត្រកូលទាំង៣

**១. ខត្តិយមហាសាល =** *ក្សត្រឯណា មានព្រះរាជទ្រព្យយ៉ាងទាបប្រមាណមួយរយកោដិ ដែលជាដើមទុន មានប្រយោជន៍ និងបានតាំងរណ្ដៅទ្រព្យទុក៣ឆ្នាំង ធ្វើជាគំនរត្រង់កណ្ដាលផ្ទះ ដើម្បីប្រយោជន៍ដល់ការប្រើប្រាស់ ក្សត្រទាំងនោះ ឈ្មោះថា* ***ខត្តិយ-មហាសាល។***

**២. ព្រាហ្មណមហាសាល =** *ព្រាហ្មណ៍ឯណា មានទ្រព្យជាដើមទុន ប្រមាណ ៨០ កោដិ តាំងរណ្ដៅទ្រព្យទុកកន្លះឆ្នាំង សម្រាប់ប្រើប្រាស់ក្នុងផ្ទះ ព្រាហ្មណ៍នោះ ឈ្មោះថា* ***ព្រាហ្មណមហាសាល។***

**៣. គហបតីមហាសាល=** *គហបតីឯណា មានទុនទ្រព្យ៤០កោដិ តាំងរណ្ដៅទ្រព្យទុកមួយឆ្នាំង ធ្វើជាគំនរត្រង់កណ្ដាលផ្ទះ ដើម្បីត្រូវការប្រើប្រាស់ក្នុងផ្ទះ គហបតីនោះ ឈ្មោះថា****គហបតីមហាសាល។***

ចប់បុគ្គល៤ពួកមកងងឹត ទៅងងឹតជាដើម

## (២១). ចត្តារោ រុក្ខូបមា បុគ្គលា

## *(បុគ្គល៤ពួកប្រៀបដូចដើមឈើ)*

## ដើមឈើ៤ពួក

**១.ផេគ្គុ សារបរិវារោ =** *ឈើស្រាយមានឈើខ្លឹមជាបរិវារ ។*

**២.សារោ ផេគ្គុបរិវារោ** = *ឈើខ្លឹមមានឈើស្រាយជាបរិវារ។*

**៣. ផេគ្គុ ផេគ្គុបរិវារោ** = *ឈើស្រាយមានឈើស្រាយជាបរិវារ ។*

**៤. សារោ សារបរិវារោ** = *ឈើខ្លឹមមានឈើខ្លឹមជាបរិវារ។*

## បុគ្គល៤ពួកប្រៀបដូចដើមឈើ

*១. បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកទ្រុស្តសីល មានធម៌អាក្រក់ តែមានបរិវារជាអ្នកមានសីល មានធម៌ល្អ ។*

*២. បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកមានសីល មានធម៌ល្អ តែមានបរិវារជាអ្នកទ្រុស្តសីល មានធម៌អាក្រក់ ។*

*៣.បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកទ្រុស្តសីល មានធម៌អាក្រក់ ទាំងបរិវារក៏ជាអ្នកទ្រុស្តសីល មានធម៌អាក្រក់ ។*

*៤. បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកមានសីល មានធម៌ល្អ ទាំងបរិវារ ក៏ជាអ្នកមានសីល មានធម៌ល្អ។*

ចប់បុគ្គល៤ពួកប្រៀបដូចដើមឈើ

## (២២). សេចក្តីជ្រះថ្លា ៤ ពួក

**១. រូបប្បមាណោ រូបប្បសន្នោ** = *បុគ្គលរាប់អានក្នុងរូប ជ្រះថ្លាក្នុងរូប។*

**២. ឃោសប្បមាណោ ឃោសប្បសន្នោ =** *បុគ្គលរាប់អានក្នុងសំឡេង ជ្រះថ្លាក្នុងសំឡេង។*

**៣. លូខប្បមាណោ លូខប្បសន្នោ =** *បុគ្គលរាប់អានក្នុងវត្ថុសៅហ្មង ជ្រះថ្លាក្នុងវត្ថុសៅហ្មង។*

**៤.ធម្មប្បមាណោ ធម្មប្បសន្នោ =***បុគ្គលរាប់អានក្នុងធម៌ជ្រះថ្លាក្នុងធម៌។*

*អធិប្បាយ*

***បុគ្គលទី១*** = *បុគ្គលខ្លះក្នុងលោកនេះឃើញកំពស់ក្តី ឃើញទំហំក្តី ឃើញទ្រង់ទ្រាយក្តី ឃើញរូបដ៏ពេញលេញក្តី ក៏កាន់យកនូវសេចក្តីរាប់អាន ក្នុងចំណែក មានកំពស់ជាដើមនោះ ហើយញ៉ាំងសេចក្តីជ្រះថ្លាឱ្យកើត។*

***បុគ្គលទី២*** = *បុគ្គលឯណា រមែងធ្វើសំឡេងដែលកិត្តិស័ព្ទឱ្យជាប្រមាណ ហើយជ្រះថ្លាក្នុងបុគ្គលនោះ ព្រោះអាស្រ័យសំឡេងនោះជាប្រមាណ។*

***បុគ្គលទី៣*** = *បុគ្គលខ្លះក្នុងលោកនេះ ឃើញចីវរសៅហ្មងក្តី ឃើញបាត្រសៅហ្មងក្តី ឃើញសេនាសនៈសៅហ្មងក្តី ឃើញអំពើដែលគេធ្វើបានដោយក្រមានប្រការផ្សេងៗក្តី ក៏កាន់យកសេចក្តី*

រាប់អាន ក្នុងចំណែកមានចីវរសៅហ្មងជាដើមនោះ ហើយញុំាង សេចក្តីជ្រះថ្លា ឱ្យកើត ។

បុគ្គលទី៤ = បុគ្គលខ្លះក្នុងលោកនេះឃើញសីលក្តី ឃើញ សមាធិក្តី ឃើញបញ្ញាក្តីក៏កាន់យក សេចក្តីរាប់អាន ក្នុងគុណមាន សីលគុណជាដើមនោះ ហើយញុំាងសេចក្តីជ្រះថ្លា ឱ្យកើត។

## ការចែកសេចក្តីជ្រះថ្លារបស់សត្វលោក

**បណ្តាសត្វលោកទាំងអស់ ចែកជា ៣ ចំណែក** = *សត្វលោកដែល កាន់រូបជាប្រមាណ២ចំណែក, ១ចំណែកទៀតមិនកាន់យក។*

**បណ្តាសត្វលោកទាំងអស់ចែកជា ៥ ចំណែក**=*សត្វលោកដែលកាន់ យក**សំឡេង ជាប្រមាណ ៤ ចំណែក** ,១ ចំណែកមិនកាន់យក។*

**បណ្តាសត្វលោកទាំងអស់ ចែកជា ១០ ចំណែក** =*សត្វលោកដែល កាន់**យកសេចក្តីសៅហ្មងជាប្រមាណ៩ចំណែក**, ១ ចំណែកទៀត មិនកាន់យក។*

**សត្វលោកទាំងអស់ចែកជា ១០០០០០ (១សែន) ចំណែក**=*១ចំណែក តែប៉ុណ្ណោះដែលសត្វលោកកាន់យកធម៌ជាប្រមាណ,ចំណែកដ៏ សេសមិនកាន់យក។*

សេចក្តីជ្រះថ្លាទាំង៤មានក្នុងព្រះសម្មាសម្ពុទ្ធ៖ បណ្តាសេចក្តីជ្រះថ្លាទាំង៤នេះសត្វដែលមិនជ្រះថ្លាក្នុងរូបព្រះពុទ្ធជាម្ចាស់ទាំងឡាយមានប្រមាណតិច , ដែលជ្រះថ្លាមានចំនួនច្រើន។ ព្រោះថា បុគ្គលដែលកាន់យករូបជាប្រមាណ ឈ្មោះថា រូបដែលនាំមកសេចក្តីជ្រះថ្លាឱ្យក្រៃលែងជាងរូបរបស់ព្រះពុទ្ធជាម្ចាស់ មិនមានឡើយ។

អ្នកកាន់យកសំឡេងជាប្រមាណ ឈ្មោះថា សំឡេងដែលនាំមកនូវសេចក្តីជ្រះថ្លា ឱ្យក្រៃលែង ជាងសំឡេងប្រកាសកិត្តិគុណរបស់ព្រះពុទ្ធជាម្ចាស់ មិនមានឡើយ។

អ្នកដែលកាន់យកសេចក្តីសៅហ្មងជាប្រមាណ ឈ្មោះថា សេចក្តីសៅហ្មងដទៃ ដែលនាំមកសេចក្តីជ្រះថ្លា ក្រៃលែងជាងសេចក្តីសៅហ្មងរបស់ព្រះពុទ្ធជាម្ចាស់ អ្នកដែលលះសំពត់ទាំងឡាយដែលគេត្បាញក្នុងដែនកាសី លះភាជន៍មាសដែលមានតម្លៃច្រើន និងលះប្រាសាទ ដែលប្រកបដោយសម្បត្តិទាំងពួង ដ៏សមគួរដល់រដូវកាលទាំង៣ ហើយសេព (ប្រើប្រាស់)សំពត់

បង្សុកូល បាត្រដែលសម្រេចដោយសិលា និងសេនាសនៈ មាន ឈើជាដើម រមែងមិនមាន។

អ្នកដែលកាន់យកធម៌ជាប្រមាណ ឈ្មោះថា គុណមានសីល ជាដើមដទៃ ដែលនាំមកនូវសេចក្តីជ្រះថ្លា ក៏ក្រៃលែងជាងគុណ មានសីលគុណជាដើមរបស់ព្រះតថាគត អ្នកមានសីលាទិគុណ ដែលមិនទូទៅក្នុងលោកនេះ រហូតទេវលោក រមែងមិនមាន, ដោយ ហេតុនេះ ព្រះដ៏មានព្រះភាគទ្រង់តាំងនៅហាក់ដូចជាកាន់យក លោកសន្និវាស មានប្រមាណ ៤ នេះ ដោយកណ្តាប់ព្រះហស្ត។

ចប់សេចក្តីជ្រះថ្លា ៤ពួក

## (២៣). បុគ្គលបដិបត្តិដើម្បីប្រយោជន៍ខ្លួនជាដើម៤ពួក

**១. បុគ្គលោ អត្តហិតាយ បដិបន្នោ ហោតិ នោ បរហិតាយ=** បុគ្គល បដិបត្តិដើម្បីប្រយោជន៍ខ្លួន តែមិនបដិបត្តិដើម្បីប្រយោជន៍បុគ្គល ដទៃទេ សេចក្តីថា បុគ្គលនេះបរិបូណ៌ដោយសីល សមាធិ បញ្ញា ដោយខ្លួនឯង តែមិនបបួលគេឱ្យបរិបូណ៌ដោយសីល សមាធិ បញ្ញា វិមុត្តិ និងវិមុត្តញ្ញាណទស្សនៈផងទេ ។

**២. បុគ្គលោ បរហិតាយ បដិបន្នោ ហោតិ នោ អត្តហិតាយ** = *បុគ្គលមិនបដិបត្តិ ដើម្បីប្រយោជន៍ខ្លួន តែបដិបត្តិដើម្បីប្រយោជន៍បុគ្គលដទៃ សេចក្ដីថា បុគ្គលនេះមិនបរិបូណ៌ដោយសីល សមាធិ បញ្ញាដោយខ្លួនឯងទេតែបបួលបុគ្គលដទៃឱ្យបរិបូណ៌ដោយសីល សមាធិ បញ្ញា វិមុត្តិ និងវិមុត្តញ្ញាណទស្សនៈផងទេ ។*

**៣. បុគ្គលោ អត្តហិតាយ ចេវ បដិបន្នោ ហោតិ បរហិតាយ ច** = *បុគ្គលបដិបត្តិដើម្បីប្រយោជន៍ខ្លួនឯងផង បដិបត្តិដើម្បីប្រយោជន៍បុគ្គលដទៃផង សេចក្ដីថា បុគ្គលនេះបរិបូណ៌ដោយសីល សមាធិ បញ្ញាដោយខ្លួនឯងផង បបួលគេឱ្យបរិបូណ៌ដោយសីល សមាធិ បញ្ញា វិមុត្តិ និងវិមុត្តញ្ញាណទស្សនៈផង ។*

**៤. បុគ្គលោ នេវ អត្តហិតាយ បដិបន្នោ ហោតិ នោ បរហិតាយ**= *បុគ្គលមិនបដិបត្តិដើម្បីប្រយោជន៍ខ្លួនឯងផង មិនបដិបត្តិដើម្បីប្រយោជន៍បុគ្គលដទៃផង។ សេចក្ដីថា បុគ្គលនេះមិនបរិបូណ៌ដោយសីល មិនបរិបូណ៌ដោយសមាធិ មិនបរិបូណ៌ដោយបញ្ញា មិនបរិបូណ៌ដោយវិមុត្ត មិនបរិបូណ៌ដោយវិមុត្តញ្ញាណទស្សនៈដោយខ្លួនឯងផង មិនបបួលបុគ្គលដទៃឱ្យបរិបូណ៌ដោយសីល សមាធិ បញ្ញា វិមុត្តិ និងវិមុត្តញ្ញាណទស្សនៈផងទេ ។*

## អធិប្បាយ

**សេចក្ដីថា** បុគ្គលខ្លះក្នុងលោកនេះជាអ្នកបរិបូណ៌ដោយ**សីល** បានដល់ លោកិយសីល និងលោកុត្តរសីល, **សមាធិ** បានដល់ លោកិយសមាធិ និងលោកុត្តរសមាធិ, **បញ្ញា** បានដល់ លោកិយបញ្ញា និងលោកុត្តរបញ្ញា, **វិមុត្តិ** បានដល់វិមុត្តនៃអរហាត្តផល, វិមុត្តិញ្ញាណទស្សនៈ(បច្ចវេក្ខណញ្ញាណ១៩)តែមិនបបួលអ្នកដទៃឱ្យបរិបូណ៌ដោយសីល សមាធិ បញ្ញា វិមុត្តិ វិមុត្តញ្ញាណទស្សនៈផងទេ។

**បណ្ដាបុគ្គលទាំង៤នោះ** បុគ្គលទី១ ដូចព្រះថេរៈ ពាកុល, បុគ្គលទី២ ដូចព្រះឧបនន្ទសក្យបុត្រ , បុគ្គលទី៣ ដូចព្រះសារីបុត្តត្ថេរ និងព្រះមហាមោគ្គលានត្ថេរៈ, បុគ្គលទី៤ ដូចភិក្ខុទេវទត្ត ។

ចប់បុគ្គលបដិបត្តិដើម្បីប្រយោជន៍ខ្លួនជាដើម

## (២៤). បុគ្គលដុតកំដៅខ្លួនឯងជាដើម

**១.បុគ្គលោ អត្តន្តបោ ហោតិ អត្តបរិតាបនានុយោគមនុយុត្តោ** = បុគ្គលដុតខ្លួនឯង ប្រកបនូវការព្យាយាមដុតកំដៅខ្លួនឯង។

**២. បុគ្គលោ បរន្តបោ ហោតិ បរបរិតាបនានុយោគមនុយុត្តោ** = បុគ្គលដុតកំដៅអ្នកដទៃប្រកបនូវការព្យាយាមដុតកំដៅអ្នកដទៃ។

៣. បុគ្គលោ អត្តន្តបោ ច ហោតិ អត្តបរិតាបនានុយោគមនុយុត្តោ បរន្តបោ ច បរបរិតាបនានុយោគមនុយុត្តោ = *បុគ្គលដុតកំដៅខ្លួនឯង ប្រកបនូវការព្យាយាមដើម្បីដុតកំដៅខ្លួនឯង ដុតកំដៅអ្នកដទៃ ប្រកបនូវការព្យាយាមដើម្បីដុតកំដៅអ្នកដទៃ ។*

៤. បុគ្គលោ នេវ អត្តន្តបោ ហោតិ ន អត្តបរិតាបនានុយោគមនុយុត្តោ ។ ន បរន្តបោ ច ន បរិតាបនាន យោគមនុយុត្ត សោ អនត្តន្តបោ អបរន្តបោ ទិដ្ឋេវ ធម្មេ និច្ឆាតោ និព្វុតោ សីតីភូតោ សុខប្បដិសំវេទី ព្រហ្មភូតេន អត្តនា វិហរតិ = *បុគ្គលមិនដុតកំដៅខ្លួនឯង មិនប្រកបនូវការព្យាយាមដើម្បីដុតកំដៅខ្លួនឯង មិនដុតកំដៅអ្នកដទៃ មិនប្រកបនូវការព្យាយាមដើម្បីដុតកំដៅអ្នកដទៃ ។ បុគ្គលនោះមិនដុតកំដៅខ្លួនឯង មិនដុតកំដៅអ្នកដទៃ ជាអ្នកមិនមានសេចក្តីស្រេកឃ្លាន មានតែសេចក្តីរំលត់ទុក្ខ ត្រជាក់ត្រជំទទួលសេចក្តីសុខ មានខ្លួនដ៏ប្រសើរសម្រេចសម្រាន្តនៅក្នុងបច្ចុប្បន្ន ។*

*អធិប្បាយ*

បុគ្គលទី១ = *បុគ្គលនេះជាអ្នកប្រព្រឹត្តខ្លួនឯងឱ្យលំបាក មានការអាក្រាតកាយ លះបង់មារយាទល្អ ស៊ីលិទ្ធដៃ(ទាំងជម្រះឧច្ចារៈ*

ដោយម្រាមដៃ) ជាដើម ។ (អត្តកិលមថានុយោគ : ការប្រកបខ្លួនឱ្យទុក្ខលំបាក) ។

**បុគ្គលទី២**=បុគ្គលខ្លះក្នុងលោកនេះជាអ្នកសំលាប់ចៀម សម្លាប់ជ្រូក សម្លាប់ម្រឹគ សម្លាប់សត្វស្លាបជាព្រាន សម្លាប់ត្រី ជាចោរ ជាអ្នកសំលាប់ចោរ សម្លាប់គោ ជានាយគុក ពុំនោះសោតបុគ្គលណាមួយជាអ្នកធ្វើការងារអាក្រក់ ។

**បុគ្គលទី៣** = បុគ្គលនេះជាព្រះរាជាដែលបានអភិសេករួចហើយ ជាព្រាហ្មណមហាសាល ជាគហបតីមហាសាល ធ្វើខ្លួនឯងឱ្យសៅហ្មង មានការកោសក់ ពុកមាត់ ពុកចង្ការ ស្លៀកដណ្តប់ស្បែកខ្លាទាំងក្រចក និងចិញ្ចឹមជីវិតដោយទឹកដោះមេគោ.... ហើយឱ្យគេសំលាប់សត្វដើម្បីបូជាយញ្ញ (បុគ្គលទី៣នេះជាប់ទាក់ទីនឹងពិធីបូជាយញ្ញ)។

**បុគ្គលទី៤**=បុគ្គលនេះបានដល់ភិក្ខុដែលបានស្តាប់ធម៌របស់ព្រះតថាគត ហើយមានសទ្ធាចេញបួស ប្រតិបត្តិដ៏ត្រឹមត្រូវក្នុងអធិសីលសិក្ខា អធិចិត្តសិក្ខា អធិបញ្ញាសិក្ខា បានសម្រេចនូវ

ភាពជាព្រះអរហន្ត ដល់ព្រមដោយបដិសម្ភិទា៤ វិមោក្ខ៨ និង អភិញ្ញា៦ ។

**អដ្ឋកថា =** ព្រះមានព្រះភាគកាលសម្តែងធម៌ រមែងសម្តែងធម៌ ដល់គហបតីមុន។ សួរថា ព្រោះហេតុអ្វី? ឆ្លើយថា ព្រោះគេកម្ចាត់មានះបានហើយ និងបានជាអ្នកបានកុសលយ៉ាងក្រាស់ ។ មែនពិត ជនចំនួនច្រើនដែលបួសមកពីខត្តិយត្រកូល អាស្រ័យពូជពង្ស ជាតិហើយប្រកាន់ខ្លួន,ដែលបួសមកអំពីត្រកូលព្រាហ្មណ៍ អាស្រ័យមន្តហើយ ក៏ប្រកាន់ខ្លួន , ពួកដែលមានត្រកូលទាបបួសហើយ ក៏មិនអាចតាំងនៅបាន ព្រោះភាវៈនៃខ្លួនមានជាតិត្រកូលទាប ។ក៏ទារករបស់គហបតីទាំងឡាយ ធ្វើការងារមានញើសហូរចេញអំពីរន្ធក្លៀកទាំងសងខាង មានខ្នងទទឹកដោយទឹកប្រៃ(ញើស) ធ្វើការភ្ជួរដី គេមិនមានមានះ មិនមានសេចក្តីក្រអែងក្រអោង ព្រោះមិនមានមានះក្រអឺតក្រទមដូច្នោះ, កូនគហបតីទាំងនោះ បួសហើយទើបមិនមានមានះ មិនធ្វើការក្រអឺតក្រទម គេនឹងរៀនពុទ្ធវចនៈតាមកម្លាំង , ធ្វើការចម្រើនវិបស្សនា រមែងអាចដើម្បីតាំងនៅក្នុងព្រះអរហត្តបាន។ ក៏ឈ្មោះថា ជនអ្នកចេញចាកត្រកូល ដែល

ក្រៅអំពីនេះ មកបួសមានមិនច្រើន, គហបតីប៉ុណ្ណោះ មានច្រើន ព្រោះហេតុដូច្នោះ ទើបព្រះមានព្រះភាគទ្រង់សម្ដែងធម៌ជាមួយ គហបតីមុន ព្រោះគេជាអ្នកកំចាត់មានះគឺការប្រកាន់ខ្លួនបាន ហើយ និងព្រោះគេ **មានកុសលដែលបានសន្សំមកច្រើនហើយផង**។

## សម្បត្តិរបស់ភិក្ខុអ្នកនៅក្នុងព្រៃ

**១. សីលក្ខន្ធ, ២. ឥន្ទ្រិយសំវរៈ,៣ .សតិសម្បជញ្ញៈ, ៤. សេចក្ដីសន្ដោស** ។ ក៏ភិក្ខុណាកាលមិនមានបច្ច័យសម្បត្តិទាំងបួននេះហើយ កាលនៅក្នុងព្រៃ ក៏មិនអាចសម្រេចប្រយោជន៍ដល់ភិក្ខុនោះឡើយ សំដៅសេចក្ដីថា ភិក្ខុនោះនឹងដល់នូវភាពជាអ្នកដែលបុគ្គលណាមួយគប្បីតិះដៀល ដោយពោលប្រៀបនឹងសត្វតិរច្ឆាន និងព្រានព្រៃ ។ ទេវតាអ្នកអាស្រ័យនៅក្នុងព្រៃ រមែងប្រកាសពាក្យឱ្យបានឮសំឡេងដែលគួរឱ្យភ័យខ្លាចថា “ នឹងមានប្រយោជន៍អ្វី ដោយការនៅព្រៃរបស់អ្នកលាមកបែបនេះ” ពួកមនុស្សទាំងឡាយនឹងនាំគ្នាយកដៃស្ទាបអង្អែលក្បាល ធ្វើអាការឱ្យលោកគេចចេញទៅ, ភាពមិនមានយសរបស់លោក រមែងខ្ចរខ្ចាយទៅថា ភិក្ខុឈ្មោះនេះ ចូលទៅនៅក្នុងព្រៃហើយ សាងកម្មដ៏លាមកយ៉ាងនេះៗ ។ ក៏បច្ច័យបួន

*នេះមានដល់ភិក្ខុអង្គណា ការនៅក្នុងព្រៃរមែងសម្រេចប្រយោជន៍ដល់ភិក្ខុអង្គនោះ ព្រោះថា កាលលោកពិចារណាឃើញសីលរបស់ខ្លួន កាលបើមិនឃើញការពព្រុស ពពាលត្រឹមតែម្យ៉ាង លោកក៏ញ៉ាំងបីតិ និងបាមោជ្ជឱ្យកើតឡើង ហើយក៏ពិចារណាបីតិនោះដោយការអស់ទៅ សូន្យទៅ រមែងឈានចុះកាន់ភូមិរបស់ព្រះអរិយៈ ។ ពួកទេវតាទាំងឡាយដែលស្ថិតនៅក្នុងព្រៃ មានចិត្តជារបស់ខ្លួន មានចិត្តរីករាយ រមែងពោលសរសើរគុណ ដោយហេតុនេះ យសរបស់ភិក្ខុនោះ រមែងរីកផ្សាយទៅ ដូចតំណក់ប្រេងដែលបុគ្គលដាក់ចូលក្នុងទឹក រមែងរីកផ្សាយចេញទៅដូច្នោះដែរ។*

ចប់បុគ្គលដុតកំដៅខ្លួនឯងជាដើម

## (២៨). បុគ្គលមានរាគៈជាដើម៤ពួក

**១. សរាគោ =** *បុគ្គលប្រកបដោយរាគៈ បានដល់ អ្នកលះរាគៈមិនទាន់បានដោយ**តទង្គប្បហាន**(គ្របសង្កត់ដោយអង្គវិបស្សនា) ដោយ**វិក្ខម្ភនប្បហាន**(គ្របសង្កត់ដោយសមាធិ)និងដោយ **សមុច្ឆេទប្បហាន** (ដោយអរិយមគ្គ)។*

**២. សទោសោ=** *បុគ្គលប្រកបដោយទោសៈ ។ បុគ្គលមិនទាន់លះទោសៈដោយបហានទាំង៣បាន។*

**៣. សមោហ =** *បុគ្គលមានមោហៈ ។ បុគ្គលមិនទាន់លះមោហដោយបហានទាំង៣បាន។*

**៤. សមានោ =** *បុគ្គលប្រកបដោយមានៈ ។ បុគ្គលមិនទាន់លះមានៈដោយបហានទាំង៣បាន។*

ចប់បុគ្គលមានរាគៈជាដើម

## (២៦). បុគ្គលបានចេតោសមថៈជាដើម៤ពួក

**១. បុគ្គលោ លាភី ហោតិ អជ្ឈត្តំ ចេតោសមថស្ស ន លាភី អធិប្បញ្ញាធម្មវិបស្សនាយ=** *បុគ្គលជាអ្នកបានចេតោសមថៈក្នុងសន្ដាន តែមិនបានអធិប្បញ្ញាធម្មវិបស្សនា បានដល់ បុគ្គលដែលបានរូបជ្ឈានក្ដី អរូបជ្ឈានក្ដី តែមិនបានលោកុត្តរ មគ្គក្ដី ផលក្ដី ។បុគ្គលនេះបានដល់* ***បុថុជ្ជនអ្នកបានសមាបត្តិ៨។***

**២. បុគ្គលោ លាភី ហោតិ អធិប្បញ្ញាធម្មវិបស្សនាយ ន លាភី អជ្ឈត្តំ ចេតោសមថស្ស =** *បុគ្គលជាអ្នកបានអធិប្បញ្ញាធម្មវិបស្សនា តែមិនបានចេតោសមថៈក្នុងសន្ដាន បានដល់ អ្នកបានសម្រេចលោកុត្តរ*

*មគ្គ និងលោកុត្តរផល តែមិនបានសមាបត្តិប្រកបដោយរូប និងអរូប។បុគ្គលនេះបានដល់* ***ព្រះអរិយសាវកដែលជាសុក្ខ-វិបស្សកៈ។***

៣. **បុគ្គលោ លាភី ចេវ ហោតិ អជ្ឈត្តំ ចេតោសមថស្ស លាភី ច អធិប្បញ្ញាធម្មវិបស្សនាយ** = *បុគ្គលជាអ្នកបានចេតោសមថៈក្នុងសន្ដានទាំងបានអធិប្បញ្ញាធម្មវិបស្សនា បានដល់* ***ព្រះអរិយសាវកដែលបានសមាបត្តិ៨។***

៤. **បុគ្គលោ នេវ លាភី ហោតិ អជ្ឈត្តំ ចេតោសមថស្ស ន លាភី អធិប្បញ្ញាធម្មវិបស្សនាយ**= *បុគ្គលជាអ្នកមិនបានចេតោសមថក្នុងសន្ដាន ទាំងមិនបានអធិប្បញ្ញាធម្មវិបស្សនា បានដល់* ***លោកិយ-បុថុជ្ជន ។***

ចប់បុគ្គលបានចេតោសមថជាដើម

## (២៧) .បុគ្គលទៅតាមក្រសែទឹកជាដើម៤ពួក

**១. អនុសោតគាមី** = *បុគ្គលទៅបណ្ដោយតាមខ្សែទឹក។*

**២. បដិសោតគាមី** = *បុគ្គលទៅច្រាសខ្សែទឹក។*

**៣. ឋិតត្តោ** = *បុគ្គលមានខ្លួនតាំងនៅនឹង។*

**៤. តិណ្ណោ បារគតោ ថលេ តិដ្ឋតិ ព្រាហ្មណោ =** *បុគ្គលឆ្លងដល់ត្រើយ ជាព្រាហ្មណ៍ឋិតនៅលើគោក ។*

*អធិប្បាយ*

**១.អនុសោតគាមី=** *បុគ្គលខ្លះក្នុងលោកនេះ សេពកាមទាំងឡាយផង ធ្វើបាបផង។*

***អដ្ឋកថា*** **:** *អនុសោតគាមីបុគ្គលនេះ បានដល់ បុថុជ្ជនដែលទៅតាមក្រសែ គឺវដ្តៈ អ្នកលិចចុះក្នុងក្រសែ គឺវដ្តៈ ។*

**២. បដិសោតគាមី =** *បុគ្គលនេះមិនសេពកាមផង មិនធ្វើបាបផង បុគ្គលនោះខំប្រព្រឹត្តព្រហ្មចរិយធម៌ឱ្យបរិសុទ្ធពេញលេញ ទាំងប្រកបដោយទុក្ខខ្លះ ទាំងប្រកបដោយទោមនស្សខ្លះ ទាំងមានមុខទទឹកដោយទឹកភ្នែកទួញយំខ្លះ (ព្រោះមិនទាន់បានលះ បរិយុដ្ឋានកិលេសនាំឱ្យធ្វើកម្មដ៏លាមកបាន) ។*

***អដ្ឋកថា*** *: បុគ្គលទី២នេះ បានដល់ បុថុជ្ជនដែលបរិបូណ៌ដោយសីល, ព្រះសោតាបន្ន និងព្រះសកទាគាមី។*

***សួរថា*** *: បុគ្គលនេះ នៅយំស្រែកប្រព្រឹត្តព្រហ្មចរិយឬ?*

**ឆ្លើយថា** ៖ ត្រូវហើយ លោកទាំងនេះ ឈ្មោះថា ស្រែកយំប្រព្រឹត្តព្រហ្មចរិយដោយអំណាចនៃកិលេស

**៣. ឋិតត្តោ =** បុគ្គលនេះជាព្រះអនាគមី ដែលលះសញ្ញោជនៈជាចំណែកខាងក្រោម៥អស់ហើយ លោកលែងមកកាន់លោកនេះដោយអំណាចបដិសន្ធិទៀតហើយ លោកនិងបរិនិព្វាននៅក្នុងសុទ្ធាវាសភូមិនោះ។

**អដ្ឋកថា :** បុគ្គលនេះ បានដល់ព្រះអនាគាមី ព្រោះលោកបានលះបង់កាមរាគៈ និងព្យាបាទបានអស់ហើយ។

**៤. តិណ្ណោ បារគតោ ថលេ តិដ្ឋតិ ព្រាហ្មណោ =** បុគ្គលខ្លះក្នុងលោកនេះធ្វើឱ្យជាក់ច្បាស់សម្រេចដោយបញ្ញាដ៏ឧត្តមខ្លួនឯងក្នុងបច្ចុប្បន្ន នូវចេតោវិមុត្តនិងបញ្ញាវិមុត្តដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ។

**អដ្ឋកថា :** បុគ្គលនេះបានដល់ព្រះអរហន្ត ដែលលោកបានឆ្លងកាត់ក្រសែតណ្ហាបានហើយ ដល់ត្រើយគឺព្រះនិព្វាន ឈរនៅលើគោក គឺអរហត្តផល និងសមាបត្តិផល លោកហៅថា "**ព្រាហ្មណ៍**"

។ព្រះខីណាស្រព នេះ ឈ្មោះថា ព្រាហ្មណ៍ព្រោះលោកជាអ្នកមានបាបដែលបានបណ្តេញចេញហើយ។

ចប់បុគ្គលទៅតាមក្រសែទឹកជាដើម៤ពួក

## (២៨). បុគ្គលជាអ្នកចេះដឹងតិចជាដើម

**១. បុគ្គលោ អប្បស្សុតោ ហោតិ សុតេន អនុបបន្នោ** = *បុគ្គលជាអ្នកចេះដឹងតិច មិនប្រតិបត្តិតាមដោយការចេះដឹង សេចក្តីថា បុគ្គលនេះចេះព្រះបរិយត្តិ គឺ សុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្មៈ វេទល្លៈតិចហើយ មិនដឹងនូវធម៌ មិនប្រតិបត្តិនូវធម៌។*

**២. បុគ្គលោ អប្បស្សុតោ ហោតិ សុតេន ឧបបន្នោ** = *បុគ្គលជាអ្នកចេះដឹងតិច តែប្រតិបត្តិដោយការចេះដឹង សេចក្តីថា បុគ្គលនេះជាអ្នកចេះព្រះបរិយត្តិតិច តែជាអ្នកប្រតិបត្តិសមគួរដល់ធម៌។*

**៣. បុគ្គលោ ពហុស្សុតោ ហោតិ សុតេន អនុបបន្នោ** = បុគ្គលជាអ្នកចេះ*ដឹងច្រើន តែមិនប្រតិបត្តិធម៌តាមសមគួរដល់ធម៌។*

**៤. បុគ្គលោ ពហុស្សុតោ ហោតិ សុតេន ឧបបន្នោ** = *បុគ្គលជាអ្នកចេះដឹងទាំងប្រតិបត្តិតាមដោយការចេះដឹង។*

ចប់បុគ្គលជាអ្នកចេះដឹងតិចជាដើម

## (២៩). បុគ្គលជាសមណៈ មិនកម្រើកញាប់ញ័រជាដើម

**១. សមណមចលោ** = *បុគ្គលជាសមណមិនកម្រើក ។*

**២. សមណបទុមោ** = *បុគ្គលជាសមណៈដូចផ្កាឈូកក្រហម។*

**៣. សមណបុណ្ឌរីកោ** = *បុគ្គលជាសមណៈដូចផ្កាឈូកស។*

**៤. សមណេសុ សមណសុខុមាលោ** = *បុគ្គលជាសមណៈចម្រើនដោយសុខ ក្នុងពួកសមណៈ ។*

*អធិប្បាយ*

**១. សមណមចលោ** = *បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកដល់នូវសោតៈ មានកិរិយាមិនធ្លាក់ចុះ(អបាយ)ជាធម្មតា ជាបុគ្គលទៀងទាត់ មានការត្រាស់ដឹងប្រព្រឹត្តទៅខាងមុខ ព្រោះការអស់ទៅនៃសញ្ញោជនៈ ៣ នេះហៅថា សមណៈមិនកម្រើក បានដល់ ព្រះ***សោតាបន្ន** ។

**២. សមណបទុមោ**= *បុគ្គលខ្លះ ក្នុងលោកនេះ ជា***សកទាគាមី** *មកកាន់លោកនេះអស់វារៈម្តងទៀត ទើបធ្វើទីបំផុតនៃទុក្ខបាន ព្រោះការអស់ទៅនៃសញ្ញោជនៈ៣ ព្រោះភាពស្រាលស្តើងនៃរា-គៈ ទោសៈ និងមោហៈ នេះហៅថា បុគ្គលជាសមណៈ ដូចផ្កាឈូក ។*

**៣. សមណបុណ្ឌរីកោ** = *បុគ្គលខ្លះ ក្នុងលោកនេះ ជាឱបបាតិកៈកំណើត ព្រោះការអស់ទៅនៃសញ្ញោជនៈ ជាចំណែកខាងក្រោម៥ ជាអ្នកបរិនិព្វាន ក្នុងសុទ្ធាវាសព្រហ្មលោកនោះ មានសភាពមិនត្រឡប់ចាកលោកនោះវិញ នេះហៅថា បុគ្គលជាសមណៈ ដូចផ្កាឈូកស បានដល់ ព្រះ**អនាគាមី**។*

**៤. សមណេសុ សមណសុខុមាលោ** = *បុគ្គលខ្លះ ក្នុងលោកនេះធ្វើឱ្យជាក់ច្បាស់សម្រេច ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្ននូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះការអស់ទៅនៃអាសវៈទាំងឡាយ នេះហៅថា បុគ្គលជាសមណៈចម្រើនដោយសុខ ក្នុងពួកសមណៈ បានដល់ ព្រះអរហន្ត ។*

***អដ្ឋកថា*** *:ព្រះអរហន្តខីណាស្រពឈ្មោះថាសមណៈសុខុមាល ព្រោះភាពជាអ្នកមិនមានកិលេសទាំងឡាយ ដែលធ្វើសេចក្តីរឹងប៉ឹង និងជាអ្នកមានទុក្ខតិច។*

ចប់បុគ្គលជាសមណៈ មិនកម្រើកញាប់ញ័រជាដើម

ចប់បុគ្គលពួក៤ ត្រឹមតែប៉ុណ្ណោះ

## បញ្ចកនិទ្ទេស

**(បុគ្គលពួក៥)**

## (ក). បុគ្គលប្រព្រឹត្តល្មើសផង ក្តៅក្រហាយផងជាដើម

**១. បុគ្គលោ អារព្ភតិ ច វិប្បដិសារី ច ហោតិ** = *បុគ្គលប្រព្រឹត្តល្មើសផង (ត្រូវអាបត្តិ) ជាអ្នកមានសេចក្តីក្តៅក្រហាយផង ។*

**២. បុគ្គលោ អារព្ភតិ ន វិប្បដិសារី ហោតិ** = *បុគ្គលប្រព្រឹត្តល្មើស តែជាអ្នកមិនមានសេចក្តីក្តៅក្រហាយ ។*

**៣.បុគ្គលោ ន អារព្ភតិ វិប្បដិសារី ហោតិ** = *បុគ្គលមិនប្រព្រឹត្តល្មើស តែមានសេចក្តីក្តៅក្រហាយ ។*

**៤.បុគ្គលោ ន អារព្ភតិ ន វិប្បដិសារី ហោតិ** = *បុគ្គលមិនប្រព្រឹត្តល្មើស ទាំងមិនមានសេចក្តីក្តៅក្រហាយ ។*

**៥. ឥមេ ចត្តារោ បុគ្គលា អមុនា បញ្ចមេន បុគ្គលេន ឯវំ ឱវទិយមានា ឯវមនុសាសិយមានា អនុបុព្វេន អាសវានំ ខយំ បាបុណន្តិ** = *នេះបុគ្គល៤ពួក ដែលបុគ្គលជាទី៥ឯណោះ កាលទូន្មានយ៉ាងនេះ ប្រៀនប្រដៅយ៉ាងនេះហើយ រមែងដល់នូវការអស់ទៅនៃអាសវៈទាំងឡាយតាមលំដាប់ (ព្រះអរហត្ត) ។*

*អធិប្បាយ*

**បុគ្គលទី១ =** បណ្ដាភិក្ខុទាំងនោះ ភិក្ខុណាក្នុងសាសនានេះ ជាអ្នកត្រូវអាបត្តិដោយកន្លងព្រះបញ្ញត្តិ **ហើយមានសេចក្ដីក្ដៅក្រហាយ** ទាំងភិក្ខុនោះមិនដឹងច្បាស់តាមពិតនូវចេតោវិមុត្តិ(ផលសមាបត្តិ) និងបញ្ញាវិមុត្តិ(ផលញ្ញាណ) ដែលជាហេតុធ្វើឱ្យអកុសលធម៌ដ៏លាមកទាំងនោះ ដែលកើតឡើងហើយឱ្យវិនាសទៅវិញ មិនមានសេសសល់ផង ។ បុគ្គលនោះ គួរឱ្យគេស្ដីយ៉ាងនេះថា **លោកមានអាយុនៅមានអាសវៈទាំងឡាយដែលនាំឱ្យប្រព្រឹត្តល្មើសកើតមាន, ទាំងអាសវៈទាំងឡាយដែលកើតអំពីសេចក្ដីក្ដៅក្រហាយចម្រើនដុះដាលក៏នៅមាន** ព្រោះហេតុនោះ សូមលោកមានអាយុ លះបង់នូវពួកអាសវៈ ដែលកើតអំពីការប្រព្រឹត្តល្មើស បន្ទោបង់នូវពួកអាសវៈ ដែលកើតអំពីសេចក្ដីក្ដៅក្រហាយចោលចេញទៅ ហើយចម្រើននូវចិត្ត(វិបស្សនាចិត្ត) និងបញ្ញា (វិបស្សនាបញ្ញា) តទៅ កាលបើយ៉ាងនេះ លោកមានអាយុនឹងជាអ្នកស្មើដោយបុគ្គលទី៥ (បានសម្រេចជាព្រះអរហន្ត)។

**បុគ្គលទី២** = បណ្ដាភិក្ខុទាំងនោះ ភិក្ខុណាជាអ្នកប្រព្រឹត្តល្មើស (ត្រូវអាបត្តិ) **តែជាអ្នកមិនមានសេចក្ដីក្ដៅក្រហាយ** ទាំងភិក្ខុនោះមិនដឹងច្បាស់តាមពិតនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលជា

ហេតុធ្វើឱ្យអកុសលធម៌ដ៏លាមកទាំងនោះរបស់បុគ្គលនោះដែលកើតឡើងហើយ រលត់ទៅវិញមិនមានសេសសល់ ។ បុគ្គលនោះគួរឱ្យគេស្តីបានយ៉ាងនេះថា **លោកមានអាយុ មានអាសវៈទាំងឡាយដែលកើតអំពីការប្រព្រឹត្តល្មើសកើតមាន តែអាសវៈទាំងឡាយ ដែលកើតអំពីសេចក្តីក្តៅក្រហាយ មិនចម្រើនដុះដាលទេ** (ព្រោះហេតុនោះ) សូមលោកមានអាយុ លះបង់ពួកអាសវៈដែលកើតអំពីការប្រព្រឹត្តល្មើសចេញ ហើយចម្រើននូវចិត្ត (វិបស្សនាចិត្ត) និងបញ្ញា(វិបស្សនាបញ្ញា) តទៅ កាលបើយ៉ាងនេះ លោកមានអាយុនឹងស្មើដោយបុគ្គលទី៥ឯណោះ។

**បុគ្គលទី៣=** បណ្តាភិក្ខុទាំងនោះ **ភិក្ខុណាមិនប្រព្រឹត្តល្មើសព្រះបញ្ញត្តិទេ តែមានសេចក្តីក្តៅក្រហាយ** ទាំងមិនដឹងច្បាស់នូវចេតោវិមុត្តនិងបញ្ញាវិមុត្តដែលជាហេតុធ្វើឱ្យពួកអកុសលធម៌ របស់បុគ្គលនោះដែលកើតឡើងហើយ រលត់ទៅវិញ មិនមានសេសសល់ ។ បុគ្គលនោះ គួរឱ្យគេស្តីបានយ៉ាងនេះថា **លោកមានអាយុ មានអាសវៈទាំងឡាយដែលកើតអំពី ការប្រព្រឹត្តល្មើស មិនកើតឡើងទេ តែមានអាសវៈទាំងឡាយដែលកើតអំពីសេចក្តីក្តៅក្រហាយចម្រើនដុះដាល** ( ព្រោះហេតុនោះ ) សូមលោកមានអាយុ

បន្ទោសបង់ពួកអាសវៈដែលកើតអំពីសេចក្តីក្តៅក្រហាយចោល ចេញ ហើយចម្រើននូវចិត្ត និង បញ្ញាតទៅ កាលបើយ៉ាងនេះ លោកមានអាយុ នឹងជាអ្នកស្មើដោយបុគ្គលទី៥ឯណោះ ។

**ព្រះអដ្ឋកថា** : ភិក្ខុនេះជាអ្នកមិនត្រូវអាបត្តិទេ តែព្រោះ លោកជាអ្នកមិនឈ្លាសក្នុងវិន័យបញ្ញត្តិ ជាអ្នកមានការសម្គាល់ អនាបត្តិ ថាជាអាបត្តិ ទើបមានវិប្បដិសារី គឺក្តៅក្រហាយ ។

**នៅក្នុងអដ្ឋកថា អង្គុត្តរនិកាយ** សម្តែងថា ភិក្ខុត្រូវអាបត្តិ១ ដង ចេញចាកអាបត្តិនោះហើយ ខាងក្រោយមិនត្រូវអាបត្តិអ្វីៗ ឡើយ ក៏ពិតមែនហើយ តែថាលោកនៅតែមិនអាចដើម្បីនឹង លះបង់វិប្បដិសារីបានឡើយ ។ ទាំងភិក្ខុនោះមិនដឹងច្បាស់តាមពិត នូវចេ-តោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលជាហេតុធ្វើឱ្យអកុសលធម៌ដ៏ លាមកទាំងនោះ ដែលកើតឡើងហើយឱ្យវិនាសទៅវិញ មិនមាន សេស-សល់ផង ។ល។

**បុគ្គលទី៤** = បណ្តាភិក្ខុទាំងនោះ ភិក្ខុណា មិនប្រព្រឹត្តល្មើស មិនមានសេចក្តីក្តៅក្រហាយទេ តែមិនដឹងតាមពិតនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិនោះ ដែលជាហេតុធ្វើឱ្យពួកអកុសលធម៌ដ៏លាមក

ទាំងនោះ របស់បុគ្គលនោះ ដែលកើតឡើងហើយ រលត់ទៅវិញ មិនមានសេសសល់ ។បុគ្គលនោះគួរឱ្យគេស្តីបានយ៉ាងនេះថា **លោកមានអាយុ មានអាសវៈទាំងឡាយ ដែលកើតអំពីការប្រព្រឹត្ត ល្មើសមិនកើតមាន ទាំងមានអាសវៈទាំងឡាយដែលកើតអំពីសេចក្តីក្តៅក្រហាយ ក៏មិនដុះដាលឡើយ** (ព្រោះហេតុនោះ) សូមលោកមានអាយុ ចម្រើននូវចិត្ត និងបញ្ញា តទៅ កាលបើយ៉ាងនេះ លោកមានអាយុ នឹងជាអ្នកស្មើដោយបុគ្គលទី ៥ ឯណោះ ។

**សេចក្តីក្នុងព្រះអដ្ឋកថា** : ភិក្ខុនោះជាអ្នកប្រព្រឹត្តព្យាយាមលះបង់អាសវៈដែលជាហេតុនាំឱ្យត្រូវអាបត្តិ ដើម្បីជាអ្នកមានសីលបរិសុទ្ធ តែភិក្ខុអង្គនោះមិនបំពេញបដិបត្តិដោយគិតថា “ប្រយោជន៍អ្វីចំពោះយើង ដោយការបរិនិព្វានក្នុងពុទ្ធកាលនេះ យើងនឹងបរិនិព្វានក្នុងសម័យព្រះមេត្តេយ្យសម្មាសម្ពុទ្ធជាម្ចាស់ក្នុងអនាគតកាលវិញ” ភិក្ខុនេះត្រូវអ្នកដទៃនិយាយឱ្យឱវាទថា អ្នកមានអាយុ ជាអ្នកប្រមាទដើម្បីប្រយោជន៍អ្វី?”ក៏ឈ្មោះថា គតិរបស់បុថុជ្ជនជារបស់មិនពិតប្រាកដឡើយ,លោកអ្នកមានអាយុ តើនរណានឹងអាចដឹងថា បុគ្គលគប្បីបាន ឬមិនបាននូវភាពជាអ្នកមាន

*មុខ ចំពោះព្រះមេត្តេយ្យសម្មាសម្ពុទ្ធជាម្ចាស់ ព្រោះហេតុដូច្នោះ ចូលលោកចម្រើនវិបស្សនា ដើម្បីដល់អរហត្តចុះ ។*

***បុគ្គលទី៤*** = *បុគ្គលទី៤នេះ គឺជាបុគ្គលទី១ក្តី ទី២ក្តី ទី៣ក្តី ទី៤ក្តី កាលគេស្តីបន្ទោសដើម្បីលះបង់អាសវៈដែលនាំឱ្យត្រូវអាបត្តិ ភិក្ខុនោះរមែងលះបង់បាន ហើយប្រតិបត្តិដើម្បីដឹងច្បាស់តាមពិតនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ទីបំផុតភិក្ខុនោះក៏បានដឹងច្បាស់នូវធម៌នោះ ហើយភិក្ខុនោះក៏បានឈ្មោះថាបុគ្គលទី៤ ។*

ចប់បុគ្គលប្រព្រឹត្តល្មើសផង ក្តៅក្រហាយផងជាដើម

## (២). បុគ្គលឱ្យហើយមើលងាយវិញជាដើម

**១.បុគ្គលោ ទត្វា អវជានាតិ** = *បុគ្គលឱ្យហើយត្រឡប់មើលងាយវិញ ។*

**២.បុគ្គលោ សំវាសេន អវជានាតិ** =*បុគ្គលមើលងាយព្រោះការនៅរួម។*

**៣.បុគ្គលោ អាធេយ្យមុខោ ហោតិ** = *បុគ្គលមានមុខជឿងាយ។*

**៤.បុគ្គលោ លោលោ ហោតិ** = *បុគ្គលរេរ៉េះពរ្ភេះ។*

**៥.បុគ្គលោ មន្ទោ មោមូហោ ហោតិ** = *បុគ្គលល្ងង់ខ្លៅ។*

## ***អធិប្បាយ***

**បុគ្គលទី១** = ភិក្ខុ១អង្គជាអ្នកមានបុណ្យច្រើន អ្នកមានប្រក្រតីបានបច្ច័យ៤ មានចីវរបច្ច័យជាដើម ភិក្ខុអ្នកមើលងាយភិក្ខុដែលមានបុណ្យតិចថា “ អាវុសោមានបច្ច័យប្រើប្រាស់ទេឬ? ភិក្ខុនោះឆ្លើយថា : ខ្ញុំព្រះករុណាជាអ្នកមានបុណ្យតិច ធ្វើដូចម្តេចនឹងសម្បូរបច្ច័យ ដូចលោកម្ចាស់ដែលជាអ្នកមានបុណ្យច្រើនទៅ” ភិក្ខុអ្នកមើលងាយឱ្យបច្ច័យមានចីវរជាដើម ។ ភិក្ខុអ្នកមើលងាយក្រោធនឹងភិក្ខុដែលមានបុណ្យតិចនោះ,ប្រាថ្នានឹងឱ្យលោកកើតសេចក្តីអៀនប្រៀន ទើបពោលថា “ភិក្ខុនេះ មិនបានបច្ច័យទាំងឡាយ មានចីវរបច្ច័យជាដើម តាមធម្មតារបស់ខ្លួនទេ លុះត្រាតែអាស្រ័យយើងទើបបាន”នេះឈ្មោះថា**ឱ្យហើយមើលងាយ**

**បុគ្គលទី២** = បុគ្គលខ្លះ ក្នុងលោកនេះ នៅរួមជាមួយនឹងបុគ្គលណាអស់ ២ ឆ្នាំក្តី ៣ ឆ្នាំក្តី ក៏មើលងាយបុគ្គលនោះ ព្រោះការនៅរួម បុគ្គលមើលងាយ ព្រោះកានៅរួមយ៉ាងនេះឯង។

**អដ្ឋកថា** : បុគ្គលម្នាក់ កាលនៅអាស្រ័យនិងបុគ្គលម្នាក់ ២-៣ឆ្នាំ តែងធ្វើសេចក្តីគោរព ក្នុងបុគ្គលនោះ តាំងពីកាលមុន តមកខាងក្រោយ កាលបើវលោកន្លងទៅៗមិនធ្វើសេចក្តីគោរពកោត

ក្រេវ គឺមិនក្រោកឡើងអំពីអាសនៈខ្លះ មិនទៅកាន់ទីបម្រើខ្លះ បុគ្គលនេះ ឈ្មោះថា ***រមែងមើលងាយដោយការនៅរួម។***

***បុគ្គលទី៣*** =បុគ្គលខ្លះក្នុងលោកនេះ កាលបើមានគេពោលគុណក្តី ពោលទោសក្តី របស់បុគ្គលដទៃ ក៏ចុះចិត្តជឿភ្លាមមួយរំពេច ***នេះបុគ្គលមានមុខជឿងាយ*** ។

***បុគ្គលទី៤***= បុគ្គលខ្លះក្នុងលោកនេះ មានជំនឿផ្តេសផ្តាស មានការសេពគប់ផ្តេសផ្តាស មានសេចក្តីស្រឡាញ់ផ្តេសផ្តាស មានសេចក្តីជ្រះថ្លាផ្តេសផ្តាស នេះហៅថា ***បុគ្គលសើះពភ្លែះ*** ។

***អដ្ឋកថា***: បទថា ***“ឯវំ បុគ្គលោ លោលោ ហោតិ”*** បុគ្គលនេះឈ្មោះថា ជាអ្នកមិននឹងធឹង ព្រោះភាពនៃខ្លួនជាអ្នកមានសទ្ធាបន្តិចបន្តួចជាដើម អធិប្បាយថា បុគ្គលដែលមិននៅនឹងនួននេះជាអ្នកមានឋានៈដែលមិនតាំងមាំ ដូចសំពត់ដែលជ្រលក់ដោយល្មៀត , ដូចបង្គោលដែលបោះទុកក្នុងគំនរអង្កាម , ដូចផ្លែឃ្លោកដែលគេដាក់ទុកលើខ្នងសេះ , រមែងជ្រះថ្លា ដោយកាលមួយភ្លែត រមែងក្រោធដោយកាលមួយភ្លែត (មួយភ្លែតស្រឡាញ់ មួយភ្លែតស្អប់) ។

***បុគ្គលទី៩*** = *បុគ្គលខ្លះក្នុងលោកនេះ មិនដឹងក្នុងធម៌ ជាកុសលនិង អកុសល មិនដឹងនូវធម៌មានទោសនិងធម៌មិនមានទោស មិនដឹង នូវធម៌ថោកទាប និងធម៌ខ្ពង់ខ្ពស់ មិនដឹងនូវធម៌មានចំណែកប្រៀប ដោយវត្ថុមានពណ៌ខ្មៅនិងពណ៌ស បុគ្គលល្ងង់ខ្លៅយ៉ាងនេះឯង។*

***អដ្ឋកថា***: *បទថា “**មន្ទោ មោមូហោ**” សេចក្តីថា បុគ្គលឈ្មោះ ថា **ល្ងង់** ព្រោះមិនមានញាណ( អញ្ញាណ) ឈ្មោះថា **ល្ងង់** ព្រោះ ភាពជាអ្នកមិនឈ្លាស អធិប្បាយថា អ្នកវង្វេងវង្វាន់ច្រើន ។*

ចប់បុគ្គលឱ្យហើយមើលងាយវិញជាដើម

## (៣). បញ្ច យោធាជីវូបមា បុគ្គលា

### (ភិក្ខុប្រៀបដូចអ្នកចម្បាំងជាអាជីព ៥ជំពូក)

## យោធា៥ពួក

**១. យោធាជីវោ រជគ្គញ្ញេវ ទិស្វា សំសីទតិ វិសីទតិ ន សន្ថម្ភតិ ន សក្កោតិ សង្គាមំ ឱតរិតុំ ឯវរូបោបិ ឥធេកិច្ចោ យោធាជីវោ ហោតិ** = *យោធាខ្លះក្នុង លោកនេះ គ្រាន់តែឃើញចុងនៃធូលី (ហុយឡើង) ក៏រួញរាថយ ក្រោយ មិនហ៊ានតទល់ មិនអាចចូលកាន់សង្គ្រាម ។*

២. យោធាជីវោ សហតិ រជគ្គំ អបិច ខោ ធជគ្គញ្ញេវ ទិស្វា សំសីទតិ វិ សីទតិ ន សន្ថម្ភតិ......=*យោធាខ្លះក្នុងលោកនេះ អត់ទ្រាំនឹងចុងធូលីបាន តែដល់ឃើញចុងទង់ជ័យ(បច្ចាមិត្ត)ក៏រួញរាថយក្រោយ មិនហ៊ានតទល់ មិនអាចចូលកាន់សង្គ្រាម....។*

៣. យោធាជីវោ សហតិ រជគ្គំ សហតិ ធជគ្គំ អបិច ខោ ឧស្សារណញ្ញេវ សុត្វា សំសីទតិ វិសីទតិ ន សន្ថម្ភតិ.....= *យោធាខ្លះអត់ទ្រាំនូវចុងនៃធូលីបាន ទ្រាំចុងនៃទង់ជ័យ(បច្ចាមិត្ត)បានដែរ តែលុះឮសំឡេងហ៊ោ ក៏រួញរាថយក្រោយ...។*

៤. យោធាជីវោ សហតិ រជគ្គំ សហតិ ធជគ្គំ សហតិ ឧស្សារណំ អបិច ខោ សម្បហារេ ហញ្ញតិ ព្យាបជ្ជតិ ឯវរូបោបិ....= *យោធាខ្លះអត់ទ្រាំនូវចុងធូលី អត់ទ្រាំនូវចុងនៃទង់ជ័យ អត់ទ្រាំនូវសំឡេងហ៊ោបានដែរ តែសត្រូវបៀតបៀន ក៏ស្លាប់ខ្លួន ព្រោះការប្រហារបន្តិចបន្តួច....។*

៥. យោធាជីវោ សហតិ រជគ្គំ សហតិ ធជគ្គំ សហតិ ឧស្សារណំ សហតិ សម្បហារំ សោ តំ សង្គាមំ អភិវិជិនិត្វា វិជិតសង្គាមោ..... = *យោធាខ្លះអត់ទ្រាំនូវចុងធូលី អត់ទ្រាំនូវចុងនៃទង់ជ័យ អត់ទ្រាំនូវសំឡេងហ៊ោបាន អត់ទ្រាំនូវការប្រហារបាន ទាហាននោះ ឈ្នះសង្គ្រាមនោះ*

មានសង្គ្រាមឈ្នះស្រឡះហើយ      ក៏នៅគ្រប់គ្រងក្បាលសង្គ្រាម (រណសិរ្ស) នោះឯង។

## ភិក្ខុជាអ្នកចម្បាំង៥ពួក

១.ភិក្ខុខ្លះក្នុងសាសនានេះ **គ្រាន់តែឃើញចុងនៃធូលី** ក៏រួញរាថយក្រោយ មិនតទល់ មិនអាចបន្តព្រហ្មចរិយធម៌ ធ្វើឱ្យប្រាកដនូវភាពថយកម្លាំងក្នុងសិក្ខា លះបង់នូវសិក្ខា វិលត្រឡប់មកកាន់ភេទថោកទាបវិញ ។ **ចុះអ្វីជាចុងនៃធូលីរបស់ភិក្ខុនោះ គឺ** ភិក្ខុខ្លះក្នុងសាសនានេះ បានឮថា ក្នុងស្រុកក្តី ក្នុងនិគមក្តី នៅឯណោះ មានស្រីឬកុមារីមានរូបស្អាត គួររមិលមើល គួរជ្រះថ្លា ប្រកបដោយពណ៌នៃសរីរៈក៏ល្អក្រៃលែង  ភិក្ខុនោះលុះដឹងដំណឹងដូច្នេះហើយ ក៏រួញរាថយក្រោយ   មិនតទល់   មិនអាចបន្តនូវព្រហ្មច-រិយធម៌   ធ្វើឱ្យប្រាកដនូវភាពថយកម្លាំង ក្នុងសិក្ខា លះបង់នូវសិក្ខា វិលត្រឡប់មកកាន់ភេទថោកទាបវិញ **នេះហៅថា ចុងនៃធូលីរបស់ភិក្ខុនោះ**។ នេះបុគ្គលទី១ ប្រៀបដោយទាហាន រមែងមានក្នុងពួកភិក្ខុ។

**២.ភិក្ខុនេះអត់ទ្រាំនូវចុងនៃធូលីបាន តែគ្រាន់តែឃើញចុងនៃទង់ជ័យរបស់សត្រូវក៏អត់ទ្រាំមិនបាន រួញរា...= ចុងនៃទង់ជ័យ របស់ភិក្ខុនោះ** គឺ ភិក្ខុខ្លះក្នុងសាសនានេះមិនបានឮ គេសរសើរស្ត្រីឯណោះទេ តែ

*លុះបានឃើញដោយខ្លួនឯងហើយ ក៏មិនអាចបន្តព្រហ្មចរិយធម៌មិនបាន.....ភិក្ខុនោះបានលាចាកសិក្ខាទៅកាន់ភេទថោកទាបវិញ។ នេះហៅថា ចុងនៃទង់ជ័យរបស់ភិក្ខុនោះ។ នេះបុគ្គលទី២ ប្រៀបដោយទាហាន រមែងមានក្នុងពួកភិក្ខុ។*

៣. ភិក្ខុនេះអត់ទ្រាំនូវចុងនៃធូលីបាន អត់ទ្រាំនូវទង់ជ័យបានដែរ តែលុះបានឮសំឡេងហ៊ោ(នៃបច្ចាមិត្ត)ក៏រួញរាថយក្រោយ...=***ចុះអ្វីជាសំឡេងហ៊ោរបស់ភិក្ខុនោះ*** *គឺភិក្ខុខ្លះក្នុងសាសនានេះកាល មាតុគ្រាមចូលទៅរកភិក្ខុនោះ ដែលនៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី ហើយសើចល្បួង និយាយចែចង់ សើចខ្លាំង ចំអកចំអន់ភិក្ខុនោះ កាលបើមាតុគ្រាម ធ្វើអាការៈមានសភាពដូច្នេះ ក៏មិនអាចបន្តព្រហ្មចរិយធម៌បាន....ក៏លាចាកសិក្ខា មកកាន់ភេទថោកទាបវិញ នេះឈ្មោះថា សំឡេងហ៊ោរបស់ភិក្ខុនោះ។ នេះបុគ្គលទី៣ ប្រៀបដោយទាហាន រមែងមានក្នុងពួកភិក្ខុ។*

៤. ភិក្ខុនេះអត់ទ្រាំនឹងចុងនៃធូលី អត់ទ្រាំនឹងទង់ជ័យរបស់សត្រូវ អត់ទ្រាំនឹងសម្លេងហ៊ោរបស់សត្រូវបាន តែត្រូវគេបៀតបៀនវិនាសស្លាប់ខ្លួន ព្រោះការប្រហារ របស់បច្ចាមិត្ត = ***ចុះអ្វីជាការប្រហាររបស់ភិក្ខុនោះ*** *គឺភិក្ខុខ្លះក្នុងសាសនានេះកាល មាតុគ្រាមចូលទៅរកភិក្ខុនេះ ដែល*

*នៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី ហើយអង្គុយកៀកកើយ ដេកជិត ឱបរឹត ភិក្ខុនោះកាលបើមាតុគ្រាម ធ្វើអាការៈមានសភាពដូច្នេះ មិនលះបង់នូវសិក្ខា មិនធ្វើឱ្យប្រាកដនូវភាពជាអ្នកមានកម្លាំងថយទេ ហើយសេពនូវមេថុនធម្ម (និងមាតុគ្រាមនោះ) នេះជាការប្រហាររបស់ភិក្ខុនោះ ។ នេះបុគ្គលទី៤ ប្រៀបដោយទាហាន រមែងមានក្នុងពួកភិក្ខុ ។*

**៥.ភិក្ខុខ្លះក្នុងសាសនានេះ ជាអ្នកឈ្នះសង្គ្រាមទាំង៤ខាងដើម ក៏នៅគ្រប់គ្រងក្បាលសង្គ្រាមជ័យនោះឯង** = ***ចុះអ្វីជាការឈ្នះសង្គ្រាមរបស់ភិក្ខុនោះ*** *គឺ កាលមាតុគ្រាម ចូលទៅរកភិក្ខុក្នុងសាសនានេះ ដែលនៅក្នុងព្រៃ...ហើយអង្គុយកៀកកើយ ដេកជិត ឱបរឹត ។ ភិក្ខុនោះកាលបើមាតុគ្រាមធ្វើដូច្នេះ ក៏ប្រានចេញដោះខ្លួន ចៀសចេញទៅតាមប្រាថ្នា ។ ភិក្ខុនោះគប់រកសេនាសនៈស្ងាត់ គឺព្រៃ គល់ឈើ ភ្នំ ញកភ្នំ រូងភ្នំ ព្រៃស្មសាន ព្រៃធំ ទីវាល គំនរចំបើង ។ ភិក្ខុនោះកាលនៅក្នុងទីដូច្នេះ ក៏បំពេញព្យាយាមក្នុងកម្មដ្ឋានដើម្បីលះបង់អកុសលដ៏លាមក ភិក្ខុនោះក៏បានសម្រេចជាព្រះអរហន្ត ភិក្ខុនោះក៏ដឹងច្បាស់ថាជាតិអស់ហើយ មគ្គព្រហ្មចរិយអាត្មាអញបានធ្វើហើយ សោឡសកិច្ចអាត្មាអញបានធ្វើរួចហើយ មគ្គភាវនាកិច្ចឯ*

*ទៀតក្រៅពីនេះ មិនមានទៀតឡើយ។ នេះជាការឈ្នះសង្គ្រាមគ្រប់គ្រងក្បាលជ័យរបស់ភិក្ខុនោះ ។ នេះបុគ្គលទី៥ ប្រៀបដោយទាហាន រមែងមានក្នុងពួកភិក្ខុ ។*

ចប់ភិក្ខុប្រៀបដូចអ្នកចម្បាំងជាអាជីព ៥ជំពូក

## (៤). បញ្ចា បិណ្ឌបាតិកា

(ហេតុនាំឱ្យភិក្ខុកាន់បិណ្ឌបាតិកធុតង្គ មាន៥ពួក)

**១. មន្ទត្តា មោមូហត្តា បិណ្ឌបាតិកោ ហោតិ** = *ភិក្ខុជាអ្នកប្រព្រឹត្តបិណ្ឌបាតិកធុតង្គ ព្រោះភាពនៃខ្លួនជាមនុស្សល្ងង់ ជាបុគ្គលវង្វេងសេចក្ដីថា ភិក្ខុនេះប្រព្រឹត្តធុតង្គព្រោះមិនស្គាល់ការសមាទាន និងមិនស្គាល់អានិសង្ស។*

**២. បាបិច្ឆោ ឥច្ឆា បកតោ បិណ្ឌបាតិកោ ហោតិ** = *ភិក្ខុមានសេចក្ដីប្រាថ្នាលាមកត្រូវសេចក្ដីប្រាថ្នាគ្របសង្កត់ ជាអ្នកប្រព្រឹត្តបិណ្ឌបា-តិកធុតង្គ។*

**៣. ឧម្មាទា ចិត្តវិក្ខេបា បិណ្ឌបាតិកោ ហោតិ** = *ភិក្ខុជាអ្នកប្រព្រឹត្តបិណ្ឌបាតិកធុតង្គ ព្រោះការឆ្កួត និងការរវើរវាយចិត្ត។*

**៤. វណ្ណិតំ ពុទ្ធេហិ ពុទ្ធសាវកេហីតិ បិណ្ឌបាតិកោ ហោតិ =** *ភិក្ខុជាអ្នកប្រព្រឹត្តបិណ្ឌបាតិកធុតង្គ ព្រោះគិតថា បិណ្ឌបាតិកវត្ត ជាកិច្ចដែលព្រះពុទ្ធនិងសាវករបស់ព្រះពុទ្ធទាំងឡាយសរសើរហើយ។*

**៥. អបិច អប្បិច្ឆំយេវ និស្សាយ សន្តុដ្ឋីយេវ និស្សាយ សល្លេខំយេវ និស្សាយ ឥទមត្ថិតំយេវ និស្សាយ បិណ្ឌបាតិកោ ហោតិ =** *ភិក្ខុអាស្រ័យសេចក្តីប្រាថ្នាតិច អាស្រ័យសេចក្តីសន្តោស អាស្រ័យការដុសខាត់ចិត្ត អាស្រ័យសេចក្តីប្រតិបត្តិជាប្រយោជន៍ ហើយជាអ្នកប្រព្រឹត្តបិណ្ឌបាតិកធុតង្គ។*

*បណ្តាបិណ្ឌបាតិកធុតង្គទាំង៥ពួកនេះ ភិក្ខុដែលប្រព្រឹត្តបិណ្ឌបាតិកធុតង្គដើម្បីប្រាថ្នាតិច ដើម្បីសន្តោស ប្រសើរជាងអស់ធុតង្គទាំងឡាយ៤ខាងដើម។*

*សូម្បីខលុបច្ឆាភត្តិកធុតង្គបុគ្គល៥ពួក(៥), ឯកាសនិកធុតង្គបុគ្គល៥ពួក(៦), បំសុកូលិកង្គធុតង្គបុគ្គល៥ពួក(៧), តេចីវរិកធុតង្គបុគ្គល៥ពួក(៨),អារញ្ញិកធុតង្គបុគ្គល៥ពួក(៩),រុក្ខមូលិកធុតង្គបុគ្គល៥ពួក(១០), អព្ភោកាសិកធុតង្គបុគ្គល៥ពួក(១១)* ,***នេសជ្ជិក-ធុតង្គ****បុគ្គល៥ពួក(១២), សន្ថតិកធុតង្គបុគ្គល៥ពួក(១៣), សោសានិកធុតង្គបុគ្គល៥ពួក(១៤) ក៏មានន័យដូចគ្នាដែរ។*

ចប់ហេតុនាំឱ្យភិក្ខុកាន់បិណ្ឌបាតិកធុតង្គ មាន៥ពួក

ចប់បុគ្គលពួក៥ ត្រឹមតែប៉ុណ្ណោះ

# ឆក្កនិទ្ទេស

(បុគ្គលពួក៦)

១.បុគ្គលណាត្រាស់ដឹងដោយខ្លួនឯង នូវសច្ចក្នុងធម៌ទាំងឡាយ ដែលខ្លួនមិនធ្លាប់បានឮ ក្នុងកាលមុន ក៏ដល់នូវសព្វញ្ញុតញ្ញាណ។ ក្នុងធម៌ទាំងនោះផង ដល់នូវភាពស្ទាត់ក្នុងទសពលញ្ញាណផង បណ្ឌិតគប្បីជ្រាបថា បុគ្គលនោះជា **ព្រះសម្មាសម្ពុទ្ធ**។

២.បុគ្គលណាត្រាស់ដឹងដោយខ្លួនឯងនូវសច្ចក្នុងធម៌ទាំងឡាយ ដែលខ្លួនមិនធ្លាប់បានឮ ក្នុងកាលមុន តែមិនដល់នូវសព្វញ្ញុត-ញ្ញាណ ក្នុងធម៌ទាំងនោះផង មិនដល់នូវ ភាពស្ទាត់ ក្នុងទសពល-ញ្ញាណផង បណ្ឌិតគប្បីជ្រាបថា បុគ្គលនោះជា **ព្រះបច្ចេកពុទ្ធ**។

៣.បុគ្គលណាមិនត្រាស់ដឹងដោយខ្លួនឯងនូវសច្ចក្នុងធម៌ទាំងឡាយ ដែលខ្លួនមិនធ្លាប់បានឮ ក្នុងកាលមុន តែជាអ្នកដល់ទីបំផុតទុក្ខ ក្នុងបច្ចុប្បន្នផង ដល់នូវសាវកបារមីញាណផង បណ្ឌិតគប្បីជ្រាបថា បុគ្គលនោះ គឺព្រះ**សារីបុត្ត និងព្រះមហាមោគ្គលាន**។

៤.បុគ្គលណា មិនត្រាស់ដឹងដោយខ្លួនឯង នូវសច្ចក្នុងធម៌ទាំងឡាយ ដែលខ្លួនមិនធ្លាប់បានឮ ក្នុងកាលមុនផង តែជាអ្នកដល់ទីបំផុតទុក្ខ ក្នុងបច្ចុប្បន្នផង តែមិនដល់នូវសាវកបារមីញាណ បណ្ឌិតគប្បីជ្រាបថា បុគ្គលនោះ **គឺព្រះអរហន្តដ៏សេស។**

៥.បុគ្គលណា មិនត្រាស់ដឹងដោយខ្លួនឯង នូវសច្ចក្នុងធម៌ទាំងឡាយ ដែលខ្លួនមិនធ្លាប់បានឮ ក្នុងកាលមុនផង ជាអ្នកមិនទាន់ដល់នូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នផង ជាអនាគាមី ព្រោះមិនមកកាន់មនុស្សលោកនេះទៀតផង បណ្ឌិតគប្បីជ្រាបថា បុគ្គលនោះ **គឺអនាគាមីបុគ្គល។**

៦.បុគ្គលណា មិនត្រាស់ដឹងដោយខ្លួនឯង នូវសច្ចក្នុងធម៌ទាំងឡាយ ដែលខ្លួនមិនធ្លាប់បានឮ ក្នុងកាលមុនផង ជាអ្នកមិនទាន់ដល់នូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្ន នៅវិលមកកាន់មនុស្សលោកនេះទៀត បណ្ឌិតគប្បីជ្រាបថា បុគ្គលនោះ **គឺព្រះសោតាបន្ន និងព្រះសកទាគាមីបុគ្គល។**

ចប់បុគ្គលពួក៦

**ចប់បុគ្គលពួក៦ត្រឹមតែប៉ុណ្ណោះ**

# សត្តកនិទ្ទេស

(បុគ្គលពួក៧)

១. បុគ្គលោ សកឹ និម្មុគ្គោ និម្មុគ្គោវ ហោតិ = *បុគ្គលជ្រមុជចុះម្ដង ហើយចេះតែមុជ ចុះទៅទៀត។*

២. បុគ្គលោ ឧម្មុជ្ជិត្វា និម្មុជ្ជតិ = *បុគ្គលងើបឡើងហើយ មុជចុះទៅវិញ ។*

៣. បុគ្គលោ ឧម្មុជ្ជិត្វា ឋិតោ ហោតិ = *បុគ្គលងើបឡើងហើយឋិតនៅ។*

៤. បុគ្គលោ ឧម្មុជ្ជិត្វា វិបស្សតិ វិលោកេតិ = *បុគ្គលងើបឡើងហើយក្រឡេកមើល។*

៥.បុគ្គលោ ឧម្មុជ្ជិត្វា បតរតិ = *បុគ្គលងើបឡើងហើយហែលទៅ។*

៦. បុគ្គលោ ឧម្មុជ្ជិត្វា បដិគាធប្បត្តោ ហោតិ = *បុគ្គលងើបឡើងហើយដល់កំពង់ហើយឋិតនៅ។*

៧.បុគ្គលោ ឧម្មុជ្ជិត្វា តិណ្ណោ ហោតិ បារគតោ ថលេ តិដ្ឋតិ ព្រាហ្មណោ = *បុគ្គលងើបឡើង ឆ្លងដល់ត្រើយ ជាព្រាហ្មណ៍ឋិតនៅលើគោក។*

## អធិប្បាយ

***បុគ្គលទី១*** = *បុគ្គលខ្លះក្នុងលោកនេះ ប្រកបដោយអកុសលធម៌ខ្មៅតែម្យ៉ាង បុគ្គលមុជចុះតែម្ដង ហើយចេះតែមុជចុះទៅទៀតយ៉ាងនេះឯង។*

**អដ្ឋកថា** : បទថា **“ឯកន្តកាឡកេហិ អកុសលេហិ”** អកុសលធម៌ខ្មៅ បានដល់ និយតមិច្ឆាទិដ្ឋិទាំងឡាយមាន នត្ថិកវាទ អកិរិយវាទ និងអហេតុកវាទ ដែលខ្មៅតែម្យ៉ាងប៉ុណ្ណោះ ។ បុគ្គលដែលមានទិដ្ឋិមានសភាពដូច្នេះ បុគ្គលនោះនឹងធ្លាក់ទៅកាន់នរក ។ អាចារ្យខ្លះពោលថា “ក៏ឈ្មោះថា ការចេញចាកភពរបស់និយតមិច្ឆាទិដ្ឋិនោះរមែងមិនមាន” អណ្តាតភ្លើង គឺសត្វនរកទាំងឡាយមាននៅខាងក្រោមនោះឯង ដូចសាស្តាទាំងឡាយមានមក្ខលិគោសាលជាដើម។

**បុគ្គលទី២** = បុគ្គលខ្លះក្នុងលោកនេះ ងើបឡើងធ្វើជាកុសលប្រកបដោយសទ្ធាដ៏ប្រពៃ ហិរិដ៏ប្រពៃ ឱត្តប្បៈដ៏ប្រពៃ វីរិយៈដ៏ប្រពៃ បញ្ញាដ៏ប្រពៃ ងើបឡើងក្នុងកុសល។ តែសទ្ធា ហិរិ ឱត្តប្បៈ វីរិ-យៈ បញ្ញា ទាំងនោះរបស់បុគ្គលនោះមិននៅនឹង មិនចំរើន តែងសាបសូន្យទៅវិញ បុគ្គលងើបឡើងហើយ មុជចុះទៅវិញ យ៉ាងនេះឯង។

**អដ្ឋកថា** : បទថា **“សាហុ សទ្ធា កុសលេសុ ធម្មេសុ”** សេចក្តីថា រមែងងើបឡើងក្នុងកុសលធម៌ទាំងឡាយ ដោយគិតថា “ឈ្មោះថា សទ្ធា ជាលទ្ធិដែលល្អ” ដូច្នេះ បុគ្គលនោះ ឈ្មោះថា រមែងងើបឡើងដោយកុសលធម៌មានប្រមាណប៉ុណ្ណោះ នោះឯង ។

ស្ទូម្បីក្នុងពាក្យថា "**សាធុ ហិរិ** = សេចក្ដីខ្មាសជាលទ្ធិដែលល្អ" ជាដើម ក៏មានន័យដូចគ្នានេះដែរ។

បទថា **ឯវំ បុគ្គលោ** សេចក្ដីថា ក៏និយតមិច្ឆាទិដ្ឋិ បុគ្គលនោះ ងើបឡើងអស់មួយវារៈ ដោយអំណាចនៃសទ្ធាជាដើម ទាំងនេះថា **ឯវំ សាហុ សទ្ធា** =សទ្ធាជាសេចក្ដីល្អយ៉ាងនេះ ក៏នឹងលិចចុះ ព្រោះសេចក្ដីសាបសូន្យចាកធម៌ មានសទ្ធាជាដើមនោះឯង ដូចភិក្ខុទេវទត្តជាដើម។ ក៏បុគ្គលនេះងើបឡើងពីអបាយភូមិដោយកុសលធម៌ មានសទ្ធាជាដើមមានប្រមាណប៉ុណ្ណោះ តែសទ្ធារបស់ពួកគេក៏លិចចុះទៅវិញដោយអំណាចអកុសលធម៌ទាំងឡាយ ដូចជាសទ្ធារបស់ភិក្ខុទេវទត្តដែលបានសមាបត្តិ៨ និងអភិញ្ញា៥កើតឡើង ក៏សាបសូន្យចាកគុណវិសេសទាំងនោះ ព្រោះភាពជាអ្នកបដិបក្ខចំពោះព្រះពុទ្ធជាម្ចាស់ ទើបធ្វើលោហិតុប្បាទ និងសង្ឃភេទកម្ម កាលបើកាយបែកធ្លាយ ទើបទៅកើតក្នុងនរកដោយវារៈចិត្តទី២ (បដិសន្ធិ), ភិក្ខុកោកាលិកៈប្រទូស្តព្រះអគ្គសាវកទាំង២ ទើបទៅកើតក្នុងបទុមនរក។

**បុគ្គលទី៣** = បុគ្គលខ្លះក្នុងលោកនេះងើបឡើងធ្វើកុសលប្រកបដោយសទ្ធាដ៏ប្រពៃជាដើម តែសទ្ធាជាដើមនោះរបស់

បុគ្គលនោះ មិនសាបសូន្យទៅ មិនចម្រើន ឋិតនៅនឹងដដែល បុគ្គលងើបឡើងហើយ ឋិតនៅ យ៉ាងនេះឯង។

**អដ្ឋកថា :** បទថា **"នេវ ហាយតិ នោ វឌ្ឍតិ"** សេចក្ដីថា ក្នុងវេលាដែលមិនសាបសូន្យក្តី ក្នុងវេលាដែលសាបសូន្យក្តី សទ្ធាក៏មិនថយចុះ និងមិនចម្រើន ។ ក៏ហេតុទាំងពីរនេះ បណ្ឌិតគប្បីសម្ដែងដោយអាគារិកបុគ្គល គឺគ្រហស្ថ និងអនាគារិកបុគ្គល គឺបព្វជិត សូម្បីទាំងពីរជាឧទាហរណ៍ ៖

គ្រហស្ថខ្លះ ក្នុងវេលាដែលខ្លួនមិនទាន់សាបសូន្យចាកសទ្ធា ទើបឱ្យចាត់ចែងបក្ខិកភត្តជង សលាកភត្តជង សំពត់ងូតទឹកភ្លៀងជង ។ គ្រហស្ថនោះ ក្នុងកាលសាបសូន្យចាកសទ្ធាខាងក្រោយ រមែងនៅត្រឹមតែបក្ខិកភត្តជាដើមប៉ុណ្ណោះ។ សូម្បីបព្វជិតក៏ដូចគ្នា ក្នុងវេលាដែលមិនសាបសូន្យសទ្ធាខាងដើម រមែងរៀនយកឧទ្ទេស ឬធុតង្គសូម្បីវេលាដែលសាបសូន្យចាកការដល់ព្រមដោយបញ្ញាពលៈ និងវីរិយពលៈ ក៏ធ្វើឱ្យក្រៃលែងជាងនេះមិនបាន ។ **ឯវំ បុគ្គលោ** = បុគ្គលនេះងើបឡើងហើយ ឈប់នៅ ព្រោះការតាំងនៅនៃធម៌ទាំងឡាយ មានសទ្ធាជាដើម។

**បុគ្គលទី៤** = បុគ្គលខ្លះ ក្នុងលោកនេះ ងើបឡើងក្នុងធម៌ជាកុសលប្រកបដោយសទ្ធាដ៏ប្រពៃ...ក្នុងធម៌ជាកុសលប្រកបដោយហិរិដ៏ប្រពៃ ក្នុងកុសលធម៌ ប្រកបដោយឱត្តប្បៈដ៏ប្រពៃក្នុងកុសលធម៌ប្រកបដោយវីរិយៈដ៏ប្រពៃក្នុងកុសលធម៌ ប្រកបដោយបញ្ញាដ៏ប្រពៃក្នុងកុសលធម៌ ព្រោះអស់ទៅនៃសញ្ញោជនៈទាំង៣ **បុគ្គលនោះជាសោតាបន្ន** ព្រោះអស់ទៅនៃសញ្ញោជនៈទាំង៣ មានសភាពមិនធ្លាក់ចុះក្នុងអបាយ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅខាងមុខ បុគ្គលងើបឡើងហើយ រមិលមើល ក្រឡេកមើលយ៉ាងនេះឯង។

បទថា "**ឧម្មុជ្ជិត្វា វិបស្សតិ វិលោកេតិ**" សេចក្ដីថា ព្រះសោតាប-ន្ន ឈ្មោះថា ងើបឡើងហើយរមិលមើល គឺ រមិលមើលមគ្គដែលជាទីនៅខាងលើ ឬទិសដែលគួរនឹងទៅ ព្រោះការងើបឡើងអំពីអន្លង់ទឹក គឺ វដ្ដៈ

**បុគ្គលទី៥** = បុគ្គលខ្លះក្នុងលោកនេះ ងើបឡើងក្នុងកុសលធម៌ ប្រកបដោយសទ្ធាដ៏ប្រពៃ....ក្នុងធម៌ជាកុសល ប្រកបដោយហិរិដ៏ប្រពៃ ក្នុងកុសលធម៌ ប្រកបដោយឱត្តប្បៈដ៏ប្រពៃក្នុងកុសលធម៌ប្រកបដោយវីរិយៈដ៏ប្រពៃក្នុងកុសលធម៌ ប្រកបដោយបញ្ញាដ៏

ប្រពៃក្នុងកុសលធម៌ **បុគ្គលនោះជាសកទាគាមី** ព្រោះអស់ទៅនៃសញ្ញោជនៈទាំង៣ ព្រោះស្រាលស្តើងនៃរាគៈ ទោសៈ និងមោហៈ នៅវិលមកកាន់លោកនេះម្តងទៀតទើបធ្វើទីបំផុតនៃកងទុក្ខបាន បុគ្គលងើបឡើងហើយ ហែលទៅយ៉ាងនេះឯង។

អដ្ឋកថា : បទថា **"ឧម្មុជ្ជិត្វា បតរតិ"** សេចក្តីថា **ព្រះសកទាគាមីបុគ្គល** ងើបឡើងអំពីអន្លង់ទឹក គឺ វដ្តៈ ហើយជាអ្នកឈានទៅខាងមុខ ចំពោះទិសដែលនឹងគប្បីទៅ ព្រោះភាពនៃខ្លួនមានកិលេសស្តួចស្តើង ទើបឈ្មោះថា រមែងឆ្លងផុតទៅបាន។

**បុគ្គលទី៦** = បុគ្គលខ្លះក្នុងលោកនេះ ងើបឡើងក្នុងកុសលធម៌ ប្រកបដោយសទ្ធាដ៏ប្រពៃ.....ក្នុងធម៌ជាកុសល ។ល។ បុគ្គលនោះជាឱបបាតិកកំណើត ព្រោះអស់ទៅនៃសញ្ញោជនៈជាចំណែកខាងក្រោម៥ បរិនិព្វានក្នុងសុទ្ធាវាសព្រហ្មលោកនោះ មានសភាពមិនវិលត្រឡប់ចាកព្រហ្មលោកនោះវិញ  បុគ្គលងើបឡើង ដល់កំពង់ហើយឋិតនៅ យ៉ាងនេះឯង។

**អដ្ឋកថា** : បទថា **បតិគាធប្បត្តោ ហោតិ** បានដល់ ព្រះអនាគាមីបុគ្គលងើបឡើងអំពីអន្លង់ទឹក គឺ វដ្តៈ ហើយក្រឡេកមើល

ទិសដែលនឹងទៅហើយ ក៏ឆ្លងទៅដល់កន្លែងមួយដែលជាទីពឹង ទើបឈប់នៅ រមែងមិនត្រឡប់។

**បុគ្គលទី៧** = បុគ្គលខ្លះក្នុងលោកនេះ ផើបឡើងក្នុងកុសលធម៌ជាកុសល ប្រកបដោយសទ្ធាដ៏ប្រពៃ ផើបឡើងក្នុងកុសលធម៌ជាកុសល ប្រកបដោយហិរិដ៏ប្រពៃ ផើបឡើងក្នុងកុសលធម៌ជាកុសល ប្រកបដោយឱត្តប្បៈដ៏ប្រពៃ ផើបឡើងក្នុងកុសលធម៌ជាកុសល ប្រកបដោយវីរិយៈដ៏ប្រពៃ ផើបឡើងក្នុងកុសលធម៌ជាកុសល ប្រកបដោយបញ្ញាដ៏ប្រពៃ បុគ្គលនោះធ្វើឱ្យជាក់ច្បាស់សម្រេចដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯងក្នុងបច្ចុប្បន្ន នូវចេតោ-វិមុត្តិនិងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់នៃអាសវៈទាំងឡាយ ហើយសម្រេចសម្រាន្តនៅ បុគ្គលផើបឡើងឆ្លងដល់ត្រើយ ជាព្រាហ្មណ៍ឋិតនៅលើគោក យ៉ាងនេះឯង ។

**អដ្ឋកថា** : បទថា "**តិណ្ណោ បារង្គតោ ថលេ តិដ្ឋតិ**" បានដល់ ព្រះខីណាស្រព លោកឆ្លងអន្លង់ទឹក គឺកិលេសទាំងអស់ ដល់ច្រាំងនោះហើយ រមែងជាអ្នកឈ្មោះថា ឈរនៅលើគោក គឺព្រះនិព្វាន ។

បុគ្គល៧ជំពូកនេះឧបមាដូចពាណិជ្ជទាំង៧នាក់ និងអង្គដំរីកា៖

បានឮថា នាយពាណិជ្ជទាំង៧នាក់ ដើរផ្លូវឆ្ងាយដល់ស្ទឹង ទឹកពេញប្រៀបក្នុងចន្លោះផ្លូវ បណ្តាអ្នកជំនួញទាំងនោះ

**អ្នកជំនួញទី១** ជាអ្នកខ្លាចទឹកសាកល្បងចុះមុន ហើយក៏បោះពួយចុះអំពីកំពង់ទឹកជាទីឆ្លងកាត់នោះឯង មិនអាចនឹងងើបឡើងទៀតបាន ទើបគេធ្លាក់លើជាចំណីរបស់ត្រីនិងអណ្តើកក្នុងស្ទឹងនោះឯង។

**អ្នកជំនួញទី២** បោះពួយចុះហើយ ក្នុងទីជាទីឆ្លងកាត់ ទើបឡើងមកម្តង ហើយក៏លិចចុះទៀតមិនអាចដើម្បីនឹងងើបឡើងបាន ទើបគេជាចំណីរបស់ត្រី និងអណ្តើកក្នុងស្ទឹងនោះដូចគ្នា ។

**អ្នកជំនួញទី៣** បោះពួយចុះហើយងើបឡើងឈប់នៅត្រង់កណ្តាលស្ទឹង មិនអាចដើម្បីនឹងទៅត្រើយនោះ មិនអាចនឹងមកប្រាំងនេះបានទេ។

**អ្នកជំនួញទី៤** បោះពួយចុះហើយងើបឡើងឈប់នៅក្រឡេកមើលកំពង់ទឹកជាទីឆ្លងកាត់ទៅ។

**អ្នកជំនួញទី៥** បោះពួយចុះហើយងើបឡើង ឈប់ក្រឡេក មើលកំពង់ទឹកជាទីឆ្លងកាត់ហើយទើបឆ្លងកាត់ទៅ។

**អ្នកជំនួញទី ៦** បោះពួយចុះហើយងើបឡើង ឆ្លងកាត់ទៅដល់ត្រើយនោះទើបឈប់នៅក្នុងទឹកត្រឹមចង្កេះ។

**អ្នកជំនួញទី ៧** បោះពួយចុះហើយ ។ល។ ដល់ច្រាំងនោះ ហើយងូតទឹកជម្រះខ្លួនដោយលម្អិតក្រអូបជាដើម ស្លៀកដណ្តប់សំពត់ដ៏ប្រសើរ លាបផាត់ដោយរបស់ប្រអូបប្រដាប់ផ្កាឧប្បលខៀវជាដើម ហើយប្រដាប់ដោយគ្រឿងអលង្ការប្រភេទនានាទើបចូលទៅកាន់មហានគរឈានឡើងកាន់ប្រាសាទបរិភោគភោជនដ៏ឧត្តម ។

ក្នុងសេចក្តីនោះបណ្ឌិតគប្បីជ្រាបពាក្យឧបមេយ្យដូច្នេះៈបុគ្គល៧ជំពូកទាំងនេះ ប្រៀបដូចអ្នកជំនួញ៧នាក់នោះ, វដ្តៈ ប្រៀបដូចស្ទឹង។

**អ្នកទី១.** ការលិចចុះក្នុងវដ្តៈរបស់និយតមិច្ឆាទិដ្ឋិ បណ្ឌិតគប្បីជ្រាបថា ដូចនឹងការលិចចុះក្នុងកំពង់ទឹកជាទីឆ្លងកាត់របស់អ្នកជំនួញដែលខ្លាចទឹក ។

**អ្នកទី២.** ងើបឡើងដោយហេតុត្រឹមតែការកើតឡើងនៃសទ្ធាជាដើម ហើយលិចចុះ ព្រោះសេចក្តីសាបសូន្យចាកសទ្ធាជាដើមនោះ ដូចនឹងអ្នកជំនួញដែល ងើបឡើងម្តងទៀត ហើយក៏លិចចុះទៅក្នុងស្ទឹង។

**អ្នកទី៣.** ងើបឡើងដោយហេតុត្រឹមតែ ការកើតឡើងនៃសទ្ធាជាដើម តែកុសលធម៌នៅនឹងដដែល មិនចម្រើនឡើង ប្រៀបដូចអ្នកជំនួញ ដែលបោះពួយ ហើយឈប់កណ្តាលស្ទឹង ។

**អ្នកទី៤.** ព្រះសោតាបន្នៈក្រឡេកមើលនូវផ្លូវដែលខ្លួនគប្បីទៅ ឬផ្លូវដែលគួរនឹងទៅ ដូចជាអ្នកជំនួញដែលងើបឡើងអំពីទឹក ក្រឡេកមើលនូវកំពង់ទឹកជាទីឆ្លងកាត់ ។

**អ្នកទី៥.** ព្រះសកទាគាមី ឈ្មោះថា កំពុងឆ្លងកាត់ទៅ ព្រោះភាពនៃខ្លួនជាអ្នកមានកិលេសស្តួចស្តើង ប្រៀបដូចជាអ្នកជំនួញដែលកំពុងឆ្លងកាត់ទៅ ។

**អ្នកទី៦.** ព្រះអនាគាមី ឈ្មោះថា ឈប់នៅ ព្រោះជាអ្នកមិនត្រឡប់មកកាន់កាមលោកនេះ ដូចជាអ្នកជំនួញដែលឆ្លងកាត់ទៅ ហើយឈរនៅត្រឹមចង្កេះ។

**អ្នកទី៧**. ព្រះខីណាស្រពអ្នកជាព្រាហ្មណ៍អ្នកឈានឆ្លងកាត់ឱឃៈទាំង៤ ហើយ ឈរនៅលើគោក គឺព្រះនិព្វាន បណ្ឌិតគប្បីជ្រាបថា ប្រៀបដូចអ្នកជំនួញដែលងូតទឹកជម្រះរាងកាយឱ្យស្អាតហើយឆ្លងឡើងច្រាំងនោះ ឈរនៅលើគោក។

បណ្ឌិតគប្បីជ្រាបថា កាលដែលព្រះខីណាស្រពលោកចូលផលសមាបត្តិ ដែលមាននិព្វានជាអារម្មណ៍ ហើយញ៉ាំងកាលឱ្យកន្លងទៅ ដូចជាអ្នកជំនួញដែលឈរនៅលើ គោកហើយចូលទៅកាន់ព្រះនគរ ឈានឡើងកាន់ប្រាសាទដ៏ប្រសើរហើយ ក៏បរិភោគអាហារដ៏ឧត្តម ។

**ព្រះអរិយបុគ្គល៧ពួក** = ១. ឧភតោភាគវិមុត្ត, ២. បញ្ញាវិមុត្ត, ៣. កាយសក្ខី,៤. ទិដ្ឋិប្បត្តៈ, ៥. សទ្ធាវិមុត្ត, ៦ .ធម្មានុសារី, ៧. សទ្ធានុសារី។ មានអធិប្បាយនៅក្នុងបុគ្គលពួក១ហើយ។

ចប់ បុគ្គលពួក៧ ត្រឹមតែប៉ុណ្ណេះ

# អដ្ឋកនិទ្ទេស

## (បុគ្គលពួក៨)

(បុគ្គលព្រមព្រៀងដោយមគ្គ៤ , ដោយផល៤)

១.សោតាបន្នបុគ្គល, ២.អ្នកប្រតិបត្តិដើម្បីធ្វើឱ្យជាក់ច្បាស់សោតាបត្តិផល(សោតាបត្តិមគ្គ), ៣.សកទាគាមីបុគ្គល, ៤.អ្នកប្រតិបត្តិដើម្បីធ្វើឱ្យជាក់ច្បាស់នូវសកទាគាមិផល(សកទាគាមិមគ្គ),៥.អនាគាមិបុគ្គល,៦.អ្នកប្រតិបត្តិដើម្បីធ្វើឱ្យជាក់ច្បាស់នូវអនាគាមិផល, ៧. ព្រះអរហន្ត, ៨. អ្នកប្រតិបត្តិដើម្បីធ្វើឱ្យជាក់ច្បាស់នូវអរហត្តផល។

ចប់បុគ្គលពួក៨

# នវកនិទ្ទេស

**(បុគ្គល ៩ពួក)**

១. ព្រះសម្មាសម្ពុទ្ធ, ២. ព្រះបច្ចេកពុទ្ធ , ៣. បុគ្គលជាឧភតោភាគវិមុត្ត, ៤.បុគ្គលជាបញ្ញាវិមុត្ត, ៥. បុគ្គលជាកាយសក្ខី, ៦. បុគ្គលជាទិដ្ឋិប្បត្តៈ, ៧. បុគ្គលជាសទ្ធាវិមុត្តិ, ៨. បុគ្គលជាធម្មានុសារី , ៩.បុគ្គលជាសទ្ធានុសារី ។ បានអធិប្បាយនៅក្នុងបុគ្គលពួក១ហើយ។

ចប់បុគ្គលពួក៩

# ទសកនិទ្ទេស

**(បុគ្គលពួក១០)**

១.ព្រះសោតាបន្នសត្តក្ខត្តុំបរម, ២.ព្រះសោតាបន្នកោលំ - កោល, ៣. ព្រះសោតាបន្នឯកពីជីបុគ្គល, ៤.ព្រះសកទាគាមិបុគ្គល , ៥. ព្រះអរហន្តក្នុងបច្ចុប្បន្ន, ៦. អន្តរាបរិនិព្វាយី, ៧.ឧបហច្ចបរិ- និព្វាយី ,៨. អសង្ខារបរិនិព្វាយី ,៩. សសង្ខារបរិនិព្វាយី ១០. ឧទ្ធំ- សោតោអកនិដ្ឋគាមី ។ បានអធិប្បាយនៅក្នុងបុគ្គលពួក១ហើយ។

**ព្រះសោតាបន្នទាំង៣** (សត្តក្ខត្តុំបរមបុគ្គល,កោលំកោល បុគ្គល និងឯកពីជីបុគ្គល) ដែលនៅក្នុងកាមាវចរភូមិ លោករមែង សម្រេចក្នុងកាមភូមិនុ៎ះឯង បានសេចក្តីថា ការសម្រេចព្រះអរហត្ត ក្តី ការសម្រេចអនុបាទិសេសនិព្វានក្តី រមែងមានក្នុងអត្តភាពដែល លោកកើតនៅក្នុងកាមាវចរភូមិនុ៎ះឯង។

**ព្រះអនាគាមី៥ជំពូក** រមែងបានសម្រេចជាព្រះអនាគាមី ក្នុងអត្តភាពនៅកាមាវរភូមិនេះហើយនឹងបានសម្រេចជាព្រះ អរហន្ត បរិនិព្វាននៅសុទ្ធាវាសភូមិ។

ចប់បុគ្គលពួក១០

**<u>ចប់បុគ្គល១០ពួកដោយបរិបូរណ៍</u>**

## រាយនាមពុទ្ធបរិស័ទចូលរួមបោះពុម្ពសៀវភៅ

## ជាប្រាក់រៀល

1. អ៊ុក សុផល ៥.០០០៛ អ៊ូឫស្សី
2. ប៊ុន សុង និង ភរិយា ៥.០០០៛ អ៊ូឫស្សីទី៤
3. ប៉ោក តន ៥.០០០៛
4. បង ណេត ៥.០០០៛
5. យាយ ថុល ៥.០០០៛
6. វ៉ាន់ សំអុល សុខខេង ៥.០០០៛ ភូមិតានប់
7. អ៊ុំ ង៉ាន់ ៥.០០០៛
8. ឧ.សិ តូ ប៉ក់ ៥.០០០៛
9. សន ស្រី ម៉ៅ និងកូនចៅ ៥.០០០៛ ត្រាំខ្នារ
10. ឡ ស៊ីណា(បាទី តាកែវ), ណាង វី , ធី ធី និងកូនចៅ ,តា ប៉ែល +កូនចៅ, ភាព +កូនចៅ , យ៉ាង វី, ជល គឹម ហេង,អ៊ី ប៊ុន , ឌុល ថុល , កុង ជ យាយ ហេង =អ្នកខេត្តតាកែវ ៥០ម៉ឺនរៀល។
11. ហ៊ូ សារ៉ុម ៥.០០០៛ ភូមិប៉ប្រកខាងត្បូង
12. ប៉ិច ម៉ៅ ៥.០០០៛ ភូមិប៉ប្រកខាងត្បូង
13. លោកតា សេងគាង និងបុត្ត ១០.០០០៛ ត្រាំខ្នារ
14. ខឹម សារ៉ាន់ +ទេព ម៉ៅ +កូនចៅ ១០.០០០៛
15. ឧ.សិ ប៉ែន ស្រី +បុត្រ ១០.០០០៛
16. ឧ.សិ គឹម ឡាន +កូនចៅ ១០.០០០៛
17. ឧ.សិ នាង នៅ +កូនចៅ ១០.០០០៛
18. ឧ.សិ រលីហ៊ាំង +កូនចៅ ១០.០០០៛
19. ឧ.សិ ចាន់ ដេត +កូនចៅ ១០.០០០៛
20. ឧ.សិ សាគឹម ហេង +កូនចៅ ១០.០០០៛ ភ្នំពេញ
21. ឧ.សិ យឹម សយ +កូនចៅ១០.០០០៛
22. ឧ.សិ គឹម វដ្ឋា+កូនចៅ ១០.០០០៛ ភ្នំពេញ
23. ឧ.សិ យី វណ្ណា +កូនចៅ ១០.០០០៛

24. ឧ.សិ លាស់ សារឿន +កូនចៅ ១០.០០០៛

25. ឧ.សិ វង វ៉ាង ១០.០០០៛ ពោចិនតុង

26. ឧ.សិ ម៉ៅ វណ្ណាត ១០.០០០៛ បែកចាន

27. ឧ.សិ ម៉ៅ វុទ្ធី ១០.០០០៛ បែកចាន

28. ឧ.សិ ណាត សុគីម +កូនចៅ ១០.០០០៛ បែកចាន

29. ស៊ុំ ហៀន ១០.០០០៛

30. ឧ.សិ អ្នកគ្រួយន ១០.០០០៛

31. ឧ.សិ ម៉ៅ នាត ១០.០០០៛

32. ឧ.សិ ជ័យ សារី ១០.០០០៛

33. អ៊ូ គឹម ស៊ាន ១០.០០០៛

34. អ៊ីម សំអុល ១០.០០០៛

35. ឧ.ស ឈុំ សុភាព ឧ.សិ វ៉ាផល្លី ១០.០០០៛

36. ឧ.សិ ចាន់ មុំ ១០.០០០៛

37. ឧ.សិ សេង រឹម ១០.០០០៛ ពោចិនតុង

38. ឧ.សិ លារួន ថារី ១០.០០០៛ កំបូល

39. ឧ.សិ ឡាយ លី ១០.០០០៛ ពោចិនតុង

40. ឧ.សិ ខាន់ ញ៉ លិង កូនចៅ ១០.០០០៛

41. ឧ.សិ ម៉ៅ សុជាតិ + កូនចៅ ១០.០០០៛ ភ្នំពេញ

42. លោកស្រី ម៉ន សុគន្ធា ១០.០០០៛

43. លោកស្រី សុនឿន+សំអឿន ១០.០០០៛

44. ស៊ីនួន ១០.០០០៛

45. យូ ហ៊ុននី ១០.០០០៛

46. យាយ ខន +តាអុល ១០.០០០៛

47. ម៉ុត កង សៅណាយគ្រី កងស៊ីថា ១០.០០០៛

48. ប្អូនសុខឃីម +ណារី ១០.០០០៛ អ៊ូប្ញស្សី

49. លាង គឹមអេង ១០.០០០៛ តាកែវ

50. ចក់ ឡាំង+កូនចៅ ១០.០០០៛

51. កុង ណាំ ១០.០០០៛

52. យាយ ហ៊ាង ១០.០០០៛

53. លោក ម៉ៅ វ៉ាត និង មួសៀម+កូន១០.០០០៛បាត់ដំបង

54. ឧ.ស ព្រិលសៀង , ឧ.សិ ញាញ់ ១០.០០០៛

55. ឧ.សិ សីហា ពិសាល ១០.០០០៛

56. ឧ.សិ ផ ១០.០០០៛ បាត់ដំបង

57. ផ ផល្លា ១០.០០០៛ បាត់ដំបង

58. ឧ.សិ យាយ ឡា ១០.០០០៛

59. ឧ.សិ សេង យ៉ិន ១០.០០០៛

60. សុទ្ធ ផូ ១០.០០០៛ បាត់ដំបង

61. រ៉ែម ភូន,ឡុញ សុភ័ក្រ ឡុញ សុតឿត ១០.០០០៛បាត់ដំបង

62. វ៉ិត ចន្ទី ១០.០០០៛ បាត់ដំបង

63. ទេព វីរៈ ,អ្នកស្រី ឡុញសុផាន ១០.០០០៛ បាត់ដំបង

64. តាំង ស៊ុនហេង . ឡុញ សុភាត់ ១០.០០០៛ បាត់ដំបង

65. តាំង លីឈីង ១០.០០០៛ បាត់ដំបង

66. កុមារី ម៉ីអ៊ីង ១០.០០០៛ បាត់ដំបង

67. កុមារី សឿង រចនា ១០.០០០៛ បាត់ដំបង

68. សុផាច រចនា ១០.០០០៛ បាត់ដំបង

69. ឧ.សិ រឿន រឿត ១០.០០០៛

70. ម៉ៃ មេត្តា ១០.០០០៛ បាត់ដំបង

71. មៃ អាតូច ១០.០០០៛ បាត់ដំបង

72. នី ធន ១០.០០០៛ បាត់ដំបង

73. សត់ ជិន ១០.០០០៛ បាត់ដំបង

74. ហាក់ ប៊ុនប៉ា ១០.០០០៛ បាត់ដំបង

75. ឧ.សិ ចែម ថុន ១០.០០០៛ តាកែវ

76. មូល មាន់ ១០.០០០៛ ព្រៃតាមួច

77. យាយ លី ១០.០០០៛

78. តាកែម , យាយថាត ១០.០០០៛ ត្រាំខ្នារ

79. យាយ ថូ យាយណៃ ១០.០០០៛ ត្រាំខ្នារ

80. យាយ អ៊ី +កូនចៅ ១០.០០០៛ ត្រាំខ្នារ

81. ឧ.សិ ថាន់ មុំ ១០.០០០៛ ត្រាំខ្នារ

82. យាយ ជា វ៉ាត់ +កូនចៅ ១០.០០០៛ ត្រាំខ្នារ

83. ផុំ ចាន់ថន +កូនចៅ ១០.០០០៛ ត្រាំខ្នារ

84. សោម សុផល +កូនចៅ ១០.០០០៛ ត្រាំខ្នារ

85. ផៃ គុណធា ១០.០០០៛ ត្រាំខ្នារ

86. ខុម ស្រៀង+កូនចៅ ១០.០០០៛ ត្រាំខ្នារ

87. ហ៊ួតសន់ +កូនចៅ ១០.០០០៛ ត្រាំខ្នារ

88. យាយ សាត+កូនចៅ ១០.០០០៛ ត្រាំខ្នារ

89. តា ផល យាយ វ៉ូច +កូនចៅ ១០.០០០៛ ត្រាំខ្នារ

90. សិ. ព្រាប សារឿង ១០.០០០៛ ពោចិនតុង

91. សិ គង់ ម៉ិច ១០.០០០៛ ពោចិនតុង

92. សិ អ៊ុំ ប៉ិច និងបុត្រ ១០.០០០៛

93. សិ ចាន់សុខុម +កូនចៅ ១០.០០០៛

94. សិ កោឡៃអ៊ឹម ១០.០០០៛ ភូមិតាងួន ពោចិនតុង

95. សិ សុខ អ៊ួញ ១០.០០០៛

96. យ៉ែម អង្គារ ចេតនា ភរិយា ១០.០០០៛

97. សិ ស្រីពេជ្យ និងភរិយា ខឹមឡុន ១០.០០០៛ ពោចិនតុង

98. នាងទៅ +ញាតិ ១០.០០០៛

99. សុន មុនីរ័ត្ន ១០.០០០៛ ពោចិនតុង

100. សេងហ៊ន ១០.០០០៛ ភូមិប៉ប្រកខាងជើង

101. សិ ចាន់ សុភឿន+កូនចៅ ១០.០០០៛ ពោចិនតុង

102. សិ ឡៃ សុខា ១០.០០០៛ ភូមិតាងួន ពោធិនតុង

103. តារាលឹម ១ម

104. ផាន់ សោភណ្ឌ +កូនចៅ ១០.០០០៛ ភូមិប៉ប្រកខាងជើង

105. សិ តាំលីម ១ម ខណ្ឌមានជ័យ

106. សិ ហេង ភាន +កូនចៅ១ម ពោ

107. សិ មុតជាសោភា ១០.០០០៛ ភូមិប៉ប្រកខាងត្បូង

108. មុតគីមសាន់+កូនចៅក្មួយ ១០.០០០៛ ភូមិប៉ប្រកខាងត្បូង

109. សិ ជា សុខ ហេង ១០.០០០៛ ភូមិតាងួន ពោធិនតុង

110. សិ តែ គីមសួន+កូនចៅ ១០.០០០៛ ពោធិនតុង

111. ខុន ភៀន ២០.០០០៛ បាត់ដំបង

112. ឧ.ស វ៉ាន ធីរៈ ២០.០០០៛ បាត់ដំបង

113. ឧ.ស ប៊ុន ប៊ូ ,ឧ.សិ ហោ ម៉េងហិត២០.០០០៛

114. លោក យ៉ម ហាក់ និងម៉ៅ សារ៉ូន ២០.០០០៛ បាត់ដំបង

115. ម៉ោ សាវ៉ាន់ +ក្មួយៗ ២០.០០០៛ បាត់ដំបង

116. ឧ.ស លី ប៉េង ,ឧ.សិ យូតូនី ២០.០០០៛

117. ឧ.ស វ៉ាន់ រ៉ូនី ឧ.សិ ផង ហាន់ ២០.០០០៛ បាត់ដំបង

118. អ៊ី ណាង គីម ២០.០០០៛ ត្រាំខ្នារ

119. ឧ.សិ សៀអេង+កូនចៅ ២០.០០០៛ ត្រាំខ្នារ

120. ទ្រី ឆេង +កូនចៅ ២០.០០០៛ ត្រាំខ្នារ

121. ឧ.សិ ហាម ម៉ៅ +កូនចៅ ២០.០០០៛ ត្រាំខ្នារ

122. ស្រី សុខ លីម ២០.០០០៛

123. កូនចៅ តាគឿន ផុល ២០.០០០៛ តាកែវ

124. ឧ.ស ហាង ថា +កូនចៅ ២០.០០០៛ តាកែវ

125. ចាន់ថាល ធារី ,អាត ចាន់ធូ ,យាយជា ២០.០០០៛

126. ឧ.សិ ចាន់ សំអាត.ភរិយា+កូនចៅ ២០.០០០៛ កំពង់សិលា

127. លោក កង ស៊ីខែត ២០.០០០៛

128. លោកស្រី ជួន ស្រីចា ២០.០០០៛

129. ឧ.សិ សេង វី ,សេង ញ ២០.០០០៛ ពោសែនជ័យ

130. ឧ.សិ អួន ២០.០០០៛

131. ឧ.សិ ចាន់រស្មី ២០.០០០៛

132. ឧ.សិ អៀន វី ២០.០០០៛

133. លោក នួន សំណាង ណុបស្រីង+កូនចៅ ២០.០០០៛ តាកែវ

134. ឧ.សិ តាំង អួន +កូនចៅ ២០.០០០៛

135. ឧ.សិ តាំង ហួយ និង ស្វាមី+កូនចៅ ២០.០០០៛

136. ឧ.សិ រស់ សូរិយា +កូនចៅ ២០.០០០៛

137. ឧ.សិ អ៊ុក ទិព្វ +កូនចៅ ២០.០០០៛

138. អ៊ុំ វណ្ណថា ២០.០០០៛ ភ្នំពេញ

139. ឧ.សិ ផៃ ស៊ាន+កូនចៅ ៣០.០០០៛ បាត់ដំបង

140. ឧ.សិ ឆាយ ជូ ,ឧ.សិ ម៉ែន ឡុងឌី ៣០.០០០៛ បាត់ដំបង

141. ឧ.សិ ហាម ឌី និងស្វាមី +កូនចៅ ៣០.០០០៛

142. ឧ.សិ សូ កែវ នារី និងក្រុមញាតិ +កូន ៤០.០០០៛

143. ឧ.សិ ម៉ា ភឿន និងស្វាមី +កូនចៅ ៥០.០០០៛ ទឹកជ្រោះទី៣

144. ក្រុមឧបាសក អឿន ៥០.០០០៛ កំពង់ស្ពឺ

145. ឧ.សិ ពុជ សុដារី ៥០.០០០៛ តាខ្មៅ

146. លោក នង ស្រីជា,លោកស្រីឆិន សារ៉ូ +កូន ៥០.០០០៛

147. ឧ.ស យិច ឈីន និងឧ.សិ តែ សុ ម៉ាលី(ប្អួយ) +កូនចៅ ៥០.០០០៛

148. ឧ.សិ អួយ មិនា +កូនចៅ ៥០.០០០៛

149. លោក សុខ សាលឿន និង ទេព សារិ ៥០.០០០៛ បាត់ដំបង

150. តា ស្វាយ ស៊ុក យាយ ហ៊ាប+កូនចៅ ៥០.០០០៛

151. ឧ.សិ លៀប វណហេង +កូនចៅ ៥០.០០០៛ ត្រែងត្រយ៉ឹង

152. ១២៩.ឧ.សិ ប៉ុល ណារ៉ែន +កូនចៅ ៧០.០០០៛

153. លោកម្ចាស់ ផល ឡាយ ៨០.០០០៛ គល់ទទឹង

154. ឧ.ស ទេពមន្តា,ឧសិ ហឿង ចន្ថា ,កូនទេព ស៊ីវជិន និងភរិយា ១០០.០០០៛

155. លោក ទុំ ឬទ្ធី និង ក្រុមគ្រួសារ ១០០.០០០៛ ភ្នំពេញ

156. ឧ.សិ ឡុង សំអាត+កូនចៅ ១០០.០០០៛

157. ឧសិ សុខ ឆេង +ស្វាមី កូន ១០០.០០០៛ ពោធិនតុង

158. ក្រុមគ្រួសារលោកម្ចាស់ តួង ហេង ១១០.០០០៛

159. ឧ.ស តុង ឈិន +ភរិយា កូនចៅ ១៥០.០០០៛ ស្រែអំបិល

160. ឧ.ស សិទ្ធ ស៊ីវន្ថា ២០០.០០០៛ ភ្នំពេញ

161. បិណ្ឌ១៤ ក្រុមឧបាសិកា ហាវ សាវុធ ៤០០.០០០៛

162. ឧ.សិ គឹម ចាន់នី និងបុត្រ ៥០០.០០០៛ ទល់មុខផ្សារស៊ីតនី

163. លោកវិជ្ជបណ្ឌិត មូ សារឿន ឧ.សិ ហេង រួចលាង +បុត្រនិងញាតិព្រះធម៌ (ត្រែងត្រយឹ-ង) ,ឧ.សិ តុបសៅ និងកូនចៅ ព្រមទាំងពុទ្ធបរិស័ទ នៅពោធិនតុង វេនថ្ងៃ៣រោច ៥០០.០០០៛

164. ឧ.ស គឹម ហួត ឧ.សិ ហេង ម៉ាលី និងបុត្រ ១.០០០.០០០៛ ផ្សារទួលសង្កែ

**ព្រះនាមលោកម្ចាស់វត្តគីរីរម្យចាស់**

165. លោកម្ចាស់ ភូ សុភក្រ្ត ៤០០.០០០៛

166. លោកម្ចាស់ ស ឆន ១០០.០០០៛

167. លោកម្ចាស់ អ៊ុំ ប៊ុន ១០០.០០០៛

168. លោកម្ចាស់ រឿន ប៊ុនថុន ១០០.០០០៛

169. លោកម្ចាស់ នៅ ស៊ីណែត ១០០.០០០៛

170. លោកម្ចាស់ គួន គន្ធរាជ ៥០.០០០៛

171. លោកម្ចាស់ នៅ វ៉ាស្នា ៥០.០០០៛

172. លោកម្ចាស់ ឈាន សុផល ៥០.០០០៛

173. លោកម្ចាស់ វ៉ា ស៊ីរីន ៥០.០០០៛

174. លោកម្ចាស់ មៀច ម៉ាន់៥៥.០០០៛

**រាយនាមអ្នកចូលប្រាក់ដុល្លា**

175. លោកម្ចាស់ នាង ណៃ ៣០ $ វត្តគល់ទទឹង

176. ឧ.សិព្រះចន្ទ្រ ព្រះចន្ទ្រ ២៥ $

177. ឧ.ស ផៃ សារុំ ,ឧ.សិ សុង ខេងលី ២៥ $

178. ឧ.សិ គីន ស៊ីឡេង ២៥ $

179. លោក មាស សុភាព,អ្នកស្រី សុធារី កូនស្រីមាស សុធារី ,ថាវរី ១០ $បាត់ដំបង

180. ឧ.សិ ស៊ុំ សាប៊ុណ្ណា +កូនចៅ ១០ $ សង្កាត់ទឹកថ្លា

181. ក្រុមឧ.ស ឡុង សំនៀង ៤៤០ $

182. លោកម្ចាស់ យ៉ុងរដ្ឋា និងញោមៗ ៥០$

## ឯកសារពិគ្រោះ

គម្ពីរធម្មសង្គណី

គម្ពីរមជ្ឈិមនិកាយ

គម្ពីរអង្គុត្តរនិកាយ

អដ្ឋកថា ព្រះវិន័យ

អដ្ឋកថា ព្រះអភិធម្ម

ព្រះអភិធម្មត្ថសង្គហៈ៩បរិច្ឆេទ

គម្ពីរវិសុទ្ធមគ្គ

វចនានុក្រមសម្ដេចព្រះសង្ឃរាជ ជួន ណាត ។

សូមឲ្យព្រះពុទ្ធសាសនារុងរឿងចម្រើន សូមឲ្យព្រះពុទ្ធសាសនាផ្សាយទូទៅពេញសកលលោក សូមឱ្យលោកទាំងមូលប្រកបដោយសន្តិភាព ព្រះសក្យមុនីទ្រង់ត្រាស់ថា “**នត្ថិ សន្តិ បរំ សុខំ គ្មានសេចក្តីសុខណា ដទៃក្រៅអំពីសេចក្តីស្ងប់ឡើយ**”



ព្រះគោតមចេតិយ វត្តមហាវ័ន (គិរីរម្យចាស់)
ស្ថិតនៅភូមិថ្មី ឃុំចំបក់ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ